# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ២

ប្រែ និងរៀបរៀងដោយ ព្រះសុវណ្ណថេរោ ភិក្ខុ **លឹម ឆន់**

ព.ស ២៥៤៩

**ខេត្តបាត់ដំបង**

ក

# ព្រះពុទ្ធសាសនាមានអង្គ ៩

ព្រះពុទ្ធវចនៈ គឺព្រះធម្មវិន័យ ដែលព្រះមានព្រះភាគទ្រង់សម្ដែង ប្រកបដោយអង្គ ៩ គឺ ៖

**សុត្តៈ** គឺព្រះសូត្រទាំងឡាយ មាន មង្គលសូត្រ ជាដើម រួមទាំងព្រះវិន័យបិដក និងនិទ្ទេស ។

**គេយ្យៈ** គឺព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណៈ** គឺព្រះអភិធម្មបិដក មានព្រះសូត្រដែលមិនមានគាថាលាយ និងព្រះពុទ្ធវចនៈដែលមិនចាត់ចូលក្នុងអង្គ ៨ ។

**គាថា** គឺព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនឈ្មោះថា សូត្រ ក្នុងសុត្តនិបាត ។

**ឧទាន** គឺព្រះសូត្រ ៨២ សូត្រ ដែលព្រះមានព្រះភាគទ្រង់បន្លឺដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តកៈ** គឺព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមដោយពាក្យថា ***វុត្តំ ហេតំ*** ( សេចក្ដីនេះសមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកហើយ ) ។

**ជាតក** គឺរឿងអតីតជាតិ របស់ព្រះមានព្រះភាគ និងសាវក មានអបណ្ណជាតក ជាដើម រួម ៥៥០ ជាតក ។

**អព្ភូតធម្ម** គឺព្រះសូត្រដែលប្រកបដោយអច្ឆរិយអព្ភូតធម៌ (ធម៌ដ៏ក្រៃលែងដោយគុណវិសេសដ៏គួរអស្ចារ្យ) ។

**វេទល្ល:** គឺព្រះសូត្រដែលសួរហើយៗ បានការត្រាស់ដឹង និងសេចក្តីត្រេកអរក្រៃលែងឡើងៗ មាន ចូឡវេទល្លសូត្រ ជាដើម ។

****************

# អារម្ភកថា

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្តែងថា “ម្នាលភិក្ខុទាំងឡាយ ធម៌ ២ យ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យសម្មាទិដ្ឋិកើតឡើង ។ ធម៌ ២ យ៉ាងនោះតើដូចម្តេច ? គឺ បរតោឃោសៈ ១ យោនិសោមនសិការៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ២ យ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យសម្មាទិដ្ឋិកើតឡើង” ។

( ចាកគម្ពីរព្រះត្រៃបិដកលេខ ៤០ ទំព័រ ១៩៧ )

សម្មាទិដ្ឋិសំខាន់យ៉ាងណាសម្រាប់ជីវិត ពុទ្ធបរិស័ទក៏គួរតែជ្រាបហើយ ។ នៅក្នុងជីវិតសត្វលោកយើងនេះ មិនមានអ្វីដែលសំខាន់ជាងសម្មាទិដ្ឋិទៀតឡើយ ។ សម្មាទិដ្ឋិអង្គធម៌ គឺបញ្ញា អធិប្បាយថា យល់ត្រូវ ព្រោះដឹងច្បាស់នូវអ្វីៗ តាមសេចក្តីពិត ។ កាលណាបើមានការយល់ត្រូវហើយ បញ្ហាក៏ត្រូវបញ្ចប់ដែរ ។ យល់ព្រម សុខចិត្ត ស្ងប់ត្រជាក់ សុទ្ធតែបានសម្រេចពីការយល់ត្រូវទាំងអស់ ។

បច្ច័យសំខាន់របស់សម្មាទិដ្ឋិ គឺយោនិសោមនសិការៈ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ត្រូវអាស្រ័យបរតោឃោសៈ គឺពាក្យឃោសនាអំពីអ្នកដទៃផងដែរ ទាំងដែលចាំបាច់ត្រូវអាស្រ័យអ្នកដែល

ឃោសនានោះ ជាមនុស្សល្អទៀតផង យ៉ាងនេះ ទើបអាចជាឧបការៈជួយដល់យោនិសោមនសិការៈទៅបាន ។

បរតោឃោសៈមានឥទ្ធិពលណាស់ អាចធ្វើឲ្យមនុស្សដ៏ច្រើនយល់ខុសបានងាយៗ ព្រោះហេតុមកអំពីខ្វះយោនិសោមនសិការៈហ្នឹងឯង ទាំងដែលបរតោឃោសៈនោះ មិនបានជ្រោមជ្រែងដល់យោនិ-សោមនសិការៈផង ព្រោះហេតុនោះ ទើបត្រូវមាននូវកល្យាណមិត្តដើម្បីបាននូវបរតោឃោសៈដែលល្អៗ ។

នៅក្នុងសៀវភៅនេះ មានបរតោឃោសៈល្អៗ ព្រោះជាព្រះពុទ្ធដីកា និងការអធិប្បាយព្រះពុទ្ធដីការបស់ព្រះអរហន្តទាំងឡាយព្រមទាំងមានប្រវត្តិរឿងរ៉ាវ ដែលជាហេតុឲ្យព្រះអង្គសម្ដែងនូវព្រះ-គាថានីមួយៗ ទៀតផង ។

សូមព្រះព្រះករុណាគ្រប់ព្រះអង្គ ព្រមទាំងពុទ្ធបរិស័ទគ្រប់រូបព្យាយាមក្នុងការអានសៀវភៅនេះ ប្រកបដោយសមាធិក្នុងការពិចា-រណាសេចក្ដីផ្សេងៗ ។ សូមឲ្យជីវិតនៃព្រះករុណាគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទគ្រប់រូប ប្រៀបបីដូចជាអរុណពណ៌មាស ពោលគឺជីវិតបរិបូណ៌ទៅដោយយោនិសោមនសិការៈ ។

សៀវភៅនេះជាអដ្ឋកថាធម្មបទ អប្បមាទវគ្គ វគ្គទី ២

ខ្ញុំព្រះករុណា អាត្មាភាព

សុវណ្ណថេរោ **លឹម ឆន់**

ង

# សារបណ្ណ

## ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយគាថាធម្មបទ

### គាថាធម្មបទ អប្បមាទវគ្គ វគ្គទី ២ មាន ៩ រឿង


| ល.រ | ឈ្មោះរឿង | | ទំព័រទី |
|---|---|---|---|
| ១ | រឿងនាងសាមាវតី | ......................... | ១ |
| ២ | រឿងកុម្ភឃោសកៈ | ......................... | ១៦៩ |
| ៣ | រឿងព្រះចូឡបន្ថកៈ | ......................... | ១៩២ |
| ៤ | រឿងនក្ខត្តឫក្សរបស់ជនពាល | ........... | ២៣០ |
| ៥ | រឿងព្រះមហាកស្សបត្ថេរ | ........... | ២៣៧ |
| ៦ | រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប | ........ | ២៤២ |
| ៧ | រឿងសក្កទេវរាជ | ......................... | ២៤៩ |
| ៨ | រឿងភិក្ខុមួយរូប | ......................... | ២៩០ |
| ៩ | រឿងព្រះនិគមវាសីតិស្សត្ថេរ | ............ | ២៩៤ |

ប៊

# ខុទ្ទកនិកាយគាថាធម្មបទ

## អប្បមាទវគ្គ វគ្គទី ២

១ អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា អបមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត ជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបឋិតនៅ ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ជាគោចរនៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជា

ប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្ដីប្រឹងប្រែង មាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះ-និព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។

**២ ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ**

យសតែងចម្រើនយ៉ាងក្រៃលែង ដល់បុគ្គលអ្នកមានសេចក្ដីប្រឹងប្រែង មានស្មារតី មានការងារស្អាត ( ឥតទោស ) ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នកសង្រួម រស់នៅដោយធម៌ មិនមានសេចក្ដីប្រមាទ ។

**៣ ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច**
**ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។**

អ្នកប្រាជ្ញ គប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្ដីប្រឹងប្រែងផង ដោយសេចក្ដីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មាននូវ

ឥន្ទ្រីយ៍ផង ។

៤ បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយៗនូវសេចក្តីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទដូចទ្រព្យដ៏ប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ត្បិតបុគ្គលមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបាននូវសេចក្តីសុខដ៏ទូលាយ ។

៥ បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនី បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

កាលណាបណ្ឌិតបន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញនូវ

សត្វដែលមានសោក      ធីរជនតែងតែឃើញពួកជន-
ពាលដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេក
មើលពួកជនដែលនៅលើផែនដី ដូច្នេះឯង ។

**៦ អប្បមត្តោ  បមត្តេសុ   សុត្តេសុ  ពហុជាគរោ**
**អពលស្សំវ ទីឃស្សោ   ហិត្វា យាតិ សុមេធសោ ។**

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ
លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោក
ភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែប
នោះ ដូចសេះលឿន ដែលទៅចោលនូវសេះមានកម្លាំង
ទន់ទាប ដូច្នោះឯង ។

**៧ អប្បមាទេន មឃវា      ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ   បមាទោ គរហិតោ សទា**

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាង
ទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញ
ទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ត្មះតិះដៀល
នូវសេចក្តីប្រមាទ សព្វៗ កាល ។

៨ អប្បមាទរតោ ភិក្ខុ    បមាទេ ភយទស្សិ វា
សំយោជនំ អណុំ ថូលំ   ឌហំ អគ្គីវ គច្ឆតិ ។

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតបោលសំយោជនៈទាំងតូចទាំងធំ ដូចភ្លើងឆេះ ( វាលទូវកំទេចទាំងតូចទាំងធំ ) ដូច្នោះឯង ។

៩ អប្បមាទរតោ ភិក្ខុ    បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ    និព្វានស្សេវ សន្តិកេ

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

( អប្បមាទវគ្គទី ២ ចប់ )

# ២ អប្បមាទវគ្គវណ្ណនា

## ១. រឿងនាងសាមាវតី

### សេចក្តីខាងដើម

ព្រះសាស្តា កាលស្តេចចូលទៅអាស្រ័យក្រុងកោសម្ពី ទ្រង់គង់នៅក្នុងឃោសិតារាម ទ្រង់ប្រារព្ធនូវសេចក្តីស្លាប់ និងសេចក្តីវិនាសរបស់ស្ត្រី ៥០០ មានព្រះនាងសាមាវតីជាប្រធាន និងសេចក្តីវិនាសរបស់ញាតិ ៥០០ របស់មាគន្ទិយានោះ ដែលមានព្រះនាងមាគន្ទិយាជាប្រធាន ទើបត្រាស់ព្រះធម្មទេសនានេះថា ៖

“**អប្បមាទោ អមតំ បទំ**” ជាដើម ក្នុងរឿងនោះមានអនុ-បុព្វីកថា ដូចតទៅនេះ ៖

### ក្សត្រពីរព្រះអង្គជាសម្លាញ់នឹងគ្នា

ក្នុងកាលកន្លងទៅហើយ ព្រះរាជាពីរព្រះអង្គនេះគឺ “ក្នុងដែនអល្លកប្បៈ ព្រះរាជាទ្រង់ព្រះនាមថា អល្លកប្បៈ, ក្នុងដែនវេដ្ឋទីបកៈ

ព្រះរាជាទ្រង់ព្រះនាមថា វេដ្ឋទីបកៈ” ជាសម្លាញ់នឹងគ្នាតាំងអំពីកាល ដែលខ្លួននៅក្មេង ទ្រង់សិក្សាសិល្បៈ ក្នុងសំណាក់អាចារ្យជាមួយគ្នា ដោយកាលកន្លងទៅនៃព្រះបិតារបស់ខ្លួនៗ បានបញ្ជាឲ្យលើកស្វេត-ច្ឆត្រឡើងហើយ ទ្រង់ជាព្រះរាជាក្នុងដែនមានប្រមាណជប់ៗ យោជន៍ ព្រះរាជាពីរព្រះអង្គនោះ ស្ដេចយាងមកប្រជុំគ្នាអស់កាលតាមកាល ( តាមកាលដ៏សមគួរ ) ទ្រង់ឈរ ទ្រង់គង់ ទ្រង់ផ្ទំជាមួយគ្នា ទ្រង់ឃើញនូវមហាជន ដែលជាអ្នកកើតមកហើយចាស់គ្រាំគ្រា និងស្លាប់ទៅវិញ ទើបទ្រង់ប្រឹក្សាគ្នាថា ឈ្មោះថា អ្នកតាមជូនបុគ្គលដែលទៅកាន់បរលោកមិនមាន, ដោយហោចទៅសូម្បីសរីរៈរបស់ខ្លួន ក៏យកទៅតាមមិនបាន, គប្បីលះបង់នូវវត្ថុទាំងពួងហើយទៅ, ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះរបស់យើង, យើងនឹងបួស, ដូច្នោះហើយ ទើបទ្រង់ប្រគល់រាជសម្បត្តិឲ្យដល់ព្រះឱរស និងព្រះអគ្គមហេសី ទ្រង់សាងព្រះផ្នួសជាឥសីនៅក្នុងហិមវន្តប្រទេស ទ្រង់បានប្រឹក្សាគ្នាថា “ពួកយើងមិនមែនជាអ្នកមិនអាចដើម្បីរស់នៅក្នុងភាពជាគ្រហស្ថ

បាន ហើយទើបលះបង់រាជសម្បត្តិបួសទេ, ប្រសិនបើយើងទាំងពីរនៅជាមួយគ្នា ក៏ដូចជាអ្នកមិនបានបួសដែរ, ព្រោះហេតុនោះយើងរស់នៅទីកន្លែងផ្សេងគ្នា លោកចូររស់នៅលើភ្នំនោះ, ខ្ញុំនឹងនៅលើភ្នំនេះ ប៉ុន្តែនឹងជួបគ្នាក្នុងថ្ងៃឧបោសថរាល់ៗកន្លះខែ" លុះក្រោយមក តាបសទាំងពីរនោះកើតមានការប្រឹក្សាគ្នាឡើងយ៉ាងនេះថា "កាលបើដូច្នេះ ការប្រទ្បូកប្រទ្បំដោយពួកគណៈនឹងមានដល់យើងទាំង-ឡាយ លោកចូរញ៉ាំងភ្លើងឲ្យភ្លឺលើភ្នំរបស់លោក ខ្ញុំក៏នឹងញ៉ាំងភ្លើងឲ្យភ្លឺលើភ្នំរបស់ខ្ញុំដែរ ដោយគ្រឿងសម្គាល់នោះ យើងទាំងពីរក៏នឹងដឹងថា យើងទាំងពីរនៅមានជីវិត" តាបសទាំងពីរនោះធ្វើហើយដោយប្រការដូច្នោះ ។

## រឿនមន្តពិណ

ក្នុងសម័យខាងក្រោយមក វេដ្ឋទីបកៈតាបសធ្វើកាលកិរិយាហើយកើតជាស្តេចនៃទេវតាដែលមានសក្តិធំ។ លុះដល់កន្លះខែហើយអល្លកប្បៈមិនឃើញភ្លើងក៏ដឹងថា "សម្លាញ់របស់យើងធ្វើកាល

កិរិយាទៅហើយ” ចំណែកវេជ្ជទីបកតាបសក៏បានរមិលមើលនូវទិព្វសិរី របស់ខ្លួនក្នុងខណៈខ្លួនដែលខ្លួនកើត ហើយពិចារណាដល់កម្មក៏បាន ឃើញកម្មដែលខ្លួនធ្វើចាប់តាំងពីការចេញបួស ក៏គិតថា “ឥឡូវនេះយើងនឹងទៅសួរសុខទុក្ខសម្លាញ់របស់យើង”លុះគិតដូច្នោះហើយ ក៏លះបង់អត្តភាពនោះ ហើយធ្វើដូចជាបុរសអ្នកវង្វេងផ្លូវទៅកាន់ សំណាក់អល្លកប្បតាបសនោះ ថ្វាយបង្គំហើយឈរនៅក្នុងទីដ៏ សមគួរមួយ ។

គ្រានោះ អល្លកប្បតាបសនោះ ក៏សួរបុរសនោះថា អ្នកមកអំពីទីណា ?

បុ. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំជាបុរសវង្វេងផ្លូវ ដើរមកអំពីទីឆ្ងាយ, បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នៅទីនេះតែម្នាក់ឯងទេឬ ? ឬក៏មានអ្នកដទៃណានៅជាមួយដែរ ?

អល្ល. មានតាបសដែលជាសម្លាញ់របស់យើងនៅម្នាក់ដែរ ។

បុ. តាបសដែលជាសម្លាញ់របស់លោកម្ចាស់នុ៎ះ នៅទីណា ?

អល្ល.លោកនៅលើភ្នំឯណោះ ក៏ប៉ុន្តែក្នុងថ្ងៃឧបោសថ លោកមិនបានញ៉ាំងភ្លើងឲ្យភ្លឺប្រាកដជាលោកធ្វើមរណកាលទៅហើយមើលទៅ ។

បុ. បពិត្រលោកម្ចាស់ដ៏ចម្រើន យ៉ាងនោះពិតមែនឬ ?

អល្ល. ម្នាលឧបាសក យ៉ាងនុ៎ះពិតមែន ។

បុ. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំនេះឯងគឺជាសម្លាញ់របស់លោកម្ចាស់ ។

អល្ល. អ្នកកើតនៅទីណា ?

បុ. បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំកើតជាស្តេចទេវតាដែលមានសក្តិធំក្នុងទេវលោក ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមកកាន់ទីនេះវិញ ក៏ដោយបំណងថា នឹងសួរសុខទុក្ខលោកម្ចាស់ កាលលោកម្ចាស់គង់ក្នុងទីនេះ អន្តរាយដែលជាគ្រឿងបៀតបៀនណាមួយមានដល់លោកម្ចាស់ដែរឬទេ ?

អល្ល. អើ ឧបាសក អាត្មាភាពរមែងលំបាកព្រោះអាស្រ័យ ដំរី ។

បុ. បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏ដំរីរមែងធ្វើនូវអ្វីដល់លោកម្ចាស់ ?

អលូ. វាបន្ទោបង់អាចម៍ដាក់ក្នុងទីកន្លែង ជាទីបោសសំអាត យកជើងឈូសអាចម៍ដីឡើង អាត្មាកាពកាលវង់ចាំជញ្ជូន អាចម៍ដំរីយកទៅចោល នឹងចាំតែធ្វើអាចម៍ដីឲ្យស្មើ រមែងលំបាក ។

បុ. លោកម្ចាស់ប្រាថ្នានឹងមិនឲ្យដំរីទាំងនោះមកឬ ?

អលូ. អើ អាវុសោ ។

បុ. បើដូច្នោះ ខ្ញុំនឹងធ្វើមិនឲ្យដំរីទាំងនោះមកលុះពោលដូច្នោះហើយ, ក៏បានឲ្យពិណា សម្រាប់ញ៉ាំងដំរីឲ្យគាប់ចិត្តផង បង្រៀនមន្តសម្រាប់ញ៉ាំងដំរីឲ្យគាប់ ចិត្តផង ដល់ព្រះតាបសនោះ ក៏កាលនឹងឲ្យបានខ្សែពិណា ៣ ខ្សែ ឲ្យរៀនមន្ត ៣ បទ ហើយប្រាប់ថា "កាលដេញខ្សែពិណាមួយខ្សែនេះ រាយមន្តបទនេះ ហើយ, ដំរីមិនអាចនឹងបែរត្រឡប់មើល រមែងចៀសចេញទៅ,

កាលដេញពិណមួយខ្សែនេះវាយមន្តមួយបទ នេះ ហើយ ដំរីនឹងត្រឡប់ បែរមើល ក្រោយ បណ្តើរ រត់ទៅបណ្តើរ,

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៧ -

កាលដេញពិណមួយខ្សែនេះ វាយមន្តបទនេះហើយ ដំរីជាមេហ្វូងរមែងបង្អោនខ្នងមករក" ហើយពោលថា "កម្មឯណាដែលលោកម្ចាស់គាប់ចិត្ត សូមធ្វើនូវកម្មនុ៎ះចុះ" ថ្វាយបង្គំតាបសហើយ ក៏ចៀសចេញទៅ ។

តាបស វាយមន្តសម្រាប់ដេញដំរី ដេញពិណសម្រាប់ដេញដំរី ញុំាងដំរីឲ្យចៀសចេញទៅ ។

## ព្រះបាទឧទេន និង ហត្ថិលិង្គ

ក្នុងសម័យនោះ នៅក្នុងក្រុងកោសម្ពី មានព្រះរាជាទ្រង់ព្រះនាមថា ព្រះបាទបរន្តបៈ ថ្ងៃមួយ ព្រះបាទបរន្តបៈទ្រង់គង់ហាលកម្តៅថ្ងៃដ៏ស្រទន់កណ្តាលវាលជាមួយនឹងព្រះទេវី ដែលជាអ្នកទ្រទ្រង់នូវព្រះគភ៌ ។

ព្រះរាជទេវីទ្រង់ដណ្តប់សំពត់កម្ពលក្រហម ដែលមានតម្លៃមួយសែន ដែលជាព្រះពស្ត្រសម្រាប់ដណ្តប់របស់ព្រះរាជា ទ្រង់គង់ប្រាស្រ័យជាមួយនឹងព្រះរាជា ទ្រង់ដោះចិញ្ចៀនព្រះទម្រង់ដែលមាន



តម្លៃមួយសែនអំពីព្រះអង្គុលីរបស់ព្រះរាជា មកពាក់ព្រះអង្គុលីរបស់ខ្លួន ។

ក្នុងសម័យនោះ បក្សីហត្ថីលិង្គ ( សត្វស្លាបមានភេទដូចជាភេទដំរី ) ហើរមកតាមអាកាស ឃើញព្រះរាជទេវីហើយ ក៏សម្គាល់ថា "ដុំសាច់" ព្រះរាជាទ្រង់ស្លុតព្រះទ័យ ដោយសំឡេងនៃការធ្លាក់ចុះរបស់បក្សីនោះ ស្តេចក៏ក្រោកឡើងហើយយាងចូលទៅកាន់ព្រះរាជនិវេសន៍ ។ ព្រះរាជទេវី ស្តេចមិនអាចយាងទៅដោយរហ័សបាន ព្រោះព្រះនាងមានគភ៌ចាស់ផង ព្រោះជាស្ត្រីមានជាតិជាអ្នកខ្លាចផង ។

គ្រានោះ បក្សីនោះធ្លាក់ហើយ ក៏ញ៉ាំងព្រះទេវីឲ្យគង់ក្នុងរង្វង់នៃក្រចក ហើយហើរទៅកាន់អាកាស ។ បានឮថា សត្វស្លាប

ប្រភេទនោះរមែងទ្រទ្រង់នូវកម្លាំងស្មើនឹងដំរី ៥ ព្រោះហេតុនោះ ទើបនាំចំណីទៅតាមអាកាស ទំនៅក្នុងទីណាដែលខ្លួនពេញចិត្ត ហើយរមែងទំពាស៊ីនូវសាច់នោះ ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៩ -

ចំណែកព្រះទេវីនោះ ដែលបក្សីនោះនាំទៅ ទ្រង់ខ្លាចចំពោះមរណៈ ទើបទ្រង់ព្រះតម្រិះថា ( បើអញស្រែក,ធម្មតាសំឡេងមនុស្សជាទីតាំងនៃសេចក្ដីតក់ស្លុតរបស់សត្វតិរច្ឆាន វាឮសំឡេងនោះហើយ ក៏នឹងបោលអញ កាលបើដូច្នោះ អញនឹងដល់នូវការអស់ជីវិតព្រមទាំងទារកក្នុងផ្ទៃ, ប៉ុន្តែថា វាទំក្នុងទីណា ហើយផ្ដើមនឹងស៊ីអញ ក្នុងពេលនោះ អញនឹងស្រែកឡើង ហើយដេញវាឲ្យចៀសចេញទៅ។ ព្រះរាជទេវីអត់ទ្រាំបាន ក៏ព្រោះព្រះនាងជាបណ្ឌិត។ ក៏ក្នុងកាលនោះ ក្នុងហិមវន្តប្រទេស មានដើមជ្រៃមួយដើមធំចម្រើនឡើងបន្តិច ហើយក៏តាំងនៅដូចជាមណ្ឌប ។ បក្សីនោះ នាំចំណីមានសាច់ជាដើមទៅហើយ រមែងទំពាស៊ីលើដើមជ្រៃធំនោះ, ព្រោះហេតុនោះ បក្សីហត្ថីលិង្គនោះ នាំព្រះរាជទេវីនោះទៅកាន់ដើមជ្រៃធំនោះ

៦៨ តម្កល់ទុកត្រង់ចន្លោះប្រគាបនៃដើមជ្រៃធំនោះហើយងាកមើលផ្លូវ ដែលខ្លួនហើរមក ។ បានឮមកថា ការងាកមើលផ្លូវដែលខ្លួនហើរមកហើយនោះ ជាធម្មតារបស់បក្សីហត្ថិលិង្គនោះ ក្នុងខណៈនោះ



ព្រះទេវីទ្រង់ព្រះតម្រិះថា "ឥឡូវនេះ គួរអញដេញបក្សីនេះឲ្យចៀសចេញ ទៅហើយ" លុះទ្រង់ព្រះតម្រិះដូច្នោះហើយក៏លើកព្រះហស្ត ទាំង ២ ឡើង ទះដៃផង ស្រែកផង ដេញបក្សី នោះឲ្យចៀសចេញទៅ ។ គ្រានោះ ក្នុងកាលព្រះអាទិត្យអស្តង្គត ខ្យល់ កម្មជវាត ( ខ្យល់កើតពីកម្ម ) កម្រើកឡើងហើយក្នុងព្រះផ្ទៃរបស់ព្រះរាជទេវីនោះ មហាមេឃគ្រហឹមតាំងឡើងហើយក្នុងទិសទាំងពួង ឈ្មោះថា ការលង់លក់មិនបានមានហើយអស់រាត្រីទាំងមូលដល់ព្រះរាជទេវី ដែលជាអ្នកចម្រើនដោយសេចក្តីសុខ មិនបានត្រឹមតែពាក្យថា "បពិត្រព្រះនាងដ៏ចម្រើន ព្រះនាងកុំខ្លាចឡើយ" ដែលត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ លុះដល់ពេលភ្លឺច្បាស់ ការរាំងភ្លៀងក្តី ការរះ

ឡើងនៃព្រះអាទិត្យក្តី ការសម្រាលនៃសត្វដែលកើតក្នុងព្រះគភ៌

របស់ព្រះរាជទេវីក្តី បានមានហើយក្នុងខណៈជាមួយគ្នា ។

ព្រះរាជទេវីបានដាក់ឈ្មោះព្រះឱរសថា "ឧទេន" ព្រោះកាន់យកនូវរដូវនៃមេឃ និងរដូវនៃការរះឡើងនៃអរុណហើយប្រសូត ។

លំនៅរបស់អល្លកប្បតាបសនោះសោត ក៏នៅក្នុងទីមិនឆ្ងាយ



អំពីដើមជ្រៃធំនោះ ។ ដោយប្រក្រតី ក្នុងថ្ងៃមានភ្លៀង តាបសនោះតែងតែមិនទៅកាន់ព្រៃដើម្បីប្រយោជន៍ដល់ផ្លែឈើតូចធំឡើយព្រោះ ខ្លាចរងា ទៅកាន់ទីក្បែរគល់ឈើនោះ នាំយកឆ្អឹងម្រឹគដែលសត្វស៊ី ហើយ ដំចំអិនឲ្យមានរសហើយក៏ហុតនូវរសនោះ ដោយហេតុនោះ សូម្បីក្នុងថ្ងៃនោះ តាបសក៏គិតថា "នឹងរើសឆ្អឹង" ទើបទៅក្បែរដើម ឈើនោះ ស្វែងរកឆ្អឹងក្បែរគល់ឈើ បានឮសំឡេងទារកយំខាងលើ ក៏ងើយមើលឃើញព្រះរាជទេវីក៏សួរថា "នាងជានរណា" ?

ព្រះរាជទេវី. ខ្ញុំជាស្ត្រីមនុស្ស ។

តាបស. នាងមកបានដោយប្រការដូចម្តេច ? កាលព្រះរាជទេវីពោលថា សត្វហត្ថីលិង្គនាំនាងខ្ញុំមក, ក៏ពោលថា ( នាងចូរចុះមក ) ។

ព្រះទេវី. បពិត្រលោកម្ចាស់ ខ្ញុំខ្លាចអំពីការបែកធ្លាយនៃជាតិ ។

តាបស. នាងជាអ្វី ?

ព្រះទេវី. នាងខ្ញុំជាក្សត្រិយ៍ ។



តាបស. សូម្បីយើងក៏ជាក្សត្រដែរ ។

ព្រះទេវី. បើដូច្នោះ លោកចូរពោលមាយារបស់ក្សត្រទៅមើល៍!

ព្រះតាបសនោះក៏ថ្លែងមាយារបស់ក្សត្រថ្វាយព្រះរាជទេវី។

ព្រះទេវី. បើដូច្នោះ លោកចូរឡើងមកនាំបុត្រតូចរបស់នាងខ្ញុំចុះ ។

តាបសនោះ ធ្វើផ្លូវសម្រាប់ឡើងតាមចំហៀងម្ខាង ឡើងទៅហើយទទួលយកនូវទារកនោះ, កាលព្រះរាជទេវីពោលហាមថា "កុំយក ដៃពាល់នាងខ្ញុំឲ្យសោះ"

ក៏មិនប៉ះពាល់ព្រះរាជទេវីសោះឡើយ បី ទារកចុះមក ។ ចំណែកព្រះទេវីក៏ចុះមកដែរ ។

គ្រានោះ ព្រះតាបសនាំនាងទៅកាន់អាស្រមបទ មិនធ្វើនូវកិរិយាទម្លាយនូវសីលសោះឡើយ ថែទាំហើយដោយអនុគ្រោះ, នាំទឹកឃ្មុំដែលមិនមានមេមក នាំស្រូវសាលីដែលកើតឯងមកចំអិនឲ្យទៅជាបបរ ហើយថ្វាយព្រះរាជទេវី ។ កាលព្រះតាបសនោះកំពុងថែទាំយ៉ាងនោះ, ក្នុងកាលចំណែកដទៃ ព្រះរាជទេវីគិតថា "យើងមិន



ស្គាល់ផ្លូវទៅផ្លូវមកសោះឡើយ, សូម្បីហេតុត្រឹមតែការស្និទ្ធស្នាលតិចតួចរបស់អញជាមួយនឹងតាបសនេះក៏មិនមាន ប្រសិនបើតាបសនេះនឹងលះបង់អញទៅទីណាៗ, អញទាំងពីរនាក់ ក៏នឹងដល់នូវការស្លាប់ក្នុងទីនេះមិនខាន, គួរតែអញធ្វើអំពើណាមួយហើយញុំាងសីលរបស់តាបសរូបនេះឲ្យវិនាស ធ្វើដោយប្រការដែលតាបសរូបនេះមិនអាចបោះបង់ចោលអញបាន ។ គ្រានោះ ព្រះរាជទេវីក៏ល្បួងលួងលោមតាបសនោះ ដោយការសម្តែងនូវសំពត់ដែលខ្លួន

ស្លៀក មិនល្អ និងសំពត់ដែលខ្លួនដណ្តប់មិនល្អឲ្យវិនាសទៅនូវសីល ។ ចាប់ តាំងពីថ្ងៃនោះមក ជនទាំងពីរនោះក៏នៅរួមគ្នាដោយការព្រមព្រៀងគ្នា ។

## កុមារឧទេនលើកទ័ពដំរី

ថ្ងៃមួយ តាបសពិចារណាមើលនូវគន្លងនៃ ផ្កាយនក្ខត្តឫក្ស ឃើញការសៅហ្មងនៃផ្កាយនក្ខត្តឫក្សរបស់ព្រះរាជាបរន្តបៈ ក៏បាន ពោលថា “ម្នាលនាងដ៏ចម្រើន ព្រះរាជាព្រះនាមបរន្តបៈដែល សោយរាជ



នៅក្នុងក្រុង កោសម្ពីសោយទិវង្គតហើយ” ។

ព្រះរាជទេវីសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ព្រោះហេតុអ្វី ទើប លោកម្ចាស់ពោលយ៉ាងនេះ ? លោកចង់អាឃាតជាមួយនឹង ព្រះបាទ បរន្តបៈឬ ?

តាបសឆ្លើយថា ម្នាលនាងដ៏ចម្រើន មិនមែនទេ អាត្មាបាន ឃើញសេចក្តីសៅហ្មងនៃផ្កាយនក្ខត្តឫក្សរបស់ព្រះរាជាព្រះនាម បរន្តបៈ ទើបនិយាយយ៉ាងនេះ ។

ព្រះរាជទេវីក៏ទ្រង់ព្រះកន្សែងយំសោក ។

គ្រានោះ ព្រះតាបសក៏ត្រាស់សួរព្រះរាជទេវីនោះថា ព្រោះហេតុអ្វី ទើបនាងសោយសោក ? កាលព្រះរាជទេវីត្រាស់ប្រាប់ការដែលព្រះបាទបរន្តបៈនោះជាព្រះស្វាមីរបស់ព្រះនាងហើយ, ក៏ត្រាស់ថា ម្នាលនាងដ៏ចម្រើន កុំសោយសោកឡើយ ធម្មតាសត្វដែលកើតមក ហើយ ទៀងតែស្លាប់យ៉ាងនេះ” ។

ព្រះរាជទេវីត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំដឹង



ហើយ ។

ព្រះតាបសសួរថា កាលបើដឹងដូច្នោះហើយ ហេតុអ្វីទើបនាងសោយសោក ។

ព្រះរាជទេវី. បពិត្រលោកជាម្ចាស់ដ៏ចំរើន បុត្ររបស់ខ្ញុំជាអ្នកគួរ ដល់រាជសម្បត្តិដែលជារបស់ត្រកូល, ប្រសិនបើបុត្ររបស់ខ្ញុំនៅឯ ក្រុងនោះ គេនឹងឲ្យលើកនូវស្វេតច្ឆត្រ ឡើងហើយជាធំក្នុងដែននោះ, ឥឡូវ នេះ គេនឹងជាបុគ្គលសាបសូន្យធំ ហើយ ព្រោះសេចក្ដីស្ដាយយ៉ាង នេះ ទើបខ្ញុំសោយសោក ។

តាបស. ម្នាលនាងដ៏ចម្រើន រឿងហ្នឹងចូលលើកទុកសិនចុះ កុំគិតឡើយ ប្រសិនបើនាងប្រាថ្នាព្រះរាជសម្បត្តិឲ្យដល់បុត្ររបស់ព្រះនាងនោះ អាត្មានឹងធ្វើឧបាយឲ្យបុត្ររបស់ព្រះនាងបាននូវសម្បត្តិ ( សម តាមសេចក្ដីប្រាថ្នា ) ។

គ្រានោះ តាបសបានឲ្យពិណាសម្រាប់ញ៉ាំងដំរីឲ្យគាប់ ចិត្តផង មន្តសម្រាប់ញ៉ាំងដំរីឲ្យគាប់ចិត្តផង ដល់បុត្ររបស់ព្រះរាជទេវី ។



ក្នុងកាលនោះ ដំរីច្រើនសែនមកប្រជុំគ្នាក្បែរដើមជ្រៃធំនោះ ។

គ្រានោះ ព្រះតាបសក៏ត្រាស់ទៅកាន់ព្រះកុមារនោះថា "កាលដំរីទាំងឡាយមិនទាន់មកដល់ ឯងចូរឡើងកាន់ដើមឈើ, កាលដំរីទាំងឡាយមកហើយ, ឯងចូរវាយមន្តបទនេះ ចូរដេញខ្សែពិណាមួយ នេះ, ដំរីទាំងអស់មិនអាចនឹងងាកមកមើល និងរត់ទៅ, ពេល នោះ ឯងគប្បីចុះមក" ព្រះកុមារទ្រង់ធ្វើដោយប្រការដូច្នោះហើយ ត្រឡប់មកតាបសប្រាប់នូវការប្រព្រឹត្តិទៅនោះហើយ លុះដល់ថ្ងៃទី ២ តាបសក៏ពោលនឹងព្រះកុមារនោះថា ក្នុងថ្ងៃនេះ ឯងចូរវាយមន្តនេះ គប្បីនូវខ្សែពិណានេះ ដំរីងាកមើលក្រោយបណ្តើរ រត់ទៅ បណ្តើរ សូម្បីក្នុងកាលនោះ ព្រះកុមារក៏ទ្រង់ធ្វើតាមការណែនាំនោះ ហើយ ត្រឡប់មកប្រាប់តាបសម្តងទៀត ។ គ្រានោះ ព្រះតាបស ហៅព្រះមាតារបស់ព្រះកុមារនោះមកហើយប្រាប់ថា "ម្នាលនាងដ៏ចំរើន នាងចូរប្រាប់បុត្ររបស់នាង, កាលណាបុត្ររបស់នាងទៅអំពីទីនេះ ហើយនឹងបានជាស្តេចផែនដី" ព្រះទេវីទ្រង់ត្រាស់ហៅព្រះឱរសមក

ហើយប្រាប់ថា "នៃកូន កូនឯងជាបុត្តរបស់ព្រះបាទបរន្តបៈក្រុងកោសម្ពី, សត្វហត្ថីលិង្គនាំមាតាមកទីនេះទាំងដែលមាតាមានគភ៌" ដូច្នេះហើយ ត្រាស់ប្រាប់ ឈ្មោះរបស់សេនាបតីជាដើមហើយត្រាស់ថា "បើពួកគេមិនជឿ កូន ឯងគប្បីយកសំពត់កម្ពលសម្រាប់ដណ្តប់ របស់ព្រះបិតា និងចិញ្ចៀន ព្រះទម្រង់ដែលជាគ្រឿងប្រដាប់របស់ ព្រះបិតានេះ បង្ហាញពួកគេ ដែលជាអ្នកមិនជឿ, លុះទ្រង់មានព្រះសវនីដូច្នេះហើយ បញ្ជូនបុត្តទៅ ។

ព្រះកុមារក៏សួរតាបសនោះថា "ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេច" ?

តាបសនោះពោលថា "ឯងចូរអង្គុយលើមែកឈើខាងក្រោមចូរ ពោលនូវមន្តនេះ ចូរដេញខ្សែពិណនេះ ដំរីជាមេហ្វូងនឹងបង្អោនខ្នងចូលមករកឯង, ឯងចូរអង្គុយលើខ្នងដំរីនោះហើយចូលទៅយករាជសម្បត្តិចុះ" ។

ព្រះកុមារនោះ ថ្វាយបង្គំព្រះរាជបិតាព្រះរាជមាតាហើយ ទ្រង់ធ្វើតាមពាក្យរបស់ព្រះតាបសនោះហើយ អង្គុយលើខ្នងដំរីដែលមកហើយ ខ្សឹបប្រាប់ដំរីថា "នៃដំរី យើងជាបុត្ររបស់ព្រះ

បាទបរន្តបៈក្រុងកោសម្ពី, សូមអ្នកចូរកាន់យករាជសម្បត្តិដែលជារបស់ព្រះបិតាខ្ញុំឲ្យដល់ខ្ញុំចុះ" ។ ដំរីជាមេហ្វូងស្តាប់ពាក្យនោះហើយក៏ស្រែកនូវសម្រែកជាសំឡេងដំរីថា "ដំរីចូរមកប្រជុំគ្នាច្រើនៗ ពាន់" ។ ដំរីច្រើនពាន់ក៏មកប្រជុំគ្នា ។ ស្រែកទៀតថា "ដំរីចាស់ៗ ចូរថយចេញ" ។ ដំរីចាស់ៗ ក៏នាំគ្នាថយចេញទៅ ។ ស្រែកទៀតថា "ដំរីក្មេងៗពេកចូរត្រឡប់ទៅវិញចុះ" ។ សូម្បីដំរីទាំងនោះក៏នាំគ្នាត្រឡប់ ទៅវិញអស់ ។ ព្រះកុមារនោះ ដែលដំរីចំបាំងទាំងឡាយច្រើនពាន់ ចោមរោមហើយ ទៅដល់ស្រុកដែលឋិតនៅក្នុងទីបំផុតនៃដែនហើយ ប្រកាសថា "យើងជាបុត្ររបស់ស្តេចផែនដី, អ្នកដែលប្រាថ្នារាជ សម្បត្តិ ចូរមកជាមួយនឹងយើង" ។ ចាប់ដើមអំពីនោះទៅក៏ទ្រង់ ធ្វើការរួបរួមប្រមូលមនុស្សទៅឡោមព័ទ្ធព្រះនគរ ហើយបញ្ជូន សាសន៍ទៅថា "នឹងឲ្យយើងច្បាំង ឬក៏ឲ្យរាជសម្បត្តិដល់យើង" ? អ្នក នគរទាំងឡាយពោលថា "យើងមិនឲ្យទាំងពីរយ៉ាង, ពិតណាស់ ព្រះ រាជទេវីរបស់ពួកយើងមានព្រះគភ៌ចាស់ ត្រូវសត្វហត្ថីលិង្គនាំយកទៅ

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ១៩ -

ហើយ យើងទាំងឡាយមិនដឹងថា ព្រះទេវីនៅមានព្រះជន្មឬក៏សោយទិវង្គត់ទៅហើយ ដរាបណាដែលយើងមិនបានដឹងរឿងរ៉ាវរបស់ព្រះទេវីទេ ដរាបនោះយើងនឹងមិនឲ្យទាំងការច្បាំងទាំងរាជសម្បត្តិ"។បាន

ព្វថា ភាពជាស្តេចផែនដីជារាជសម្បត្តិតាមប្រពៃណីតៗ វង្សត្រកូលបានមានមកហើយក្នុងកាលនោះ ។ លំដាប់នោះ ព្រះកុមារក៏ត្រាស់ថា “ខ្ញុំជាបុត្តរបស់ព្រះនាង ហើយអាងឈ្មោះរបស់សេនាបតីជាដើម ។ កាលពួកនគរទាំងនោះមិនជឿនូវសេចក្តីនោះ ក៏បង្ហាញសំពត់កម្ពលក្រហម និងចិញ្ចៀនព្រះទម្រង់ដល់អ្នកនគរទាំងអស់ ។ ពួកអ្នកនគរចាំសំពត់កម្ពលក្រហម និងចិញ្ចៀនព្រះទម្រង់នោះបាន ក៏អស់សេចក្តី សង្ស័យក្នុងចិត្ត ទើបបើកទ្វារអភិសេកកុមារនោះទុក ក្នុងរាជសម្បត្តិ ។

( នេះជាការកើតឡើងនៃព្រះបាទឧទេន )

## ពីរនាក់ប្តីប្រពន្ធទៅរកអាជីព

ក៏កាលទុព្ភិក្ខភ័យកើតឡើងក្នុងដែនអល្លកប្បៈ បុរសម្នាក់



ឈ្មោះកោតុហលិកមិនអាចនឹងរស់នៅបាន, ក៏នាំភរិយាដែលមានកូនខ្ចីឈ្មោះកាឡី កាន់យកនូវស្បៀងសម្រាប់ដើរផ្លូវចេញទៅហើយដោយបំណងថា “នឹងទៅរស់នៅឯក្រុងកោសម្ពី” ។ អាចារ្យពួកខ្លះពោលថា “បុរសឈ្មោះកោតុហលិក ចេញទៅហើយក្នុងកាលមហា

ជនកំពុងស្លាប់ដោយអហិវាតរោគ ( រោគខ្យល់មានពិស ដូចជាពិសពស់ )" ពីរនាក់ប្តីប្រពន្ធធ្វើដំណើរទៅ កាលស្បៀងអស់ហើយ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ មិនអាចនឹងនាំបុត្ររបស់ខ្លួនទៅបាន ។ គ្រានោះ បុរសជាស្វាមីពោលនឹងភរិយាថា "ម្នាលនាងដ៏ចំរើន កាលយើងទាំង ២ នាក់នៅមានជីវិត ក៏នឹងបានបុត្រទៀត, ចោលបុត្តនេះហើយធ្វើដំណើរទៅចុះ" ធម្មតាថា ហឫទ័យរបស់មាតាជាធម្មជាតិដ៏ទន់ ព្រោះហេតុនោះ ទើបនាងនិយាយថា "ខ្ញុំមិនអាចចោលកូនដែលនៅមានជីវិតបានទេ ។

ស្វាមី. បើដូច្នេះ យើងនឹងធ្វើដូចម្តេច ?

ភរិយា. យើងផ្លាស់ប្តូរវេនគ្នានាំគេទៅ ។ មាតាលើកបុត្រ



ឡើង ដូចជាលើកកម្រងផ្កា ក្នុងវារៈវេនរបស់ខ្លួនឲ្យដេកពួដ៏ទ្រូងនាំទៅដោយចង្កេះ ក៏ឲ្យដល់បិតា ។ វេទនាមានកម្លាំងខ្លាំងជាងសេចក្តីស្រេកឃ្លានកើតឡើងដល់បុរសដែលជាស្វាមីនោះ ក្នុងកាលដែលខ្លួនទទួលយកបុត្រនោះហើយដាក់ចុះ បុរសដែលជាស្វាមីក៏និយាយនឹងភរិយានោះរឿយៗថា ម្នាលនាងដ៏ចម្រើន យើងនៅមានជីវិតនឹងបានបុត្រទៀតពុំខាន ចូរចោលកូននេះទៅចុះ" ។ ចំណែកស្ត្រីជា

កិរិយាក៏ហាមឃាត់បុរសដែលជាស្វាមីរឿយៗ ហើយក៏ស្ងៀមទៅ មិនបានឆ្លើយអ្វីទាំងអស់ ។ កូននោះត្រូវមាតា និងបិតាផ្លាស់ប្តូរវេនគ្នាតាមវារៈយ៉ាងនោះនឿយហត់ ហើយក៏ដេកលក់ក្នុងដៃរបស់បិតាទៅ ។ បុរស ដែលជាស្វាមីដឹងថាកូនប្រុសរបស់ខ្លួនដេកលក់ក៏បណ្តោយ ឲ្យកិរិយាដើរទៅមុន ហើយយកកូនឲ្យដេកលើកម្រាលស្លឹកឈើ ក្រោមគុម្ពឈើមួយគុម្ព ហើយដើរទៅតាមក្រោយ, មាតាបែរត្រឡប់មកមើលមិនឃើញកូន ក៏សួរថា “បពិត្រអ្នកជាស្វាមី កូនរបស់ យើងទៅ ណា” បុរសដែលជាស្វាមី ឆ្លើយថាខ្ញុំឲ្យដេកលើកម្រាលក្រោម



គុម្ពឈើមួយគុម្ពឯណោះ កិរិយាគក់ទ្រូងខ្សឹបខ្សួលពោលថា បពិត្រអ្នកជាស្វាមី លោកកុំធ្វើឲ្យខ្ញុំវិនាសឡើយ, ខ្ញុំវៀរកូនចេញហើយមិនអាចរស់នៅបានទេ, សូមលោកចូលទៅនាំយកកូនមកឲ្យខ្ញុំវិញ ។ គ្រានោះ បុរសដែលជាស្វាមីក៏ត្រឡប់ទៅយកកូននោះមកវិញ ក៏ឯកូននោះបានស្លាប់តាមផ្លូវបាត់ទៅហើយ ។ នាយកោតុហលិកចោលកូនក្នុងទីប្រមាណប៉ុណ្ណោះ ទើបត្រូវគេយកទៅបោះចោលអស់ ៧ ដងក្នុងវាងនៃភពដោយផលនៃកម្មនោះ ដោយប្រការដូច្នេះ ។ ដែល

ឈ្មោះថា បាបកម្ម បុគ្គលមិនគួរមើលងាយថាមានប្រមាណ ( តិចតួច ) ដូច្នេះឡើយ ពីរនាក់ប្ដីប្រពន្ធធ្វើដំណើរទៅកាន់ត្រកូលអ្នករក្សាគោមួយ ( គឺអ្នកចិញ្ចឹមគោ ) ។

## នាយកោតុហលិកស្លាប់ទៅកើតជាសុនខ

ក៏ក្នុងថ្ងៃនោះ មានពិធីមង្គលដើម្បីមេគោរបស់នាយគោបាល ។ ព្រះបច្ចេកពុទ្ធមួយព្រះអង្គ រមែងឆាន់ក្នុងផ្ទះរបស់នាយគោបាលជានិច្ច ។ នាយគោបាលនោះនិមន្តព្រះបច្ចេកពុទ្ធឲ្យឆាន់ស្រេចហើយ



ទើបបានធ្វើនូវពិធីមង្គល ។ បាយបាយាសជាច្រើនដែលនាយគោ-បាលនោះតាក់តែងទុកហើយ នាយគោបាលបានឃើញពីរនាក់ប្ដីប្រ-ពន្ធនោះមកដល់ហើយ ក៏សួរថា “អ្នកមកអំពីទីណា” ? បានដឹងរឿងនោះហើយជាកុលបុត្រអ្នកមានចិត្តទន់ ក៏ធ្វើសេចក្ដីអនុគ្រោះចំពោះប្ដីប្រពន្ធនោះ ញ៉ាំងគេឲ្យៗ នូវបាយាស និងទឹកដោះថ្លាជាច្រើនដល់ពីរនាក់ប្ដីប្រពន្ធនោះ ។

ប្រពន្ធពោលនឹងប្តីថា "បពិត្រអ្នកជាម្ចាស់ កាលលោកនៅមានជីវិត ខ្ញុំក៏ឈ្មោះថា នៅមានជីវិតដែរ លោកជាអ្នកមានពោះផតអស់កាលជាយូរមកហើយ ចូរបរិភោគតាមសេចក្តីត្រូវការចុះ" ដូច្នេះហើយ ក៏ដាក់បាយាស និងសប្បិចំពោះមុខប្តី ចំណែកខ្លួនឯងបរិភោគនូវសប្បិតែបន្តិចបន្តួចប៉ុណ្ណោះ ។ ចំណែកនាយកោតុហលិកៈបរិភោគមធុបាយាសច្រើនពេក មិនអាចកាត់ចំណង់ក្នុងរសនៃអាហារបាន ព្រោះខ្លួនស្រេកឃ្លានអស់ ៧-៨ ថ្ងៃហើយ ។

នាយគោបាល លុះញុំាងបុគ្គលឲ្យៗនូវបាយាសដល់ប្តីប្រពន្ធ



ហើយ ទើបបរិភោគជាខាងក្រោយ ។ នាយកោតុហលិកៈអង្គុយមើលនាយគោបាលឃើញដុំបាយាស ដែលនាយគោបាលពូតហើយឲ្យដល់មេឆ្កែដែលដេកនៅខាងក្រោមតុ ក៏គិតថា "យី អើ! មេឆ្កែនេះមានបុណ្យច្រើនណាស់ហ្ន៎ ទើបបានភោជនបែបនេះជានិច្ច" ។ នាយកោតុហលិកៈនោះ មិនអាចញុំាងបាយាស ឲ្យរលាយបាន ទើបធ្វើកាលកិរិយាក្នុងពេលរាត្រីនោះ ហើយកើតក្នុងផ្ទៃនៃមេឆ្កែនោះ ។ គ្រានោះ ភរិយារបស់គាត់ធ្វើសរីរកិច្ច ( ដុត ) ហើយក៏ធ្វើការស៊ីឈ្នួលក្នុងផ្ទះនោះឯង បានអង្ករមួយនាឡិចំអិន

ហើយយកទៅដាក់បាត្រព្រះបច្ចេកពុទ្ធហើយពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមកុសលនេះចូរមានដល់ទាសៈរបស់លោកម្ចាស់ចុះ” ដូច្នេះហើយ ទើបគិតថា “អញគួរតែនៅក្នុងទីនេះឯង,លោកម្ចាស់ដ៏ចម្រើនអង្គនេះតែងតែមកកាន់ទីនេះជានិច្ច, ទេយ្យធម៌មានក្តីមិនមានក្តីមិនជាបញ្ហា, យើងថ្វាយបង្គំហើយធ្វើការខ្វល់ខ្វាយបម្រើញុំាងចិត្តឲ្យ ជ្រះថ្លារាល់ៗ ថ្ងៃ និងជួបប្រសព្វនូវបុណ្យច្រើន ( គិតដូច្នេះហើយ )



ទើបនាងធ្វើជាទាសីក្នុងផ្ទះនោះឯង ។

## សុនខងាប់ព្រោះអាស្រ័យព្រះបច្ចេកពុទ្ធ

ក្នុងខែទី ៦ ឬទី ៧ មេឆ្កែនោះឯង ក៏កើតកូនឈ្មោលមួយ ។ នាយគោបាលក៏បញ្ចូឲ្យៗនូវទឹកដោះស្រស់ដល់កូនឆ្កែនោះ មិនយូរប៉ុន្មានកូនឆ្កែនោះក៏ធំធាត់ឡើង ។ គ្រានោះ ព្រះបច្ចេកពុទ្ធ-កាលឆាន់ រមែងឲ្យដុំបាយមួយដុំដល់កូនឆ្កែនោះជានិច្ច ។ ព្រោះអា-ស្រ័យដុំបាយនោះ ទើបកូនឆ្កែនោះមានសេចក្តីស្រឡាញ់ព្រះបច្ចេក-ពុទ្ធនោះ ។ នាយគោបាលរមែងទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធ ( មួយថ្ងៃ ) ២ ដងជានិច្ច ។ នាយគោបាលនោះកាលដើរទៅតែងប្រហារនូវគុម្ពឈើទាំងឡាយផង នូវផែនដីផងដោយដំបង ក្នុងទីដែលមានសត្វសាហាវតាមផ្លូវបញ្ចេញសំឡេងថា “សុ សុ” អស់ វារៈ ៣ ដង

ញុំាំងសត្វសាហាវទាំងឡាយឲ្យរត់ចេញទៅ ។ ឯកូនឆ្កែនោះតែងតែ ទៅជាមួយនឹងនាយគោលបាលនោះដែរ ក្នុងសម័យថ្ងៃមួយ នាយ គោបាលក៏ពោលទៅកាន់ព្រះបច្ចេកពុទ្ធថា “បពិត្រលោកម្ចាស់ដ៏ចំរើន



កាលណាខ្ញុំព្រះអង្គមិនមានឱកាសទំនេរ ក្នុងកាលនោះ ខ្ញុំម្ចាស់នឹង បញ្ជូនកូនឆ្កែនេះមក សូមលោកម្ចាស់គប្បីមកតាមសញ្ញានៃកូនឆ្កែ ជាសត្វដែលខ្ញុំម្ចាស់បញ្ជូនមកហើយ” ។ តាំងពីកាលនោះមក ក្នុងថ្ងៃ ដែលមិនមានឱកាស នាយគោបាលនោះក៏បញ្ជូនកូនឆ្កែទៅថា “នែ៎ បា ឯងចូរទៅនាំលោកម្ចាស់មក” ។ ដោយពាក្យត្រឹមតែមួយមាត់ ប៉ុណ្ណោះ កូនឆ្កែនោះក៏ស្ទុះរត់ទៅ ដល់ទីដែលនាយគោបាលវាយ គុម្ពឈើ និងផែនដីក៏ព្រុសឡើង ៣ ដង ដឹងថាសត្វសាហាវរត់បាត់ អស់ដោយសារសំឡេងនោះហើយ ក៏ទៅកាន់សំណាក់របស់ ព្រះបច្ចេកពុទ្ធ ដែលធ្វើសរីរបដិបត្តិពីព្រលឹមចូលទៅកាន់បណ្ណ សាលា ទៅដល់ទ្វារបណ្ណសាលាហើយ ព្រុសឡើង ៣ ដង ឲ្យព្រះបច្ចេកពុទដឹងថា ខ្លួនមកដល់ហើយ ក៏ដេកក្រាបនៅ ទីដ៏សមគួរមួយ ។ កាលព្រះបច្ចេកពុទ្ធកំណត់ពេលវេលាចេញ ទៅហើយ កូនឆ្កែនោះដើរបណ្ដើរព្រុសបណ្ដើរអំពី ខាងមុខៗចំណែក ព្រះបច្ចេកពុទ្ធកាលនឹងល្បងមើលកូនឆ្កែ ក៏ធ្វើជានិមន្តទៅកាន់ផ្លូវ ដទៃក្នុងចន្លោះៗ ពេលនោះ កូនឆ្កែនោះក៏រត់ទៅឈរព្រុស

ស្មាក់មុខព្រះបច្ចេកពុទ្ធ ហើយនាំលោកចុះកាន់ផ្លូវក្រៅពីនេះ ។ ក្នុងថ្ងៃមួយនោះ ព្រះបច្ចេកពុទ្ធកាលនឹងល្បងមើលសុនខនោះ ទើបនិមន្តទៅកាន់ផ្លូវដទៃទៀត សូម្បីកូនឆ្កែនោះ ក៏ឈរព្រួសស្មាក់នៅពីខាងមុខក៏មិនត្រឡប់ យកជើងទាត់សុនខហើយនិមន្តទៅ សុនខដឹងថាព្រះបច្ចេកពុទ្ធមិនត្រឡប់ ក៏ត្រឡប់ទៅខាំជាយស្បង់ទាញមកនាំលោកចុះកាន់ផ្លូវដើមវិញទៀត ។

សុនខនោះបានញុំាងសេចក្ដីស្រឡាញ់ដ៏មានកម្លាំងឲ្យកើតមានហើយចំពោះព្រះបច្ចេកពុទ្ធអង្គនោះ ដោយប្រការ ដូច្នេះ ។

ក្នុងកាលជាចំណែកដទៃ ចីវររបស់ព្រះបច្ចេកពុទ្ធបានចាស់គ្រាំគ្រា ។ គ្រានោះ នាយគោបាលបានប្រគេនសំពត់សម្រាប់ធ្វើចីវរដល់លោក ។ ព្រះបច្ចេកពុទ្ធពោលទៅកាន់នាយគោបាលនោះថា "ម្នាលអ្នកដ៏ចម្រើន ការធ្វើចីវរជាកម្មដែលបុគ្គលធ្វើម្នាក់ឯងបានដោយលំបាក, អាត្មានឹងទៅកាន់ទីជាទីសប្បាយ ហើយនឹងធ្វើ" ។

នាយ. បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តធ្វើក្នុងទីនេះចុះ ។

ព្រះ. ម្នាលអ្នកដ៏មានអាយុ អាត្មាមិនអាច ។

នាយ. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះសូមលោកម្ចាស់កុំ ទៅកាន់ទីដទៃអស់កាលយូរពេក ។

សុនខបានឈរស្តាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធ និងនាយគោ-បាលនោះនិយាយគ្នា ។

ព្រះបច្ចេកពុទ្ធពោលនឹងនាយគោបាលនោះថា "នែ៎ ឧបាសក ចូរឈប់ចុះ" ឲ្យនាយគោបាលត្រឡប់ទៅវិញ ហើយហោះឡើងទៅកាន់វេហាស៍ មានមុខឆ្ពោះទៅកាន់ភ្នំគន្ធមាទន៍ ។ សុនខសម្លឹងមើលព្រះបច្ចេកពុទ្ធដែលហោះទៅកាន់អាកាស ហើយក៏ ឈរលូកាលព្រះបច្ចេកពុទ្ធនោះកន្លងផុតគន្លងចក្ខុទៅ ហទយៈក៏ បែក ។

## សុនខបានទៅកើតជាឃោសកទេវបុត្រ

ដែលឈ្មោះថា សត្វតិរច្ឆានទាំងឡាយ ជាសត្វមានជាតិជាអ្នកស្មោះត្រង់, ចំណែកមនុស្ស ចិត្តគិតផ្សេង មាត់និយាយផ្សេង(មិន

ដូចគ្នា ) ព្រោះហេតុនោះឯង បុត្ររបស់នាយទូមាក់ជីវីឈ្មោះបេស្សៈ ពោលថា "បពិត្រព្រះអង្គដ៏ចម្រើន ខន្ធបញ្ចកៈ គឺមនុស្សនេះសាំញ៉ាំ ( កកិចកកុច ) ណាស់ បពិត្រព្រះអង្គដ៏ចម្រើន ខន្ធបញ្ចកៈនេះ គឺបសុសត្វនេះជាសត្វស្លូតត្រង់ ។ សុនខនោះ ធ្វើកាលកិរិយាទៅហើយកើតក្នុងឋានតាវត្តិង្ស មានទេពអប្សរ ១០០០ ហែហមចោមរោមជាបរិវារ បានសម្បត្តិដ៏ធំ ក៏ព្រោះជាសត្វមានការឃើញដ៏ត្រូវត្រង់ និងមិនវៀចវេរនោះ ដោយប្រការដូច្នេះ ។

កាលទេវបុត្រនោះខ្សឹបក្នុងទីជិតត្រចៀករបស់បុគ្គលណាៗ សំឡេងរមែងផ្សាយទៅកាន់ទីឆ្ងាយ ១៦ យោជន៍ ចំណែកសំឡេងដែលនិយាយធម្មតារមែងផ្សាយទៅពេញទាំង ទេពនគរ ដែលមានប្រមាណមួយម៉ឺនយោជន៍ ។ ព្រោះហេតុនោះឯង ទើបទេវបុត្រនោះមាននាមថា "ឃោសកទេវបុត្រ" ។ នេះជាផលនៃកម្មអ្វី ? ជាផលនៃការព្រួសដោយសេចក្តីស្រឡាញ់ព្រះបច្ចេកពុទ្ធ ។ ឃោសក-ទេវបុត្រនោះ តាំងនៅក្នុងទេពនគរនោះមិនយូរប៉ុន្មានក៏ចុតិ ។

## ហេតុដែលធ្វើឲ្យទេវបុត្រចុតិមាន ៤ ប្រការ

ពិតណាស់ ទេវបុត្រទាំងឡាយ រមែងចុតិចាកទេវលោកដោយហេតុ ៤ យ៉ាងគឺ ៖

**១. អាយុក្ខយេន** ដោយការអស់អាយុ ។

**២. បុញ្ញក្ខយេន** ដោយការអស់បុណ្យ ។

**៣. អាហារក្ខយេន** ដោយការអត់អាហារ ។

**៤. កោបេន** ដោយសេចក្តីក្រោធ ។

ក្នុងបណ្តាហេតុ ៤ យ៉ាងនោះ ទេវបុត្រអង្គណាធ្វើបុញ្ញកម្ម ទុកច្រើន ទេវបុត្រអង្គនោះកើតក្នុងទេវលោក តាំងនៅក្នុងទេវលោក ដរាបអស់អាយុហើយ ក៏រមែងកើតក្នុងទេវលោកជាន់ខ្ពស់ៗឡើងទៅ, យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអស់អាយុ ។ ទេវបុត្រអង្គ ណាធ្វើបុណ្យទុកតិចតួច, បុណ្យនោះរមែងអស់ទៅក្នុងចន្លោះ ដូច ធញ្ញជាតិ ដែលបុគ្គលដាក់ក្នុងជង្រុកធំប្រមាណត្រឹមតែ ៤-៥ នាឡិ ដូច្នោះ, យ៉ាងនេះឈ្មោះថា រមែងចុតិដោយការអស់បុណ្យ ។ ទេវ-បុត្រអង្គខ្លះ រវល់តែបរិភោគកាមគុណ មិនបរិភោគអាហារ ព្រោះ

ការវង្វេងភ្លេចសតិ មានការនឿយហត់ក៏ចុតិទៅ, យ៉ាងនេះឈ្មោះថា ចុតិដោយការអស់អាហារ ។ ទេវបុត្រអង្គខ្លះ អត់ទ្រាំមិនបានចំពោះសម្បត្តិទេវបុត្រដទៃ ក្រោធហើយក៏ចុតិ, យ៉ាងនេះឈ្មោះថា ចុតិដោយសេចក្តីក្រោធ ។

## ឃោសកទេវបុត្រទៅកើតក្នុងក្រុងកោសម្ពី

ចំណែកឃោសកទេវបុត្រអង្គនេះ វង្វេងតែបរិភោគកាមគុណ វង្វេងភ្លេចសតិ ទើបចុតិដោយការអស់អាហារ ។ លុះចុតិហើយទៅបដិសន្ធិក្នុងផ្ទៃនៃស្ត្រីលំអនគរក្នុងក្រុងកោសម្ពី ។ក្នុងថ្ងៃសម្រាលនាងសួរទាសីថា "កូនប្រុស ឬកូនស្រី" ? កាលនាងទាសីឆ្លើយថា "បពិត្រព្រះនាងជាម្ចាស់ កូនប្រុស" ទើបប្រាប់នាងទាសីឲ្យយកទៅបោះចោលដោយពាក្យថា "នាងចូរយកទារកនេះដាក់ក្នុងចង្អេរចាស់ហើយយកទៅបោះចោលលើគំនរសំរាមចុះ" ពិតណាស់ ស្ត្រីលំអក្រុងទាំងឡាយ រមែងចិញ្ចឹមតែកូនស្រី មិនចិញ្ចឹមកូនប្រុសទេ, ត្បិតថា ប្រពៃណីនៃពួកនាង រមែងជាប់តមិនដាច់ដោយសារកូនស្រី ។

ក្អែកទាំងឡាយ ឆ្កែទាំងឡាយនាំគ្នាចោមរោមនៅជុំវិញទារកនោះ ។ ដោយ ផលនៃការព្រួស ដែលកើតអំពីសេចក្ដីស្រឡាញ់ព្រះ-បច្ចេកពុទ្ធ សូម្បីសត្វតែមួយក៏មិនអាចចូលទៅជិតបាន ។ ក្នុងខណៈនោះ មនុស្ស ចេញទៅខាងក្រៅផ្ទះឃើញក្អែក និងឆ្កែប្រជុំគ្នា ក៏គិតថា អ្វីហ្ន៎ ?, ក៏ដើរទៅកាន់ទីនោះ ឃើញទារកក៏មានសេចក្ដីស្នេហាទារកនោះដូច ជាកូនរបស់ខ្លួន ទើបនាំយកទៅផ្ទះដោយសេចក្ដីរីករាយថា "យើងបានកូនប្រុសមួយហើយ ។

## នាងទាសីនាំយោសកទារកទៅឲ្យគោជាន់

គ្រានោះ សេដ្ឋីអ្នកនៅក្នុងក្រុងកោសម្ពី ទៅកាន់រាជត្រកូល បានជួបបុរោហិតដែលដើរមកពីព្រះរាជវាំង ក៏សួរថា "បពិត្រលោកអាចារ្យ ថ្ងៃនេះលោកបានពិចារណាមើលការប្រកបនៃផ្កាយនក្ខត្ត-ឫក្ស ដែលជាហេតុនៃគ្រោះល្អ ឬអាក្រក់ហើយឬ ?

បុរោហិត. អើ មហាសេដ្ឋី កិច្ចអ្វីដទៃរបស់យើងមានឬ ?

សេដ្ឋី. បពិត្រលោកអាចារ្យ អ្វីនឹងមានដល់អ្នកជនបទឬ ?

បុរោហិត. អ្វីយ៉ាងដទៃមិនមានទេ, ប៉ុន្តែទារកណាដែលកើតក្នុងថ្ងៃ នេះ នឹងបានជាសេដ្ឋីដ៏ប្រសើរក្នុងក្រុងនេះ ។

គ្រានោះ ភរិយារបស់សេដ្ឋីមានគភ៌ចាស់ខែ ព្រោះហេតុនោះ សេដ្ឋីនោះ ក៏បានបញ្ជាបម្រើឲ្យទៅកាន់ផ្ទះយ៉ាងឆាប់ដោយពាក្យថា "នែ៎ ឋា ឯងចូរទៅ ចូរដឹងនូវភរិយារបស់អញនេះថា "សម្រាលហើយ ឬថានៅឡើយទេ" ។ លុះដឹងថា "មិនទាន់សម្រាល" គាល់ព្រះរាជា ហើយ ទៅកាន់ផ្ទះយ៉ាងរហ័ស ហៅទាសីម្នាក់ឈ្មោះកាឡីមកហើយ ឲ្យយកទ្រព្យ ១ ពាន់ ពោលថា "នាងចូរទៅរកមើលក្នុងក្រុងនេះ ឲ្យទ្រព្យ ១ ពាន់ នាំយកទារកដែលកើតក្នុងថ្ងៃនេះមក" ។ នាង កាឡីនោះបានដើរទៅកាន់ផ្ទះនោះ ឃើញទារកហើយ ក៏សួរស្ត្រីមេផ្ទះ ថា "ក្មេងនេះ កើតអំពីកាលណា ? កាលស្ត្រីមេផ្ទះនោះឆ្លើយថា "កើត ថ្ងៃនេះឯង" ទើបនិយាយថា "ចូរឲ្យក្មេងនេះដល់ខ្ញុំ ឲ្យតម្លៃតាំងពី មួយកហាបណៈជាដើមរហូតដល់មួយពាន់ ហើយនាំក្មេងនោះទៅឲ្យ លោកសេដ្ឋី ។ លោកសេដ្ឋីគិតថា "បើកូនរបស់យើងកើតមកជាស្រី

យើងនឹងផ្គុំផ្គុំវាជាមួយនឹងកូនស្រីរបស់យើង ហើយធ្វើឲ្យវាជាម្ចាស់តំណែងសេដ្ឋី, បើកូនរបស់យើងជាប្រុស យើងនឹងសម្លាប់វាចោល" ដូច្នោះហើយ ក៏ទទួលក្មេងនោះទុកក្នុងផ្ទះរបស់ខ្លួន ។ ក្រោយមក កន្លងទៅបានពីរបីថ្ងៃ ភរិយារបស់លោកសេដ្ឋីនោះ ក៏សម្រាលបុត្រប្រុសមួយ ។ សេដ្ឋីក៏គិតថា "ប្រសិនបើមិនមានក្មេងនេះទេ កូនប្រុសរបស់យើងក៏នឹងបានតំណែងជាសេដ្ឋី, ឥឡូវនេះ យើងគួរតែសម្លាប់ក្មេងនេះចោល" ដូច្នេះហើយ ក៏ហៅនាងទាសីមកហើយប្រាប់ថា "ក្នុងវេលាហ្វូងគោចេញពីក្រោល នាងចូរយកក្មេងនេះឲ្យវាដេកទទឹងផ្លូវ ត្រង់កណ្តាលទ្វារក្រោលគោទាំងឡាយ គោទាំងឡាយនឹងជាន់វាឲ្យស្លាប់, តែត្រូវដឹងថាគោជាន់វា ឬមិនជាន់ហើយសឹមមក ។ នាងទាសីនោះទៅហើយ គ្រាន់តែនាយគោបាលបើកទ្វារក្រោលភ្លាម ក៏យកក្មេងនោះឲ្យដេកនៅនាទ្វារក្រោលតាមពាក្យបញ្ជារបស់លោកសេដ្ឋី ។ គោឧសភដែលជាមេហ្វូង ក្នុងថ្ងៃមុនៗ ចេញអំពីក្រោលក្រោយគេបង្អស់, ប៉ុន្តែក្នុងថ្ងៃនោះ ចេញទៅ

មុនគោជទៃទាំងអស់ ហើយបានឈរបាំង ការពារទារកទុកក្នុងចន្លោះជើងទាំង ៤ ។ មេគោទាំងឡាយច្រើនរយ នាំគ្នាប្រជ្រៀតនូវចំហៀងទាំងពីរខាងនៃគោឧសភៈចេញទៅ ។ សូម្បីនាយគោបាលក៏គិតថា "គោឧសភៈនេះ ក្នុងថ្ងៃមុនៗ ចេញពីក្រោលក្រោយគេបង្អស់, ប៉ុន្តែថ្ងៃនេះ ចេញទៅមុនគោទាំងអស់ ហើយឈរនៅស្ងៀមត្រង់ទ្វារក្រោល តើមានហេតុអ្វីហ្ន៎ ? ទើបដើរទៅ ក្រឡេកមើលឃើញក្មេងដេកនៅខាងក្រោមពោះគោនោះ ត្រឡប់បាននូវសេចក្ដីស្នេហាក្មេងនោះដូចជាបុត្ររបស់ខ្លួន ក៏នាំទៅកាន់ផ្ទះ ដោយគិតថា "យើងបានកូនប្រុសមួយហើយ" ។ នាងកាឡីទៅកាន់ផ្ទះ ហើយត្រូវសេដ្ឋីសួរ ក៏ដំណាលរឿងនោះប្រាប់លោកសេដ្ឋី ដែលលោកសេដ្ឋីពោលថា ម្នាលនាងកាឡី នាងឯងចូរទៅហើយ ចូរឲ្យទ្រព្យ ១ ពាន់កហាបណៈដល់បុរសនោះ ហើយនាំវាត្រឡប់មកវិញ ដូច្នេះហើយនាងកាឡីបានឲ្យទ្រព្យ ១ ពាន់ដល់បុរសនោះ ហើយនាំទារកនោះត្រឡប់មកប្រគល់ឲ្យសេដ្ឋីវិញ ។

## <u>នាងកាឡីនាំឃោសកៈទៅឲ្យរទេះកិន</u>

គ្រានោះ សេដ្ឋីនោះពោលនឹងនាងកាឡីថា “នែ៎ នាងកាឡី ក្នុងក្រុងនេះមានពួកឈ្មួញរទេះ ៥០០ តែងតែក្រោកឡើងអំពីងងឹត ដែលអរុណមិនទាន់រះ ទៅដើម្បីជួញ ។ ដូច្នោះ នាងចូរនាំក្មេងនេះទៅឲ្យដេក ក្នុងផ្លូវរទេះ ( ផ្លូវកង់ ) គោទាំងឡាយនឹងជាន់វា ឬកង់រទេះទាំងឡាយ នឹងកិនខ្ទួនវា ក៏នាងគប្បីដឹងព្រឹត្តិការណ៍នោះហើយ សឹមមក, ។ នាង កាឡីនាំក្មេងនោះទៅហើយ ឲ្យដេកនៅនឹងផ្លូវរទេះ ។ គ្រានោះ ដង្ខៅ រទេះបានទៅខាងមុខគេ ។ លុះទៅដល់ទីនោះ គោទាំងឡាយ ក៏ឈរទ្រឹងមិនទៅមុខទៀត ព្រមទាំងរលាស់នឹមចេញ ។ សូម្បីដង្ខៅ រទេះចាប់ទឹមញយៗដង គោទាំងនោះក៏មិនព្រមដើរទៅមុខ ។ កាល ដង្ខៅនោះព្យាយាមមួយអន្លើដោយគោទាំង ២ នោះយ៉ាងនេះអរុណក៏រះ ឡើង ។ ទើបគាត់គិតថា “គោទាំង ២ នាំគ្នាធ្វើនូវកម្មហ្នឹង តើមាន ហេតុដូចម្ដេច ទើបរមិលមើលនូវផ្លូវ ឃើញទារកក៏គិតថា “កម្មរបស់ យើងធ្ងន់ណាស់ហ្ន៎” ? មានចិត្តត្រេកអរថា “យើងបានកូនប្រុស ហើយ” ទើបនាំក្មេងនោះទៅកាន់ផ្ទះ នាងកាឡីទៅដល់ហើយ សេដ្ឋីសួរ



ក៏ប្រាប់ព្រឹត្តិការណ៍នោះដល់លោកសេដ្ឋី លោកសេដ្ឋីក៏ប្រាប់ថា “នាងចូរយកទ្រព្យ ១ ពាន់ឲ្យដល់ដង្ខៅរទេះនោះ ហើយនាំក្មេងនោះ

ត្រឡប់មកវិញ, ដូច្នេះហើយ នាងកាឡីក៏បានធ្វើតាមពាក្យបញ្ជានោះ ។

## នាងកាឡីនាំឃោសកៈទៅចោលនៅព្រៃស្មសាន

គ្រានោះ សេដ្ឋីពោលនឹងនាងកាឡីនោះថា “ឥឡូវនេះ នាងចូរនាំវាទៅកាន់ព្រៃស្មសាន ហើយឲ្យវាដេកក្នុងចន្លោះនៃគុម្ពឈើ, វាត្រូវសត្វទាំងឡាយមានឆ្កែព្រៃជាដើមទំពាស៊ី ឬក៏ត្រូវអមនុស្សប្រហារឲ្យស្លាប់នៅក្នុងទីនោះ, នាងគប្បីដឹងថា វាស្លាប់ ឬក៏មិនទាន់ស្លាប់ សឹមត្រឡប់មក នាងកាឡីនាំក្មេងនោះទៅឲ្យដេកនៅក្នុងព្រៃស្មសាន ហើយបានឈរនៅក្នុងទីដ៏សមគួរមួយ ។ ឆ្កែក្តី ក្អែកក្តី អមនុស្សក្តី មិនអាចចូលទៅជិតក្មេងនោះបាន ។ មានពាក្យសួរថា “បណ្តាជន ទាំងឡាយមានមាតាបិតាបងប្អូនជាដើម នរណាមួយឈ្មោះថាជាអ្នក រក្សាក្មេងនោះមិនមានមិនមែនឬ ? តើនរណារក្សាក្មេងនោះ” ? ឆ្លើយ ថា បុញ្ញកម្ម គឺការព្រួសដែលទារកនោះឲ្យប្រព្រឹត្តទៅហើយដោយ



សេចក្តីស្នេហាក្នុងព្រះបច្ចេកពុទ្ធ កាលខ្លួននៅជាឆ្កែនោះឯង រមែងរក្សា” ។

គ្រានោះ បុរសអ្នករក្សាពពែម្នាក់ គៀងមេពពែជាច្រើនសែនក្បាលទៅកាន់ទីគោចរឯព្រៃស្មសាន មេពពែមួយទំពាស៊ីនូវវត្ថុទាំង-ឡាយ មានស្លឹកឈើជាដើម ចូលទៅកាន់គុម្ពឈើឃើញទារក ហើយក៏លុតជង្គង់ឲ្យទារកបៅ សូម្បីបុរសអ្នករក្សាពពែធ្វើសំឡេងថា "ហេ ហេ" ក៏មិនចេញ បុរសនោះគិតថា "នឹងយកឈើវាយវាឲ្យចេញ" ទើបចូលទៅកាន់គុម្ពឈើ ឃើញមេពពែលុតជង្គង់ឲ្យទារកបៅដូច្នោះ ក៏កើតសេចក្ដីស្រឡាញ់ក្នុងទារកនោះថា ដូចជាបុត្ររបស់ខ្លួន ទើបនាំយកទារកនោះទៅ ដោយគិតថា "យើងបានកូន ប្រុសមួយហើយ" នាងកាឡីឃើញហេតុនោះហើយក៏ត្រឡប់ទៅ ផ្ទះ ត្រូវសេដ្ឋីសួរហើយក៏ប្រាប់នូវហេតុនោះដល់លោកសេដ្ឋី សេដ្ឋី ពោលថា "នាងចូរទៅយកទ្រព្យមួយពាន់កហាបណៈឲ្យបុរសនោះ ហើយនាំវាត្រឡប់មកវិញ" នាងកាឡីក៏បានធ្វើតាមពាក្យបញ្ជារបស់



លោកសេដ្ឋី ។

## នាងកាឡីយកឃោសកៈទៅបោលក្នុងជ្រោះ

គ្រានោះ សេដ្ឋីពោលនឹងនាងកាឡីនោះថា "នែ៎ មេកាឡី នាងឯងចូរនាំយកទារកនេះទៅ ឡើងកាន់ភ្នំដែលជាទីបោលចោររួចហើយចូរបោះវាទៅក្នុងជ្រោះ វាប៉ះទង្គិចនឹងភ្នំ ក៏ដាច់ជា

កំណាត់តូច និងកំណាត់ធំ ធ្លាក់ចុះលើផែនដី នាងនៅចាំមើលឲ្យដឹងជាក់ថា វាស្លាប់ហើយ ឬក៏មិនទាន់ស្លាប់ សឹមត្រឡប់មក នាងកាឡីនាំយកទារកទៅកាន់ទីនោះហើយ ឈរនៅលើកំពូលភ្នំបោះទារកនោះចូលទៅក្នុងជ្រោះ ។ ក៏គុម្ពឫស្សីមួយគុម្ពធំអាស្រ័យភ្នំនោះឯង ចម្រើនឡើងដោយសារភ្នំនោះឯង ។ គុម្ពវល្លិទំពាំងបាយជូរជាដុំក្រាស់គ្របនៅពីលើគុម្ពឫស្សីធំនោះ ទារកកាលធ្លាក់ ក៏ធ្លាក់ចុះទៅលើគុម្ពវល្លិទំពាំងបាយជូរនោះ ហាក់ដូចជាធ្លាក់ទៅលើផ្ទាំងសំពត់រោមសត្វដូច្នោះ ក្នុងថ្ងៃនោះ មេជាងផែងមានសេចក្តីត្រូវការបន្ទះ ឫស្សី, ក៏ ទៅកាន់ព្រៃភ្នំជាមួយនឹងកូនរបស់គាត់ ប្រារព្ធនឹង កាប់គុម្ពឫស្សីនោះ,



នាកាលគុម្ពឫស្សីកម្រើក ទារកក៏ស្រែកយំឡើង ។ មេជាងនោះ ក៏និយាយថា "ដូចជាឮសំឡេងក្មេងយំ" ក៏ឡើងតាមចំហៀងភ្នំ ឃើញទារកនោះក៏មានចិត្តសប្បាយរីករាយ នាំទៅកាន់ផ្ទះ ដោយគិត ថា "យើងបានកូនប្រុសហើយ" ។ នាងកាឡីទៅកាន់សម្នាក់សេដ្ឋី ត្រូវសេដ្ឋីសួរហើយ ក៏ប្រាប់រឿងនោះដល់សេដ្ឋី សេដ្ឋី ក៏ពោលថា

“នាងចូរយកទ្រព្យមួយពាន់កហាបណៈទៅលោះយកវា មកវិញ” នាងកាឡីក៏បានធ្វើតាមសេដ្ឋី ។

## ឲ្យទុក្ខដល់គេទុក្ខនោះធ្លាក់មកលើខ្លួនវិញ

កាលលោកសេដ្ឋីធ្វើនូវកម្មនេះផង នោះផង ទារកនោះក៏ចំរើនធំឡើង ។ មានឈ្មោះថា “ឃោសកៈ” ។ ឃោសកកុមារនោះប្រាកដដល់សេដ្ឋីហាក់ដូចជាបន្លាចាក់ភ្នែក ។ សេដ្ឋី មិនអាចនឹងសំឡឹងមើលឃោសកកុមារនោះចំៗបាន គ្រានោះ សេដ្ឋីគិតរកឧបាយដើម្បីនឹងសម្លាប់ឃោសកកុមារនោះ ទើបទៅកាន់សំណាក់នាយស្មូនឆ្នាំងដែលជាសម្លាញ់របស់ខ្លួន ហើយសួរ



ថា “កាលណាលោកនឹងដុតឡ” ? កាលនាយស្មូនឆ្នាំងឆ្លើយថា ខ្ញុំដុតក្នុងថ្ងៃស្អែកនេះ” ក៏ពោលថា “បើដូច្នោះ លោកចូរទទួលយកទ្រព្យមួយ ពាន់កាហាបណៈនេះចុះ ហើយចូរធ្វេការងារមួយឲ្យខ្ញុំ ។

នាយស្មូនឆ្នាំងសួរថា “បពិត្រសេដ្ឋី ឲ្យខ្ញុំធ្វើនូវកិច្ចអ្វី ?

សេដ្ឋីប្រាប់ថា ខ្ញុំមានអវជាតបុត្ត ( បុត្រខូចបំផុត ) ម្នាក់ ខ្ញុំនឹងបញ្ជូនវាមកកាន់សំណាក់របស់លោក កាលបើដូច្នោះ លោកចូរឲ្យវាចូលទៅកាន់បន្ទប់ យកកាំបិតឲ្យមុតកាត់ឲ្យជាកំណាត់តូចកំណាត់ធំ ដាក់ក្នុងពាង ហើយដុតក្នុងឡ ទ្រព្យមួយពាន់នេះជារង្វាន់របស់លោក ។ ថ្ងៃក្រោយ ខ្ញុំនឹងធ្វើអំពើដែលគួរធ្វើដល់លោកឲ្យក្រៃលែងជាងនេះទៅទៀត ។

នាយស្ទូនឆ្នាំងឆ្លើយថា បាន ។

ថ្ងៃស្អែកឡើង សេដ្ឋីនោះក៏ហៅឃោសកកុមារមកហើយបញ្ជូនទៅដោយពាក្យថា “នែ កូន កាលពីម្សិល បិតាបង្គាប់ឲ្យស្ទូនឆ្នាំងធ្វើកិច្ចការងារមួយឲ្យបិតា, កូនឯងចូរទៅកាន់សម្នាក់របស់នាយ



ស្ទូនឆ្នាំង ហើយពោលយ៉ាងនេះថា “លោកចូរញ៉ាំងកិច្ចការដែលបិតារបស់ខ្ញុំបង្គាប់ទុកកាលពីថ្ងៃម្សិលឲ្យសម្រេចចុះ” ។ ឃោសកកុមារនោះទទួលថា ( បាទ ) ហើយក៏បានធ្វើដំណើរទៅ ។ ចំណែកកូនប្រុសរបស់លោកសេដ្ឋីកំពុងលេងអង្គញ់ ( គោឡ ) ជាមួយនឹងពួកក្មេងៗ

ដទៃទៀត ឃើញឃោសកកុមារនោះដើរទៅកាន់ទីនោះ ក៏ហៅឃោសកកុមារនោះ ហើយសួរថា "បពិត្របង បងឯងទៅទីណា"? កាលឃោសកកុមារប្រាប់ថា "បងយកពាក្យបណ្តាំរបស់បិតាយើងទៅកាន់សំណាក់ស្មូនឆ្នាំង" ក៏និយាយថា "ខ្ញុំនឹងទៅទីនោះជំនួស, ក្មេងទាំងនេះឈ្នះខ្ញុំច្រើនខ្ទាច់ហើយ បងចូរដណ្តើមនូវជ័យជំនះឲ្យខ្ញុំវិញ ។

ឃោសកកុមារប្រាប់ប្អូនថា បងខ្លាចបិតា ។

កូនសេដ្ឋី. បពិត្របង បងឯងកុំខ្លាច ខ្ញុំនឹងនាំយកបណ្តាំនោះទៅដោយខ្លួនឯង ពួកក្មេងច្រើននាក់បានឈ្នះខ្ញុំហើយ បងចូរដណ្តើមយកជ័យជំនះនោះឲ្យខ្ញុំវិញ ។ បានឮមកថា ឃោសក-



កុមារជាអ្នកឈ្លាសវៃក្នុងការលេងអង្គញ់ ( គោឡ ) ព្រោះហេតុនោះ កូនប្រុសរបស់លោកសេដ្ឋី ក៏បានទទួចអង្វរឃោសកកុមារនោះយ៉ាងនេះ ។

ចំណែកឃោសកៈ ក៏និយាយនឹងកូនប្រុសរបស់សេដ្ឋី នោះថា “បើដូច្នោះ ប្អូនឯងចូរទៅប្រាប់ស្ទូនផ្ទាំងថា “កាលពីថ្ងៃម្សិល បិតារបស់ខ្ញុំបង្គាប់ឲ្យលោកធ្វើកិច្ចការមួយ, លោកចូរធ្វើកិច្ចការនោះ ឲ្យសម្រេចទៅចុះ” ដូច្នេះហើយ ក៏បញ្ជូនកូនប្រុសរបស់សេដ្ឋី ទៅកាន់សំណាក់នាយស្ទូនផ្ទាំង ។

កូនប្រុសរបស់សេដ្ឋីនោះ ទៅកាន់សំណាក់នាយស្ទូន ផ្ទាំងនោះហើយ បានពោលតាមពាក្យបណ្ដាំនោះ ។ គ្រានោះ ស្ទូនផ្ទាំង បានសម្លាប់កូនប្រុសរបស់សេដ្ឋីនោះ ហើយបោះទៅក្នុងឡ ។

ចំណែកឃោសកៈលេងរហូតអស់កាលជាចំណែកនៃថ្ងៃ លុះ ដល់ពេលរសៀលក៏ត្រឡប់ទៅកាន់គេហដ្ឋាន, កាលសេដ្ឋីឃើញ ហើយ ក៏សួរថា “ម្នាលកូនសម្លាញ់ កូនឯងមិនបានទៅទេឬ” ? ក៏



ប្រាប់នូវហេតុដែលខ្លួនមិនទៅ

និងហេតុដែលកូនប្រុសទៅឲ្យសេដ្ឋីជ្រាប ។ សេដ្ឋីបានស្ដាប់ពាក្យ នោះហើយ ក៏ស្រែកនូវ សម្រែកយ៉ាងខ្លាំងថា “កុំសម្លាប់ឡើយ”

ហាក់ដូចជាមានលោហិត ពុះហើយក្នុងសរីរៈទាំងអស់ ផ្គងអញ្ជលីឡើងកន្ទក់កន្ទេញថា "ម្នាល នាយស្នូនផ្ទាំងដ៏ចម្រើន លោកកុំធ្វើឲ្យយើងវិនាសឡើយ កុំឲ្យយើង វិនាសឡើយ" ដូច្នេះ ក៏បានទៅកាន់សំណាក់នាយស្នូនផ្ទាំងនោះ ។

នាយស្នូនផ្ទាំង ឃើញសេដ្ឋីនោះ មកដោយអាការ យ៉ាងនោះ ក៏និយាយថា "បពិត្រសេដ្ឋី លោកកុំធ្វើសំឡេងឮ ខ្លាំងពេក, ការងាររបស់លោកសម្រេចហើយ" ។ សេដ្ឋីនោះ ត្រូវសេចក្ដីសោកដ៏ធំដូចជាភ្នំគ្របសង្កត់ហើយ បានសោយនូវទោមនស្សមានប្រមាណយ៉ាងក្រៃលែង ដូចបុគ្គលអ្នកមានចិត្តប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្តតបដូច្នោះ ។

អ្នកប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្តតប រមែងដល់ឋានៈ ១០ យ៉ាង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖



បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ

ដែលមិនមានអាជ្ញា មិនប្រទូស្តតប បុគ្គលនោះរមែងដល់

នូវហេតុនៃសេចក្ដីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង យ៉ាង

ទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្ដីវិនាស

ទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡុកចិត្ត ( ឆ្កួត ) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសំបត្តិ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។

## ឧបាយថ្មីរបស់លោកសេដ្ឋី

សូម្បីមានសភាពយ៉ាងនោះហើយក៏ដោយ សេដ្ឋីក៏មិនអាចសម្លឹងមើលឃោសកៈនោះដោយត្រង់ៗទៀតបាន គិតរកឧបាយថា “ធ្វើយ៉ាងណាហ្ន៎ ទើបសម្លាប់វាបាន” ? សម្លឹងឃើញឧបាយថា



“យើងនឹងបញ្ជូនវាទៅកាន់សំណាក់អ្នកយកសួយ ( នាយស្មៀន ) នៅក្នុងស្រុកសួយ ១០០ របស់យើង ឲ្យវាស្លាប់នៅក្នុងទីនោះ” ដូច្នេះហើយ ទើបសរសេរលិខិតផ្ញើទៅនាយស្មៀននោះថា “បុគ្គលនេះជាកូនថោកទាបរបស់យើង, សម្លាប់វាហើយ ចូរបោះវាទៅក្នុងរណ្តៅ

ចុះ ។ កាលធ្វើយ៉ាងនេះស្រេចហើយ ខ្ញុំនឹងដឹងវត្ថុដែលគួរធ្វើដល់លោកក្នុងកាលជាខាងក្រោយ” ដូច្នេះហើយ ក៏ពោលថា “នែ៎ កូនសម្លាញ់ នាយស្មៀនរបស់បិតាមាននៅឯស្រុកសួយមួយរយ, កូនឯងចូរនាំយកលិខិតមួយច្បាប់នេះទៅឲ្យគេ” ដូច្នេះហើយ ក៏យកសំបុត្រចងទុកនឹងជាយសំពត់របស់នាយឃោសកៈ ។

ក៏ឃោសកកុមារនោះ មិនចេះអក្សរសម័យ,ព្រោះតាំងពីកុមារនោះនៅក្មេង សេដ្ឋីគិតតែពីរកឧបាយសម្លាប់ចោលជានិច្ច ( ប៉ុន្តែ ) មិនអាច សម្លាប់បាន កុមារនោះនឹងសិក្សាអក្សរសាស្ត្របានដូចម្តេច ? នាយ ឃោសកៈនោះចងសំបុត្រសម្លាប់ខ្លួនឯងទុកនឹងជាយសំពត់ដោយ ប្រការដូច្នេះ មុននឹងចេញដំណើរទៅក៏និយាយជាមួយនឹងសេដ្ឋីថា



“បពិត្របិតា ខ្ញុំមិនមានស្បៀងសម្រាប់ធ្វើដំណើរទេ” ។

សេដ្ឋី. កូនឯងមិនចាំបាច់យកស្បៀងសម្រាប់ធ្វើដំណើរទៅជាមួយទេ នៅស្រុកឯណោះ ក្នុងចន្លោះផ្លូវ សេដ្ឋីដែលជាសម្លាញ់

របស់បិតាមានម្នាក់, កូនឯងចូលទៅបរិភោគអាហារពេលព្រឹកឯផ្ទះរបស់សេដ្ឋីនោះហើយ សឹមបន្តដំណើរទៅមុខទៀតចុះ ។

នាយឃោសកៈនោះទទួលយល់ព្រមថា "ប្រពៃហើយ" សំពះលាបិតាហើយ ចេញដំណើរទៅកាន់ស្រុកនោះ លុះទៅដល់ស្រុកនោះ ក៏សួររកផ្ទះសេដ្ឋី ដើរទៅជួបភរិយារបស់សេដ្ឋី ។ កាលភរិយារបសសេដ្ឋី សួរថា "ឯងមកអំពីទីណា" ? ក៏ឆ្លើយថា "មកអំពីក្រុង" ។

ភរិយារបស់លោកសេដ្ឋី. ឯងជាកូនរបស់នរណា ?

ឃោសកៈ. បពិត្រអ្នកស្រី ខ្ញុំជាកូនរបស់លោកសេដ្ឋីដែលជាសម្លាញ់របស់អ្នកស្រី ។

ភរិយារបស់លោកសេដ្ឋី. ឯងឈ្មោះឃោសកៈឬ ?

ឃោសកៈ. ពិតមែនហើយ អ្នកស្រី ។



គ្រាន់តែឃើញឃោសកៈភ្លាម សេចក្តីស្រឡាញ់ដូចជាបុត្តក៏កើតឡើងដល់ភរិយារបសសេដ្ឋីនោះភ្លាមដែរ ។

## <u>សេចក្តីស្រឡាញ់កើតឡើងដោយហេតុ ២ យ៉ាង</u>

ក៏សេដ្ឋីនេះមានកូនស្រីម្នាក់, មានអាយុប្រហែល ១៥-១៦ ឆ្នាំ មានរូបរាងស្រស់ស្អាត គួរជាទីជ្រះថ្លាជាទីស្រឡាញ់ ។ សេដ្ឋីប្រគល់ទាសី ម្នាក់ ទុកដើម្បីបម្រើនាង ហើយឲ្យនៅក្នុងបន្ទប់ដ៏មានសិរី ( បន្ទប់ពិសេស ) ជាន់លើនៃប្រាសាទ ៧ ជាន់ គ្រានោះ កូនស្រីរបស់ សេដ្ឋីនោះប្រើទាសីឲ្យទៅផ្សារ ។ គ្រានោះ ករិយារបស់សេដ្ឋីឃើញនាង ទាសីនោះហើយ ក៏សួរថា "នាងទៅណា" ? កាលនាងទាសីឆ្លើយថា "បពិត្រអ្នកស្រី នាងខ្ញុំធ្វើកិច្ចបម្រើកូនស្រីរបស់អ្នកស្រី" ក៏ពោលថា "នាងចូលមកណេះសិន បន្ទន់នូវកិច្ចបម្រើនោះសិន ។ ចូរក្រាលតាំង លាងជើង លាបប្រេងឲ្យបុត្តរបស់យើង ហើយសឹមធ្វើការបម្រើជាខាងក្រោយ" ។ នាងបានធ្វើកិច្ចការតាមពាក្យបញ្ជារបស់ករិយាលោកសេដ្ឋី ។ គ្រានោះ កូនស្រីរបស់សេដ្ឋី បានគម្រាមនាងទាសីថា ហេតុ

ដូចម្ដេចបានជានាងយឺតម៉្លេះ ។ ខណៈនោះ នាងទាសីនោះប្រាប់នាងថា "បពិត្រនាងម្ចាស់ កុំខឹងខ្ញុំម្ចាស់អី ។ បុត្តសេដ្ឋីឈ្មោះឃោសកៈមក ហើយ, នាងខ្ញុំធ្វើនូវកម្មនេះៗ ដល់បុត្តសេដ្ឋីនោះហើយ ទើបទៅផ្សារ គ្រាន់តែឮឈ្មោះថា "ឃោសកៈ" ដែលជាបុត្តរបស់សេដ្ឋីនោះភ្លាម សេចក្ដីស្រឡាញ់កាត់នូវសរីរាវយវៈទាំងឡាយមានសម្បុរស្បែកជាដើមចូលដល់ខួរក្នុងឆ្អឹង ហើយតាំងនៅ កើតឡើងដល់កូនស្រីសេដ្ឋី ។

## កូនស្រីសេដ្ឋីក្លែងសារ

ពិតណាស់ កូនស្រីសេដ្ឋីនោះ ជាភរិយារបស់នាយឃោសកៈនោះ ក្នុងកាលដែលនាយឃោសកៈនោះជានាយកោតុហលិកៈ បានថ្វាយបាយមួយនាឡិអង្ករដល់ព្រះបច្ចេកពុទ្ធ ដោយអានុភាពនៃការថ្វាយបាយមួយនាឡិអង្ករនោះ ទើបនាងបានមកកើតក្នុងត្រកូលសេដ្ឋីនេះ ។ សេចក្ដីស្រឡាញ់ក្នុងកាលមុន បានគ្របសង្កត់ចិត្តកូនស្រីសេដ្ឋីនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមាន

ព្រះភាគទ្រង់ត្រាស់ថា ៖

“សេចក្ដីស្រឡាញ់នោះកើតឡើងដោយហេតុ ២ ប្រការ គឺ ដោយការនៅរួមគ្នាក្នុងកាលមុន ១ ដោយការប្រព្រឹត្តិនូវអំពើ ដែលជាប្រយោជន៍ដល់គ្នានិងគ្នាក្នុងបច្ចុប្បន្ន ១ ដូចផ្កាឧប្បល ( អាស្រ័យភក់ និងទឹក ) កើតក្នុងទឹកដូច្នេះ ។

គ្រានោះ សេដ្ឋីធីតាសួរនាងទាសីនោះថា “ឥឡូវនេះ” គេនៅឯណា ?

ទាសី. បពិត្រនាងម្ចាស់ គេដេកនៅលើទីដេក ។

សេដ្ឋីធីតា. ក៏ក្នុងដៃរបស់គេមានវត្ថុអ្វីដែរឬ ?

ទាសី. បពិត្រនាងម្ចាស់ មានសំបុត្រមួយច្បាប់នៅក្នុងជាយសំពត់ ។ ឃោសកៈនោះកំពុងដេកលក់, កាលមាតាបិតាមើលមិនឃើញ ព្រោះរវល់តែបញ្ជូនចិត្តទៅកាន់រឿងដទៃ, ក៏ចុះទៅកាន់សំណាក់ ( របស់ឃោសកៈ ) ហើយស្រាយសំបុត្រនោះ ចូលទៅកាន់បន្ទប់

របស់ខ្លួន បិទទ្វារ បើកបន្ទួចអានសំបុត្រ ព្រោះនាងជាស្ត្រីឈ្លាសក្នុងអក្សរសាស្ត្រ ហើយគិតថា "ស្លាប់ហើយ មនុស្សល្ងង់នេះចងសំបុត្រ ដែលជាគ្រឿងញ៉ាំងខ្លួនឲ្យស្លាប់ទុកក្នុងជាយសំពត់ហើយមិនដឹងទៀត ។ ប្រសិនបើយើងមិនបានឃើញសំបុត្រនេះទេជីវិតរបស់ គេនឹងត្រូវអស់ជាពិតប្រាកដ ។ ដូច្នេះហើយក៏ហែកសំបុត្រនោះ ចោល សរសេរសំបុត្រមួយច្បាប់ផ្សេងទៀតតាមពាក្យរបស់សេដ្ឋី ថា "កូនប្រុសរបស់ខ្ញុំនេះឈ្មោះថាឃោសកៈ, អ្នកទាំងឡាយចូរញ៉ាំង បុគ្គលឲ្យនាំនូវបណ្ណាការអំពីស្រុកសួយ ១០០ ធ្វើនូវមង្គលជាមួយ កូនស្រីសេដ្ឋីក្នុងជនបទនេះ ឲ្យសង់ផ្ទះពីជាន់នៅត្រង់កណ្តាល ស្រុកសម្រាប់ជាលំនៅរបស់ពួកគេ ធ្វើការរក្សាដោយល្អដោយការ បិទបាំង គឺកំពែង និងដោយគ្រឿងបិទបាំងគឺបុរស, ហើយចូរបញ្ជូន ដំណឹងទៅប្រាប់ខ្ញុំថា ការនេះផងការនេះផង ខ្ញុំធ្វើស្រេចហើយ" ។ កាលកម្មយ៉ាងនេះលោកធ្វើហើយ

ខ្ញុំនឹងដឹងនូវអំពើដែលគួរធ្វើតបស្នងសងគុណលោកក្នុងកាលជាខាងក្រោយ, លុះសរសេររួចហើយ ក៏បត់ចង



ទុកនឹងជាយសំពត់របស់ឃោសកៈដូចដើម ។

## នាយឃោសកៈបានភរិយា

នាយឃោសកៈនោះ ដេកលក់រហូតអស់មួយថ្ងៃ ក្រោកឡើងបរិភោគហើយចៀសចេញទៅ ក្នុងថ្ងៃស្អែកឡើង គេបានទៅកាន់ស្រុកនោះតាំងអំពីព្រលឹម ។ ឃើញនាយស្មៀនកំពុងធ្វើការងារក្នុងស្រុក ។ នាយស្មៀននោះឃើញនាយឃោសកៈនោះហើយក៏សួរថា "ម្នាលបា អ្នកឯងមកមានកិច្ចការអ្វី" ? នាយឃោសកៈឆ្លើយថា "បិតារបស់ខ្ញុំប្រើឲ្យនាំយកសំបុត្រមកជូនលោក" នាយស្មៀនសួរថា "ម្នាលអ្នកដ៏ចម្រើន តើមានកិច្ចការអ្វី ? ចូរប្រាប់មក" ទទួលយកសំបុត្រមកអានហើយក៏មានចិត្តត្រេកអរ ពោលនឹងគហបតីទាំងឡាយថា "ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរមើលនូវសេចក្ដីស្រឡាញ់ក្នុងយើងរបស់នាយយើង, សេដ្ឋីបញ្ជូន

សំបុត្រមកកាន់សំណាក់យើង ដោយប្រាប់ថា "ចូរធ្វើមង្គលដល់បុត្រច្បងរបស់យើង, ពួកលោកចូរប្រញាប់នាំយកឈើជាដើមមក"

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៥៣ -

ដូច្នេះហើយ ឲ្យគេសង់ផ្ទះមានប្រការដូចពោលហើយ ក្នុងកណ្តាលស្រុក ឲ្យនាំគ្រឿងបណ្ណាការមកអំពីស្រុកសួយ ១០០ នាំកូនស្រីសេដ្ឋីក្នុងជនបទមកធ្វើមង្គលស្រេចហើយ ក៏បញ្ជូនដំណឹងទៅប្រាប់លោកសេដ្ឋីថា "ការនេះ និងការនេះ ខ្ញុំបាទធ្វើរួចស្រេចហើយ" ។

## សេដ្ឋីខូចចិត្តរហូតកើតរោគ

ព្រោះបានឮដំណឹងនោះ ការខូចចិត្តយ៉ាងធំបានកើតឡើងដល់សេដ្ឋីថា "យើងឲ្យធ្វើនូវវត្ថុណា វត្ថុនោះមិនសម្រេច វត្ថុណាដែលយើងមិនឲ្យធ្វើ ក៏ត្រឡប់ជាសម្រេចទៅវិញ" ។ សេចក្តីសោកសៅនោះ និងសេចក្តីសោកសៅចំពោះបុត្រដែលស្លាប់ទៅនោះដូចគ្នា ញុំាងកម្តៅក្នុងពោះឲ្យកើតឡើង ឲ្យកើតរោគក្អួតឈាម ។ ចំណែកកូនស្រីរបស់សេដ្ឋីផ្តាំពួកមនុស្សថា "ប្រសិនបើមាននរណាមកអំពី សំណាក់របស់សេដ្ឋី, មិនទាន់ប្រាប់យើងទេ

កុំប្រាប់សេដ្ឋីបុត្រ មុន ។ ចំណែកសេដ្ឋីគិតថា ឥឡូវនេះ យើងនឹងមិនធ្វើកូន ថោកទាបនោះឲ្យជាម្ចាស់នៃទ្រព្យរបស់យើងទេ” ដូច្នេះហើយ ក៏



ប្រាប់នាយស្មៀនម្នាក់ថា “នែ នាយស្មៀន ខ្ញុំប្រាថ្នាចង់ជួបបុត្ររបស់ខ្ញុំ អ្នកចូរបញ្ជូនបម្រើម្នាក់ឲ្យទៅហៅបុត្ររបស់ខ្ញុំមក” នាយស្មៀននោះទទួលថា “បាទនាយ” ឲ្យសំបុត្រហើយបញ្ជូនបម្រើម្នាក់ទៅ ។ ចំណែក កូនស្រីរបស់សេដ្ឋីដឹងថាបុរសនោះមកឈរនៅទៀបទ្វារ ក៏ឲ្យគេទៅហៅបុរស នោះមកហើយសួរថា “ម្នាលអ្នកដ៏ចម្រើន អ្នកមកមានការអ្វី” ?

អ្នកបម្រើ. បពិត្រនាងម្ចាស់ លោកសេដ្ឋីឈឺ ប្រើខ្ញុំឲ្យមកហៅបុត្ររបស់គាត់ ។

សេដ្ឋីធីតា. ម្នាលអ្នកដ៏ចម្រើន តើសេដ្ឋីនៅមានកម្លាំង ឬខ្សោយកម្លាំង ?

អ្នកបម្រើ. បពិត្រនាងម្ចាស់ នៅមានកម្លាំង នៅបរិភោគអាហារបាននៅឡើយ ។

កូនស្រីសេដ្ឋីនោះ មិនឲ្យបុត្តរបស់សេដ្ឋីនោះដឹងទេ បញ្ជាឲ្យៗនូវទីស្នាក់ និងស្បៀងដល់អ្នកបម្រើនោះហើយ ពោលថា “អ្នកនឹងទៅបានក្នុងកាលដែលខ្ញុំអនុញ្ញាតឲ្យទៅ ចូរស្នាក់នៅទីនេះ



សិនហើយ” ។

មហាសេដ្ឋី. បានពោលនឹងនាយស្មៀនទៀតថា “នែ នាយស្មៀន អ្នកមិនទាន់បានផ្ញើសំបុត្រទៅកាន់សំណាក់បុត្ររបស់ខ្ញុំទេ ឬ ? នាយស្មៀនឆ្លើយថា បពិត្រនាយខ្ញុំបញ្ជូនទៅហើយ ប៉ុន្តែអ្នកទៅនោះមិនទាន់ ត្រឡប់មកវិញ ។

មហាសេដ្ឋី. បើដូច្នោះ អ្នកចូរបញ្ជូនអ្នកដទៃទៅទៀតចុះ ។

នាយស្មៀននោះក៏បញ្ជូនមនុស្សទៅទៀត ។

កូនស្រីរបស់សេដ្ឋី បដិបត្តិចំពោះបុរសនោះដូចបុរសដែលមក មុននោះដែរ, ក្នុងកាលនោះ រោគរបស់សេដ្ឋីកាន់តែធ្ងន់ឡើង ។ កាជនះមួយចូល, កាជនះមួយចេញ ។ សេដ្ឋីក៏សួរនាយស្មៀនទៀត

ថា "នែ នាយស្មៀន អ្នកមិនទាន់បញ្ជូនមនុស្សឲ្យទៅហៅបុត្ររបស់យើងទេឬ ?

នាយស្មៀនប្រាប់ថា បពិត្រនាយ បញ្ជូនទៅហើយ ប៉ុន្តែអ្នកដែលទៅនោះមិនទាន់ត្រឡប់មក ។



សេដ្ឋីប្រាប់ថា បើដូច្នេះ អ្នកចូរបញ្ជូនអ្នកដទៃទៅទៀតចុះ។ នាយស្មៀននោះក៏បញ្ជូនមនុស្សទៅទៀត ។ កូនស្រីសេដ្ឋីសួរព្រឹត្តិ-ការណ៍នោះនឹងបុរសដែលមកក្នុងវារៈទី ៣ ទៀត ។ បុរសនោះប្រាប់ថា "បពិត្រនាងជាម្ចាស់ សេដ្ឋីឈឺធ្ងន់ណាស់ កាត់ផ្តាច់អាហារហើយជាអ្នកមានសេចក្តីស្លាប់ជាទីទៅខាងមុខ, ភាជនៈ ១ ចេញ, ភាជនៈ ១ ចូល" កូនស្រីរបស់សេដ្ឋីគិតថា "ឥឡូវនេះជាកាលដែលនាយឃោសកៈគួរទៅបានហើយ" ទើបប្រាប់នាយឃោសកៈថា "បពិត្រនាយបានឮថា បិតារបស់លោកឈឺធ្ងន់" ។ កាលឃោសកៈសួរថា "ម្នាល នាងដ៏ចម្រើន នាងនិយាយថាអ្វី" ? ក៏និយាយថា "បពិត្រនាយ ការមិនសប្បាយកើតមានដល់បិតារបស់លោក" ។

ឃោសកៈ. ឥឡូវនេះ ខ្ញុំគួរធ្វើយ៉ាងណា ?

សេដ្ឋីធីតា. បពិត្រនាយ យើងនឹងកាន់យកគ្រឿងបណ្ណាការដែលកើតអំពីស្រុកសួយមួយរយស្រុកទៅសួរសុខទុក្ខគាត់ នាយឃោសកៈយល់ព្រមថា “ប្រពៃហើយនាង” ហើយបញ្ជាឲ្យមនុស្ស



នាំយករទេះផ្ទុកគ្រឿងបណ្ណាការពេញរទេះហើយ ចេញដំណើរទៅ ។

គ្រានោះ កូនស្រីរបស់សេដ្ឋី និយាយនឹងឃោសកៈនោះថា “បិតារបស់លោកមានកម្លាំងខ្សោយហើយ, កាលយើងកាន់យកគ្រឿងបណ្ណាការមានប្រមាណប៉ុណ្ណោះទៅនឹងជាការយឺតយូរ, សូមលោកបញ្ជាឲ្យគេនាំយកគ្រឿងបណ្ណាការនេះត្រឡប់ទៅវិញចុះ”ដូច្នេះហើយ ក៏បញ្ជូនគ្រឿងបណ្ណាការនោះទាំងអស់ទៅកាន់ផ្ទះរបស់ខ្លួនវិញ ហើយនិយាយទៀតថា “បពិត្រនាយ លោកគប្បីឈរនៅខាងជើងបិតារបស់លោក, ខ្ញុំនឹងឈរនៅខាងសិរសា” កាលចូលទៅដល់ផ្ទះនោះហើយ នាងក៏បង្គាប់មនុស្សរបស់ខ្លួនថា ពួកលោកចូររក្សាទាំងខាងមុខផ្ទះ ទាំងខាងក្រោយផ្ទះ ។ ក៏កាលដើរចូល ទៅ

សេដ្ឋីបុត្តបានឈរនៅខាងជើងរបស់បិតា ។ ចំណែកកិរិយាបានឈរនៅខាងលើសិរសា ។

## <u>សេដ្ឋីធ្វើកាលកិរិយា</u>

គ្រានោះសេដ្ឋីដេកផ្ងារនៅលើគ្រែ ។ ចំណែកនាយស្មៀន



កាលប្រាប់ជើងរបស់សេដ្ឋីនោះ ក៏និយាយថា “បពិត្រនាយ បុត្ររបស់លោកមកហើយ” ។

សេដ្ឋីសួរថា កូនប្រុសរបស់ខ្ញុំគេនៅឯណា ? នាយស្មៀនប្រាប់ថា គេឈរនៅខាងចុងជើង ។

គ្រានោះ សេដ្ឋីឃើញកូនប្រុសនោះហើយ ក៏ឲ្យហៅនាយស្មៀនមកហើយសួរថា “ក្នុងផ្ទះរបស់ខ្ញុំមានទ្រព្យប៉ុន្មាន ? កាលនាយស្មៀនប្រាប់ថា “បពិត្រនាយ មាន ៤០ កោដិ ប៉ុណ្ណោះ, ប៉ុន្តែគ្រឿងឧបភោគបរិភោគ និងស្រែ ចំការ សត្វជើង ២ សត្វជើង ៤ យានវាហនៈមានចំនួនប៉ុណ្ណេះៗ” ចង់និយាយថា “ខ្ញុំមិនឲ្យទ្រព្យដែលមានប្រមាណប៉ុណ្ណេះដល់ឃោសកៈកូនរបស់ខ្ញុំទេ” ។ ( ត្រឡប់ ) ជា

និយាយថា “ខ្ញុំឲ្យ” កូនស្រីសេដ្ឋីបានឮពាក្យនោះហើយគិតថា “សេដ្ឋីនេះកាលពោលពាក្យម្តងទៀតគប្បីពោលនូវពាក្យអ្វីមួយដទៃ” ដូច្នេះហើយ ធ្វើអាការដូចជារពលរពលដោយសេចក្តីសោក រំសាយសក់ស្រែកយំ ពោលថា “បពិត្របិតា តើបិតាពោលពាក្យដូចម្តេច ពួក



យើងជាអ្នកមិនមានបុណ្យពិតមែន” ដូច្នេះហើយ យកក្បាលប្រហារសេដ្ឋីនោះត្រង់ដើមទ្រូង ផ្តួលចុះយកក្បាលត្រដុះត្រង់ដើមទ្រូងរបស់សេដ្ឋីនោះហើយ សម្តែងអាការទួញយំ រហូតទាល់តែសេដ្ឋីនិយាយមិនបានទៀត ចំណែកសេដ្ឋីក៏បានធ្វើកាលកិរិយាក្នុងខណៈនោះឯង ។

## ព្រះបាទឧទេនប្រទានតំណែងដល់នាយឃោសកៈ

ជនទាំងឡាយបានដឹងថា “សេដ្ឋីអនិច្ចកម្មហើយ” ទើបទៅក្រាបទូលព្រះបាទឧទេន ។ ព្រះបាទឧទេន ទ្រង់បញ្ជាឲ្យធ្វើឈាបនកិច្ចសរីរៈរបស់សេដ្ឋីនោះហើយ ត្រាស់សួរថា “ក៏បុត្រ ឬធីតារបស់សេដ្ឋីនោះមានដែរឬ” ?

ជនទាំងឡាយក្រាបទូលថា “បពិត្រព្រះសម្មតិទេព មានកូនប្រុសរបស់សេដ្ឋីនោះឈ្មោះ ឃោសកៈ, បពិត្រព្រះសម្មតិទេព សេដ្ឋីនោះ ប្រគល់ទ្រព្យទាំងអស់ឲ្យដល់ឃោសកៈនោះជាស្រេចហើយ ទើបអនិច្ចកម្ម ព្រះរាជាទ្រង់បញ្ជាឲ្យហៅសេដ្ឋីបុត្តមក, គាប់ជួនថ្ងៃនោះ ភ្លៀងក៏បានបង្អុរចុះមកនៅនាទីលានព្រះរាជវាំង មាន



ទឹកដក់ក្នុងទីនោះ ។ សេដ្ឋីបុត្តទៅកាន់ព្រះរាជវាំងដោយបំណងថា “ទឹងគាល់ ព្រះរាជា” ។ ព្រះរាជាទ្រង់បើកបង្អួចទតមើលនាយឃោសកៈ ដែលកំពុងដើរមក ទ្រង់ឃើញឃោសកៈលោតផ្លោះទឹកនាទីលានព្រះ-រាជវាំងដើរមក ទើបត្រាស់សួរឃោសកៈដែលមកថ្វាយបង្គំ ហើយ ឈរក្នុងទីដ៏សមគួរមួយថា “ម្នាលអ្នកដ៏ចម្រើន អ្នកឯងឈ្មោះ ឃោសកៈឬ ? កាលឃោសកៈទូលថា “ព្រះករុណាថ្ងៃវិសេស” ទ្រង់ លួងលោមថា “ម្នាលអ្នកដ៏ចម្រើន អ្នកឯងកុំខូចចិត្តថា “បិតារបស់ យើងអនិច្ចកម្មហើយ, យើងនឹងប្រគល់តំណែងសេដ្ឋី ដែលជារបស់ បិតាឯងឲ្យដល់ឯង”

ដូច្នេះហើយ ទ្រង់បញ្ជូននាយឃោសកៈទៅថា “ម្នាលអ្នកដ៏ចម្រើន អ្នកឯងទៅចុះ” ព្រះរាជាក៏បានឈរទត មើលនាយឃោសកៈ ដែលធ្វើដំណើរចេញទៅនោះ។ នាយឃោសកៈ មិនលោតក្នុងទីដែលខ្ជិនលោតក្នុងពេលដែលមក បានដើរចុះទៅ សន្សឹមៗ ។

គ្រានោះ ព្រះរាជាត្រាស់បញ្ជាឲ្យហៅនាយឃោសកៈនោះមក



វិញ ហើយទ្រង់ត្រាស់សួរថា “ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុដូចម្តេច កាលអ្នកមកកាន់សំណាក់របស់យើងផ្លោះមកហើយ កាលចេញទៅវិញ ចុះទៅសន្សឹមៗហើយដើរទៅ” ។ នាយឃោសកៈទូលថា “ព្រះករុណាថ្លៃវិសេស កាលនោះខ្ញុំព្រះអង្គនៅជាកុមារ កាលនោះ ឈ្មោះថា ជាកាលលេង ក្នុងឥឡូវនេះ ខ្ញុំព្រះអង្គបានទទួលដំណឹងអំពីព្រះអង្គហើយ ។ ព្រោះហេតុនោះ ការដែលខ្ញុំព្រះអង្គមិនត្រាច់ទៅដូចក្នុងកាលមុន ហើយដើរទៅសន្សឹម ៗ ទើបគួរក្នុងកាលឥឡូវនេះ” ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ទ្រង់ត្រិះរិះថា “បុរសនេះមានបញ្ញា, យើងនឹងប្រគល់តំណែងសេដ្ឋីដល់គេក្នុងកាល

ឥឡូវនេះចុះ” ដូច្នេះហើយ ក៏ប្រទានភោគៈដែលបិតាបរិភោគហើយ បានប្រទានតំណែងសេដ្ឋីអន្ទើដោយវត្ថុទាំងពួង ១០០ មុខ ។

## នាយឃោសកៈទទួលតំណែងសេដ្ឋី

នាយឃោសកៈនោះឈរនៅលើរថ ប្រទក្សិណព្រះ



នគរ ។ ទីដែលនាយឃោសកៈនោះក្រឡេកមើលហើយៗ រមែងកំរើក ញាប់ញ័រ ។ ចំណែកកូនស្រីសេដ្ឋីក៏អង្គុយប្រឹក្សានឹងនាងទាសីថា “ម្នាល នាងកាឡីដ៏ចម្រើន សម្បត្តិមានប្រមាណប៉ុណ្ណេះ សម្រេចហើយដល់ បុត្តរបស់នាង ក៏ព្រោះអាស្រ័យយើង ។

នាងកាឡី. បពិត្រនាងដ៏ចម្រើន ព្រោះហេតុអ្វី ?

សេដ្ឋីធីតា. ត្បិតថា ឃោសកៈនេះចងសំបុត្រជាគ្រឿងញុំាងខ្លួនឲ្យស្លាប់ក្នុងជាយសំពត់ ហើយមកកាន់ផ្ទះរបស់យើង, គ្រានោះខ្ញុំហែកសំបុត្ររបស់គេនោះហើយ សរសេរសំបុត្រមួយច្បាប់ដទៃផ្សេងដើម្បីឲ្យរៀបមង្គលគាត់ជាមួយនឹងខ្ញុំ ធ្វើការរក្សាគាត់អស់កាលប្រមាណប៉ុណ្ណេះ ។

នាងកាឡី. បពិត្រនាងម្ចាស់ នាងដឹងហេតុត្រឹមតែប៉ុណ្ណោះ, ប៉ុន្តែសេដ្ឋីប្រាថ្នានឹងសម្លាប់ឃោសកៈនេះ តាំងអំពីកាលគាត់នៅក្មេងមកម្ល៉េះ ក៏មិនអាចនឹងសម្លាប់បាន, អាស្រ័យនាយឃោសកៈនេះតែម្យ៉ាង អស់ទ្រព្យទៅយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៦៣ -

សេដ្ឋីធីតា. បពិត្រអ្នកម៉ែ សេដ្ឋីបានធ្វើកម្មធ្ងន់ណាស់ហ្ន៎ ! សេដ្ឋីធីតានោះឃើញនាយឃោសកៈ ដែលប្រទក្សិណព្រះនគរហើយចូលទៅកាន់ផ្ទះ ក៏សើចដោយគិតថា "សម្បត្តិមានប្រមាណប៉ុណ្ណោះៗ សម្រេចហើយក៏ព្រោះអាស្រ័យយើង ។

គ្រានោះ សេដ្ឋីបុត្តឃើញអាការដូច្នោះហើយ ក៏សួរថា "នាងសើចអ្វី" ?

សេដ្ឋីធីតា. ព្រោះអាស្រ័យហេតុម្យ៉ាង ។

សេដ្ឋីបុត្ត. ចូរប្រាប់ហេតុនោះមក ។

សេដ្ឋីធីតា. មិនប្រាប់ ។

សេដ្ឋីបុត្តនោះ គម្រាមថា “ប្រសិនបើនាងមិនប្រាប់ ខ្ញុំនឹងកាត់នាង ជា ២ កំណាត់” ។ ដូច្នេះហើយ ក៏ទាញដាវចេញមក ។

សេដ្ឋីធីតានោះក៏ប្រាប់ថា “ខ្ញុំសើចព្រោះខ្ញុំគិតឃើញថា សម្បត្តិមានប្រមាណប៉ុណ្ណេះនេះ លោកបានហើយ ក៏ព្រោះអាស្រ័យខ្ញុំ ។

សេដ្ឋី. ប្រសិនបើបិតារបស់ខ្ញុំ មិនប្រគល់មត៌ិករបស់ខ្លួនឲ្យ



ដល់ខ្ញុំទេ នាងនឹងបានជាអ្វីក្នុងទ្រព្យនោះ ។ បានឮមកថា ឃោសក-សេដ្ឋីមិនដឹងអ្វីអស់កាលប្រមាណប៉ុណ្ណេះ ។ ព្រោះហេតុនោះ ទើបមិនជឿពាក្យរបស់សេដ្ឋីធីតានោះ ។ គ្រានោះ សេដ្ឋីធីតាក៏បានដំណាលរឿងនោះទាំងអស់ប្រាប់សេដ្ឋីបុត្រនោះថា “បិតារបស់លោកឲ្យសំបុត្រ សម្លាប់ ( ខ្លួន ) បញ្ជូនលោកមកហើយ ។ នាងខ្ញុំធ្វើកម្មយ៉ាងនេះ ៗ ការពារលោកទុកហើយ” ។ សេដ្ឋីបុត្រមិនជឿហើយនិយាយថា “នាង និយាយមិនពិត” ទើបគិតថា “យើងនឹងសួរនាងកាឡី” ដូច្នេះហើយ ក៏ពោលថា “បពិត្រម៉ែកាឡីយ៉ាងនោះពិតមែនឬ ? នាងកាឡីក៏ ពោលថា

“បពិត្រនាយ ចាប់ដើមអំពីកាលដែលលោកនៅក្មេង សេដ្ឋីប្រាថ្នានឹងសម្លាប់លោក តែមិនអាចសម្លាប់បាន អាស្រ័យលោកតែម្នាក់គត់សេដ្ឋីត្រូវអស់ទ្រព្យយ៉ាងសន្ធឹកសន្ធាប់, លោករួចផុតហើយអំពីសេចក្ដីស្លាប់ក្នុងទី ៧ កន្លែង, ឥឡូវនេះ វិលត្រឡប់មកអំពីស្រុកសួយ ហើយបានទទួលតំណែងជាសេដ្ឋីអន្ទើដោយវត្ថុទាំងពួង ក្នុងមួយមុខមួយរយ” ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៦៥ -

យោសកសេដ្ឋីស្ដាប់ពាក្យនោះហើយ គិតថា “យើងធ្វើកម្មធ្ងន់ណាស់ហ្ន៎ យើងរួចផុតអំពីសេចក្ដីស្លាប់បែបនេះ ហើយនៅដោយសេចក្ដីប្រមាទ មិនសមគួរសោះឡើយ, យើងនឹងជាអ្នកមិនប្រមាទហើយរស់នៅ” ដូច្នេះហើយ លះបង់ទ្រព្យសម្បត្តិក្នុងមួយថ្ងៃមួយពាន់កហាបណៈ ធ្វើទាន ។

កុដុម្ពិកៈឈ្មោះមិត្តៈ បានជាអ្នកខ្វល់ខ្វាយក្នុងការឲ្យទានរបស់យោសកសេដ្ឋីនោះ ។

( ការកើតឡើងនៃយោសកសេដ្ឋីមានដោយប្រការយ៉ាងនេះឯង )

# ទម្លាយជញ្ជាំងផ្ទះរត់គេចទៅរមែងរួចផុត
# អំពីអហិវាតក៍

ក្នុងកាលនោះ សេដ្ឋីឈ្មោះ ភទ្ទវតិយៈ ដែលមានប្រក្រតីនៅក្នុងនគរឈ្មោះភទ្ទ-វតិយៈ បានជាសម្លាញ់មិនដែលឃើញគ្នា ( អទិដ្ឋបុព្វសហាយ ) របស់ ឃោសកសេដ្ឋី ។ ឃោសកសេដ្ឋី បានឮនូវទ្រព្យសម្បត្តិផង នូវវ័យ



និងប្រទេសរបស់ភទ្ទវតិយសេដ្ឋី ក្នុងសំណាក់នៃឈ្មួញទាំងឡាយ ដែលមកអំពីភទ្ទវតិយនគរ ឃោសកសេដ្ឋីព្រោះតែប្រាថ្នាភាពជាសម្លាញ់នឹងសេដ្ឋីនោះៗ ទើបបញ្ជូនគ្រឿងបណ្ណាការទៅ ។ សូម្បីភទ្ទ-វតិយសេដ្ឋី ក៏បានស្តាប់សម្បត្តិ និងវ័យព្រមទាំងប្រទេសរបស់ឃោសកសេដ្ឋីក្នុងសំណាក់នៃពួកឈ្មួញ ដែលមកអំពីក្រុងកោសម្ពី ប្រាថ្នាភាពជាសម្លាញ់នឹងសេដ្ឋីនោះ ទើបបញ្ជូនគ្រឿងបណ្ណាការទៅ, សេដ្ឋីទាំងពីរនោះបានជាអទិដ្ឋបុព្វសហាយគ្នានិងគ្នាហើយយ៉ាងនេះ ។

ក្នុងកាលជាចំណែកដទៃ អហិវាតករោគឡើង រុយក្បាលខៀវរមែងស្លាប់មុនគេ, តអំពីនោះ, តុកកែ, កណ្តុរ, មាន់, ជ្រូក, ឆ្កែ, ឆ្មា, គោ, ទាសា, ទាសី រមែងស្លាប់តាមជាប់ ។ ពួកមនុស្សដែលជាម្ចាស់ផ្ទះរមែងស្លាប់ទៅ ក្នុងកាលជាខាងក្រោយនៃសត្វទាំងនោះ ។ បណ្តាជនទាំងនោះ ពួកណាទម្លាយនូវជញ្ជាំងរត់គេចចេញទៅ ពួកនោះរមែងបាននូវជីវិត ។ សូម្បីក្នុងកាលនោះសេដ្ឋី និងភរិយាព្រមទាំងកូនស្រី ក៏រត់គេចទៅដោយវិធីនោះ ប្រាថ្នា



នឹងឃើញឃោសកសេដ្ឋី ទើបធ្វើដំណើរទៅកាន់ក្រុងកោសម្ពី ។ អ្នកទាំង ៣ នាក់នោះមានស្បៀងអស់ហើយក្នុងចនោះផ្លូវ មានសរីរៈលំបាកហើយដោយខ្យល់ និងកម្តៅថ្ងៃ និងដោយការស្រេកឃ្លាន ធ្វើដំណើរទៅដល់ក្រុងកោសម្ពីដោយសេចក្តីលំបាក ផ្ងូតទឹកក្នុងកន្លែងដែលជាទីសប្បាយដោយទឹកហើយ ក៏ចូលទៅកាន់សាលាមួយទៀបទ្វារព្រះនគរ ។

ក្នុងកាលនោះ សេដ្ឋីពោលនឹងភរិយាថា "ម្នាលនាងដ៏ចម្រើន អ្នកមកដោយទំនងយ៉ាងនេះ រមែងមិនជាទីគាប់ចិត្ត សូម្បីតែមាតាបង្កើត ។ បានឮថា សេដ្ឋីដែលជាសម្លាញ់របស់យើងលះបង់ទ្រព្យមួយថ្ងៃមួយពាន់ឲ្យដល់អ្នកដំណើរ មនុស្សកំព្រាជាដើម, យើងបញ្ជូនកូនស្រីទៅកាន់ទីនោះ ឲ្យយកនាំអាហារមកទំនុកបម្រុងយើងក្នុងទីនេះ ពីរបីថ្ងៃ សិន សឹមចូលទៅជួបសម្លាញ់របស់យើង" នាងយល់ព្រមថា "ប្រពៃហើយ នាយ" ។ ក៏សម្រាកនៅក្នុងសាលានោះឯង ។ ថ្ងៃស្អែកឡើង កាលអ្នកបម្រើប្រាប់ពេលវេលាដើម្បីឲ្យមនុស្សកំព្រា



និងអ្នកធ្វើដំណើរជាដើមទៅទទួលយកអាហារ កាលមនុស្សកំព្រានិងអ្នកដំណើរជាដើម កំពុងធ្វើដំណើរទៅដើម្បីទទួលយកអាហារ, ពីរនាក់ស្វាមីភរិយានោះ បានបញ្ជូនកូនស្រីទៅដោយពាក្យថា "ម្នាលកូនស្រី កូនឯងចូរទៅនាំយកអាហារមកដើម្បីពួកយើង" ។ ធីតានៃត្រកូលដែលមានភោគៈច្រើនមិនមានសេចក្តីអៀនខ្មាស ព្រោះភាវៈ

នៃខ្លួនជាស្រីមានសេចក្តីអៀនខ្មាសត្រូវវិបត្តិកាត់ផ្តាច់ហើយ កាន់យកថាសទៅដើម្បីត្រូវការអាហារ មួយអន្ទើដោយមនុស្សកំព្រា លុះទៅដល់រោងទានហើយ ត្រូវមិត្តកុដុម្ពិកៈសួរថា “ម្នាលនាងដ៏ចម្រើន នាងត្រូវការប៉ុន្មានចំណែក” ? ក៏ប្រាប់ថា “បីចំណែក” ។ គ្រានោះ មិត្តកុដុម្ពិកសេដ្ឋីក៏បានឲ្យភត្តាហារ ៣ ចំណែកដល់នាង ។ កាលនាងនាំភត្តមកហើយ ទាំង ៣ នាក់ ក៏អង្គុយបរិភោគរួមគ្នា ។ គ្រានោះ មាតា និងកូនស្រីបានពោលទៅកាន់សេដ្ឋីថា “បពិត្រនាយ ដែលឈ្មោះថាវិបត្តិនេះ រមែងកើតឡើងដល់ត្រកូលធំ ៗ ទាំងឡាយ សូមលោកកុំគិតដល់ឡើយ ចូរបរិភោគចុះ ។ អង្វរដោយប្រការផ្សេងៗ ញុំាង



សេដ្ឋីនោះឲ្យបរិភោគហើយដោយប្រការដូច្នេះ ។ សេដ្ឋីនោះបរិភោគហើយ ក៏មិនអាចនឹងញុំាងអាហារឲ្យរលួយបាន, នាកាលអរុណរះឡើង, ក៏បានធ្វើកាលកិរិយាទៅ ។ មាតា និងកូនស្រីបានខ្សឹកខ្សួលយំរៀបរាប់ដោយប្រការផ្សេងៗ ។ ថ្ងៃស្អែកឡើង ក្មេងស្រី ( កុមារិកា ) យំដើរទៅដើម្បីត្រូវការអាហារ មិត្តកុដុម្ពិកៈនោះឃើញហើយ

សួរថា “ម្នាលនាងដ៏ចម្រើន នាង ត្រូវការប៉ុន្មានចំណែក” ? នាងក៏ប្រាប់ថា “បពិត្រនាយ ២ ចំណែក” មិត្តកុដុម្ពិកៈនោះក៏បានឲ្យកត្តាហារ ២ ចំណែកដល់នាង ។ នាងនាំមកហើយ ក៏អង្វរមាតាឲ្យបរិភោគ ។ ស្ត្រីនោះដែលធីតារបស់ខ្លួនអង្វរក៏បរិភោគហើយ មិនអាចនឹងញ៉ាំងអាហារឲ្យរលួយបាន ក៏ធ្វើកាលកិរិយាទៅក្នុងថ្ងៃនោះឯង ។ ក្មេងស្រីនោះតែម្នាក់ឯងខ្សឹកខ្សួលដោយប្រការផ្សេងៗ ជាអ្នកមានសេចក្តីទុក្ខ ព្រោះសេចក្តីស្រេកឃ្លានកើតឡើងហើយយ៉ាងក្រៃ-លែងជាងការកើតឡើងនៃទុក្ខនោះ ។ ថ្ងៃស្អែកឡើង យំដើរទៅដើម្បីត្រូវការអាហារជាមួយនឹងពួកស្មូមយាចក មិត្តកុដុម្ពិកៈឃើញហើយ



សួរថា “នាងត្រូវការប៉ុន្មានចំណែក” ? ក៏ប្រាប់ថា “បពិត្រនាយ ១ ចំណែក” ។ មិត្តកុដុម្ពិកចាំនាងដែលជាអ្នកមកទទួលភត្តបានទាំង ៣ ថ្ងៃ ព្រោះហេតុនោះ ទើបពោលទៅកាន់នាង ថា “នែ៎ ស្រីខូច ( ស្រីចង្រៃ ) នាងឯងចូរវិនាសទៅ ថ្ងៃនេះនាងឯងស្គាល់ប្រមាណផ្ទៃរបស់នាងឯងហើយឬ” ? ធីតាអ្នកមានត្រកូល ដែលបរិបូណ៌ដោយហិរិ

និងឱត្តប្បៈហាក់បីដូចត្រូវជាប្រហារដោយលំពែងត្រង់ដើមទ្រូង និងដូច ជាត្រូវស្រោចដោយទឹកផ្សាត្រង់ដំបៅ ស្រែកសួរថា "បពិត្រនាយ ខ្ញុំ មានកំហុសអ្វី" ?

កុដុម្ពិកៈ. ថ្ងៃមុននាងទទួលយក ៣ ចំណែក, ពីម្សិល មិញ ២ ចំណែក, ថ្ងៃនេះទទួលយកតែ ១ ចំណែក, ថ្ងៃនេះនាងឯងស្គាល់ប្រមាណផ្ទៃរបស់ខ្លួនហើយឬ ?

កុលធីតា. បពិត្រនាយ លោកកុំយល់ថា "ខ្ញុំយកទៅបរិភោគតែខ្លួនម្នាក់ឯងនោះ" ។

មិត្តៈ. បើដូច្នោះ ហេតុដូចម្តេច ទើបនាងទទួលយកទៅ ៣



ចំណែក ?

កុល. បពិត្រនាយ ក្នុងថ្ងៃមុនពួកខ្ញុំមានគ្នា ៣ នាក់, ពីម្សិលមិញមាន ២ នាក់, ថ្ងៃនេះមានតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ ។

មិត្តកុដុម្ពិកៈក៏សួរថា "ព្រោះហេតុអ្វី" ? បានស្តាប់រឿងទាំងអស់ដែលនាងដំណាលប្រាប់ហើយតាំងពីដើម មិនអាចនឹងទប់ទឹកភ្នែកបាន

កើតទោមនស្សយ៉ាងខ្លាំង ទើបពោលថា "ម្នាលនាងដ៏ ចម្រើន នាងកុំបារម្ភអី, ចាប់តាំងពីថ្ងៃនេះទៅ នាងចូរជាធីតារបស់ យើងចុះ" ដូច្នេះហើយ ក៏ថើបសរីរៈនាំទៅកាន់ផ្ទះ ចាត់ទុកថាជាធីតាច្បង របស់ខ្លួន ។

## ព្រោះធ្វើរបងទើបមានឈ្មោះថាសាមាវតី

សេដ្ឋីធីតានោះ ឮសំឡេងទ្រហឹងអឺងកងក្នុងរោងទានហើយ ក៏សួរថា "បពិត្របិតា ព្រោះហេតុអ្វី ទើបបិតាមិនធ្វើជនទាំងនេះឲ្យជាអ្នកមានសំឡេងស្ងប់ស្ងាត់សិន សឹមឲ្យទានទៅ" ?

មិត្តកុដុម្ពិកៈពោលថា "ម្នាលនាងដ៏ចម្រើន មិនអាចធ្វើបានទេ" ។



សេដ្ឋីធីតា. "បពិត្របិតា ខ្ញុំអាចធ្វើបាន" ។

កុដុម្ពិកៈសួរថា "ម្នាលនាងដ៏ចម្រើន នាងធ្វើដូចម្តេច" ?

សេដ្ឋីធីតា. បពិត្របិតា សូមបិតាធ្វើរបងព័ទ្ធរោងទាន ដាក់ទ្វារ ២ ល្មមប្រមាណមនុស្សម្នាក់ចូលទៅបានប៉ុណ្ណោះហើយ ចូរប្រាប់ថា "ពួកអ្នកទាំងអស់គ្នាចូរចូលតាមទ្វារមួយ ចេញតាមទ្វារមួយ" ដោយ

អាការយ៉ាងនេះ ជនទាំងឡាយក៏នឹងជាអ្នកមានសំឡេងស្ងប់ស្ងៀមទទួលទាន ។

មិត្តកុដុម្ពិកៈនោះ ស្ដាប់ពាក្យនោះហើយ ក៏ពោលថា "ម្នាលនាងដ៏ចម្រើន ឧបាយនេះល្អមែន" ដូច្នេះហើយ ក៏បញ្ជាឲ្យគេធ្វើដូច្នោះ ។ សេដ្ឋីធីតានោះ ក្នុងកាលមុនឈ្មោះ សាមា តែព្រោះនាងឲ្យធ្វើរបងព័ទ្ធជុំវិញរោងទាន ទើបមានឈ្មោះថា សាមាវតី, ចាប់តាំងពីពេលនោះមក ភាពកោលាហលក្នុងរោងទានក៏ដាច់បាត់ទៅ ។ ឃោសកសេដ្ឋីបានឮសំឡេងនោះ ក្នុងកាលមុនសប្បាយរីករាយថា "សំឡេងក្នុងរោងទានរបស់យើង" ប៉ុន្តែកាលមិនបានឮ



សំឡេង ២-៣ ថ្ងៃ ក៏សួរមិត្តកុដុម្ពិកៈដែលជាអ្នកមកកាន់ទីបម្រើរបស់ខ្លួនថា "ទានដើម្បីមនុស្សកំព្រា និងអ្នកដំណើរជាដើម លោកនៅតែឲ្យឬ" ?

មិត្តៈ. បពិត្រលោកម្ចាស់ ខ្ញុំនៅតែឲ្យដដែល ។

ឃោសកៈ. កាលបើដូច្នេះ ព្រោះហេតុអ្វី ទើបខ្ញុំមិនបានឮសំឡេងអស់ ២-៣ ថ្ងៃមកហើយ ។

មិត្តៈ. ខ្ញុំធ្វើឧបាយ ដោយអាការដែលពួកអ្នកទទួលទានមានសំឡេងស្ងាត់ស្ងៀមទទួល ។

ឃោសកៈ. កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកមិនធ្វើក្នុងកាលមុនទៅ ?

មិត្តៈ. ព្រោះមិនដឹង លោកម្ចាស់ ។

ឃោសកៈ. ឥឡូវនេះ លោកដឹងបានដោយសារអ្វី ?

មិត្តៈ. បពិត្រលោកម្ចាស់ កូនស្រីរបស់ខ្ញុំប្រាប់ ។

ឃោសកៈ. ក៏កូនស្រីរបស់អ្នក ដែលខ្ញុំមិនស្គាល់មានដែរឬ ?



មិត្តកុដុម្ពិកៈនោះ ដំណាលរឿងរបស់ភទ្ទវតិយសេដ្ឋីទាំងអស់ចាប់តាំងពីការកើតឡើងនៃអហិវាតករោគហើយ ក៏ប្រាប់ការដែលខ្លួនតាំងធីតារបស់សេដ្ឋីនោះទុកក្នុងតំណែងជាកូនស្រីច្បងរបស់ខ្លួន ។

គ្រានោះ ឃោសកសេដ្ឋីពោលនឹងមិត្តកុដុម្ពិកៈនោះថា "កាលបើមានរឿងដូច្នេះ ព្រោះហេតុអ្វី បានជាលោកមិនប្រាប់ខ្ញុំ ? ធីតានៃសម្លាញ់របស់ខ្ញុំ ក៏ដូចជាធីតារបស់ខ្ញុំដែរ" ដូច្នេះហើយ បញ្ជូឲ្យគេហៅនាងសាមាវតីមកសួរថា "ម្នាលនាងដ៏ចម្រើន នាងជាធីតារបស់សេដ្ឋីឬ" ?

សាមាវតី. "បពិត្របិតា ពិតមែនហើយ" ។

ឃោសកសេដ្ឋីពោលថា "បើដូច្នេះ នាងកុំគិតឡើយ នាងចូរជាធីតារបស់ខ្ញុំចុះ" ដូច្នេះហើយ ថើបព្ធដ៏ក្បាលរបស់នាងសាមាវតី ប្រគល់ស្ត្រី ៥០០ នាក់ឲ្យដល់នាងសាមាវាតី ដើម្បីប្រយោជន៍ដល់ការៈជាបរិវារ ហើយតែងតាំងនាងសាមាវតីទុកក្នុងតំណែងជាធីតាច្បងរបស់ខ្លួន ។

## ព្រះបាទឧទេនបានអគ្គមហេសី

ក្រោយមក នៅថ្ងៃមួយ ក្នុងនគរនោះ ប្រកាសបុណ្យនក្ខត្តឫក្ស ក៏ក្នុងបុណ្យនក្ខត្តឫក្សនោះ សូម្បីធីតានៃត្រកូលទាំងឡាយដែលមិនធ្លាប់ចេញទៅខាងក្រៅ ក៏នាំគ្នាធ្វើដំណើរទៅកាន់ស្ទឹង

ងូតទឹកជាមួយនឹងបរិវាររបស់ខ្លួនៗ ។ ព្រោះហេតុដូច្នោះ ក្នុងថ្ងៃនោះ សូម្បីនាងសាមាវតី ដែលមានស្ត្រី ៥០០ នាក់ហែហមហើយ ក៏បានទៅងូតទឹក ដោយធ្វើដំណើរតាមលានព្រះរាជវាំង ។ ចំណែកព្រះបាទឧទេន ទ្រង់ស្ថិតនៅជិតសីហបញ្ជរ ( បង្អួច ) ទ្រង់ទតឃើញនាងសាមាវតីនោះ ក៏ត្រាស់សួរថា "ស្ត្រីទាំងនោះ ជាស្រីរបាំរបស់ អ្នកណា" ?

រាជបុរសក្រាបទូលថា "បពិត្រមហារាជ ស្ត្រីទាំងនោះ មិនមែនជាស្រីរបាំរបស់អ្នកណាទេ" ។

ឧ. បើដូច្នោះ នាងជាធីតាអ្នកណា ?

រ.បពិត្រមហារាជ នាងជាកូនស្រីរបស់ឃោសកសេដ្ឋី ឈ្មោះសាមាវតី ។



ព្រះបាទឧទេន គ្រាន់តែទតឃើញភ្លាម ក៏ទ្រង់កើតសេចក្តីស្នេហាភ្លាមដែរ ទើបបញ្ជាឲ្យបញ្ជូនសាសន៍ទៅឲ្យសេដ្ឋីថា "សូមសេដ្ឋីបញ្ជូនធីតាមកឲ្យយើង" ។

ឃោសកសេដ្ឋី បញ្ជូនសាសន៍តបទៅវិញថា "បពិត្រមហារាជ ទូលព្រះបង្គំ មិនបញ្ជូនទៅទេ" ។

ព្រះបាទឧទេនបញ្ជូនសាសន៍ទៅទៀតថា សូមសេដ្ឋីកុំធ្វើយ៉ាងនេះឡើយ ចូរបញ្ជូនមកកុំខាន ។

ឃោសកសេដ្ឋី បញ្ជូនសាសន៍តបទៅព្រះរាជាទៀតថា បពិត្រមហារាជ ពួកយើងខ្ញុំព្រះអង្គជាគហបតិ មិនថ្វាយកុមារីចំពោះព្រះអង្គ ព្រោះខ្លាចពីការវាយធ្វើបាប ហើយបណ្តេញកុមារីទាំងឡាយចេញចាក រាជវាំង ។

ព្រះរាជាទ្រង់ខ្ញាល់ហើយ ក៏ទ្រង់បញ្ជាឲ្យបោះត្រាផ្ទះ ទ្រង់បញ្ជាឲ្យចាប់សេដ្ឋី និងភរិយារបស់សេដ្ឋីអូសចេញទៅក្រៅ ។

នាងសាមាវតីងូតទឹកហើយត្រឡប់មក កាលមិនបានឱកាស



ចូលទៅកាន់ផ្ទះ ក៏សួរថា "បពិត្របិតា តើមានរឿងអ្វី ? សេដ្ឋីឆ្លើយថា ម្នាលកូនសម្លាញ់ ព្រះរាជាទ្រង់បញ្ជូនសាសន៍មក ព្រោះហេតុនៃកូនឯង ។ កាលពួកយើងពោលថា ( មិនថ្វាយ ) ក៏បញ្ជាឲ្យ

បោះត្រាផ្ទះ ហើយបញ្ជាឲ្យចាប់អូសពួកយើងចេញខាងក្រៅ” នាងសាមាវតី ក៏ពោលថា “បពិត្របិតា បិតាធ្វើកម្មនេះធ្ងន់ណាស់, ធម្មតាព្រះរាជា កាលបញ្ជូនសាសន៍មកហើយ មិនគួរទូលថាមិនថ្វាយទេ, គួរទូលថា “ប្រសិនបើព្រះអង្គទ្រង់ទទួលធីតារបស់ខ្ញុំព្រះអង្គ ព្រមទាំងបរិវារ ខ្ញុំព្រះអង្គនឹងថ្វាយ” សេដ្ឋីពោលថា “ម្នាលកូនសម្លាញ់ ប្រពៃហើយ” ប្រសិនបើកូនឯងយល់ព្រមយ៉ាងនេះ បិតាក៏យល់ព្រមដែរ ព្រះរាជា ទ្រង់នាំនាងសាមាវតីព្រមទាំងបរិវារនោះមក, ទ្រង់អភិសេកហើយ តាំងទុកក្នុងតំណែងជាអគ្គមហេសី ។ ស្រីដ៏សេសក៏បានជាបរិវារ របស់នាងសាមាវតីនោះឯង ។

( នេះជារឿងរបស់នាងសាមាវតី )

## ព្រះបាទឧទេនត្រូវចាប់

ក៏ព្រះបាទឧទេន បានមានព្រះរាជទេវីមួយព្រះអង្គទៀត ទ្រង់ព្រះនាមថា ព្រះនាងវាសុលទត្តា ជាព្រះរាជធីតារបស់ព្រះបាទចណ្ឌ-

បជ្ជោត ។ មានសេចក្ដីដំណាលពិស្ដារថា នៅក្នុងក្រុងឧជ្ជេនី មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា ព្រះបាទចណ្ឌប្បជ្ជោត ថ្ងៃមួយ ព្រះអង្គស្ដេចយាងមកអំពីព្រះរាជឧទ្យាន ទ្រង់ទតមើលនូវសម្បត្តិរបស់ព្រះអង្គហើយ ត្រាស់សួរថា “សម្បត្តិដូច្នេះរបស់អ្នកណាមួយ មានដែរឬហ្ន៎” ? កាលអាមាត្យក្រាបទូលថា “សម្បត្តិហ្នឹង ឈ្មោះថាជាសម្បត្តិអ្វី” ? សម្បត្តិរបស់ព្រះបាទឧទេន ដែលនៅក្នុងក្រុងកោសម្ពីច្រើនក្រៃលែងជាងសម្បត្តិរបស់ព្រះអង្គឆ្ងាយណាស់” ។

ដូច្នេះហើយ ទ្រង់ត្រាស់ថា “បើដូច្នេះ យើងនឹងចាប់ព្រះរាជាអង្គនោះ ។

អាមាត្យ. “បពិត្រមហារាជអ្នកណាមួយក៏ដោយ ក៏មិនអាចចាប់ព្រះរាជាអង្គនោះបានដែរ ។

ព្រះរាជា. យើងរកឧបាយចាប់ឲ្យខានតែបាន ។



អាមាត្យ. បពិត្រមហារាជ មិនអាចទេ ។

ព្រះរាជា. ព្រោះហេតុអ្វី ?

អាមាត្យ. ព្រោះព្រះបាទឧទេននោះចេះសិល្បៈ ឈ្មោះហត្ថិ-កន្តៈ, ទ្រង់រាយមន្តហើយដេញពិណឈ្មោះហត្ថិកន្តៈ នឹងញុាំងដំរីឲ្យរត់ទៅក៏បាន, នឹងចាប់យកក៏បាន, បុគ្គលអ្នកដល់ព្រមដោយដំរីជាពាហនៈ ដូចព្រះរាជាអង្គនោះមិនមាន ។

ព្រះរាជា. យើងមិនអាចនឹងចាប់ព្រះរាជាអង្គនោះបានឬ?

អាមាត្យ. បពិត្រមហារាជ ប្រសិនបើព្រះអង្គមានចំណង់ក្នុងព្រះទ័យដូច្នេះ ដោយចំណែកមួយហើយ, សូមព្រះអង្គ ទ្រង់បញ្ជាឲ្យជាងធ្វើដំរីឈើឡើង ហើយបញ្ជូនទៅកាន់សម្នាក់ ព្រះរាជាអង្គ នោះ, ព្រះរាជាទ្រង់ព្រះសណ្តាប់នូវវាហនៈដំរី ឬវាហនៈ សេះ រមែងយាងទៅសូម្បីកាន់ទីឆ្ងាយ, ព្រះអង្គនឹងអាចចាប់ព្រះបាទ ឧទេនដែលទ្រង់យាងមកកាន់ទីនោះបាន ។

ព្រះរាជាត្រាស់ថា “ឧបាយនេះប្រើបាន” ដូច្នេះហើយ ក៏បញ្ជា



ឲ្យជាងធ្វើដំរីយន្តសម្រេចអំពីឈើ យកក្រណាត់សំពត់ទាំងឡាយរុំព័ទ្ធព្ធដ៏ខាងក្រៅ ហើយទ្រង់បញ្ជាឲ្យធ្វើដំរីយន្តនោះឲ្យមានចិត្តកម្ម

ផ្សេងៗ បញ្ជាឲ្យរាជបុរសលែងទៅក្បែរស្រះមួយ ក្នុងទីជិតដែន របស់ព្រះបាទឧទេន ។ បុរស ៦០ នាក់ អាចដើរទៅមកខាងក្នុងពោះ ដំរីនោះបាន, ពួកបុរសទាំងអស់នោះ នាំអាចម៍ដំរីមកទម្លាក់ចោល ក្នុងទី នោះៗ ព្រានព្រៃម្នាក់ឃើញដំរីហើយក៏គិតថា "ដំរីនេះសមគួរ ដល់ ស្តេចផែនដីរបស់យើង" ដូច្នេះហើយ ក៏ក្រាបទូល ព្រះបាទឧទេនថា "បពិត្រមហារាជ ខ្ញុំព្រះអង្គឃើញដំរីដ៏ប្រសើរ ដែលមានអវយវៈ សសុទ្ធ មានចំណែកប្រៀបដូចកំពូលភ្នំកៃ-លាស សមគួរនឹងព្រះ អង្គណាស់" ព្រះបាទឧទេនទ្រង់ធ្វើព្រានព្រៃ នោះឯងឲ្យជាអ្នកនាំផ្លូវហើយ ស្តេចឡើងកាន់ដំរីព្រមទាំងបរិវារ យាងចេញទៅ ពួកចារបុរស ដឹងថាព្រះបាទឧទេនយាងមក ក៏ទៅ ក្រាបទូល ព្រះបាទ ចណ្ឌប្បជ្ជោត ។ ព្រះបាទចណ្ឌប្បជ្ជោតស្តេច យាងមកហើយ ទ្រង់ធ្វើនូវទីទំនេរទុកត្រង់កណ្តាល ប្រកបពួក ពលនិកាយទុកពីសងខាង ។

ព្រះបាទឧទេន ស្ដេចមិនជ្រាបដល់ការយាងមករបស់ព្រះបាទចណ្ឌបជ្ជោតទេ, ចេះតែប្រឹងដេញតាមដំរីទៅ ។ មនុស្សដែលនៅខាងក្នុង ដំរីក៏ប្រញាប់នាំដំរីទៅដោយរហ័ស កាលព្រះរាជាទ្រង់វាយមន្តដេញ ពិណ, ដំរីឈើធ្វើដូចមិនឮសំឡេងពិណ រត់ទៅតែម្យ៉ាង ។ ព្រះរាជា មិនអាចតាមទាន់ស្ដេចដំរីបាន ក៏ស្ដេចឡើងកាន់សេះដេញតាមទៅ ។ កាលព្រះរាជាអង្គនោះស្ដេច ដេញតាមដោយរហ័ស ក៏ដាច់ឆ្ងាយអំពីកង ពល ។ ព្រះរាជាបានជាអ្នកតែមួយព្រះអង្គឯងប៉ុណ្ណោះ ។ គ្រានោះ ពួកបុរសរបស់ ព្រះបាទចណ្ឌប្បជ្ជោត ដែលដាក់កងទ័ពទុកក្នុងទីទាំង សងខាង ( ផ្លូវ ) នោះចាប់ព្រះបាទឧទេនថ្វាយស្ដេចផែនដីរបស់ខ្លួន ។ គ្រានោះពួកពលរបស់ព្រះបាទឧទេនដឹងថា ព្រះរាជារបស់ខ្លួនធ្លាក់ ក្នុងអំណាចនៃបុគ្គលដែលមិនមែនជាមិត្ត ( សត្រូវ ) ក៏សង់ បន្ទាយនៅព្លង់ខាងក្រៅ ។

## ព្រះបាទចណ្ឌប្បជ្ជោតទ្រង់ឲ្យធីតារៀនមន្ត

ចំណែកព្រះបាទចណ្ឌប្បជ្ជោត ទ្រង់បញ្ជាឲ្យចាប់ព្រះបាទ

ឧទេនទាំងរស់ ហើយដាក់ក្នុងផ្ទះជាទីឃុំឃាំងចោរ ទ្រង់បញ្ជាឲ្យបិទទ្វារហើយ ទ្រង់សោយនូវទឹកជ័យរហូតអស់ ៣ ថ្ងៃ ។ ក្នុងថ្ងៃទី ៣ ព្រះបាទឧទេនសួរពួកអ្នកយាមគុកថា "ម្នាលអ្នកទាំងឡាយ ស្ដេចផែនដីរបស់ពួកឯងទៅណា" ?

អ្នកយាមគុក. ស្ដេចផែនដីរបស់ពួកយើងទ្រង់សោយនូវទឹកជ័យ ( ទឹកដែលបុគ្គលផឹកក្នុងពេលដែលខ្លួនឈ្នះ ) ដោយទ្រង់ត្រេកអរថា បច្ចាមិត្ត គឺខ្មាំងអញចាប់បានហើយ ។

ព្រះបាទឧទេន. ស្ដេចផែនដីរបស់ពួកឯងមានកិរិយាស្អីបែបហ្នឹង ? ហាក់ដូចជាកិរិយារបស់មាតុគ្រាមចាប់ព្រះរាជាដែលជាសត្រូវបានហើយ ចាត់ចែងឲ្យគេលែងទៅ ឬក៏សម្លាប់មិនមែនឬ ? ត្រឡប់ជាញ៉ាំងយើងឲ្យអង្គុយជាទុក្ខ ហើយទៅអង្គុយផឹកទឹកជ័យទៅវិញ ។

អ្នកយាមគុកទាំងនោះ ក៏នាំគ្នាទៅក្រាបទូលសេចក្ដីនោះដល់ព្រះរាជា, ព្រះអង្គស្ដេចយាងទៅត្រាស់សួរថា "បានឮថា ព្រះអង្គត្រាស់យ៉ាងនេះពិតមែនឬ" ?

ឧទេន. ព្រះករុណាថ្លៃវិសេស ។

ចណ្ឌប្បជ្ជោត. ពាក្យដែលព្រះអង្គពោលនោះប្រពៃហើយ, ទូលបង្គំនឹងលែងព្រះអង្គ, បានឮថា ព្រះអង្គមាននូវមន្ត, ព្រះអង្គនឹងឲ្យមន្តនោះដល់ទូលបង្គំឬទេ ?

ឧទេន. ប្រពៃហើយ ទូលបង្គំនឹងថ្វាយ, ក្នុងពេលរៀន សូមព្រះអង្គសំពះទូលបង្គំហើយរៀនយកមន្តចុះ, ក៏ព្រះអង្គសំពះទូលបង្គំឬ ក៏មិនសំពះ ?

ចណ្ឌប្បជ្ជោត. ទូលបង្គំនឹងសំពះព្រះអង្គដូចម្តេចទៅ ?

ឧទេន. ព្រះអង្គមិនសំពះទូលបង្គំឬ ?

ចណ្ឌប្បជ្ជោត. ខ្ញុំព្រះអង្គនឹងមិនសំពះទេ ។

ឧទេន. ទូលបង្គំក៏នឹងមិនអាចថ្វាយនូវមន្តដល់ព្រះអង្គដែរ ។

ចណ្ឌប្បជ្ជោត. ប្រសិនបើ ព្រះអង្គមិនថ្វាយមន្តដល់ទូលបង្គំទេ, ទូលបង្គំក៏ដាក់អាជ្ញាដល់ព្រះអង្គ ។

ឧទេន. សូមព្រះអង្គ ទ្រង់ធ្វើចុះ, ព្រះអង្គជាធំចំពោះតែសរីរៈ

របស់ទូលបង្គំប៉ុណ្ណោះ ប៉ុន្តែមិនជាធំលើចិត្តរបស់ទូលបង្គំទេ ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវពាក្យដ៏អង់អាចក្លាហានរបស់ព្រះបាទឧទេនហើយ ក៏ទ្រង់ព្រះតម្រិះថា "អញនឹងរៀនមន្តរបស់ព្រះបាទឧទេននេះ បានដោយប្រការដូចម្ដេចហ្ន៎" ? ហើយទ្រង់ព្រះចិន្តាថា "អញមិនអាចញុំាងអ្នកដទៃឲ្យចេះនូវមន្តនោះបានទេ, អញនឹងឲ្យធីតារបស់អញរៀនក្នុងសំណាក់ព្រះបាទឧទេននេះ ហើយសឹមអញរៀនក្នុងសំណាក់ធីតារបស់អញវិញ" ។ គ្រានោះ ព្រះបាទចណ្ឌបជ្ជោតក៏ត្រាស់ទៅកាន់ព្រះបាទឧទេននោះថា "ព្រះអង្គនឹងឲ្យអ្នកដទៃដែលសំពះហើយរៀនយកនូវមន្តនោះឬ" ?

ឧ. ព្រះករុណាថ្លៃវិសេស ។

ច. បើដូច្នេះ ក្នុងផ្ទះរបស់ទូលបង្គំមានស្ត្រីគមម្នាក់, ព្រះអង្គចូរស្ថិតនៅខាងក្រៅវាំងននបង្រៀនមន្តដល់ស្រីនោះ ដែលជាអ្នកអង្គុយខាងក្នុងវាំងននចុះ ។

ឧ. បពិត្រមហារាជ ប្រពៃហើយ ស្រីគមក្តី ស្រីខ្វិនក្តី ចូរ

លើកទុកសិនចុះ, កាលនាងសំពះទូលបង្គំ, ទូលបង្គំនឹងឲ្យ ។ គ្រានោះ ព្រះរាជាស្តេចយាងទៅត្រាស់ប្រាប់វាសុលទត្តារាជធីតា ថា “ម្នាលកូនស្រី បុរសកើតរោគឃ្លង់ម្នាក់ចេះមន្តកាត់ថ្លៃពុំបាន, បិតាមិនអាចនឹងញ៉ាំងបុគ្គលដទៃឲ្យចេះមន្តនោះបានទេ, កូនឯងចូរអង្គុយខាងក្នុងវាំងននសំពះបុរសនោះហើយរៀនមន្តនោះចុះ, បុរសនោះឈរនៅខាងក្រៅវាំងននទីងបង្រៀនមន្តដល់កូនឯង, បិតានឹងរៀនអំពីសំណាក់កូនឯង” ។ ព្រះបាទចណ្ឌប្បជ្ជោតនោះត្រាស់ធ្វើធីតារបស់ ខ្លួនឲ្យជាស្រីគម ចំណែកព្រះបាទឧទេនឲ្យជាបុរសកើតរោគឃ្លង់យ៉ាងនេះ ព្រោះខ្លាចក្រែងអ្នកទាំង ២ នោះធ្វើសន្ថវៈគ្នានឹងគ្នា ។

ព្រះបាទឧទេនបិតនៅខាងក្រៅវាំងនន ទ្រង់បង្រៀនមន្តដល់ព្រះរាជធីតាដែលអង្គុយសំពះឰដ៏ខាងក្នុងវាំងនន ។

## <u>អគ្គមហេសីអង្គទី</u> ២ <u>របស់ព្រះបាទឧទេន</u>

សម័យថ្ងៃមួយ ព្រះបាទឧទេនត្រាស់ទៅកាន់ព្រះនាងវាសុ-លទត្តា សូម្បីព្រះអង្គត្រាស់ប្រាប់រឿយៗ ក៏មិនអាចនឹងពោលនូវបទ



មន្តបានថា "ម្នាលស្រីគម មេស្រីចង្រៃ បបូរមាត់របស់ហាងឯងក្រាស់ក្រៃលែងណាស់, ហាងឯងចូរពោលយ៉ាងនេះ" ។ ព្រះនាងវាសុលទត្តាខ្ញាល់ ក៏ត្រាស់ថា "យើ ! អាគំលង់ ឯងនិយាយអ្វី ស្រីដូចជាយើងនេះឬ ជាស្រីគម" ? ដូច្នេះហើយ ទ្រង់សើយជាយវាំងននឡើង, កាលព្រះឧទេនត្រាស់សួរថា "នាងជានរណា" ? ក៏ត្រាស់ប្រាប់ថា "ខ្ញុំឈ្មោះវាសុលទត្តាជាធីតានៃព្រះបាទផែនដី" ។

ព្រះបាទឧទេន. បិតារបស់នាង កាលត្រាស់អំពីព្រះនាងប្រាប់ខ្ញុំ ក៏បានត្រាស់ប្រាប់ថា "នាងជាស្រីគម" ។

វាសុលទត្តា. សូម្បីកាលត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ ព្រះបិតាក៏មានព្រះបន្ទូលធ្វើឲ្យព្រះអង្គជាមនុស្សកើតរោគឃ្លង់ ។ ទាំងពីរព្រះអង្គនោះ ទ្រង់ព្រះចិន្តាថា "ពាក្យនោះ ព្រះរាជាត្រាស់ហើយ

ដោយខ្លាចក្រែងយើងទាំងពីរធ្វើសន្ថវៈគ្នានិងគ្នា" ហើយក៏ទ្រង់ធ្វើសន្ថវៈ គ្នានិងគ្នាខាងក្នុងវាំងនននោះឯង ។

ចាប់តាំងអំពីកាលនោះមក ការរៀនមន្តឬសិល្បៈក៏មិនមាន ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៨៧ -

ចំណែកព្រះរាជាទ្រង់សួរព្រះរាជធីតាជារឿយៗថា "ម្នាលកូនស្រី កូនឯងនៅតែរៀនសិល្បៈឬ ?

ព្រះនាងវាសុលទត្តាត្រាស់ថា "បពិត្រព្រះបិតា ខ្ញុំម្ចាស់កំពុងតែរៀន ខាងក្រោយមក នៅថ្ងៃមួយ ព្រះបាទឧទេនត្រាស់ទៅកាន់ព្រះនាងវាសុលទត្តាថា "ម្នាលនាងដ៏ចម្រើន ឈ្មោះថា អំពើដែលស្វាមីគប្បីធ្វើ មាតាបិតា បងប្អូនប្រុស និងបងប្អូនស្រីមិនអាចធ្វើអំពើនោះបានឡើយ, ប្រសិនបើនាងនឹងឲ្យជីវិតដល់យើង, យើងនឹងប្រគល់ស្ត្រី ៥០០ នាក់ ឲ្យដល់នាងធ្វើជាបរិវារ ហើយប្រទានតំណែងអគ្គមហេសីឲ្យដល់នាង ។

ព្រះនាងវាសុលទត្តាត្រាស់ថា "បើព្រះអង្គនឹងតាំងនៅក្នុងព្រះតម្រាស់នេះ, ខ្ញុំម្ចាស់នឹងថ្វាយជីវិតទានដល់ព្រះអង្គ" ។

ព្រះបាទឧទេនត្រាស់តបថា "ម្នាលនាងដ៏ចម្រើន ខ្ញុំនឹងអាច" ។

ព្រះនាងវាសុលទត្តាទ្រង់ទទួលនូវព្រះតម្រាស់នោះថា ប្រពៃហើយ ដូច្នេះហើយក៏ស្ដេចទៅកាន់សំណាក់ព្រះរាជបិតា ថ្វាយបង្គំ



ហើយបានឈរនៅក្នុងចំណែកម្ខាង ។ ខណៈនោះ ព្រះបាទចណ្ឌប្បជ្ជោតត្រាស់សួរព្រះនាងវាសុលទត្តាថា "ម្នាលកូនស្រី សិល្បៈសម្រេចហើយឬ" ?

នាងវាសុលទត្តា. បពិត្រព្រះបិតា មិនទាន់សម្រេចទេ ។

គ្រានោះ ព្រះបាទចណ្ឌប្បជ្ជោត ត្រាស់សួរព្រះនាងវាសុលទត្តាថា "ម្នាលកូនស្រីព្រោះហេតុអ្វី" ?

នាងវាសុលទត្តា. បពិត្រព្រះបិតា ខ្ញុំម្ចាស់គួរនឹងបានទ្វារមួយនិងពាហនៈមួយ ។

ចណ្ឌប្បជ្ជោត. ម្នាលកូនស្រី កម្មនេះតើដូចម្ដេច ?

វាសុលទត្តា. បពិត្រព្រះបិតា មានឱសថមួយមុខនឹងត្រូវកាន់យកក្នុងវេលារាត្រី ដោយសញ្ញាតាមផ្កាយព្រឹក ដើម្បីជាប្រយោជន៍ឧបការៈដល់មន្ត ។ ព្រោះហេតុនោះ ក្នុងវេលាដែលខ្ញុំម្ចាស់ ទៅតាមវេលា ឬក៏មិនតាមវេលា ក៏គួរនឹងបានទ្វារមួយ និងពាហនៈមួយ ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៨៩ -

ព្រះរាជាទ្រង់ព្រមដោយព្រះរាជាតម្រាស់ថា “បាន” ព្រះបាទឧទេន និងនាងវាសុលទត្តា បានទ្រង់កាន់យកទ្វារ ១ ដែលខ្លួនពេញចិត្តទុកក្នុងកណ្ដាប់ដៃរបស់ខ្លួន ។

## ពាហនៈ ៥ របស់ព្រះបាទចណ្ឌប្បជ្ជោត

ក៏រាជពាហនៈ ៥ គឺ ៖

-ដំរីញីមួយឈ្មោះ ភទ្ទវតី អាចទៅបាន ៥០ យោជន៍ក្នុង ១ ថ្ងៃ ។

-ទាសៈឈ្មោះ កាកៈ អាចទៅបាន ៦០ យោជន៍ក្នុង ១ ថ្ងៃ ។

-សេះ ២ គឺសេះឈ្មោះ វេលកង្សិ ១ និងមុញ្ជកេសិ ១ អាចទៅបាន ១០០ យោជន៍ក្នុង ១ ថ្ងៃ ។

-ដំរីនាឡាគិរី អាចទៅបាន ១២០ យោជន៍ក្នុង ១ ថ្ងៃ ។

## ប្រវត្តិដែលនឹងបានពាហនៈទាំងនោះ

បានឮមកថា ព្រះរាជាអង្គនោះ កាលព្រះសម្មាសម្ពុទ្ធមិនទាន់ទ្រង់ឧប្បត្តិឡើង បានជាអ្នកបម្រើឥស្សរជនម្នាក់ ។ ថ្ងៃមួយ កាល



ឥស្សរជននោះ ចេញទៅខាងក្រៅព្រះនគរងូតទឹកហើយត្រឡប់មកវិញ ។ ព្រះបច្ចេកពុទ្ធ ១ អង្គចូលទៅកាន់ព្រះនគរដើម្បីបិណ្ឌបាតមិនបានកិច្ចាសូម្បីតែ ១ វែក ព្រោះអ្នកក្រុងទាំងអស់ត្រូវមារបណ្ដាលចិត្ត មានបាត្រតាមដែលលាងទុកហើយ ( ទទេ ) ចេញមក ។ គ្រានោះ មារចូលទៅរកព្រះបច្ចេកពុទ្ធនោះ ដោយភេទដែលមិនមានបុគ្គលណាស្គាល់ ហើយសួរព្រះបច្ចេកពុទ្ធក្នុងខណៈដែលលោកនិមន្តទៅដល់ទ្វារព្រះនគរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន លោកបានវត្ថុអ្វីៗ ខ្លះដែរឬទេ” ? ព្រះបច្ចេកពុទ្ធឆ្លើយថា “ក៏អ្នកឯងធ្វើមិនឲ្យអាត្មាបានអាហារពិតមែនឬ” ?

មារ. បើដូច្នោះ សូមលោកម្ចាស់ត្រឡប់ចូលទៅកាន់ក្រុងម្តងទៀតចុះ, លើកនេះខ្ញុំនឹងមិនធ្វើទៀតទេ ។

ប. អាត្មានឹងមិនត្រឡប់វិញទេ ។

ដ្បិតថា បើព្រះបច្ចេកពុទ្ធនោះគប្បីត្រឡប់ចូលកាន់ក្រុងម្តងទៀតសោត មារនោះនឹងគប្បីជ្រែកចូលក្នុងសរីរៈរបស់អ្នកក្រុងទាំង



អស់ ហើយទះដៃសើចចំអកឲ្យព្រះបច្ចេកពុទ្ធវិញ, កាលព្រះបច្ចេក-ពុទ្ធមិនត្រឡប់ មារក៏អន្តធានទៅក្នុងទីនោះឯង ។

គ្រានោះ ឥស្សរជននោះ គ្រាន់តែឃើញព្រះបច្ចេកពុទ្ធដែលនិមន្តចេញមកអំពីក្រុងដោយបាត្រទទេ ក៏ថ្វាយបង្គំហើយសួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ បានវត្ថុអ្វីខ្លះហើយឬ” ? “ព្រះបច្ចេកពុទ្ធឆ្លើយថា “ម្នាលអ្នកមានអាយុ អាត្មាកាពត្រាច់ទៅហើយចេញមកវិញហើយ” ឥស្សរជននោះគិតថា “លោកម្ចាស់ដ៏ចម្រើននេះមិនឆ្លើយសំណួរដែលយើងសួរ ត្រឡប់ពោលពាក្យដទៃទៅវិញ, ប្រាកដជាលោកមិនបាននូវវត្ថុអ្វីៗ ខ្លះហើយមើលទៅ” ។ គ្រានោះ

ឥស្សរជននោះក៏បានដើរចូលទៅមើលបាត្រព្រះបច្ចេកពុទ្ធ ឃើញទទេ ក៏ជាអ្នកក្លៀវក្លា ប៉ុន្តែមិនអាចទទួលបាត្រ ព្រោះមិនដឹងថា ភត្តក្នុងផ្ទះរបស់ខ្លួនឆ្អិនហើយ ឬក៏មិនទាន់ឆ្អិន ក៏ពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់រង់ចាំបន្តិច” ដូច្នេះហើយ ក៏ទៅកាន់ផ្ទះដោយរហ័ស ហើយសួរថា “ភត្តសម្រាប់យើងឆ្អិន



ហើយឬ” ? កាលអ្នកបម្រើឆ្លើយថា “សម្រេចហើយ” ក៏ពោលនឹងអ្នកបម្រើនោះថា “ម្នាលអ្នកដ៏ចម្រើន បុគ្គលដែលជាអ្នកមានកម្លាំងខ្លាំង ហើយរហ័សវិសេសជាងឯងមិនមាន, ឯងចូលទៅដល់លោកម្ចាស់ដ៏ចម្រើននោះហើយពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឲ្យបាត្រមកខ្ញុំព្រះករុណា, ហើយទទួលយកមកដោយរហ័ស” ។ អ្នកបម្រើនោះស្ទុះទៅដោយពាក្យត្រឹមតែមួយម៉ាត់ប៉ុណ្ណោះ ទទួលយកបាត្រមក ។ ឥស្សរជននោះក៏ញុំាងបាត្រនោះឲ្យពេញដោយភោជនរបស់ខ្លួនហើយពោលថា “ឯងចូរទៅយ៉ាងឆាប់ ថ្វាយបាត្រនេះដល់លោកម្ចាស់ដ៏ចម្រើន យើងនឹងឲ្យនូវចំណែកបុណ្យអំពីទាននេះ

ដល់ឯង” ។ អ្នកបម្រើទទួលបាត្រនោះហើយទៅដោយបាទជើងដ៏រហ័សប្រគេនបាត្រនោះដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គ-ប្រតិស្ឋាន ហើយពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន វេលាជិតដល់ហើយ, ខ្ញុំម្ចាស់ទៅ និងមកដោយល្បឿនរត់យ៉ាងរហ័សក្រៃ-លែង, ដោយផលនៃសន្ទុះជើងរបស់ខ្ញុំម្ចាស់នេះ សូមពាហនៈទាំង-



ឡាយ ៥ ដែលអាចទៅបាន ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ ចូរកើតមានដល់ខ្ញុំម្ចាស់ ម្យ៉ាងទៀត រាងកាយរបស់ខ្ញុំម្ចាស់កាលមកនឹងទៅ ត្រូវកម្ដៅព្រះអាទិត្យដុតរោលហើយ, ដោយផលនៃរាងកាយដែលត្រូវក្ដៅ ដោយតេជៈនៃព្រះអាទិត្យរបស់ខ្ញុំ សូមអាជ្ញារបស់ខ្ញុំម្ចាស់ផ្សាយទៅដូចតេជៈនៃព្រះអាទិត្យក្នុងទីដែលខ្ញុំម្ចាស់កើតហើយៗចុះ ចំណែកបុណ្យក្នុង បិណ្ឌ-បាត នេះ ដែលម្ចាស់ទានឲ្យហើយដល់ខ្ញុំម្ចាស់ ដោយផលដែលហូរចេញអំពីចំណែកនៃបុណ្យនោះ សូមឲ្យខ្ញុំម្ចាស់ជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយចុះ” ។ ព្រះបច្ចេកពុទ្ធពោលថា

“សូមឲ្យសេចក្តីប្រាថ្នាដែលអ្នកប្រាថ្នាហើយ បានសម្រេច” ហើយបានធ្វើអនុមោទនាថា ៖

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ
តាំងចិត្តហើយ ចូរឲ្យសម្រេចដល់អ្នក ឲ្យឆាប់រួសរាន់
ទាន់ចិត្ត ។ សូមតម្រិះត្រូវទាំងពួងចូរពេញ ( ដល់អ្នក )



ដូចព្រះច័ន្ទក្នុងថ្ងៃ ១៥ កើត ( ពុំនោះសោត ) ដូចកែវ
មណីមានរស្មីដ៏រុងរឿង ជាកែវវិសេស អាចញុំាង
សេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេចបាន ។

បានឮមកថា គាថាទាំងពីរនេះឯង ជាគាថាសម្រាប់អនុមោទនារបស់ព្រះបច្ចេកពុទ្ធគ្រប់ព្រះអង្គ ។ រតនៈ គឺកែវមណីដែលអាចឲ្យសម្រេចនូវសម្បត្តិទាំងពួងបាន ហៅថា “កែវមណីជោតិរស” ក្នុងគាថានោះ នេះជាបុញ្ញកម្មរបស់បុរសបម្រើនោះ ។ គេបានជាព្រះបាទចណ្ឌប្បជ្ជោតក្នុងកាលឥឡូវនេះ ។ ហើយដោយផលដែលហូរចេញអំពីបុញ្ញកម្មនោះ ពាហនៈ ៥ នេះក៏កើតឡើង ។

# ស្តេចលួចរត់

ថ្ងៃមួយ ព្រះរាជាស្តេចចេញទៅដើម្បីក្រសាលក្នុងឧទ្យាន ។ ព្រះបាទឧទេនទ្រង់ព្រះចិន្តាថា "អញគប្បីរត់ចេញក្នុងថ្ងៃនេះ" ក៏ញ៉ាំងការុងស្បែកធំៗ ឲ្យពេញដោយប្រាក់ និងមាសដាក់លើខ្នងដំរី ហើយនាំព្រះនាងវាសុលទត្តារត់ចេញទៅ ។ ទាហានដែលរក្សាខាងក្នុង

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ៩៥ -

រាជវាំងទាំងឡាយ ឃើញព្រះបាទឧទេនរត់ចេញទៅ ក៏ក្រាបទូលព្រះរាជា ។ ព្រះបាទចណ្ឌប្បជោតិទ្រង់បញ្ជូនពលទៅដោយព្រះតម្រាស់ថា "ពួកឯងចូរទៅយ៉ាងឆាប់" ព្រះបាទឧទេនទ្រង់ជ្រាបថាទាហានរបស់ព្រះបាទចណ្ឌប្បជោតិដេញតាមមកហើយ ក៏ទ្រង់ស្រាយមាត់ការុងកហាបណៈ ធ្វើកហាបណៈឲ្យធ្លាក់ ទាហានរបស់ព្រះបាទចណ្ឌប្បជោតិរើសយកកហាបណៈឡើងហើយ ទើបដេញទៅទៀត ។ ចំណែកព្រះបាទឧទេនក៏ទ្រង់ស្រាយមាត់ការុងមាស ធ្វើមាសឲ្យធ្លាក់ កាលទាហានទាំងនោះរវល់តែយឺតយូរ ព្រោះការលោភចំពោះមាស ព្រះបាទឧទេន ក៏ស្តេចយាងដល់បន្ទាយរបស់ព្រះអង្គ

ដែលតាំងនៅ ខាងក្រៅព្រះនគរ ។ គ្រានោះ ពួកទាហាន ទាំងនោះគ្រាន់តែឃើញ ស្ដេចយាងមកដល់ភ្លាម ក៏ចោមរោមហើយ ញាំងព្រះរាជាឲ្យស្ដេច យាងចូលកាន់ព្រះនគររបស់ខ្លួន ។ ព្រះបាទឧទេនព្រះអង្គគ្រាន់តែ ស្ដេចយាងដល់ព្រះនគរភ្លាម ក៏អភិសេក ព្រះនាងវាសុលទត្តាជាព្រះ អគ្គមហេសីភ្លាមដែរ ។

## ប្រវត្តិរបស់ព្រះនាងមាគន្ទិយា

មិនតែប៉ុណ្ណោះ ព្រះនាងទេវីដទៃទៀត ព្រះនាមមាគន្ទិយា ក៏បានទទួលតំណែងជាអគ្គមហេសីអំពីសំណាក់នៃព្រះបាទឧទេនដែរ ។ បានឮមកថា នាងជាធីតារបស់ព្រាហ្មណ៍ឈ្មោះមាគន្ទិយៈក្នុងដែនកុរុ, សូម្បីមាតារបស់នាងក៏ឈ្មោះថា មាគន្ទិយៈដែរ។ សូម្បីឪពុកមាររបស់នាងក៏ឈ្មោះមាគន្ទិយៈដែរ នាងជាស្រ្តីមានរូបស្រស់ស្អាតយ៉ាងក្រៃលែង ប្រៀបដូចជាទេពអប្សរ ។ ក៏បិតារបស់ព្រះនាង កាលមិនបានបុរសដែលសមនិងនាង សូម្បីត្រកូលធំៗ ទាំងឡាយ ដណ្ដឹងក៏ត្រឡប់ជាគម្រាម ហើយបញ្ជូនទៅថា "ពួកលោកមិន សមនឹងធីតារបស់យើងទេ" ។ ថ្ងៃមួយព្រះសាស្ដាទ្រង់ប្រមើល មើលនូវ

សត្វលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃអនាគាមិផលរបស់មាគន្ទិយព្រាហ្មណ៍ព្រមទាំងបជាបតី ( ភរិយា ) ទ្រង់កាន់បាត្រ និងចីវររបស់ព្រះអង្គហើយ ស្តេចទៅកាន់ទីបម្រើភ្លើងរបស់ព្រាហ្មណ៍នោះដែលនៅខាងក្រៅនិគម ។ ព្រាហ្មណ៍នោះឃើញអត្តភាពដ៏ឆ្នើមដោយលម្អនៃព្រះរូបរបស់ព្រះតថាគតហើយ ក៏



គិតដូច្នេះថា "បុរសដទៃជាអ្នកប្រាកដស្មើដោយបុរសនេះ រមែងមិនមានក្នុងលោក, បុរសនេះសមនឹងធីតារបស់យើង, យើងនឹងឲ្យធីតារបស់យើងដល់បុរសនេះ ដើម្បីប្រយោជន៍ដល់ការចិញ្ចឹមរក្សាគ្នា" ហើយក៏ពោលថា "បពិត្រសមណៈ ខ្ញុំមានធីតាម្នាក់ ខ្ញុំមិនទាន់ឃើញនូវបុរសដែលសមនិងនាង រហូតអស់កាលមានប្រមាណប៉ុណ្ណោះ, លោកជាអ្នកសមនិងនាង, ហើយនាងក៏សមនិងលោកដែរ, លោកគួរបាននាងទុកជាស្ត្រីអ្នកបម្រើក្បែរ ជើងលោក ហើយនាងក៏គួរបានលោកទុកជាភស្តាដែរ, ខ្ញុំនឹងឲ្យធីតា របស់ខ្ញុំដល់លោក លោកចូរឈរនៅទីនេះឯង ដរាបខ្ញុំនឹងត្រឡប់មកវិញ" ។

ព្រះសាស្ដា មិនត្រាស់នូវពាក្យអ្វីៗទាំងអស់ ទ្រង់ បាននៅស្ងៀម ។ ព្រាហ្មណ៍ទៅកាន់ផ្ទះដោយរហ័ស ហើយពោលទៅកាន់ព្រាហ្មណីថា "នែនាងដ៏ចម្រើន ខ្ញុំឃើញបុរសដែលសមនិងកូនស្រីរបស់យើងហើយ, នាងចូរតាក់តែងខ្លួនកូនស្រីយើងឆាប់ៗ" ប្រើព្រាហ្មណីឲ្យតាក់តែងកូនស្រីហើយ នាំទៅមួយអន្លើដោយ



ព្រាហ្មណី បានទៅកាន់សំណាក់របស់ព្រះសាស្ដា ។ អ្នកនគរទាំងមូលភ្ញាក់ផ្អើលថា "ព្រាហ្មណ៍នេះមិនឲ្យកូនស្រីដល់អ្នកណាមួយដោយសំអាងថា បុរសដែលសមនិងកូនស្រីរបស់យើងមិនមាន" រហូតអស់កាលមាន ប្រមាណប៉ុណ្ណោះ ។ បានឮថា "គាត់ពោលថាថ្ងៃនេះយើងបានបុរសដែលនិងកូនស្រីរបស់យើងហើយ, បុរសនោះយ៉ាងណាទៅហ្ន៎ ? ពួកយើងនឹងទៅមើលបុរសនោះ" ។ មហាជនក៏បានចេញទៅជាមួយនឹងព្រាហ្មណ៍នោះដែរ ។ កាល ព្រាហ្មណ៍នោះនាំធីតាមក ព្រះសាស្ដាមិនបានទ្រង់ឋិតនៅក្នុងទីដែលព្រាហ្មណ៍នោះពោលទេ ទ្រង់សម្ដែងចេតិយ គឺស្នាមព្រះបាទទុកក្នុង

ទីនោះហើយ ស្តេចយាងទៅកាន់ទីដទៃ ។ ពិតណាស់ ចេតិយ គឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដក្នុងទីដែលព្រះអង្គទ្រង់អធិដ្ឋានហើយជាន់ប៉ុណ្ណោះ, រមែងមិនប្រាកដក្នុងទីដទៃ, មួយវិញទៀត ចេតិយគឺស្នាមព្រះបាទ ជាវត្ថុដែលទ្រង់អធិដ្ឋានទុកដើម្បីប្រយោជន៍ដល់ជនទាំងឡាយណា, ជនទាំងឡាយនោះប៉ុណ្ណោះ រមែង



ឃើញចេតិយ គឺស្នាមព្រះបាទនោះ, ក៏សត្វមានដំរីជាដើមជាន់ក៏ដោយ, មហាមេឃ ( ភ្លៀងធំ ) បង្អុរចុះក៏ដោយ, ខ្យល់កំបុតត្បូងប្រហារក៏ដោយ ដើម្បីនឹងឲ្យបុគ្គលទាំងនោះមើលមិនឃើញ, អ្វីមួយក៏មិនអាចនឹងលុបលាងនូវចេតិយ គឺស្នាមព្រះបាទបានឡើយ ។ គ្រានោះ នាងព្រាហ្មណីពោលទៅកាន់ព្រាហ្មណ៍ថា “បុរសនោះនៅទីណា” ? ព្រាហ្មណ៍គិតថា យើងបានពោលនឹងគេថា “លោកចូរឈរនៅទីនេះសិន, គេទៅកាន់ទីណាហ្ន៎ ” ? រកមើលក៏ឃើញចេតិយ គឺស្នាមព្រះបាទក៏ពោលថា “នេះជាស្នាមជើងរបស់គេ” នាងព្រាហ្មណីរាយលក្ខណមន្ត ហើយពិចារណាមើលលក្ខណៈនៃស្នាមព្រះបាទ

ព្រោះភាពជាអ្នកស្ទាត់ជំនាញក្នុងវេទទាំង ៣ ព្រមទាំងមន្តសម្រាប់ទាយលក្ខណៈ ហើយពោលថា "បពិត្រព្រាហ្មណ៍ នេះមិនមែនស្នាមជើងរបស់បុគ្គលអ្នកមានប្រក្រតីបរិភោគកាមគុណ ៥ ទេ" ហើយក៏ពោលគាថាដូច្នេះថា ៖

( ក៏បុគ្គលជារាគចរិត រមែងមានស្នាមជើងប្រហោង

អប្បមាទវគ្គវណ្ណនា រឿងព្រះនាងសាមាវតី - ១០០ -

(ផត) ត្រង់កណ្ដាល, បុគ្គលជាទោសចរិត រមែងមានស្នាមជើងគឺកែងតាមបៀតបៀន (ធ្ងន់មុខ, ចុចចុងម្រាម) បុគ្គលជាមោហចរិត រមែងមានស្នាមជើងគឺកែងទាញចុះ ( ធ្ងន់កែង ), បុគ្គលដែលមានកិលេសដូចជាដំបូលរបើកហើយ រមែងមានស្នាមជើងដូច្នេះ ។

គ្រានោះ ព្រាហ្មណ៍ពោលទៅកាន់ព្រាហ្មណីថា "ម្នាលនាងដ៏ចម្រើន នាងមានប្រក្រតីឃើញមន្ត ដូចជាការឃើញក្រពើក្នុងពាងទឹក និងដូចជាការឃើញចោរដែលនៅក្នុងផ្ទះ, នាងចូរស្ងៀមទៅ" ។ នាងព្រាហ្មណីពោលថា "បពិត្រព្រាហ្មណ៍ លោកប្រាថ្នាដើម្បីនឹងពោល

នូវពាក្យឯណា ចូរពោលនូវពាក្យនោះចុះ, ប៉ុន្តែស្នាមជើងនេះមិនមែន ជាស្នាមជើងរបស់បុគ្គលអ្នកបរិភោគកាមគុណ ៥ ទេ" ។ ព្រាហ្មណ៍ រកមើលខាងនេះខាងនោះ ឃើញព្រះសាស្តាហើយពោលថា "នេះ គឺបុរសនោះ" ក៏ដើរចូលទៅរកហើយពោលដូច្នេះថា "បពិត្រសមណៈ ខ្ញុំឲ្យធីតារបស់ខ្ញុំដល់លោក ដើម្បីប្រយោជន៍ដល់ការចិញ្ចឹមរក្សាគ្នា"

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ១០១ -

ព្រះសាស្តាមិនត្រាស់ថា តថាគតត្រូវការធីតារបស់អ្នក ឬក៏មិនត្រូវ ការអ្វីទាំងអស់" ទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍ តថាគតនឹងត្រាស់ ប្រាប់នូវរឿងមួយដល់អ្នក" កាលព្រាហ្មណ៍ពោលថា "បពិត្រសមណៈ សូមប្រាប់មកចុះ" ទើបត្រាស់ប្រាប់នូវភាវៈនៃព្រះអង្គដែលត្រូវមារ ជាប់តាមចាប់ តាំងអំពីកាលដែលព្រះអង្គចេញបួស រហូតដល់គល់ ដើមអជបាលនិគ្រោធ និងការលួងលោមដែលធីតារបស់មារទាំង ឡាយ អ្នកមកដើម្បីរម្ងាប់នូវសេចក្តីសោករបស់មារនោះ អ្នករពេល រាលព្រោះសេចក្តីសោកថា ឥឡូវនេះ ព្រះសមណគោតមនេះកន្លង បង់នូវវិស័យរបស់យើងហើយ" ប្រកបហើយដោយអំណាចនៃភេទ

មានភេទជានាងកុមារិកាជាដើម កាលដល់ដើមអជបាលនិគ្រោធហើយ ទ្រង់ត្រាស់ព្រះគាថាដូច្នេះថា ៖

“សេចក្ដីប្រាថ្នាក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគា ( ដែលជាធីតារបស់មារ ) ម្ល៉ោះទៅហើយ ធ្វើម្ដេចឡើយតថាគតនឹង

អប្បមាទវគ្គវណ្ណនា រឿងព្រះនាងសាមាវតី - ១០២ -

មានសេចក្ដីប្រាថ្នាក្នុងមេថុន ព្រោះឃើញរូបរបស់ទារិកា ( នៃអ្នក ) ដែលពោរពេញដោយមូត្រ និងករីសនេះ តថាគតមិនប្រាថ្នាដើម្បីនឹងប៉ះពាល់នូវធីតារបស់អ្នកនោះ សូម្បីតែដោយជើង” ។

ក្នុងទីបំផុតនៃគាថា ព្រាហ្មណ៍ និងព្រាហ្មណីក៏តាំងនៅក្នុងអនាគាមិផល ចំណែកនាងមាគន្ទិយាធីតា ចងគំនុំនឹងព្រះសាស្ដាថា “ប្រសិនបើព្រះសមណៈនោះមិនត្រូវការយើង, ក៏គួរពោល ថាតថាគតមិនត្រូវការ , ប៉ុន្តែសមណៈនេះ ( ត្រឡប់ ) ធ្វើយើងឲ្យជាអ្នកពេញទៅដោយមូត្រ និងករីស, ណ្ហើយចុះ រឿងហ្នឹងលើកទុក

សិនចុះ, យើងអាស្រ័យការដល់ព្រមដោយជាតិ, ត្រកូល, ប្រទេស, គោត្រ, យស និងវ័យ បានកស្ដាំបែបនោះហើយ នឹងដឹងអំពើដែលយើងគួរធ្វើចំពោះសមណគោតម” ។

សួរថា “ក៏ព្រះសាស្ដា ទ្រង់ជ្រាបនូវការកើតឡើងនៃអាឃាតក្នុងព្រះអង្គរបស់នាង ឬក៏មិនទ្រង់ជ្រាប” ?



ឆ្លើយថា “ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ជ្រាបច្បាស់ណាស់ ។

សួរថា “កាលបើព្រះអង្គទ្រង់ជ្រាបដូចោះ ហេតុអ្វីទើបទ្រង់ត្រាស់ព្រះគាថានេះ ” ?

ឆ្លើយថា “ព្រះអង្គទ្រង់ត្រាស់ព្រះគាថានេះ ដោយអំណាចនៃព្រាហ្មណ៍ និងព្រាហ្មណីទាំងពីរនាក់ប៉ុណ្ណោះ” ។

ធម្មតា ព្រះពុទ្ធទាំងឡាយមិនទ្រង់អើពើដល់អាឃាតទេ រមែងទ្រង់សម្ដែងធម៌ដោយអំណាចនៃបុគ្គលអ្នកគួរដល់ការសម្រេចមគ្គផលប៉ុណ្ណោះ ។ ព្រាហ្មណ៍ និងព្រាហ្មណីនាំនាងមាគន្ទិយានោះទៅ

ផ្ញើនឹងនាយចូឡមាគន្ទិយៈដែលជាប្អូន ហើយទៅកាន់សំណាក់របស់ព្រះសាស្តា ទាំងពីរនាក់បួសហើយ ក៏បានសម្រេចព្រះអរហត្តផល ។

ចំណែកនាយចូឡមាគន្ទិយៈគិតដូច្នេះថា “ធីតារបស់យើងមិននឹងបុគ្គលថោកទាបទេ, សមគួរដល់ព្រះរាជាតែមួយព្រះអង្គប៉ុណ្ណោះ ទើបនាំនាងទៅកាន់ក្រុងកោសម្ពី តាក់តែងដោយគ្រឿងអលង្ការទាំងពួងហើយ ថ្វាយចំពោះព្រះបាទឧទេនដោយពាក្យថា



“ស្រីរត្ននេះជារបស់សមគួរដល់មហាបពិត្រ” ព្រះបាទឧទេនគ្រាន់តែទ្រង់ទតឃើញព្រះនាងមាគន្ទិយានោះភ្លាម ក៏ទ្រង់កើតសេចក្តីស្នេហាដ៏មានកម្លាំងភ្លាមដែរ ទើបទ្រង់ប្រទាននូវការអភិសេក ទ្រង់ធ្វើនូវមាតុគ្រាម ៥០០ ឲ្យជាបរិវារនាងមាគន្ទិយានោះ ទ្រង់តាំងទុកក្នុងតំណែងអគ្គមហេសី ។

( នេះរឿងរបស់មាគន្ទិយា )

ព្រះបាទឧទេននោះ មានអគ្គមហេសី ៣ ដែលមានស្ត្រី ១៥០០ នាក់ ជាបរិវារ ដោយប្រការដូច្នេះឯង ។

# សេដ្ឋី ៣ នាក់ និង តាបស

ក៏ក្នុងសម័យនោះឯង ក្រុងកោសម្ពី មានសេដ្ឋី ៣ នាក់ គឺ ឃោសកសេដ្ឋី ១ កុក្កុដសេដ្ឋី ១ បវារិកសេដ្ឋី ១, សេដ្ឋីទាំង ៣ នាក់ នោះ កាលវស្សូបនាយិកាជិតចូលមកដល់ហើយ,ឃើញតាបស៥០០ មកអំពីព្រៃហិមពានកំពុងត្រាច់ទៅដើម្បីភិក្ខាក្នុងព្រះនគរ ក៏ជ្រះថ្លា



និមន្តឲ្យគង់ ឲ្យឆាន់ហើយ អារាធនាតាបសទាំងនោះឲ្យស្នាក់នៅក្នុង សំណាក់របស់ខ្លួនរហូតអស់ ៤ ខែ ញុំាងតាបសទាំងនោះឲ្យប្ដេជ្ញា ដើម្បីប្រយោជន៍ដល់ការមកទៀតក្នុងកាល ដែលភូមិភាគជោគជាំ ដោយទឹកភ្លៀង ( រដូវភ្លៀង ) ហើយបញ្ជូនតាបសទាំងនោះទៅកាន់ ព្រៃហិមពានវិញ ចាប់តាំងពីកាលនោះមក តាបសទាំងនោះនៅក្នុង ហិមពាន្តអស់ ៨ ខែ នៅក្នុងសំណាក់របស់សេដ្ឋីទាំង ៣ នោះ ៤ ខែ ។ តាបសទាំងនោះ កាលមកអំពីព្រៃហិមពាន្តក្នុងវេលាដទៃ ឃើញដើម ជ្រៃមួយដើមធំក្នុងទីជិតព្រៃ ( ជាយព្រៃ ) ក៏គង់ក្បែរគល់ជ្រៃនោះ ។

បណ្ដាតាបសទាំងនោះ តាបសដែលជាប្រធានគិតដូច្នេះថា "ទេវតាដែលអាស្រ័យនៅនាដើមឈើនេះ មិនមែនជាទេវតាតូចទាបទេ ដោយពិត ជាទេវរាជអ្នកមានសក្តិធំ គប្បីមាននៅនាដើមឈើនេះ, ប្រសិនបើទេវរាជនេះគប្បីឲ្យនូវទឹកផឹកដល់ពួកឥសី មិនដឹងថាជាការល្អយ៉ាងណាទៅទេ" ទេវរាជនោះក៏បានថ្វាយទឹកផឹកដល់ពួកឥសីទាំងនោះ តាបសទាំងនោះក៏គិតរកនូវទឹកសម្រាប់ស្រង់ ។ ទេវរាជក៏បានប្រគេន ទឹកសម្រាប់ស្រង់ដល់តាបសទាំងនោះទៀត ។ លំដាប់នោះតាបស ដែលជាប្រធានក៏គិតដល់ភោជន ទេវរាជក៏បានឲ្យភោជនលំដាប់ នោះ តាបសនោះបានមានតម្រិះដូច្នេះថា "ទេវរាជនេះរមែងឲ្យនូវ គ្រប់វត្ថុដែលយើងគិតហើយៗ" ឱហ្ន៎ ! យើងគប្បីឃើញទេវរាជ នោះ" ទេរាជនោះក៏ទម្លាយដើមឈើសម្ដែងខ្លួនដល់តាបសទាំងនោះ ។ គ្រានោះ តាបសទាំងនោះសួរទេវរាជនោះថា "បពិត្រទេវរាជ អ្នក មានសម្បត្តិធំ សម្បត្តិនេះអ្នកបានហើយ ដោយអាស្រ័យកម្មអ្វី ? កាលពីមុនអ្នកបានធ្វើកម្មអ្វីទុក ? ទើបអ្នកបានសម្បត្តិបែបនេះ ។

ទេវរាជ. បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយ កុំសាកសួរខ្ញុំម្ចាស់ធ្វើអី ។

តាបស. បពិត្រទេវរាជ សូមអ្នកប្រាប់មកចុះ ។

ទេវរាជនោះអៀនខ្មាស មិនហ៊ានពោលប្រាប់ ព្រោះកម្មដែលខ្លួនធ្វើហើយនោះ ជាកម្មបន្តិចបន្តួច ប៉ុន្តែ កាលត្រូវតាបសទាំងនោះជម្រិតសួររឿយ ៗ ក៏ពោលថា "បើដូច្នោះ សូមលោកម្ចាស់ទាំង-ឡាយចូរស្តាប់ចុះ" ដូច្នេះហើយ ទើបប្រាប់ ។

## ប្រវត្តិរបស់ទេវតា

បានឮមកថា ទេវរាជនោះជាមនុស្សទុគ៌តម្នាក់ ស្វែងរកការ-ងារធ្វើដើម្បីចិញ្ចឹមជីវិត បានការងារធ្វើក្នុងសំណាក់អនាថបិណ្ឌិក-សេដ្ឋី ក៏អាស្រ័យការងារនោះចិញ្ចឹមជីវិត ។ ខាងក្រោយមក កាលដល់ថ្ងៃឧបោសថមួយ អនាថបិណ្ឌិកសេដ្ឋីមកអំពីវិហារហើយ សួរថា "ថ្ងៃនេះ មានអ្នកណាៗ បានប្រាប់បុរសដែលជាអ្នកធ្វើការស៊ីឈ្នួលនោះថា ថ្ងៃនេះជាថ្ងៃឧបោសថដែរឬ ? មនុស្សដែលនៅក្នុងផ្ទះនោះឆ្លើយប្រាប់ថា "បពិត្រលោកម្ចាស់ មិនទាន់មាននរណាមួយបានប្រាប់

ទេ” អនាថបិណ្ឌិកពោល ក៏ដូច្នេះថា “បើដូច្នោះ ពួកឯងចូរចំអិនអាហារល្ងាចទុកសម្រាប់គេចុះ” ។ គ្រានោះ ជនទាំងនោះក៏ដាំបាយដោយ អង្ករ ១ កំប៉ុងទុកដើម្បីបុរសអ្នកធ្វើការឈ្នួលនោះ ។ បុរសនោះធ្វើ ការងារក្នុងព្រៃរហូតអស់វេលាថ្ងៃ មកផ្ទះវិញក្នុងវេលាល្ងាចកាល គេជូសបាយឲ្យ ក៏មិនទាន់បរិភោគភ្លាមទេ ដោយគិតថា “យើងជាអ្នក ឃ្លានហើយ” គិតថា “ក្នុងថ្ងៃមុនៗ ភាពជ្រួលជ្រើមធំរមែងមានក្នុង ផ្ទះនេះថា សូមលោកឲ្យបាយ ឲ្យសម្ល ឲ្យម្ហូប, ក្នុងថ្ងៃនេះ



ជនដ៏សេស ជាអ្នកមានសំឡេងស្ងប់ស្ងៀមដេកហើយ,នាំគ្នាជូសអាហារទុកសំរាប់អញតែម្នាក់ឯងប៉ុណ្ណោះ, ហេតុនេះតើដូចម្តេចទៅហ្ន៎ ? ទើបសួរថា “អ្នកទាំងឡាយបរិភោគហើយឬ” ? ជនទាំងនោះ ឆ្លើយថា “ម្នាលអ្នក ដ៏ចំរើន ថ្ងៃនេះគេមិនបរិភោគទេ” ។

អ្នកធ្វើការឈ្នួល. ព្រោះហេតុអ្វី ?

ជនទាំងឡាយ. ក្នុងផ្ទះនេះ គេមិនចំអិនអាហារពេលល្ងាចក្នុងថ្ងៃឧបោសថទាំងឡាយទេ ។ ព្រោះមនុស្សគ្រប់គ្នា គេជាអ្នករក្សាឧបោសថ, ដោយហោចទៅ សូម្បីទារកដែលនៅបៅដោះជាប្រក្រតី មហាសេដ្ឋីក៏ឲ្យទារកនោះខ្ពុរមាត់ហើយ ប្រើបម្រើឲ្យដាក់វត្ថុមានរសផ្អែម ៤ មុខ ទៅក្នុងមាត់ ធ្វើឲ្យជាអ្នករក្សាឧបោសថ, កាលប្រទីបដែលបុគ្គលអុជហើយដោយប្រេងមានក្លិនក្រអូប បំភ្លឺទារកតូចធំទាំង-ឡាយទៅកាន់ទីដេកហើយ រមែងស្វាធ្យាយអាការ ៣២ ប្រការ, ប៉ុន្តែថា ពួកយើងមិនបានធ្វើសតិទុកដើម្បីនឹងប្រាប់ប្រាប់អ្នកឯងថាថ្ងៃនេះជាវថ្ងៃឧបោសថ ព្រោះហេតុនោះ ទើបពួកយើងដាំបាយទុកដើម្បីអ្នកតែម្នាក់ឯងអ្នក



ឯងចូរទទួលអាហារនោះចុះ ។

បុរសអ្នកធ្វើការឈ្នួល. ប្រសិនបើខ្ញុំរក្សាឧបោសថក្នុងកាលឥឡូវនេះ រមែងសមគួរសោត សូម្បីខ្ញុំក៏រក្សាឧបោសថដែរ ។

ជនទាំងឡាយ. សេដ្ឋីរមែងជ្រាបនូវកិច្ចនេះ ។

បុរសអ្នកធ្វើការឈ្នួល. បើដូច្នោះ សូមពួកលោកសួរសេដ្ឋី នោះឲ្យខ្ញុំផង ។

ជនទាំងនោះ ទៅសួរសេដ្ឋី សេដ្ឋីក៏ពោលយ៉ាងនេះថា “បុរស នោះមិនបរិភោគក្នុងកាលឥឡូវនេះ ខ្ពុរមាត់ហើយ អធិដ្ឋានអង្គឧបោ-សថទាំងឡាយនឹងបានឧបោសថកម្មពាក់កណ្ដាល” ។ ចំណែកបុរស អ្នកធ្វើការឈ្នួលស្ដាប់ពាក្យនោះហើយ បានធ្វើហើយដោយប្រការ ដូច្នោះ ។ កាលគេស្រេកឃ្លានព្រោះការងាររហូតអស់វេលាថ្ងៃ ខ្យល់ ក៏កម្រើកឡើងហើយក្នុងសរីរៈ, គេយកខ្សែចងពោះ ចាប់ត្រង់ចុងខ្សែ បម្រះនទៀលទៅមក ។ សេដ្ឋីឮព្រឹត្តិហេតុដូច្នោះ មានអ្នកកាន់គប់ ភ្លើង ប្រើបម្រើឲ្យយកវត្ថុមានរសផ្អែម ៤ មុខ មកកាន់សំណាក់របស់



នោះ ហើយសួរថា “ម្នាលអ្នកដ៏ចម្រើន អ្នកកើតអ្វី” ?

បុរសអ្នកធ្វើការឈ្នួល. បពិត្រលោកម្ចាស់ ខ្យល់កម្រើក ឡើងដល់ខ្ញុំ។

សេដ្ឋី. បើដូច្នោះ ឯងចូរក្រោកឡើង ផឹកនូវភេសជ្ជៈនេះចុះ ។ បុរសអ្នកធ្វើការឈ្នួលសួរថា បពិត្រលោកម្ចាស់ ជនទាំងឡាយគេទទួលទានហើយឬ ?

សេដ្ឋី. សេចក្តីមិនសប្បាយ ( ឥតជម្ងឺ ) របស់ពួកយើងមិនមាន ឯងចូរផឹកចុះ ។ បុរសនោះពោលថា "បពិត្រលោកម្ចាស់ ខ្ញុំកាលរក្សាឧបោសថ មិនបានដើម្បីនឹងរក្សាឧបោសថកម្មទាំងអស់បាន, សូមឲ្យឧបោសថកម្មពាក់កណ្តាលរបស់ខ្ញុំ កុំបានជារបស់ខ្វះខាតឡើយ" ដូច្នេះហើយ ក៏មិនព្រមផឹកនូវភេសជ្ជៈនោះ ។ បុរសនោះសូម្បីសេដ្ឋីពោលថា "ម្នាលអ្នកដ៏ចម្រើន អ្នកកុំធ្វើយ៉ាងនេះឡើយ" ក៏នៅតែមិនព្រមផឹក, កាលអរុណរះឡើង ក៏ធ្វើកាលកិរិយាទៅ ដូចផ្កាឈើដែលស្វិតដូច្នោះ កើតជាទេវតានៅនាដើមជ្រៃនោះ ។ ព្រោះហេតុ



នោះ ទេវតានោះ លុះពោលសេចក្តីនេះហើយ ក៏ពោលដូច្នេះថា "សេដ្ឋីនោះជាអ្នករាប់អានព្រះពុទ្ធថា ជារបស់យើង រាប់អានព្រះធម៌

ថាជារបស់យើង រាប់អានព្រះសង្ឃថាជារបស់យើង, សម្បត្តិនោះខ្ញុំបានហើយដោយផល ដែលហូរចេញអំពីឧបោសថកម្មកម្មពាក់កណ្តាលដែលខ្ញុំអាស្រ័យសេដ្ឋីនោះធ្វើហើយ ។

## តាបសជ្រះថ្លាចេញបួស

តាបស ៥០០ នោះ គ្រាន់តែឮពាក្យថា “ព្រះពុទ្ធ” ក៏ក្រោកឡើងផ្គងអញ្ជលីចំពោះទេវតា ពោលថា “លោកនិយាយថា ព្រះពុទ្ធដូច្នេះឬ” ដូច្នេះហើយ ក៏ញុំាងទេវតានោះឲ្យប្តេជ្ញា ៣ ដងថា “ខ្ញុំនិយាយថា ព្រះពុទ្ធមែន” ហើយបន្លឺឡើងនូវឧទានថា “ក៏សំឡេងគឹកកងបែបហ្នឹងឯង គឺបុគ្គលរកបានដោយកម្រក្នុងលោក” ហើយពោលថា “បពិត្រទេវតា ពួកយើងជាអ្នកដែលលោកឲ្យបានស្តាប់សំឡេងដែលមិនធ្លាប់បានឮមកហើយក្នុងសែនកប្បជាអនេក”។ គ្រានោះ ពួកតាបសដែលជាអន្តេវាសិកបានពោលពាក្យនេះនឹងអាចារ្យថា “បើ



ដូច្នោះ ពួកយើងចូរនាំគ្នាទៅកាន់សំណាក់របស់ព្រះសាស្តាទៅ” អាចារ្យពោលថា “ម្នាលអ្នកទាំងឡាយ សេដ្ឋី ៣ រូប ជាអ្នកមាន

ឧបការៈច្រើនដល់យើង ថ្ងៃស្អែកនេះ ពួកយើងទទួលភិក្ខាក្នុងលំនៅរបស់ សេដ្ឋីទាំងនោះ ប្រាប់សេដ្ឋីទាំងនោះហើយ សឹមទៅ, ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរបង្អង់សិនចុះ" តាបសទាំងនោះក៏បង្អង់ចាំតាម ពាក្យរបស់អាចារ្យ ។ ថ្ងៃស្អែកឡើង សេដ្ឋីទាំង ៣ រូបនោះ ត្រៀម យាគូ និងភត្តហើយ ក្រាលអាសនៈទុក ដឹងថា "ថ្ងៃនេះ លោកម្ចាស់ ដ៏ចម្រើនទាំងឡាយរបស់យើងមក" ធ្វើការក្រោកទទួលតាបសទាំង នោះហើយនាំទៅកាន់លំនៅ និមន្តឲ្យគង់បានប្រគេនភិក្ខា ។ តាបស ទាំងនោះធ្វើភត្តកិច្ចរួចស្រេចហើយពោលថា "បពិត្រមហាសេដ្ឋី ទាំងឡាយ ពួកយើងនឹងទៅ" ។

សេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើនទាំងឡាយ លោកម្ចាស់ទាំងឡាយបានប្តេជ្ញាជាមួយនឹងខ្ញុំម្ចាស់ទាំងឡាយថា នឹងនៅទីនេះរហូត ៤ ខែ ក្នុងរដូវភ្លៀងនេះមិនមែនឬ ? ឥឡូវនេះ លោកម្ចាស់



ទាំងឡាយនឹងទៅទីណា ?

តាបស. ព្រះពុទ្ធកើតឡើងហើយក្នុងលោក, ព្រះធម៌កើតឡើងហើយ, ព្រះសង្ឃកើតឡើងហើយក្នុងលោក, ព្រោះហេតុនោះ យើងទាំងឡាយនឹងទៅកាន់សំណាក់ព្រះសាស្តា ។

សេដ្ឋី. ក៏ការទៅសំណាក់ព្រះសាស្តាអង្គនោះ គួរចំពោះតែលោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ ?

តាបស. ម្នាលអ្នកមានអាយុ សូម្បីជនពួកដទៃក៏គួរ, មិនហាមឃាត់ទេ ។

សេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយរង់ចាំសិន ពួកខ្ញុំម្ចាស់ ត្រៀមរៀបចំហើយ នឹងទៅដែរ ។

តាបសទាំងនោះពោលថា "កាលអ្នកទាំងឡាយធ្វើការត្រៀមរៀបចំ ដំណើរយឺតយូរមែនមានដល់ពួកយើង, ពួកយើងនឹងទៅមុនអ្នកទាំងឡាយគប្បីមកតាមក្រោយចុះ" ដូច្នេះហើយក៏ទៅមុនចូលទៅ



គាល់ព្រះសម្មាសម្ពុទ្ធ ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ។

គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់តាបសទាំងនោះ ។ ក្នុងទីបំផុតនៃទេសនា តាបសទាំង ៥០០ នោះបានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ទូលសូមបព្វជ្ជា បានជាអ្នកទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ហាក់ដូចជាព្រះថេរៈមានវស្សា ១០០ ក្នុងលំដាប់នៃព្រះតម្រាស់ដែលព្រះអង្គត្រាស់ថា “អ្នកទាំងឡាយ ចូរជាភិក្ខុចុះ” ។

## សេដ្ឋី ៣ នាក់ កសាងវិហារ

សេដ្ឋីទាំង ៣ រូបនោះ ចាត់ចែងរទេះម្នាក់ៗ ៥០០ ផ្ទុកគ្រឿងឧបករណ៍នៃទាន មានសំពត់ គ្រឿងស្លៀកដណ្តប់ ទឹកដោះថ្លា ទឹកឃ្មុំ និងទឹកអំពៅជាដើម ទៅដល់ក្រុងសាវត្ថីហើយ ចូលទៅកាន់វត្តជេត-ពន ថ្វាយបង្គំព្រះសាស្តា ស្តាប់នូវធម្មកថាហើយ ក្នុងទីបំផុតនៃធម្ម-កថា ក៏តាំងនៅក្នុងសោតាបត្តិផល ថ្វាយទានក្នុងសំណាក់ព្រះ



សាស្តាអស់កន្លះខែហើយ ទូលអារាធនាព្រះសាស្តា ដើម្បីប្រយោជន៍ដល់កិរិយាស្តេចយាងទៅកាន់ក្រុងកោសម្ពី, ព្រះសម្មាសម្ពុទ្ធកាលនឹង

ទ្រង់ប្រទាននូវការប្តេជ្ញា ក៏បានត្រាស់ថា “ម្នាលគហបតីទាំងឡាយ ព្រះតថាគតទាំងឡាយ រមែងត្រេកអរយ៉ាងក្រៃលែងក្នុងផ្ទះស្ងាត់” ទើបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនុ៎ះ ពួកខ្ញុំព្រះអង្គជ្រាបច្បាស់ហើយ ការដែលស្តេចយាងទៅតាមសាសន៍ដែលពួកខ្ញុំព្រះអង្គបញ្ជូនមក រមែងគួរ ។ ដូច្នេះហើយ ទៅកាន់ក្រុងកោសម្ពី បញ្ជាឲ្យជាងសាងមហាវិហារ ៣ គឺ ឃោសកសេដ្ឋី ឲ្យសាងឃោសិតារាម, កុក្កុដសេដ្ឋី ឲ្យសាងកុក្កុដារាម, បាវារិកសេដ្ឋី ឲ្យសាងបាវារិការាម, ហើយបញ្ជូនទៅដើម្បីប្រយោជន៍ដល់ការដែលស្តេចយាងមក នៃព្រះសាស្តា ។

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវដំណឹងរបស់សេដ្ឋីទាំងនោះ ក៏បានយាងទៅកាន់ទីនោះ ។ សេដ្ឋីទាំងនោះក្រោកទទួល អារាធនានិមន្តព្រះសាស្តាឲ្យស្តេចចូលទៅខាងក្នុងវិហារហើយ ប្រគល់ថ្វាយ



៣ ជងថា “ខ្ញុំព្រះអង្គសូមថ្វាយវិហារនេះចំពោះភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ដែលមានព្រះពុទ្ធជាប្រធាន” ដូច្នេះហើយ រមែងប្រតិបត្តិ តាមវេនៗ ។ ព្រះសាស្តារមែងគង់នៅក្នុងវិហារមួយៗ

មួយថ្ងៃ, ទ្រង់គង់នៅក្នុងវិហាររបស់សេដ្ឋីណា ក៏រមែងត្រាច់ទៅដើម្បីបិណ្ឌបាតទៀបទ្វារផ្ទះសេដ្ឋីនោះឯង ។

## នាយសុមនមាលាការអង្គាសភិក្ខុសង្ឃ

ក៏សេដ្ឋីទាំង ៣ នាក់នោះ មាននាយមាលាការឈ្មោះសុមនៈ ជាអ្នកឧបដ្ឋាក ។ នាយសុមនមាលាការនោះ ពោលនឹងសេដ្ឋីទាំងនោះយ៉ាងនេះថា "ខ្ញុំបាទជាអ្នកធ្វើការបម្រើលោកទាំងឡាយរហូតអស់កាលយូរ, ជាអ្នកប្រាថ្នានឹងញុំាងព្រះសាស្តាឲ្យសោយ សូមលោកទាំងឡាយ ចូរឲ្យព្រះសាស្តាដល់ខ្ញុំមួយថ្ងៃ" ។

សេដ្ឋីទាំង ៣ នាក់នោះពោលថា "ម្នាលនាយ បើដូច្នោះ អ្នកចូរនិមន្តព្រះសាស្តាឲ្យសោយក្នុងថ្ងៃស្អែកនេះចុះ" ។ នាយសុមនមាលាការនោះទទួលពាក្យថា "ល្អហើយ នាយ" ដូច្នេះ ទើប



និមន្តព្រះសាស្តា ត្រៀមគ្រឿងសក្ការៈ ។ ក្នុងកាលនោះ ព្រះរាជាព្រះរាជទាន ៨ កហាបណៈ ឲ្យជាតម្លៃផ្កាដល់នាងសាមាវតីរាល់ៗ ថ្ងៃ ។ ទាសីរបស់នាងសាមាវតីនោះ ឈ្មោះនាងខុជ្ជុត្តរា ទៅកាន់សំណាក់សុមនមាលាការ ទទួលយកផ្កាទាំងឡាយជានិច្ច ។ ខាងក្រោយមក

នៅថ្ងៃមួយ នាយមាលាការពោលនឹងនាងខុជ្ជុត្តរាដែលជាអ្នកមកក្នុងថ្ងៃនោះថា "ម្នាលនាងខុជ្ជុតរាខ្ញុំនិមន្តព្រះសាស្តាទុកហើយ, ថ្ងៃនេះខ្ញុំនឹងបូជាព្រះ សាស្តាដោយផ្កាដ៏ប្រសើរ, នាងចូររង់ចាំស្តាប់ព្រះធម៌សិនហើយ សឹម ទទួលយកផ្កាទៅចុះ" ។ នាងខុជ្ជុត្តរាទទួលថា "បាន" ។

នាយសុមនៈអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានទទួលបាត្រដើម្បីប្រយោជន៍ដល់ការធ្វើអនុមោទនា ។ ព្រះអង្គទ្រង់ប្រារព្ធធម្មទេសនាជាគ្រឿងអនុមោទនា ។ ចំណែកនាងខុជ្ជុត្តរាស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃមុនៗ នាងកាន់យកកហាបណៈ ៤ កហាបណៈទុកសម្រាប់ខ្លួនទិញផ្កាតែ ៤ កហាបណៈប៉ុណ្ណោះ ។ ក្នុងថ្ងៃនោះ នាងទិញផ្កាទាំង ៨



កហាបណៈ ។

គ្រានោះ នាងសាមាវតី ពោលនឹងនាងខុជ្ជុត្តរានោះថា "ម្នាលនាងដ៏ចម្រើន ព្រះរាជាព្រះរាជទានតម្លៃផ្កាដល់យើងជាទ្វេរគុណឬ" ?

នាងខុជ្ជុត្តរា. បពិត្រព្រះនាងម្ចាស់ មិនមែនទេ ។

សាមាវតី. កាលបើដូច្នេះ ព្រោះហេតុអ្វី បានជាផ្កាច្រើនម៉្លេះ ?

ខុជ្ជុត្តរា. ក្នុងថ្ងៃមុនៗ ខ្ញុំកាន់យក ៤ កហាបណៈ ទុកសំរាប់ខ្លួន ទិញផ្កាតែ ៤ កហាបណៈប៉ុណ្ណោះ ។

សាមាវតី. ព្រោះហេតុអ្វី ក្នុងថ្ងៃនេះ ទើបនាងមិនកាន់យក ?

ខុជ្ជុត្តរា. ព្រោះខ្ញុំស្តាប់ធម្មកថារបស់ព្រះសម្មាសម្ពុទ្ធហើយ សម្រេចធម៌ ។

គ្រានោះ នាងសាមាវតីមិនបានគម្រាមនាងខុជ្ជុត្តរានោះថា "នែមេទាសីកំណាច ហាងឯងចូរឲ្យកហាបណៈ ដែលហាងឯងកាន់យកហើយអស់កាលមានប្រមាណប៉ុណ្ណោះដល់អញវិញ" ត្រឡប់ជាឲ្យពោល ថា "ម្នាលនាងដ៏ចម្រើន នាងចូរញុំាំងយើងទាំងឡាយឲ្យផឹកនូវទឹកអម្រឹត



ដែលនាងបានផឹកហើយផង," កាលនាងខុជ្ជុត្តរាពោលថា "បើដូច្នោះសូម ព្រះនាងម្ចាស់ញុំាំងនាងខ្ញុំឲ្យងូតទឹក" ក៏ឲ្យនាងងូតទឹកដោយទឹកក្រអូប ១៦ ក្អមហើយ បញ្ជាឲ្យប្រទានសំពត់សាដកសាច់មដ្ឋពីរផ្ទាំង

។ នាង ខុជ្ជុត្តរានោះ ស្លៀកមួយផ្ទាំង ដណ្តប់មួយផ្ទាំង ប្រើគេឲ្យក្រាល អាសនៈហើយ ឲ្យនាំផ្ចិតមួយមកអង្គុយលើអាសនៈចាប់ផ្ចិតដ៏វិចិត្រ ហៅមាតុគ្រាម ៥០០ មកហើយ សម្តែងធម៌ដល់ស្រ្តីទាំងនោះ ដូចដែលព្រះសាស្តាទ្រង់សម្តែងហើយនោះឯង ។ ស្រ្តីទាំងអស់នោះ ស្តាប់ធម្មកថារបស់ខុជ្ជុត្តរាហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ស្រ្តីទាំងនោះថ្វាយបង្គំនាងខុជ្ជុត្តរាហើយ ពោលថា "ម្នាលនាងដ៏ចម្រើន ចាប់តាំងពីថ្ងៃនេះទៅ នាងកុំធ្វើការងារដ៏សៅហ្មងឡើយ, នាងចូរតាំងនៅក្នុងឋានៈជាមាតា និងអាចារ្យរបស់ពួកយើងទាំងឡាយ ទៅកាន់សំណាក់ព្រះសាស្តា ស្តាប់ធម៌ដែលព្រះសាស្តាទ្រង់សម្តែងហើយ ចូរសម្តែងប្រាប់ពួកយើងទាំងឡាយ" ។ នាងខុជ្ជុត្តរាក៏ធ្វើតាមពាក្យបញ្ជានោះ ក្រោយមក នាងក៏បានជាអ្នកទ្រទ្រង់ព្រះ ត្រៃបិដក ។

នាងខុជ្ជុត្តរាជាឯតទគ្គៈផ្នែកខាងសម្ដែងធម៌ គ្រានោះ ព្រះសាស្ដាទ្រង់តែងតាំងនាងខុជ្ជុត្តរានោះទុកក្នុងឯតទគ្គៈថា "ម្នាលភិក្ខុទាំងឡាយ នាងខុជ្ជុត្តរានេះ ជាអ្នកធ្វើមជាងបណ្ដាឧបាសិកាសាវិការបស់តថាគត ជាធម្មកថិកា "អ្នកសម្ដែងធម៌" ។ ស្ត្រីទាំង ៥០០ នោះ ពោលទៅកន់នាងខុជ្ជុត្តរានោះយ៉ាងនេះថា "ម្នាលនាងដ៏ចម្រើនពួកយើង ទាំងឡាយប្រាថ្នានឹងគាល់ព្រះសាស្ដា សូមនាងចូរសម្ដែងព្រះសាស្ដា ដល់យើងទាំងឡាយ, ពួកយើងនឹងបូជាព្រះសាស្ដាដោយសក្ការៈទាំង ឡាយ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម" ។

នាងខុជ្ជុត្តរា. បពិត្រព្រះនាងម្ចាស់ដ៏ចម្រើនទាំងឡាយ ដែលឈ្មោះថាព្រះរាជត្រកូល ជារបស់ធ្ងន់, នាងខ្ញុំមិនអាចដើម្បីនឹងនាំព្រះនាងទាំងឡាយទៅពួដ៏ខាងក្រៅបានទេ ។

ស្ត្រីទាំងឡាយ. ម្នាលនាងដ៏ចម្រើន នាងកុំញុំាងយើងទាំង-ឡាយឲ្យវិនាសឡើយ ។ សូមនាងចូរសម្ដែងព្រះសាស្ដាដល់យើង



ទាំងឡាយចុះ ។

នាងខុជ្ជុត្តរា. បើដូច្នោះ ការមើល ជាការដែលនាងអាចមើលបានតាមប្រហោងមានប្រមាណប៉ុណ្ណា, ចូរចោះប្រហោងមានប្រមាណប៉ុណ្ណោះ នាជញ្ជាំងបន្ទប់ដែលជាលំនៅរបស់ពួកព្រះនាងទាំងឡាយ ចូរបញ្ជាឲ្យគេនាំគ្រឿងក្រអូប និងកម្រងផ្កាជាដើមមក ហើយឈរនៅក្នុងទីនោះៗ ចូរក្រឡេកមើល ចូរលាតដៃទាំងពីរថ្វាយបង្គំ និងចូរបូជាព្រះសាស្តា ដែលស្តេចយាងទៅកាន់ផ្ទះសេដ្ឋីទាំង ៣ នោះចុះ ។

ស្ត្រីទាំងនោះ បានធ្វើហើយយ៉ាងនោះ ក្រឡេកមើលព្រះ-សាស្តាដែលយាងទៅ និងយាងមក ថ្វាយបង្គំ និងបូជាហើយ ។

## ប្រវត្តិបន្ទប

ថ្ងៃមួយ ព្រះនាងមាគន្ទិយា ចេញអំពីប្រាសាទរបស់ខ្លួនធ្វើដំណើរទៅកាន់លំនៅរបស់ស្ត្រីទាំងនោះ ឃើញប្រហោងជញ្ជាំងបន្ទប់ ទាំងឡាយ ក៏សួរថា “ប្រហោងអ្វីនេះ”? កាលស្ត្រីទាំងនោះ

មិនដឹងថានាងមាគន្ទិយានេះចងគំនុំនិងព្រះសាស្តា ក៏ឆ្លើយប្រាប់ថា "ព្រះ សាស្តាយាងមកកាន់នគរនេះ, ពួកយើងទាំងឡាយឈរនៅក្បែរប្រហោងនេះ ហើយថ្វាយបង្គំ និងបូជាព្រះសាស្តា" លុះបានស្តាប់ដូច្នេះហើយ ក៏គិតថា "ព្រះសមណគោតមមកកាន់នគរនេះហើយ, ឥឡូវនេះ យើងនឹងដឹង នូវអំពើដែលគួរធ្វើចំពោះសមណគោតម នេះ ចំណែកស្ត្រីទាំងនេះ ក៏ជា ឧបដ្ឋាយិការបស់ព្រះសមណគោតមនោះ, យើងនឹងដឹងនូវអំពើដែលគប្បីធ្វើសូម្បីដល់ស្ត្រីទាំងនេះ"ទើបទៅក្រាបទូលព្រះរាជាថា "បពិត្រមហារាជ ស្ត្រីទាំង ៥០០ រួមទាំងនាងសាមាវតីផងនោះ មានសេចក្តីប្រាថ្នាខាងក្រៅ, ស្ត្រីទាំងនោះនឹងប្រហារព្រះជន្មរបស់ព្រះអង្គដោយពីរបីថ្ងៃទៀតជាពិតប្រាកដ" ព្រះរាជាមិនទ្រង់ជឿដោយទ្រង់មានព្រះតម្រាស់ថា "ស្ត្រីទាំងនោះនឹងមិនធ្វើនូវអំពើបែបនេះទេ" ។ សូម្បីនាងមាគន្ទិយាក្រាបទូលទៀត ក៏នៅតែមិនព្រមជឿ ។

គ្រានោះ នាងមាគន្ទិយាក្រាបទូលព្រះរាជាអង្គនោះដោយពាក្យដែលខ្លួនធ្លាប់ក្រាបទូលអស់វារៈ ៣ ដង ព្រះរាជាមិនទ្រង់ជឿរ ក៏ក្រាបទូលថា

“ប្រសិនបើព្រះអង្គមិនទ្រង់ជឿ ( ពាក្យ ) ខ្ញុំម្ចាស់សោត សូមព្រះអង្គស្តេចយាងទៅកាន់លំនៅរបស់ស្ត្រីទាំងនោះ ហើយទ្រង់ពិនិត្យមើលចុះ” ។ ព្រះរាជាស្តេចយាងទៅទតឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ក៏ត្រាស់សួរថា “ប្រហោងអ្វីនេះ” ? កាលស្ត្រីទាំងនោះក្រាបទូលសេចក្តីនោះហើយ មិនទ្រង់ពិរោធនិងស្ត្រីទាំងនោះ មិនបានត្រាស់នូវអ្វីៗឡើយ, បញ្ជាឲ្យបិទប្រហោងទាំងឡាយហើយ ឲ្យធ្វើបង្អួចមានប្រហោងតូចៗ ក្នុងបន្ទប់ទាំងពួង ។ បានឮថា បង្អួចមានប្រហោងតូចៗ ទាំងឡាយ កើតឡើងហើយក្នុងកាលនោះ ។

ព្រះនាងមាគន្ទិយា មិនអាចនឹងធ្វើអ្វីៗ ស្ត្រីទាំងនោះ បានក៏គិតថា “យើងនឹងធ្វើនូវអំពើដែលគប្បីធ្វើ ចំពោះសមណៈឲ្យខានតែបាន” ទើបឲ្យកហាបណៈដល់អ្នកនគរហើយពោលថា “ពួកឯងព្រមទាំងពួកបុរសដែលជាខ្ញុំប្រុស និងកម្មករទាំងឡាយចូរជេរផ្តាសាព្រះសមណគោតម

ដែលជាអ្នកចូលទៅកាន់ព្រះនគរឲ្យចៀសចេញទៅ” ពួកមិច្ឆាទិដ្ឋិដែល ជាអ្នកមិនជ្រះថ្លាក្នុងរតនៈទាំង៣ ក៏ជាប់តាមព្រះសាស្តាដែល

យានចូលទៅកាន់ព្រះនគរ ជេរផ្ដាសាដោយវត្ថុសំរាប់ ជេរ ១០ យ៉ាងថា ៖

១. ឯងជាចោរ

២. ឯងជាបុគ្គលពាល

៣. ឯងជាមនុស្សច្កួត

៤. ឯងជាអូដ្ឋ

៥. ឯងជាគោ

៦. ឯងជាលា

៧. ឯងជាសត្វនរក

៨. ឯងជាសត្វតិរច្ឆាន

៩. សុគតិរបស់ឯងមិនមានទេ

១០. ឯងសង្ឃឹមបានតែទុគ្គតិម្យ៉ាងប៉ុណ្ណោះ ។

ព្រះអានន្ទបានឮពាក្យនោះហើយ បានក្រាបទូលពាក្យនេះ ចំពោះព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន អ្នកនគរទាំងនេះ

រមែងជេរ រមែងផ្ដាសាពួកយើងទាំងឡាយ, ពួកយើងនឹងទៅកាន់ទីដទៃអំពីទីនេះ" ។ ព្រះសាស្ដាត្រាស់សួរថា "ម្នាលអានន្ទ យើងនឹងទៅកាន់ទីណា" ។

ព្រះអានន្ទក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន យើងនឹងទៅកាន់នគរដទៃ" ។

ព្រះសាស្ដា. ម្នាលអានន្ទ កាលពួកមនុស្សក្នុងក្រុងនោះជេរ, យើងនឹងទៅកាន់នគរណាទៀត ?

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់ក្រុងដទៃទៀត ។

ព្រះសាស្ដា. កាលពួកមនុស្សក្នុងក្រុងនោះជេរ យើងនឹងទៅកាន់ទីណាទៀតទៅ ?

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ទៅកាន់ក្រុងដទៃអំពីក្រុងនោះទៀត ។

ព្រះសាស្ដា. ម្នាលអានន្ទ កាលធ្វើយ៉ាងនេះមិនសមគួរទេ, អធិករណ៍កើតឡើងក្នុងទីណា, កាលអធិករណ៍នោះស្ងប់រម្ងាប់ហើយក្នុង

ទីនោះ ទើបគួរទៅកាន់ទីដទៃ ម្នាលអានន្ទ ក៏ពួកមនុស្សទាំងនោះ ពួកណាទៅ តែងជេរ ?

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងនោះទាំងអស់ រហូតដល់ពួកទាសៈ និងកម្មករ រមែងជេរ ។

ព្រះសាស្តាត្រាស់ថា "ម្នាលអានន្ទ តថាគតដូចជាដំរីចូលកាន់សង្គ្រាម ក៏ការអត់ទ្រាំចំពោះកូនសរដែលមកអំពីទិសទាំង ៤ រមែងជាភារៈរបស់ដំរីដែលចូលកាន់សង្គ្រាម យ៉ាងណាមិញ ដែលឈ្មោះថា ការអត់ទ្រាំចំពោះពាក្យដែលមនុស្សទ្រុស្តសីលជាច្រើនពោលហើយ ក៏ជាភារៈរបស់តថាគតដូច្នោះដែរ" ដូច្នេះហើយ កាលទ្រង់ប្រារព្ធចំពោះព្រះអង្គ សម្តែងនូវគាថា ៣ គាថានេះក្នុងនាគវគ្គថា ៖

**អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ**
**អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ ។**
**ទន្តំ ន យន្តិ សមិតឹ ទន្តំ រាជាភិរូហតិ**
**ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ ។**

វរមស្សតរា ទន្តា អាជានីយា វ សិន្ធវា
កុញ្ជរា វ មហានាគា អត្តទន្តោ តតោ វរំ ។

តថាគតនឹងអត់ទ្រាំពាក្យល្មើស ដូចដំរីអត់ទ្រាំចំពោះព្រួញ ដែលរបូតចេញអំពីធ្នូ ក្នុងសង្គ្រាមដូច្នោះ ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។ ពួកជនតែងនាំវាហនៈដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជាតែងស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់សង្កត់នឹងពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថា ជាបុគ្គលប្រសើរបំផុត ។

ពួកសេះអស្សតរក្តី ពួកសេះអាជានេយ្យក្តី សេះសិន្ធពក្តី ដំរីកុញ្ជរដ៏ប្រសើរក្តី ដែលបុគ្គលប្រៀនប្រដៅបានហើយ រាប់ថាជាសត្វប្រសើរបំផុត បុគ្គលដែលមានខ្លួនទូន្មានហើយ ប្រសើរជាងសត្វទាំងអស់នោះ ។

ធម្មកថាបានជាប្រយោជន៍ដល់មហាជន អ្នកដល់ព្រមហើយ, ព្រះសាស្តាលុះទ្រង់សម្តែងធម្មកថាយ៉ាងនេះហើយ ទ្រង់ត្រាស់ថា "ម្នាលអានន្ទ អ្នកកុំគិតឡើយ, ពួកជនទាំងនោះនឹងជេរបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៨ នឹងជាអ្នកស្ងៀម, ព្រោះថា អធិករណ៍ដែលកើតឡើងចំពោះព្រះពុទ្ធទាំងឡាយ មិនហួសពី ៧ ថ្ងៃទេ" ។

## ព្រះនាងមាគន្ទិយារករឿងដោយមាន់

ព្រះនាងមាគន្ទិយា ជួលមនុស្សឲ្យជេរព្រះសាស្តាហើយ ( ប៉ុន្តែ ) មិនអាចធ្វើឲ្យព្រះសាស្តាចៀសចេញទៅបាន ទើបគិតថា "យើងនឹងធ្វើយ៉ាងណាហ្ន៎" ? ដូច្នេះហើយ គិតថា "ស្ត្រីទាំងនោះ ជាអ្នកឧបដ្ឋាយិកាព្រះសមណគោតមនោះ, យើងនឹងធ្វើសេចក្តីវិនាសឲ្យដល់ស្ត្រីទាំងនោះ" ថ្ងៃមួយ កាលធ្វើការបម្រើព្រះរាជាក្នុងទីជាទីសោយទឹកចណ្ឌ បញ្ជូនដំណឹងទៅឪពុកមាថា ខ្ញុំត្រូវការមាន់ទាំងឡាយ សូមពុកមាចូរនាំយកមាន់ងាប់ ៨ មាន់រស់ ៨ មក, លុះមក ដល់ហើយ ចូរឈរនៅក្នុងទីបំផុតនៃជណ្តើរ ចូរបញ្ជាបុគ្គលឲ្យថ្វាយដំណឹងដល់

ព្រះរាជាថា ខ្ញុំនមកដល់ហើយ សូម្បីកាលព្រះរាជាត្រាស់ថា "ចូរចូលមក" ក៏កុំចូលទៅ ចូរបញ្ជូនមាន់រស់ ៨ ទៅមុន បញ្ជូនមាន់ងាប់ទៅជាខាងក្រោយ" ហើយបានប្រទានសំណូកឲ្យអ្នកបម្រើ ដោយពាក្យ ថា "ឯងគប្បីធ្វើតាមពាក្យរបស់យើង" ។

នាយចូឡមាគន្ទិយៈមកហើយ ញុំាងបុគ្គលឲ្យថ្វាយដំណឹងដល់ព្រះរាជាឲ្យទ្រង់ជ្រាប កាលព្រះរាជាត្រាស់ថា "ចូរចូលមក" ក៏ពោលថា "យើងនឹងមិនចូលទៅកាន់ទីជាទីសោយទឹកចណ្ឌរបស់ព្រះរាជា" ចំណែកព្រះនាងមាគន្ទិយាបញ្ជូនបម្រើទៅដោយពាក្យថា "ម្នាលបា ឯងចូរទៅកាន់សំណាក់ពុកមារបស់យើង" ។ បម្រើនោះទៅហើយ នាំយកមាន់រស់ ៨ ដែលនាយចូឡមាគន្ទិយៈនោះឲ្យហើយមក ក្រាបទូលថា "បពិត្រព្រះសម្មតិទេព បុរោហិតបញ្ជូនបណ្ណាការមក ហើយ" ។ ព្រះរាជាត្រាស់ថា "ប្រពៃណាស់ សម្លកកូរកើតឡើងដល់ ពួកយើងហើយ, នរណាហ្ន៎ គប្បីចំអិន" ?

ព្រះនាងមាគន្ទិយាក្រាប ទូលថា "បពិត្រមហារាជ ស្រ្តី ៥០០ មាននាងសាមាវតីជាប្រធាន ជា



អ្នកមិនមានការងារធ្វើ និងទំនេរ សូមព្រះអង្គបញ្ជូនទៅឲ្យស្ត្រី ទាំងនោះចុះ, ស្ត្រីទាំងនោះចំអិនហើយនឹងនាំមក ( ថ្វាយ )" ។ ព្រះរាជា ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ឯងចូរនាំទៅឲ្យស្ត្រី ទាំងនោះ, បានឮថា ស្ត្រីទាំងនោះ ចូរកុំឲ្យក្នុងដៃអ្នកដទៃ ចូរសម្លាប់ ហើយចំអិនដោយខ្លួនឯង" ។ អ្នកបម្រើទទួលរាជតម្រាស់ថា "ប្រពៃ ហើយ ព្រះអង្គ" ហើយទៅប្រាប់យ៉ាងនោះ ជាអ្នកដែលស្ត្រីទាំង នោះប្រកែក ហើយថា "ពួកខ្ញុំមិនធ្វើបាណាតិបាតទេ" ទើបមកក្រាប ទូលសេចក្តីនោះ ដល់ព្រះរាជា ។ ព្រះនាងមាគន្ទិយា ក្រាបទូលថា "បពិត្រមហារាជ ព្រះអង្គឃើញទេ ? ឥឡូវនេះព្រះអង្គនឹងទ្រង់ ជ្រាបការធ្វើ ឬមិនធ្វើ បាណាតិបាតនៃស្ត្រីទាំងនោះ, សូមព្រះអង្គ បញ្ជាថា ស្ត្រីទាំងនោះចូរ ចំអិន ហើយបញ្ជូនទៅថ្វាយសមណៈ ដូច្នេះចុះ" ។

ព្រះរាជាត្រាស់យ៉ាងនោះហើយបញ្ជូនទៅ ។ អ្នកបម្រើនោះកាន់មាន់ដែលនៅរស់នោះធ្វើហាក់ដូចជាដើរទៅ ទៅហើយបានឲ្យមាន់ទាំងនោះដល់បុរោហិត ទទួលយកមាន់ងាប់ទៅកាន់សំណាក់



ស្ត្រីទាំងនោះ ពោលថា “ព្រះអាជ្ញាបញ្ជា ពួកនាងឲ្យចំអិនមាន់ទាំងនេះ ហើយបញ្ជូនទៅកាន់សំណាក់ព្រះសាស្តា” ។ ស្ត្រីទាំងនោះពោលថា ល្អហើយ អ្នកជាម្ចាស់ចូរនាំមកចុះ ដែលឈ្មោះថាការចំអិនមាន់ងាប់ នេះជាកិច្ចរបស់ពួកយើង” ដូច្នេះហើយ ក៏ទទួលទុក ។ បម្រើនោះមក កាន់សំណាក់របស់ព្រះរាជា ដែលព្រះរាជាត្រាស់សួរថា “ម្នាលបា ដូចម្តេចដែរ ? ក៏ក្រាបទូលថា កាលខ្ញុំព្រះអង្គគ្រាន់តែពោលថា “ពួក នាងចូរចំអិន រួចហើយបញ្ជូនទៅថ្វាយព្រះសមណគោតមប៉ុណ្ណោះ, ស្ត្រីទាំងនោះក៏ប្រញាប់ប្រញាល់មកទទួលយកទៅ” ។ ព្រះនាង មាគន្ទិយាក្រាបទូលថា “បពិត្រមហារាជ សូមព្រះអង្គចូរទតមើល ចុះ, ស្ត្រីទាំងនោះមិនធ្វើឲ្យបុគ្គលដូចជាព្រះអង្គទេ, កាលខ្ញុំព្រះ អង្គទូលថា “ស្ត្រីទាំងនោះមាន

សេចក្ដីប្រាថ្នាខាងក្រៅ", ព្រះអង្គ មិន ទ្រង់ជឿ" ។ ព្រះរាជាសូម្បីទ្រង់ព្រះសណ្ដាប់នូវពាក្យនោះ ក៏បាន ទ្រង់អត់សង្កត់នៅស្ងៀមដូចដើម ។ ព្រះនាងមាគន្ទិយាគិតថា "យើង នឹងធ្វើយ៉ាងណាហ្ន៎" ?

## ព្រះនាងមាគន្ទិយារកឧបាយដោយរឿងពស់

ក៏ក្នុងកាលនោះ ព្រះរាជាតែងតែទ្រង់សំណាក់នៅក្នុងប្រាសាទ របស់អគ្គមហេសីទាំង ៣ នោះ គឺប្រាសាទរបស់ព្រះនាងសាមាវតី ប្រាសាទរបស់ព្រះនាងវាសុលទត្តា និងប្រាសាទរបស់ព្រះនាងមាគន្ទិយា អស់ ៧ ថ្ងៃក្នុងប្រាសាទនីមួយ ៗ ។ គ្រានោះនាងមាគន្ទិយាដឹងថា "ថ្ងៃស្អែកនេះ ព្រះរាជានឹងស្ដេចយាងទៅកាន់ប្រាសាទរបស់ព្រះនាង សាមាវតី" ក៏បញ្ជូនដំណឹងទៅប្រាប់ពុកមាថា "សូមពុកមាជ្រាប ខ្ញុំ ត្រូវការពស់, សូមពុកមាចូរជកចង្កូមពស់ទាំងឡាយ ហើយបញ្ជូន ទៅមួយ" នាយចូឡមាគន្ទិយៈធ្វើយ៉ាងនោះ ហើយបញ្ជូនទៅ ។ ព្រះ-រាជាទ្រង់កាន់យកពិណហត្ថិកន្តគឺពិណសម្រាប់ញ៉ាំងដំរីឲ្យត្រេកអរ តែម្យ៉ាង ស្ដេចទៅកាន់ទីជាទី

ស្តេចទៅនៃព្រះអង្គ ។ ពិណនោះមាន ប្រហោងមួយៗ នាងមាគន្ទិយា ញុំាងពស់ឲ្យចូលទៅកាន់ប្រហោងនោះ ហើយបិទប្រហោងដោយដុំនៃកម្រងផ្កា ពស់បាននៅខាងក្នុងពិណ នោះឯងអស់ពីរបីថ្ងៃ ក្នុងថ្ងៃដែលព្រះរាជាស្តេចយាងទៅ ព្រះនាង មាគន្ទិយាទូលសួរថា “បពិត្រព្រះសម្មតិទេព ថ្ងៃនេះ ព្រះអង្គនឹង



ស្តេចទៅកាន់ប្រាសាទនៃអគ្គមហេសីអង្គណា” ? កាលព្រះរាជាត្រាស់ប្រាប់ថា “របស់នាងសាមាវតី” ក៏ក្រាបទូលថា “បពិត្រមហា-រាជ ថ្ងៃនេះខ្ញុំព្រះអង្គយល់សុបិន្តល្អ, បពិត្រព្រះសម្មតិទេព ព្រះអង្គមិនគួរស្តេចទៅកាន់ទីនោះបានទេ” ។ ព្រះរាជាត្រាស់ថា “យើងនឹងទៅឲ្យខានតែបាន” ព្រះនាងមាគន្ទិយាហាមអស់វារៈ ៣ ដង ហើយទូលថា “បើដូច្នោះ សូម្បីខ្ញុំព្រះអង្គក៏នឹងទៅជាមួយព្រះអង្គដែរ” សូម្បី ព្រះរាជាឲ្យត្រឡប់ទៅវិញក៏មិនត្រឡប់ ក្រាបទូលថា “បពិត្រមហារាជ ខ្ញុំព្រះអង្គមិនជ្រាបថា នឹងមានហេតុអ្វីកើតឡើងដល់ព្រះអង្គ” ដូច្នេះហើយ ក៏បានទៅជាមួយទាល់តែបាន ។

ព្រះរាជាទ្រទ្រង់សំពត់ផ្កាឈើ គ្រឿងប្រអប់ និងអាភរណៈទាំងឡាយ ដែលពួកស្ត្រីរួមជាមួយនឹងព្រះនាងសាមាវតីថ្វាយ សោយភោជនដ៏ប្រណិត ដាក់ពិណទុកលើក្បាលដំណេក ហើយផ្ទំលើទីបន្ទំ ។ នាងមាគន្ទិយាធ្វើហាក់ដូច ជាដើរទៅដើរមក បាននាំដុំកម្រងផ្កាចេញអំពីប្រហោងពិណ ។ ពស់ អត់អាហារ ២-៣ ថ្ងៃ លូនចេញមកតាមប្រហោងពិណនោះ ដក



ដង្ហើមចេញ ( ឲ្យសំឡេង ) បើកពពារដេកលើខ្នងទីព្រះបន្ទំ ។ នាងមាគន្ទិយាឃើញពស់នោះក៏ស្រែកឡើងថា "បពិត្រព្រះសម្មតិទេព ពស់" កាលនឹងជេរព្រះរាជា និងស្ត្រីទាំងនោះ ក៏ពោលថា "ព្រះរាជាល្ងង់អង្គនេះមិនមានបុណ្យ មិនជឿពាក្យរបស់យើង សូម្បីស្ត្រីទាំងនេះក៏ជាមនុស្សមិនមានសិរី ក្បាលរឹង ប្រៀនប្រដៅបានដោយកម្រ ពួកវាមិនបានអ្វីអំពីសំណាក់របស់ព្រះរាជាឬ ? ពួកនាងឯង កាលព្រះរាជាអង្គនេះសោយទិវង្គតហើយ នឹងជាអ្នកសប្បាយឬ កាលព្រះរាជានៅមានព្រះជន្ម ពួកនាងឯងរស់នៅដោយលំបាកឬ ? ថ្ងៃនេះ

យើងឃើញការយល់សុបិន្តដ៏អាក្រក់របស់យើងហើយ, ព្រះអង្គអើយ ព្រះអង្គមិនទ្រង់ស្តាប់ពាក្យរបស់ខ្ញុំព្រះអង្គ ដែលជាអ្នកអង្វរថា “មិនគួរស្តេចទៅកាន់ប្រាសាទរបស់ព្រះនាងសាមាវតីទេ” ។

## ព្រះបាទឧទេនដាក់ទោសនាងសាមាវតី

ព្រះរាជាទតឃើញពស់ ក៏ទ្រង់តក់ស្លុតព្រះទ័យអំពីមរណៈ ពោរពេញទៅដោយសេចក្តីក្រោធ “ស្ត្រីទាំងនេះធ្វើកម្មបែប



នេះ ឱអញអើយអញ ! អីក៏លាមកម្ល៉េះ មិនជឿពាក្យរបស់នាងមាគន្ទិយា ដែលជាអ្នកប្រាប់ថា ស្ត្រីទាំងនេះជាមនុស្សលាមក, កាលលើកមុនវាចោះប្រហោងទុកក្នុងបន្ទប់ទាំងឡាយរបស់ខ្លួន ហើយអង្គុយ ។ កាលយើងបញ្ជូនមាន់ទៅឲ្យក៏បញ្ជូនត្រឡប់មកវិញទៀត, ថ្ងៃនេះលែងពស់ទុកលើទីបន្ទំ” ។

ចំណែកព្រះនាងសាមាវតី ក៏បានឲ្យឱវាទដល់ស្ត្រីទាំង ៥០០ នោះ ថា “ម្នាលនាងទាំងឡាយ ទីពឹងដទៃរបស់ពួកយើងមិនមានទេ, នាងទាំង-ឡាយចូរញ៉ាំងមេត្តាចិត្តឲ្យប្រព្រឹត្តទៅស្មើក្នុងព្រះរាជា

ដែលជាកំពូល នៃនរជន ក្នុងព្រះទេវី និងក្នុងខ្លួនឯង នាងទាំងឡាយកុំញុំាងសេចក្ដី ក្រោធឲ្យកើតឡើងដល់អ្នកណា ៗ ឡើយ” ។ ព្រះរាជាទ្រង់កាន់យក ធ្នូដែលមានសណ្ឋានដូចក្ទុកដំរី ( ឬស្នែងសត្វ ) ដ៏គួរដល់កម្លាំងនៃ បុរស ១០០០ នាក់ ទ្រង់តម្លើងខ្សែធ្នូបន្ទោះផ្ទាប់នូវសរដែលលាប ដោយថ្នាំពិស ធ្វើព្រះនាងសាមាវតីទុកក្នុងខាងមុខ ឲ្យស្ត្រីទាំងនោះ ឈរតម្រៀបគ្នាតាមលំដាប់ហើយ ក៏ទ្រង់លោះនូវកូនសរទៅចំទ្រូង



នៃនាងសាមាវតី ។ កូនសរនោះវិលត្រឡប់ជារបស់មានមុខឆ្ពោះកាន់ ផ្លូវដែលខ្លួនមកហើយ ហាក់ដូចជាចូលទៅកាន់ព្រះហឫទ័យរបស់ ព្រះរាជា បានតាំងនៅហើយដោយមេត្តានុភាពរបស់ព្រះនាងសាមា-វតីនោះ ។ ព្រះរាជាទ្រង់ព្រះចិន្តាដូច្នេះថា “កូនសរដែលយើងបាញ់ ទៅហើយ រមែងចាក់ទម្លុះសូម្បីសិលា, សូម្បីហ៊ានះដែល នឹងប៉ះខ្ទប់ក្នុងឱកាសក៏មិនមាន អើ ក៏កូនសរនេះហេតុដូចម្ដេចបានជា មានមុខឆ្ពោះមកកាន់ហឫទ័យរបស់យើងវិញ, ? ពិតណាស់ សូម្បី

កូនសរនេះ មិនមានចិត្ត មិនមែនជាសត្វ មិនមែនជារបស់មានជីវិត ប៉ុន្តែដឹងគុណនាងសាមាវតី, ខ្លួនយើងជាមនុស្ស ហេតុដូចម្តេចបានជាមិនមានការដឹងគុណអ្វីបន្តិចសោះអីចឹង ?

## ព្រះបាទឧទេនប្រទានពរដល់នាងសាមាវតី

ព្រះរាជាទ្រង់បោះធ្នូនោះចោល ទ្រង់ផ្គងអញ្ជលីគង់ប្រហោងក្នុងទីជិតបាទមូលនៃព្រះនាងសាមាវតី ហើយត្រាស់ព្រះគាថាដូច្នេះថា ( យើងជាមនុស្សវង្វេង ជាមនុស្សល្ងង់ខ្លៅ ទិសទាំងពួងរមែងមិន



ប្រាកដដល់យើង, ម្នាលនាងសាមាវតី នាងចូរការពារយើង មួយវិញទៀត នាងចូរជាទីពឹងនៃយើង ព្រះនាងសាមាវតីស្តាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ក៏មិនបានក្រាបទូលថា“បពិត្រមហារាជប្រពៃហើយ ព្រះអង្គចូរដល់ទូលបង្គំជាទីពឹងចុះ”, ( ប៉ុន្តែ ) ក្រាបទូលថា “បពិត្រមហារាជ ខ្ញុំព្រះអង្គដល់បុគ្គលណាជាទីពឹង សូមព្រះអង្គដល់បុគ្គលនោះ ជាទីពឹងដែរចុះ” ។

ព្រះនាងសាមាវតី ដែលជាសាវិការបស់ព្រះសម្មាសម្ពុទ្ធ លុះ ពោលពាក្យដូច្នេះហើយ ក៏ពោលថា ៖

ព្រះអង្គកុំទ្រង់ដល់ខ្ញុំជាទីពឹងឡើយ, ខ្ញុំព្រះអង្គដល់
បុគ្គលណាជាទីពឹង, បពិត្រមហារាជ បុគ្គលនោះ គឺ
ព្រះពុទ្ធ, ព្រះពុទ្ធនោះជាបុគ្គលដ៏កំពូល, សូមព្រះអង្គ
ទ្រង់ដល់ព្រះពុទ្ធអង្គនោះជាទីពឹងផង, ទ្រង់ជាទីពឹង
របស់ខ្ញុំព្រះអង្គផង ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យរបស់ព្រះនាងសាមាវតីនោះ



ក៏ទ្រង់ត្រាស់ថា “ឥឡូវនេះ យើងខ្វាចក្រៃលែងណាស់” ហើយត្រាស់ព្រះគាថានេះថា ៖

យើងនេះវង្វេងក្រៃលែងណាស់ ទិសទាំងពួងរមែងមិន
ប្រាកដដល់យើង នាងសាមាវតីអើយ នាងចូរគាំពារ
យើង មួយវិញទៀតនាងចូរជាទីពឹងរបស់យើង ។

គ្រានោះ ព្រះនាងសាមាវតីនោះ ក៏ហាមឃាត់ព្រះរាជាដោយន័យដូចមុននោះឯងទៀត កាលព្រះរាជាត្រាស់ថា "បើដូច្នោះ យើងសូមដល់នាង និងព្រះសាស្តាជាទីពឹង ហើយយើងនឹងឲ្យពរដល់នាង" ដូច្នេះហើយ ក្រាបទូលថា "បពិត្រមហារាជ ពរចូរជាពរដែលខ្ញុំម្ចាស់បានទទួលហើយចុះ" ។ ព្រះរាជាស្តេចចូលទៅគាល់ព្រះ-សាស្តា ទ្រង់ដល់ព្រះសាស្តាជាសរណៈហើយ ទ្រង់ថ្វាយទានដល់ភិក្ខុសង្ឃអស់ ៧ ថ្ងៃហើយ ទ្រង់ហៅនាងសាមាវតីមកត្រាស់ថា "ម្នាលនាងសមាវតី នាងចូរក្រោកឡើងទទួលពរចុះ" ព្រះនាងសាមាវតីក្រាបទូលថា "បពិត្រមហារាជ ខ្ញុំម្ចាស់មិនមានសេចក្តីត្រូវការដោយវត្ថុទាំងឡាយ



មានប្រាក់ជាដើមទេ ប៉ុន្តែសូមព្រះអង្គព្រះរាជទានពរនេះដល់ខ្ញុំម្ចាស់ ( គឺ ) ព្រះសាស្តាព្រមទាំងភិក្ខុ ៥០០ រូប នឹងស្តេចមកកាន់ទីនេះជាប់មិនដាច់បានដោយប្រការណា សូមព្រះអង្គទ្រង់ធ្វើដោយប្រការនោះចុះ, ខ្ញុំម្ចាស់នឹងស្តាប់ធម៌" ។ ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ

ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គព្រមទាំងភិក្ខុ ៥០០ រូប ចូរស្ដេចមកកាន់ទីនេះជានិច្ចចុះ ពួកស្ត្រីដែលរួមទាំងព្រះនាងសាមាវតីចូលផងនោះបានពោលថា “ខ្ញុំម្ចាស់នឹងស្ដាប់ធម៌” ។

ព្រះសាស្ដា. មហាបពិត្រ ធម្មតាការត្រាច់ទៅក្នុងទីតែមួយជានិច្ច រមែងមិនសមគួរដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះមហាជនប្រាថ្នាចំពោះព្រះពុទ្ធ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន បើយ៉ាងនោះ សូមព្រះអង្គទ្រង់ចាត់ភិក្ខុ ១ រូបចុះ ។

ព្រះសាស្ដាក៏បានទ្រង់ចាត់ព្រះអានន្ទ ។ ចាប់តាំងពីពេលនោះមក ព្រះអានន្ទត្ថេរនោះក៏នាំភិក្ខុ ៥០០ រូបទៅកាន់រាជត្រកូលជា



និច្ច ព្រះទេវីទាំងនោះញុំាងព្រះថេរៈព្រមទាំងបរិវារឲ្យឆាន់ និងស្ដាប់ធម៌ជានិច្ច ។

## ព្រះរាជាទ្រង់ថ្វាយចីវរដល់ព្រះអានន្ទ

ថ្ងៃមួយ ស្ត្រីទាំងនោះស្តាប់ធម្មកថារបស់ព្រះថេរៈហើយ ជ្រះថ្លាបានបូជាធម៌ដោយសំពត់ឧត្តរាសង្គ ៥០០ ផ្ទាំង ។ ឧត្តរា-សង្គមួយផ្ទាំងៗ មានតម្លៃ ៥០០ កហាបណៈ ។ ព្រះរាជាមិនទ្រង់ឃើញសំពត់របស់ស្ត្រីទាំងនោះសូម្បីតែមួយផ្ទាំង ទើបត្រាស់សួរថា “សំពត់ឧត្តរាសង្គនៅឯណា” ?

ពួកស្ត្រី. ពួកខ្ញុំម្ចាស់ប្រគេនលោកម្ចាស់អានន្ទហើយ ។

ព្រះរាជា. លោកម្ចាស់អានន្ទនោះ ទទួលយកទាំងអស់ឬ ?

ពួកស្ត្រី. បពិត្រមហារាជ លោកម្ចាស់អានន្ទទទួលយកទាំងអស់ ។

ព្រះរាជាស្តេចចូលទៅរកព្រះថេរៈហើយ ត្រាស់សួរដល់ការដែលស្ត្រីទាំងនោះប្រគេនសំពត់ឧត្តរាសង្គ ទ្រង់ព្រះសណ្តាប់នូវការ



ដែលស្ត្រីទាំងនោះប្រគេន និងការដែលព្រះថេរៈទទួលទុកហើយ ទើបត្រាស់សួរថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់មានច្រើនក្រៃ

ពេកមិនមែនឬ ? លោកម្ចាស់ទទួលយកសំពត់ច្រើនបែបនេះទៅធ្វើអ្វី ?

ព្រះថេរៈ. ថ្វាយព្រះពរមហារាជ អាត្មាភាពទទួលសំពត់ទុកល្មមសមគួរដល់អាត្មាភាពហើយ ប្រគេនសំពត់ដ៏សេសដល់ភិក្ខុទាំងឡាយអ្នកមានចីវរចាស់គ្រាំគ្រា ។

ព្រះរាជា. ភិក្ខុទាំងឡាយ នឹងធ្វើចីវរចាស់របស់ខ្លួនឲ្យទៅជាអ្វី ?

ព្រះថេរៈ. លោកនឹងឲ្យដល់ភិក្ខុអ្នកមានចីវរចាស់ពេកទាំង-ឡាយ ។

ព្រះរាជា. ភិក្ខុទាំងនោះនឹងធ្វើចីវរចាស់របស់ខ្លួនឲ្យជារបស់អ្វី

ព្រះថេរៈ. លោកនឹងធ្វើឲ្យទៅជាសំពត់សម្រាប់ក្រាលដេក ។

ព្រះរាជា. ភិក្ខុទាំងនោះនឹងធ្វើសំពត់សម្រាប់ក្រាលដេកចាស់



នោះឲ្យទៅជារបស់អ្វី ?

ព្រះថេរៈ. លោកនឹងធ្វើឲ្យជាសំពត់ក្រាលផ្ទៃ ។

ព្រះរាជា. ភិក្ខុទាំងនោះនឹងយកសំពត់ក្រាលផ្ទៃចាស់នោះទៅធ្វើអ្វី ?

ព្រះថេរៈ. ថ្វាយព្រះពរមហាបពិត្រ លោកនឹងធ្វើឲ្យជាសំពត់ជូតជើង ។

ព្រះរាជា. លោកនឹងយកសំពត់ជូតជើងចាស់នោះទៅធ្វើអ្វី ?

ព្រះថេរៈ. លោកនឹងចញ្ច្រាំឲ្យល្អិតហើយ ប្រឡាក់លាយជាមួយនឹងដីស្អិត បូកជញ្ជាំង ។

ព្រះរាជា. បពិត្រលោកម្ចាស់ដ៏ចម្រើន សំពត់ទាំងឡាយដែលទាយកប្រគេនដល់ពួកលោកម្ចាស់រមែងមិនវិនាសទៅព្រោះធ្វើនូវកិច្ចមានប្រមាណប៉ុណ្ណេះឬ ?

ព្រះថេរៈ. ថ្វាយព្រះពរមហាបពិត្រ យ៉ាងនោះពិតមែនហើយ ។

ព្រះរាជាទ្រង់ជ្រះថ្លាហើយ បញ្ជាឲ្យគេនាំសំពត់ ៥០០ ផ្ទាំងដទៃ

ទៀតមក ហើយបញ្ជាឲ្យតម្កល់ទុកទៀបបាទមូលរបស់ព្រះថេរៈ ។

បានឮថា ព្រះថេរៈបានសំពត់មានតម្លៃ ៥០០ កហាបណៈ ដែលព្រះរាជា ទ្រង់តម្កល់ទុកទៀបបាទមូលប្រគេនដោយចំណែក ៥០០ អស់វារៈ ៥០០ ដង បានសំពត់មានតម្លៃ ១០០០ កហាបណៈ ដែលព្រះរាជាតម្កល់ទុកទៀបបាទមូលប្រគេនដោយចំណែក ១០០០ អស់វារៈ ១០០០ ដង, បានសំពត់មានតម្លៃ ១ សែន ដែលព្រះរាជា តម្កល់ទុកទៀបបាទមូលប្រគេនដោយចំណែក ១ សែន អស់វារៈ ១ សែនដង ។ ក៏ឈ្មោះថាការរាប់សំពត់ដែលព្រះថេរៈបានហើយ ដោយន័យជាដើមថា ១-២-៣-៤-៥-១០ ដូច្នេះ រមែងមិនមាន ។ បានឮថា កាលព្រះតថាគតបរិនិព្វានហើយ ព្រះថេរៈត្រាច់ទៅកាន់ជម្ពូទ្វីបទាំងមូល បានប្រគេនបាត្រ និងចីវរទាំងឡាយដែលជារបស់ខ្លួនៗ នោះឯង ដល់ភិក្ខុទាំងឡាយក្នុងវិហារទាំងពួង ។

## ព្រះនាងសាមាវតីត្រូវភ្លើងឆេះ

ព្រះនាងមាគន្ទិយាគិតថា "យើងធ្វើនូវពំពើណា, អំពើនោះ

មិន

បានជាយ៉ាងនោះ ត្រឡប់ជាយ៉ាងដទៃទៅវិញ, យើងនឹងធ្វើដូចម្ដេចហ្ន៎ ?" ដូច្នេះហើយ គិតថា "ឧបាយនេះ ប្រើប្រាស់បាន" កាលព្រះ-រាជាស្ដេចទៅកាន់ព្រះរាជឧទ្យាន ក៏បញ្ជូនដំណឹងទៅឲ្យពុកមាថា "សូមពុកមាចូរទៅកាន់ប្រាសាទរបស់នាងសាមាវតី ប្រើឲ្យគេបើកឃ្លាំងសំពត់ និងឃ្លាំងប្រេងហើយ ជ្រលក់សំពត់ក្នុងភាជនៈសម្រាប់ដាក់ប្រេងហើយរុំសសរ ធ្វើស្ដ្រីទាំងអស់នោះទុកក្នុងទីជាមួយគ្នា បិទទ្វារចាក់សោខាងក្រៅ យកគប់ភ្លើងមានដងដុតដំណាក់ ហើយចូរចៀសចេញទៅ"។ នាយមាគន្ទិយៈនោះឡើងកាន់ប្រាសាទ ប្រើឲ្យគេបើកឃ្លាំងទាំងឡាយ យកសំពត់ទៅជ្រលក់ក្នុងប្រេងឲ្យទទឹកជោកហើយ ផ្ដើមរុំសសរ ។

គ្រានោះ ស្ដ្រីទាំង ៥០០ នាក់ ដែលមាននាងសាមាវតីជាប្រធានបានសួរនាយមាគន្ទិយៈថា "ម្នាលនាយ លោកធ្វើ អ្វីហ្នឹង" ? ហើយក៏ចូលទៅជិត ។ នាយមាគន្ទិយៈពោលយ៉ាងនេះថា "ម្នាលនាងទាំងឡាយ ព្រះរាជាបញ្ជាឲ្យរុំសសរទាំងនេះដោយសំពត់

ដែលជ្រលក់ប្រេង ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យមាំ ធម្មតាក្នុងព្រះរាជវាំង កម្មដែលបុគ្គលធ្វើល្អ និងអាក្រក់ជារបស់ដែលដឹងបានដោយកម្រ ដូច្នេះនាងទាំងឡាយ កុំនៅក្នុងទីជិតខ្ញុំឡើយ” ដូច្នេះហើយ ឲ្យ ស្រ្តី ៥០០ ដែលមាននាងសាមាវតីជាប្រធាននោះចូលទៅក្នុងបន្ទប់ បិទទ្វារហើយ ចាក់សោខាងក្រៅ ឈ្មួលភ្លើងដុតចាប់ផ្តើមអំពីដើម ចុះមក ។ ព្រះនាងសាមាវតីបានឲ្យឱវាទដល់ស្រ្តីទាំងនោះថា “ការ កំណាត់អត្តភាព ដែលត្រូវភ្លើងឆេះយ៉ាងនេះរបស់ពួកយើងអ្នកត្រាច់រង្គាត់ទៅក្នុងសង្សារ វដ្តដែលមានទីបំផុតខាងដើមដែលបុគ្គលតាមដឹង មិនបាន សូម្បីពុទ្ធញាណក៏មិនមែនធ្វើបានដោយងាយ, នាងទាំង-ឡាយចូរជាអ្នកមិនប្រមាទចុះ” ។ ស្រ្តីទាំងនោះកាលដំណាក់របស់ខ្លួន ត្រូវភ្លើងឆេះ, មនសិការនូវវេទនាបរិ-គ្គហកម្មដ្ឋាន ( គឺកម្មដ្ឋានកំណាត់ យកវេទនាជាអារម្មណ៍, ពួកបានខ្លះ សម្រេចផលទី ២ ពួកបានខ្លះសម្រេចផលទី ៣ ។

ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា គ្រា

នោះ ពួកភិក្ខុជាច្រើន ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងកោសម្ពី ។ លុះត្រាច់បិណ្ឌបាតក្នុងក្រុងកោសម្ពីហើយ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាខាងក្រោយភត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ កាលព្រះបាទឧទេនទ្រង់ស្តេចទៅកាន់ឧទ្យាន មានភ្លើងឆេះខាងក្នុងព្រះរាជវាំង ពួកស្ត្រី ៥០០ នាក់មាននាងសាមាវតីជាប្រធាន ធ្វើមរណកាលទាំងអស់ បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់ឧបាសិកាទាំងនោះ តើដូចម្តេច លោកខាងមុខតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាឧបាសិកាទាំងនោះ ឧបា-សិកាជាសោតាបន្នាក៏មាន ជាសកទាគាមិនីក៏មាន ជាអនាគាមិនីក៏មាន ម្នាលភិក្ខុទាំងឡាយ ឧបាសិកាទាំងអស់នោះ ធ្វើកាលកិរិយាទៅដោយមិនឥតផលទេ ។ លុះព្រះមានព្រះភាគជ្រាប ច្បាស់នូវ

សេចក្តីនោះហើយ ទើបទ្រង់បន្លឺឧទាននេះក្នុងវេលានោះថា សត្វលោកមានមោហៈជាចំណង ប្រាកដដូចជាមានសភាពគួរឲ្យរីករាយ បុគ្គលមានឧបធិក្កិលេសជាគ្រឿងចង ត្រូវងងឹត គឺអវិជ្ជាចោមរោមហើយ ប្រាកដដូចជាទៀងទាត់ សេចក្តីកង្វល់មានរាគៈជាដើមមិនមានដល់បុគ្គលអ្នកពិចារណាឃើញច្បាស់ ។ លុះត្រាស់យ៉ាងនោះហើយ ទ្រង់សម្តែងធម៌ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វទាំងឡាយ ដែលត្រាច់រង្គាត់ក្នុងវដ្តៈ ជាអ្នកមិនប្រមាទរហូតអស់កាលជានិច្ច ធ្វើបុញ្ញកម្មក៏មាន, ជាអ្នកមានសេចក្តីប្រមាទធ្វើបាបកម្មក៏មាន, ព្រោះហេតុនោះ សត្វលោកដែលត្រាច់ទៅក្នុងវដ្តៈទើបសោយសុខខ្លះ ទុក្ខខ្លះ" ។

## ព្រះបាទឧទេនដាក់ទោសព្រះនាង
## មាគន្ទិយា និង ពួកញាតិ

ព្រះរាជាទ្រង់ព្រះសណ្តាប់ដំណឹងថា "ដំណាក់របស់ព្រះនាងសាមាវតីត្រូវភ្លើងឆេះ" សូម្បីកាលស្តេចមកដោយប្រញាប់ប្រញាល់ក៏មិនទាន់ដំណាក់ដែលភ្លើងមិនទាន់ឆេះ លុះស្តេចមកដល់

ហើយ ត្រាស់បញ្ជាឲ្យរំលត់ហើយ ទ្រង់កើតទោមនស្សយ៉ាងខ្លាំង ពួកអាមាត្យចោមរោម ទ្រង់គន់រឭកដល់ព្រះគុណរបស់ព្រះនាង សាមាវតី ទ្រង់ព្រះចិន្តាថា អំពើនេះជាអំពើរបស់នរណាហ្ន៎ ?” ដូច្នេះ ហើយ ទ្រង់ជ្រាបថា “អំពើនេះប្រាកដជាអំពើដែលនាងមាគន្ទិយា បញ្ជា ឲ្យគេធ្វើហើយ ទ្រង់ព្រះចិន្តាថា មាគន្ទិយានោះដែលយើង គម្រាមកំហែង ហើយសួរ នឹងមិនប្រាប់តាមត្រង់ទេ យើងនឹងរក ឧបាយ ហើយសួរដោយ សន្សឹមៗ” ទើបត្រាស់នឹងអាមាត្យ ទាំងឡាយថា “នែ អ្នកដ៏ចម្រើន ទាំងឡាយ ក្នុងកាលមុនអំពីកាល នេះ យើងក្រោកឡើងហើយ ក៏ជា អ្នករង្កៀសសង្ស័យដោយជុំវិញ, នាងសាមាវតីរមែងស្វែងរកតែទោស របស់យើងជានិច្ច ឥឡូវនេះ នាងស្លាប់ហើយ, យើងបានត្រជាក់ចិត្តណាស់ យើង បានរស់នៅ ដោយសេចក្តីសុខហើយ” ពួកអាមាត្យ ទូលសួរថា “បពិត្រព្រះ-សម្មតិទេព កម្មនេះអ្នកណាហ្ន៎ ជាអ្នកធ្វើ ព្រះរាជាត្រាស់ឆ្លើយថា នឹងជាកម្មដែលអ្នកណាមួយធ្វើហើយដោយ សេចក្តីស្នេហាក្នុង យើង” ។ ព្រះនាងមាគន្ទិយាឈរនៅក្នុងទីជិត ឮ



ព្រះតម្រាស់នោះភ្លាមក៏ក្រាបទូលថា “អ្នកដទៃនឹងមិនអាចធ្វើបាន បពិត្រមហារាជ កម្មនេះខ្ញុំម្ចាស់ជាអ្នកធ្វើ, ខ្ញុំម្ចាស់បានបង្គាប់ពុកមា

របស់ខ្ញុំម្ចាស់ឲ្យធ្វើ ។ ព្រះរាជាត្រាស់ថា “អ្នកដែលជាទីស្រឡាញ់របស់យើងដទៃក្រៅអំពីនាង រមែងមិនមាន យើងពេញចិត្តណាស់ ម្នាលនាងទេវី ខ្ញុំនឹងឲ្យពរដល់នាង នាងចូរបញ្ជូនមនុស្សឲ្យទៅហៅពួកញាតិរបស់នាងមក” នាងមាគន្ទិយាបានផ្ញើដំណឹងទៅប្រាប់ពួកញាតិថា “ព្រះរាជាទ្រង់ពេញព្រះហឫទ័យនឹងព្រះរាជទានពរដល់យើង, សូមជនទាំងឡាយដែលជាញាតិរបស់យើង ចូរមកយ៉ាងឆាប់” ព្រះរាជាបញ្ជាឲ្យធ្វើនូវសក្ការៈធំដល់ញាតិទាំងឡាយ របស់ព្រះនាងមាគន្ទិយា ដែលមកហើយៗ សូម្បីពួកជនដែលមិន មែនជាញាតិរបស់ព្រះនាង មាគន្ទិយាឃើញសក្ការៈនោះហើយ ក៏ឲ្យនូវសំណូកហើយពោលថា “ពួកយើងជាញាតិរបស់ព្រះនាងមាគន្ទិយា” ហើយក៏បាននាំគ្នាមក កាន់រាជវាំង ។ ព្រះរាជាបញ្ជាឲ្យរាជបុរសចាប់ជនទាំងនោះទាំងអស់ទុក ហើយជីករណ្ដៅទាំងឡាយ មានជម្រៅប្រមាណត្រឹមផ្ចិត នាព្រះ

លាននៃព្រះរាជាហើយ ឲ្យជនទាំងនោះអង្គុយក្នុងរណ្ដៅទាំងនោះ ហើយយកដីកប់ បញ្ជាឲ្យរោយចំបើងពីខាងលើ ហើយឈ្លួលភ្លើងដុត, ក្នុងវេលាដែលស្បែកត្រូវភ្លើងឆេះហើយ, បញ្ជាឲ្យរាជបុរសក្ដួរដោយនង្គ័លដែកទាំងឡាយ បញ្ជាឲ្យរាជបុរសធ្វើឲ្យជាកំណាត់តូចកំណាត់ធំ ( ឬ ) ជាចំណិតតូច ចំណិតធំ ៗ ព្រះរាជាបញ្ជាឲ្យពន្លះសាច់អំពីសរីរៈរបស់នាង មាគន្ទិយា ត្រង់កន្លែងដែលមានសាច់ដុំៗដោយកាំបិតដ៏មុត ហើយឲ្យលើកឡើងកាន់ចង្ក្រានដែលឆ្អិនដោយប្រេង ឲ្យចៀនដូចជានំ ហើយបញ្ជាឲ្យនាងមាគន្ទិយាទំពាស៊ីសាច់នោះ ៗ

## សេចក្ដីស្លាប់របស់ព្រះនាងសាមាវតីសមគួរ ដល់កម្មក្នុងកាលមុន

សម័យថ្ងៃនោះ ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា “ម្នាលអាវុសោទាំងឡាយ សេចក្ដីស្លាប់ដូច្នេះ របស់ឧបាសិកាអ្នកដល់ព្រមដោយសភាពបែបនេះ មិនសមគួរសោះឡើយ” ព្រះសាស្ដា

ស្តេចយាងមកត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ អង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎" ? កាលពួកភិក្ខុទាំងនោះក្រាបទូលថា "ដោយរឿងឈ្មោះនេះ" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សេចក្តីស្លាប់របស់ស្ត្រីទាំងឡាយ មាននាងសាមាវតីជាប្រធាននោះ មិនសមគួរក្នុងអត្តភាពនេះពិតមែនហើយ ប៉ុន្តែថា សេចក្តីស្លាប់ ដែលស្ត្រី ទាំងនោះបានហើយ សមគួរដល់កម្មដែល ស្ត្រីទាំងនោះ បានធ្វើទុកក្នុង ជាតិមុន" ដែលភិក្ខុទាំងនោះទូលអារាធនាថា "បពិត្រ ព្រះអង្គដ៏ចម្រើន កម្មអ្វីដែលស្ត្រីទាំងនោះធ្វើទុកក្នុងកាល មុន" ? សូមព្រះអង្គត្រាស់ ប្រាប់ដល់ខ្ញុំព្រះអង្គទាំងឡាយ" ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទាន មក ( សម្តែងថា ) ៖

## បុព្វកម្មរបស់នាងសាមាវតី និង បរិវារ

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិនៅក្នុង ក្រុងពារាណសី ព្រះបច្ចេកពុទ្ធ ៨ ព្រះអង្គ តែងតែឆាន់នៅក្នុង

ព្រះរាជវាំងជានិច្ច ។ ស្ត្រី ៥០០ នាក់ តែងតែបម្រើព្រះបច្ចេកពុទ្ធទាំងនោះ ។

*អប្បមាទវគ្គវណ្ណនា រឿងព្រះនាងសាមាវតី - ១៥២ -*

បណ្ដាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធ ៧ ព្រះអង្គ ទៅកាន់ហិមវន្តប្រទេស មួយអង្គទៀត គង់ចូលឈាននៅក្នុងស្បាតនៃព្រៃមួយកន្ទែងក្បែរឆ្នេរស្ទឹង ។ ថ្ងៃមួយ កាលព្រះបច្ចេកពុទ្ធទៅហើយ, ព្រះរាជាទ្រង់នាំស្ត្រីទាំងនោះទៅដើម្បីលេងទឹកក្នុងស្ទឹង ស្ត្រីទាំងនោះលេងទឹកក្នុងស្ទឹងនោះរហូតអស់មួយថ្ងៃ ឡើងមកហើយត្រូវរងាបៀតបៀនប្រាថ្នានឹងអាំងភ្លើង ពោលថា "ម្នាលនាងទាំងឡាយ គប្បីរកមើលទីបង្កាត់ភ្លើងរបស់ពួកយើង ដើរទៅដើរមកឃើញគុម្ពស្មៅនោះ ក៏ឈរចោមរោមបង្កាត់ភ្លើងហើយដោយសម្គាល់ថា "គំនរស្មៅ" កាលស្មៅទាំងឡាយឆេះហើយធ្លាក់ចុះ, ស្ត្រីទាំងនោះឃើញព្រះបច្ចេកពុទ្ធក៏ពោលថា "យើងវិនាសហើយ !! ព្រះបច្ចេកពុទ្ធរបស់ព្រះរាជាត្រូវភ្លើងឆេះ ព្រះរាជាទ្រង់ជ្រាបនឹងធ្វើពួកយើងឲ្យវិនាស យើងនឹងធ្វើលោកឲ្យឆេះសុះទាំងអស់" គ្រប់គ្នានាំឧសមកអំពីទីនោះ

ទីនេះ ធ្វើឲ្យជាគំនរខាងលើព្រះបច្ចេកពុទ្ធនោះ គំនរឧសធំបានមាន ហើយលើព្រះបច្ចេកពុទ្ធ ។ គ្រានោះស្ត្រីទាំងនោះដុតឧសនោះហើយ



ចៀសចេញទៅ ដោយសម្គាល់ថា “ឥឡូវនេះ ភ្លើងឆេះអស់ហើយ” លើកមុនស្ត្រីទាំងនោះមិនមានចិត្តក្លែង ក៏ត្រូវកម្មជាប់តាម ហើយក្នុងកាលឥឡូវនេះ ក៏ជនទាំងឡាយសូម្បីនាំឧសមួយពាន់រទេះ មកដុតក៏មិនអាចនឹងធ្វើព្រះបច្ចេកពុទ្ធដែលកំពុងនៅក្នុងសមាបត្តិ សូម្បីឲ្យមាន អាការ គឺចំហាយក្តៅបន្តិចបន្តួចបាន ឡើយ ។ ក្នុងថ្ងៃទី ៧ ក៏បានក្រោកឡើងទៅតាមសប្បាយ ។ ស្ត្រីទាំងនោះឆេះក្នុងនរកអស់ច្រើនពាន់ឆ្នាំ ព្រោះកម្មដែលខ្លួនបានធ្វើទុក ហើយនោះឆេះហើយក្នុងផ្ទះដែលត្រូវ ភ្លើងឆេះដោយទំនងនេះឯង អស់មួយរយអត្តភាព ដោយវិបាកដ៏សេសនៃកម្មនោះឯង ។ នេះជាបុព្វកម្មរបស់ស្ត្រីទាំងនោះ ។

## បុព្វកម្មរបស់នាងខុជ្ជុត្តរា

កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ ភិក្ខុទាំងឡាយក៏ក្រាបទូលសួរព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន ក៏នាងខុជ្ជុត្តរាដោយសារកម្មអ្វីទៅ ទើបបានជាស្រីគម? ព្រោះកម្មអ្វី ទើបជាអ្នក



មានបញ្ញាច្រើន ? ព្រោះកម្មអ្វីទើបបានសម្រេចសោតាបត្តិផល ? ព្រោះកម្មអ្វីទើបបានជាអ្នកបម្រើអ្នកដទៃ ? ” ។ ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុ ទាំងឡាយ កាលដែលព្រះរាជាអង្គនោះឯងគ្រងរាជសម្បត្តិក្នុងក្រុង ពារាណសី ព្រះបច្ចេកពុទ្ធអង្គនោះ ជាមនុស្សគមបន្តិច ។ គ្រានោះ ស្ត្រីដែលជាឧបដ្ឋាយិកាម្នាក់ដណ្តប់សំពត់កម្ពលកាន់ផ្តិលមាសធ្វើជាមនុស្សគម សម្តែងអាការត្រោចទៅនៃព្រះបច្ចេកពុទ្ធនោះ ដោយនិយាយថា “ព្រះបច្ចេកពុទ្ធរបស់ពួកយើងរមែងត្រោចទៅយ៉ាងនេះៗ” ។ ព្រោះផលដែលហូរចេញអំពីកម្មនោះ ទើបនាងបានជាស្រីគម ។

ម្យ៉ាងទៀត ក្នុងថ្ងៃដំបូង ព្រះរាជាទ្រង់និមន្តព្រះបច្ចេកពុទ្ធទាំងនោះឲ្យគង់ក្នុងរាជដំណាក់ ហើយបញ្ជាឲ្យរាជបុរសទទួលបាត្រ ញ៉ាំង

បាត្រទាំងឡាយឲ្យពេញដោយបាយាស ហើយបញ្ជាឲ្យប្រគេនព្រះ-បច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ កាន់បាត្រដែលពេញដោយបាយាសដ៏ក្តៅ ត្រូវផ្លាស់ដៃទៅមកៗរឿយៗ ។ ស្រ្តីនោះឃើញព្រះ-



បច្ចេកពុទ្ធធ្វើយ៉ាងនោះ ក៏ប្រគេនកងដែលធ្វើអំពីភ្លុក ៨ ដែលជារបស់ខ្លួន ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចំរើនសូមលោកម្ចាស់ដាក់បាត្រលើកងទាំងនេះហើយ សូមកាន់យកទៅ" ព្រះបច្ចេកពុទ្ធទាំងនោះក៏ធ្វើយ៉ាងនោះ ។ ក្រឡេកមើលស្រ្តីនោះ នាងជ្រាបនូវសេចក្តីប្រាថ្នារបស់ព្រះបច្ចេកពុទ្ធ ទាំងឡាយ ទើបពោលថា "បពិត្រលោកម្ចាស់ ខ្ញុំម្ចាស់មិនត្រូវការកង ទាំងនេះទេ, ខ្ញុំម្ចាស់បរិច្ចាគកងទាំង នោះហើយដល់លោកម្ចាស់ទាំងឡាយនោះឯង សូមលោកម្ចាស់ទទួលយកទៅ" ។ ព្រះបច្ចេកពុទ្ធ ទាំងនោះទទួលហើយបានទៅកាន់ញកភ្នំឈ្មោះនន្ទមូលកៈ ។ សូម្បី សព្វថ្ងៃនេះកងទាំងនោះក៏នៅមិនទាន់បាត់បង់ គឺនៅលនៅឡើយ ។ ព្រោះផលដែលហូរចេញអំពីកម្មនោះ ក្នុងកាលឥឡូវនេះ ទើបនាងបានជា

អ្នកទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាច្រើន ។ ព្រោះផលដែលហូរចេញ អំពីការឧបដ្ឋាកព្រះបច្ចេកពុទ្ធទាំងឡាយ ទើបនាងបានសំរេចសោតា-បត្តិផល ។ នេះជាបុព្វកម្មក្នុងកាល ជាចន្លោះនៃព្រះពុទ្ធរបស់នាង ។ ចំណែកក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ធីតារបស់សេដ្ឋីក្នុងក្រុង



ពារាណសីម្នាក់កាន់យកកញ្ចក់ អង្គុយតាក់តែងខ្លួនក្នុងវេលានៃព្រះអាទិត្យមានស្រមោលចម្រើន (វេលារសៀល) ។ គ្រានោះ នាងភិក្ខុនីខីណាស្រពមួយរូប ដែលជាទីស្និទ្ធស្នាលនឹងនាងបានទៅសួរសុខទុក្ខនាង ។ ពិតណាស់ នាងភិក្ខុនីសូម្បីជាព្រះខីណាស្រពហើយក៏ដោយ

ក៏នៅតែប្រាថ្នាដើម្បីនឹងឃើញត្រកូលឧបដ្ឋាករបស់ខ្លួនក្នុងវេលារសៀល ។ ក៏ក្នុងខណៈនោះ ស្រ្តីបម្រើឯណានីមួយក៏មិនមាននៅក្នុងសំណាក់របស់សេដ្ឋីធីតានោះឡើយ ។ ទើបនាងពោលថា “បពិត្រព្រះនាងម្ចាស់ ខ្ញុំសូមថ្វាយបង្គំ សូមព្រះនាងមេត្តាយកកញ្ច្រែងនៃគ្រឿងប្រដាប់នោះហុចឲ្យខ្ញុំបន្តិច” ។ ព្រះថេរីគិតថា “ប្រសិនបើយើង

នឹងមិនយកកញ្ច្រែងគ្រឿងប្រដាប់នេះហុចឲ្យនាងសោត នាងនឹងចងអាឃាតនឹងយើង ក៏នឹងកើតក្នុងនរក" ប៉ុន្តែថា បើយើងនឹង (យក) ឲ្យ, នាងនឹងបានជាស្រីបម្រើអ្នកដទៃ, ប៉ុន្តែថា ត្រឹមជាអ្នកបម្រើអ្នកដទៃប្រសើរជាងកម្តៅក្នុងនរក" ។ ព្រះថេរីនោះអាស្រ័យសេចក្តីករុណា ទើបបានយកកញ្ច្រែងគ្រឿងប្រដាប់នោះហុចឲ្យនាង ។

ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ១៥៧ -

ព្រោះផលដែលហូរចេញអំពីកម្មនោះ ទើបនាងបានជាអ្នកបម្រើអ្នកដទៃ ។ ព្រះសាស្តា ស្តេចយាងមកសម្តែងធម៌ក្នុងធម្មសភា ថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងសាលាធម្មសភាថា "ស្ត្រី ៥០០ នាក់ មាននាងសាមាវតីជាប្រធាន ត្រូវភ្លើងឆេះហើយក្នុងសំណាក់, ពួកញាតិរបស់នាងមាគន្ទិយាត្រូវភ្លើងចំបើងឆេះពីខាងលើ ហើយបំបែកឲ្យបែកខ្ទេចដោយនង្គ័លដែក, ព្រះនាងមាគន្ទិយាត្រូវរាជបុរសចៀនដោយប្រេងដ៏ក្តៅគគុក, ក្នុងបណ្តាជនទាំងនោះ នរណាហ្ន៎ ឈ្មោះថា រស់នៅ ? នរណាហ្ន៎ ឈ្មោះថា ស្លាប់ហើយ" ?

ព្រះសាស្ដាស្ដេចយាងមកហើយត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះអ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎? កាលពួកភិក្ខុទាំងនោះក្រាបទូលថា “ដោយរឿងឈ្មោះនេះ” ដូច្នេះហើយ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលណាប្រមាទហើយ បុគ្គលនោះសូម្បីរស់នៅ ១០០ ឆ្នាំ ក៏ឈ្មោះថាស្លាប់ហើយដោយពិត, បុគ្គលណាមិនប្រមាទហើយ បុគ្គលនោះសូម្បីស្លាប់ហើយ ក៏ឈ្មោះថានៅ



រស់, ព្រោះដូច្នោះ ព្រះនាងមាគន្ទិយា ទោះបីរស់នៅក៏ដោយ ស្លាប់ហើយក៏ដោយ ក៏ឈ្មោះថា ស្លាប់ហើយដោយពិត ស្ត្រី ៥០០ នាក់ មានព្រះនាងសាមាវតីជាប្រធាន សូម្បីស្លាប់ហើយ ក៏ឈ្មោះថានៅរស់ដោយពិតប្រាកដ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អ្នកមិនប្រមាទហើយ ឈ្មោះថារមែងមិនស្លាប់, ដូច្នេះហើយ បានសម្ដែងព្រះគាថាទាំងនេះថា ៖

**អប្បមាទោ អមតំ បទំ     បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ     យេ បមត្តា យថា មតា**

ឯតំ វិសេសតោ ញត្វា អបមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ យោគក្ខេមំ អនុត្តរំ ។

សេចក្ដីមិនប្រមាទ ជាផ្លូវនៃសេចក្ដីមិនស្លាប់ សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់ ជនទាំងឡាយ ដែលមិន



ប្រមាទហើយ ឈ្មោះថា មិនស្លាប់ ជនទាំងឡាយ ដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិត ជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា ( ទើបឋិតនៅ ) ក្នុងសេចក្ដីមិនប្រមាទ រីករាយក្នុងសេចក្ដីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរ ក្នុងធម៌ជាគោចរនៃអរិយបុគ្គលទាំងឡាយ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្ដីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងប៉ះពាល់នូវព្រះ-

និព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាគុណជាតដ៏ប្រសើរបំផុត ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បមាទោ** រមែងសម្តែងនូវសេចក្តីដ៏ធំទូលាយ គឺកាន់យកសេចក្តីទូលំទូលាយតាំងនៅ ។ ពិតណាស់ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកទាំងអស់ ដែលអាចារ្យទាំង-



ឡាយនាំមកពោល រមែងប្រជុំចុះក្នុងសេចក្តីមិនប្រមាទនោះឯង, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ ស្នាមជើងឯណានីមួយនៃសត្វដែលត្រាច់លើផែនដី ស្នាមជើងទាំងអស់នោះ តែងដល់នូវការប្រជុំចុះក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរីប្រាកដជាប្រសើរជាងស្នាមជើងនៃពួកសត្វទាំងនោះ ព្រោះហេតុថា ស្នាមជើងនៃដំរីជាស្នាមជើងធំ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ កុសលធម៌ទាំងអស់នោះ មានអប្បមាទធម៌ជាមូល មានអប្បមាទធម៌

ជាទីប្រជុំចុះ អប្បមាទធម៌ប្រាកដជាប្រសើរជាងធម៌ទាំងនោះ ក៏យ៉ាងនោះដែរ ។

ក៏សេចក្ដីមិនប្រមាទនោះ ដោយអត្ថ គឺការមិនទៅប្រាសចាកសតិ ព្រោះពាក្យថា “សេចក្ដីមិនប្រមាទ” នោះ ជាឈ្មោះនៃសតិដែលតាំងនៅមាំជានិច្ច ។

គប្បីជ្រាបសេចក្ដីវិនិច្ឆ័យក្នុងពាក្យថា **អមតំ បទំ,** ព្រះ-



និព្វាន ព្រះមានព្រះភាគត្រាស់ហៅថា **អមតៈ**, ព្រោះព្រះនិព្វាននោះដែលឈ្មោះថា មិនចាស់ មិនស្លាប់ ព្រោះភាវៈជាធម្មជាតិមិនកើត, ហេតុនោះ ទើបព្រះអង្គត្រាស់ហៅព្រះនិព្វានថា **អមតៈ**, សត្វទាំង-ឡាយរមែងដល់ អធិប្បាយថា រមែងសម្រេចបាននូវអមតៈដោយសេចក្ដីមិនប្រមាទនេះ ហេតុនោះ សេចក្ដីមិនប្រមាទនេះ ទើបឈ្មោះថា ជាគ្រឿងដល់, ( សេចក្ដីមិនប្រមាទ ) លោកអធិប្បាយទុកថា “ជាឧបាយនាំឲ្យសម្រេចបាននូវអមតៈ” ទើបឈ្មោះថា **អមតំ បទំ** ។

ភាវៈ គឺសេចក្តីប្រហែសទូទៅ ( ប្រហែសធ្វេស ) ឈ្មោះថា សេចក្តីប្រមាទ ។ ពាក្យថា សេចក្តីប្រមាទនោះ ជាឈ្មោះនៃការបោះបង់សតិ បណ្តែតបណ្តោយសតិ ពោលគឺ ការវង្វេងភ្លេចសតិ ។

បទថា **មច្ចុនោ** ប្រែថា នៃសេចក្តីស្លាប់ ។

បទថា **បទំ** គឺជាឧបាយ បានដល់ជាផ្លូវ ។ ពិតណាស់ បុគ្គលប្រមាទ រមែងមិនប្រព្រឹត្តកន្លងនូវជាតិ គឺការកើត



បាន, សូម្បីកើតហើយ ក៏រមែងចាស់ផង រមែងស្លាប់ផង ហេតុនោះ សេចក្តីប្រមាទ ទើបឈ្មោះថា ជាផ្លូវនៃមច្ចុ គឺរមែងនាំចូលទៅរកសេចក្តីស្លាប់ ។

បាទព្រះគាថាថា **អប្បមត្តា ន មីយន្តិ** ក៏បុគ្គលអ្នកប្រកបដោយសតិ ឈ្មោះថា អ្នកមិនប្រមាទហើយ ។ នរណាៗ មិនគប្បីកំណត់ថា “បុគ្គលមិនប្រមាទរមែងមិនស្លាប់ គឺជាអ្នកមិន ចាស់និងមិនស្លាប់” ដូច្នេះ, ព្រោះថា សត្វណាៗ ដែលឈ្មោះថា មិនចាស់និងមិនស្លាប់ រមែងមិនមាន, ប៉ុន្តែវដ្តៈរបស់ បុគ្គលដែល ប្រមាទ

កំណាត់មិនបាន, ( វដ្តៈ ) របស់បុគ្គលអ្នកមិនប្រមាទកំណាត់ បាន, ហេតុនោះ បុគ្គលប្រមាទ សូម្បីរស់នៅក៏ឈ្មោះថា ស្លាប់ហើយដោយពិតប្រាកដ ព្រោះអ្នកមិនផុតអំពីទុក្ខ មានជាតិទុក្ខជាដើម, ចំណែកបុគ្គលមិនប្រមាទ ចម្រើនអប្បមាទលក្ខណៈហើយ ធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលយ៉ាងឆាប់រហ័ស រមែងមិនកើតក្នុងអត្តភាពទី ២ និងទី ៣ ហេតុនោះ បុគ្គលអ្នកមិន



ប្រមាទទាំងនោះ រស់នៅក៏ដោយ ស្លាប់ហើយក៏ដោយ ក៏ឈ្មោះថា មិនស្លាប់ដោយពិត ។

បាទព្រះគាថាថា **យេ បមត្តា យថា មតា** សេចក្តីថា ចំណែកបុគ្គលណាប្រមាទហើយ បុគ្គលនោះ ដូចជាបុគ្គលដែលស្លាប់ហើយដោយការដាច់ជីវិតិន្ទ្រិយ៍ មានវិញ្ញាណទៅប្រាសហើយ ដូចជាអង្កត់ឧសដូច្នោះដែរ ព្រោះការដែលខ្លួនស្លាប់ហើយ ដោយសេចក្តីស្លាប់ គឺសេចក្តីប្រមាទ, ពិតណាស់ សូម្បីចិត្តមួយដួងថា “យើងនឹងធ្វើទាន យើងនឹងរក្សាសីល យើងនឹងធ្វើឧបោសថកម្ម”

ដូច្នេះ រមែងមិនកើតឡើងសូម្បីដល់បុគ្គលទាំងឡាយ ដែលជាគ្រ-ហស្ថ, ចិត្តមួយដួងថា យើងនឹងបំពេញវត្តទាំងឡាយ មានអាចរិយ-វត្ត និងឧបជ្ឈាយវត្តជាដើម, យើងនឹងសមាទានធុតង្គ យើងនឹងចម្រើនភាវនា” ដូច្នេះ រមែងមិនកើតដល់បុគ្គលទាំងនោះសូម្បីជាបព្វ-ជិត ដូចចិត្តមួយដួងមិនកើតឡើងដល់បុគ្គលដែលស្លាប់ហើយដូច្នោះ, បុគ្គលអ្នកប្រមាទហើយនោះ នឹងជាអ្នកមានអ្វីដែលជាគ្រឿងធ្វើឲ្យ



ផ្សេងអំពីបុគ្គលដែលស្លាប់ហើយទៅ ? ព្រោះហេតុនោះ ទើបដូចជាបុគ្គលដែលស្លាប់ហើយ” ។

បាទព្រះគាថាថា **ឯតំ វិសេសតោ ញត្វា** សេចក្តីថា ដឹងនូវហេតុដ៏ប្លែកគ្នានោះថា “ការរលាស់ចេញចាកវដ្តៈរបស់បុគ្គលប្រមាទរមែងមិនមាន របស់បុគ្គលអ្នកមិនប្រមាទរមែងមាន” ។

មានបុច្ឆាថា ក៏នរណាទៅ រមែងដឹងនូវហេតុដ៏ប្លែកគ្នានោះ ?

មានវិសជ្ជនាថា បណ្ឌិតទាំងឡាយ ដែលតាំងនៅក្នុងសេចក្តីមិនប្រមាទទើបដឹង ។

អធិប្បាយថា បណ្ឌិត គឺមេធាវី បានដល់អ្នកមានបញ្ញាទាំង-ឡាយណាដែលតាំងនៅក្នុងសេចក្តីមិនប្រមាទរបស់ខ្លួនហើយ ចំរើនសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះរមែងដឹងនូវហេតុដ៏ប្លែកគ្នានោះ ។

បាទព្រះគាថាថា **អប្បមាទេ បមោទន្តិ** សេចក្តីថា បណ្ឌិតទាំងនោះ លុះដឹងយ៉ាងនេះហើយ រមែងរីករាយ គឺជាអ្នកមានទឹកមុខរីករាយ បានដល់ ត្រេកអររីករាយក្នុងសេចក្តីមិនប្រមាទរបស់ខ្លួន



នោះ ។

បាទព្រះគាថាថា **អរិយានំ គោចរេ រតា** សេចក្តីថា បណ្ឌិតទាំងនោះរីករាយក្នុងសេចក្តីមិនប្រមាទយ៉ាងនោះ ចម្រើនសេចក្តីមិនប្រមាទនោះហើយ រមែងជាអ្នកត្រេកអរ គឺត្រេកអរក្រៃលែងក្នុងពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋាន ៤ ជាដើម និងលោកុត្តរធម៌ ៩ ប្រការ ហៅថា ធម៌ជាទីគោចរនៃព្រះអរិយៈទាំង-ឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកនៃព្រះពុទ្ធទាំងឡាយ ។

ពីរបទថា **ទេ ឈាយនោ** សេចក្ដីថា បណ្ឌិតដែលជាអ្នកមិនប្រមាទទាំងនោះ ជាអ្នកមានការសម្លឹងពិនិត្យដោយឈានទាំងពីរយ៉ាង គឺដោយអារម្មណូបនិជ្ឈាន ពោលគឺ សមាបត្តិ ៨, និងដោយលក្ខណូបនិជ្ឈាន ពោលគឺ វិបស្សនា មគ្គ និងផល ។

បទថា **សាតតិកា** ជាអ្នកមានសេចក្ដីព្យាយាមដែលប្រព្រឹត្តទៅតាមកាយ និងចិត្តជាប់តគ្នា ចាប់តាំងពីកាលដែលចេញបួសរហូតដល់ការសម្រេចអរហត្ត ។



បាទព្រះគាថាថា **និច្ចំ ទឡ្ហបរក្កមា** សេចក្ដីថា អ្នកប្រកបដោយសេចក្ដីព្យាយាមបែបនេះថា ឥដ្ឋផលឯណា ដែលបុគ្គលគប្បីសម្រេចបានដោយកម្លាំងរបស់បុរស ដោយសេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស មិនទាន់បានសម្រេចនូវឥដ្ឋផលនោះ ហើយបញ្ឈប់នូវសេចក្ដីព្យាយាម នឹងមិនមាន (ដូច្នេះ) ឈ្មោះថា សេចក្ដីប្រឹងប្រែងមាំមួន ដែលខ្លួនមិនបន្ធូរបន្ថយក្នុងចន្លោះឲ្យប្រព្រឹត្តទៅអស់កាលជានិច្ច ។

ពាក្យថា **ផុសន្តិ** នេះ គប្បីជ្រាបសេចក្តីវិនិច្ឆ័យដូចតទៅនេះ

ការពាល់ត្រូវមាន ២ គឺញាណផុសនា ( ការពាល់ត្រូវដោយញាណ ) វិបាកផុសនា ( ការពាល់ត្រូវដោយវិបាក ) ។ បណ្តាផុសនា ២ យ៉ាងនោះ មគ្គ ៤ ឈ្មោះថា ញាណផុសនា ។ ផល ៤ ឈ្មោះថា វិបាកផុសនា ក្នុងផុសនា ២ យ៉ាងនោះ វិបាកផុសនា ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងបទថា **ផុសន្តិ** នេះ បណ្ឌិតកាលធ្វើនិទានឲ្យជាក់ច្បាស់ដោយអរិយផល ឈ្មោះថា រមែងធ្វើ



និព្វាន ឲ្យជាក់ច្បាស់ដោយវិបាកផុសនា ។

បាទព្រះគាថាថា **យោគក្ខេមំ** សេចក្តីថា ( នូវព្រះនិព្វាន ) ដែលជាដែនក្សេម គឺមិនមានភ័យ ចាកយោគៈ ៤ ដែលញុំាងមហាជនឲ្យលិចចុះក្នុងវដ្តៈ ដែលឈ្មោះថា កំពូល ព្រោះជាគុណជាតិប្រសើរជាងលោកិយធម៌ និងលោកុត្តរធម៌ទាំងពួង ។

ក្នុងទីបំផុតនៃធម្មទេសនា ជនជាច្រើនបានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើម ទេសនាជាកថាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

( រឿងព្រះនាងសាមាវតី ចប់ )

*************

## ២. រឿងកុម្ភឃោសកៈ

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសេដ្ឋី ឈ្មោះ កុម្ភឃោសកៈ ត្រាស់ព្រះធម្មទេសនាដូច្នេះថា “**ឧដ្ឋានវតោ**” ដូច្នេះ ជាដើម ។

# កុម្ភឃោសកៈខ្លាចស្លាប់គេចចេញទៅនៅក្នុំ

សេចក្ដីពិស្ដារថា ក្នុងក្រុងរាជគ្រឹះ អហិវាតករោគ ( រោគកើតអំពីខ្យល់មានពិសដូចជាពិសពស់ ) កើតឡើងក្នុងផ្ទះរបស់រាជ-គហសេដ្ឋី ។ កាលអហិវាតរោគនោះកើតឡើងហើយ សត្វតិរច្ឆានទាំងឡាយ ចាប់តាំងពីរុយក្បាលខៀវរហូតដល់គោរមែងស្លាប់ទៅមុន បន្ទាប់អំពីនោះមក ទាសៈ និងកម្មករ, ខាងក្រោយគេបង្អស់គឺម្ចាស់ផ្ទះ ព្រោះហេតុនោះ រោគនោះក៏ចាប់សេដ្ឋី និងភរិយាក្រោយគេបង្អស់ពីរនាក់ស្វាមីភរិយានោះកាល់ត្រូវ រោគពាល់ត្រូវហើយសម្លឹងមើលបុត្ត ដែលឈរនៅជិត មាននេត្រាទាំងពីរពេញទៅដោយទឹកភ្នែកពោល



ទៅកាន់បុត្តថា “នែ កូនសម្លាញ់ បានឮថា កាលរោគប្រភេទនេះកើតឡើង ជនទាំងឡាយ ទម្លាយជញ្ជាំងរត់គេចចេញទៅ រមែងបានជីវិត”, កូនឯងមិនចាំបាច់ហួងហែង ឬក៏អាលោះអាល័យចំពោះយើងទាំងពីរតេទ គប្បីរត់គេចចេញទៅឲ្យប្រញាប់ កាលមានជីវិតរស់នៅ

គប្បីត្រឡប់មកវិញ ហើយគាស់យកទ្រព្យ ៤០ កោដិ ដែលយើងទាំងពីរកប់ទុកក្នុងទីឯណោះឡើងចិញ្ចឹមជីវិតចុះ” ។

សេដ្ឋីបុត្រស្តាប់ពាក្យរបស់មាតា និងបិតានោះហើយ យំសំពះមាតាបិតា ខ្លាចចំពោះមរណភ័យ ទម្លាយជញ្ជាំងផ្ទះរត់គេចចេញទៅកាន់ស្បាតនៃភ្នំ នៅក្នុងទីនោះអស់ ១២ ឆ្នាំហើយ ត្រឡប់មកកាន់លំនៅរបស់មាតាបិតាវិញ ។

## សេដ្ឋីបុត្រត្រឡប់មកស្រុកកំណើត មិនមាននរណាស្គាល់

គ្រានោះ នរណាៗ ក៏មិនស្គាល់សេដ្ឋីបុត្តនោះ ព្រោះការដែលសេដ្ឋីនោះទៅក្នុងកាលដែលខ្លួននៅក្មេង ត្រឡប់មកក្នុងកាល



មានសក់ ពុកមាត់ ពុកចង្កាដុះឡើងទ្រុបទ្រុល ។

សេដ្ឋីបុត្រនោះ ទៅកាន់ទីកប់កំណប់ទ្រព្យដោយអំណាចនៃគ្រឿងសំគាល់ដែលមាតាបិតាឲ្យហើយ ដឹងថាទ្រព្យមិនទាន់ វិនាសក៏គិតថា “នរណាៗ ក៏មិនស្គាល់យើង” ។ ប្រសិនបើយើងនឹង

គាស់កំណប់ទ្រព្យឡើងប្រើប្រាស់សោត ជនទាំងឡាយគប្បីគិតថា "បុរសទុគ៌តម្នាក់នេះគាស់កំណប់ទ្រព្យឡើងហើយ, គប្បីចាប់យើងហើយបៀតបៀន, បើដូច្នោះ យើងគប្បីធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិតចុះ គ្រានោះ សេដ្ឋីបុត្រនោះស្លៀកសំពត់ចាស់មួយផ្ទាំង ដើរសួរថា "មាននរណាត្រូវការកម្មករដែរឬទេ" ( ទៅ ) ដល់ភូមិដែលជាលំនៅនៃពួកកម្មករ ។

## កុម្ភឃោសកៈទទួលធ្វើការងារ

គ្រានោះ ពួកអ្នកជួលឃើញសេដ្ឋីបុត្រនោះហើយ ពោលថា "ប្រសិនបើឯង នឹងធ្វើការងាររបស់ពួកយើងបានមួយសោត, ពួកយើងនឹងឲ្យថ្លៃឈ្នួលសម្រាប់ទិញកត្ត" ។



សេដ្ឋីបុត្រនោះសួរថា "តើពួកលោកនឹងឲ្យខ្ញុំធ្វើការងារអ្វី"?

ពួកអ្នកជួលប្រាប់ថា "ការងារ គឺការដាស់ និងការតឿន, ប្រសិនបើឯងអាចធ្វើបានសោត, ឯងចូរក្រោកឡើងពីព្រលឹម ដើរដាស់ពួកកម្មករថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរក្រោក

ឡើង ចូរត្រៀមរទេះទាំងឡាយ, ចូរទឹមគោទាំងឡាយ វេលានេះជាវេលាទៅរកស្មៅសំរាប់សត្វពាហនៈទាំងឡាយ មាន ដំរី និងសេះ ជាដើម, ម្នាលនាងទាំងឡាយ នាងទាំងឡាយចូរក្រោក ឡើង ចូរចំអិនបបរ ភត្ត” សេដ្ឋីបុត្រនោះទទួលថា “បាន” ។

គ្រានោះ ពួកអ្នកជួលបានឲ្យផ្ទះមួយខ្នងដល់សេដ្ឋីបុត្រនោះ ដើម្បីប្រយោជន៍ដល់ការនៅក្នុងទីជិត ។ សេដ្ឋីបុត្របានធ្វើការងារនោះរាល់ៗ ថ្ងៃ ។

## ព្រះបាទពិម្ពិសារទ្រង់ជ្រាបដល់ឋានៈ របស់កុម្ភឃោសកៈ

ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះនាមថា ពិម្ពិសារ បានទ្រង់ព្រះ



សណ្តាប់សំឡេងរបស់កុម្ភឃោសកៈនោះ ។ ក៏ព្រះរាជាជាអ្នកចេះស្តាប់សំឡេងរបស់សត្វទាំងឡាយ, ព្រោះហេតុនោះ ទើបត្រាស់ថា “នោះជាសំឡេងរបស់អ្នកមានទ្រព្យច្រើន” ។

គ្រានោះ ស្រីស្នំរបស់ព្រះរាជាម្នាក់ ដែលឈរគាល់ព្រះរាជា នៅក្នុងទីជិតគិតថា "ធម្មតាព្រះរាជាមិនត្រាស់នូវពាក្យផ្តេសផ្តាស់, យើងគួរដឹងនូវហេតុនេះឲ្យជាក់ច្បាស់" ។ ទើបបញ្ជូនបុរសម្នាក់ទៅ ( ស៊ើប ) ដោយពាក្យថា "នែ អ្នក អ្នកឯងចូរទៅស៊ើបឲ្យដឹងច្បាស់ នូវរឿងរបស់បុរសនោះ ( ហើយត្រឡប់មកប្រាប់យើង )" ។

បុរសនោះទៅយ៉ាងប្រញាប់ ជួបកុម្ភឃោសកៈនោះហើយ ក៏ត្រឡប់មកប្រាប់ថា "នុ៎ះជាបុរសទុគ៌តម្នាក់ ដែលធ្វើការស៊ីឈ្នួលជនទាំងឡាយដើម្បីចិញ្ចឹមជីវិត" ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យរបស់បុរសនោះហើយ ក៏ទ្រង់តុណ្ហីភាព ( ស្ងៀម ) ក្នុងថ្ងៃទី ២ ក្តី ទី ៣ ក្តី លុះទ្រង់ព្រះសណ្តាប់សំឡេងរបស់កុម្ភឃោសកៈនោះហើយ ក៏ទ្រង់ត្រាស់យ៉ាងនោះទៀត ។

*ធម្មបទដ្ឋកថា អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ - ១៧៣ -*

## ស្រីស្នំទទួលអាសារព្រះបាទពិម្ពិសារ

ស្រីស្នំនោះ ក៏គិតយ៉ាងនោះទៀតដែរ បញ្ជូន ( បុរស ) ទៅច្រើនដង កាលបុរសនោះប្រាប់ថា "ជាមនុស្សទុគ៌ត" ក៏គិតថា "ព្រះ

រាជាសូម្បីទ្រង់ព្រះសណ្ដាប់នូវពាក្យថា “បុរសនោះ ជាមនុស្សទុគ៌ត” ក៏មិនទ្រង់ជឿ ហើយទ្រង់ត្រាស់ពាក្យដដែលៗទៀតថា “នុ៎ះជាសំឡេងរបស់អ្នកមានទ្រព្យច្រើន ក្នុងសេចក្ដីនេះត្រូវមានហេតុ យើងគួរតែស្គាល់បុរសនោះឲ្យបានដឹងតាមសេចក្ដីពិត” ។ ស្រីស្នំនោះ ក៏ក្រាបទូលព្រះរាជាថា “បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គ កាលបានទ្រព្យមួយពាន់នឹងនាំធីតាទៅ ( ធ្វើនូវឧបាយ ) ឲ្យទ្រព្យនោះចូលកាន់រាជត្រកូលទាល់តែបាន” ។ ព្រះរាជាបញ្ជាឲ្យព្រះរាជទានទ្រព្យមួយពាន់ដល់នាងស្នំ ។ នាងទទួលព្រះរាជទានទ្រព្យនោះហើយ ឲ្យធីតាស្លៀកសំពត់ចាស់មួយផ្ទាំង ធ្វើដំណើរចេញចាកព្រះរាជវាំងជាមួយនឹងធីតានោះ ធ្វើអាការដូចជាអ្នកដើរផ្លូវ ទៅកាន់ភូមិដែលជាទីនៅនៃពួកកម្មករ ចូលទៅកាន់ផ្ទះមួយ ហើយនិយាយថា “បពិត្រនាងដ៏ចម្រើន



ខ្ញុំទាំងពីរនាក់ធ្វើដំណើរមកអំពីទីឆ្ងាយ ( ហត់នឿយខ្លាំងណាស់ ) សូម សម្រាកនៅក្នុងផ្ទះនេះ ២-៣ ថ្ងៃ បានដែរឬទេ” ។

## ស្រីស្នំ និង ធីតាសម្រាកនៅក្នុងផ្ទះ

# របស់កុម្ភឃោសកៈ

ស្ត្រីដែលជាម្ចាស់ផ្ទះពោលថា "ម្នាលនាងដ៏ចម្រើន មនុស្សដែលនៅផ្ទះនេះមានច្រើននាក់ណាស់ នាងមិនអាចសម្រាកក្នុងផ្ទះនេះបានទេ ផ្ទះរបស់នាយកុម្ភឃោសកៈនោះទំនេរ នាងអញ្ជើញទៅ (សុំសម្រាក) ក្នុងផ្ទះនោះចុះ" ។ នាងស្នំទៅកាន់ផ្ទះរបស់កុម្ភឃោសកៈនោះហើយ ពោលថា "នែ អ្នកដ៏ចម្រើន យើងខ្ញុំទាំងពីរនាក់ជាអ្នកធ្វើដំណើរផ្លូវឆ្ងាយ នឹង ( សុំសម្រាក ) នៅក្នុងផ្ទះនេះមួយថ្ងៃ ឬក៏ពីរថ្ងៃ" សូម្បីត្រូវកុម្ភឃោសកៈហាមឃាត់ហើយច្រើនដងក៏ដោយ ក៏នៅតែនិយាយអង្វរថា "នែ អ្នកដ៏ចម្រើន ខ្ញុំទាំងពីរនាក់នឹងសុំសម្រាកនៅក្នុងផ្ទះនេះថ្ងៃនេះមួយថ្ងៃ ព្រឹកឡើងនឹងទៅហើយ", មិនប្រាថ្នានឹងចេញទៅ ។ នាងសម្រាកនៅក្នុងផ្ទះរបស់កុម្ភឃោសកៈនោះឯង



លុះព្រឹកឡើង ក្នុងវេលាដែលកុម្ភឃោសកៈនោះចេញទៅព្រៃ ក៏និយាយថា "នែ អ្នកដ៏ចម្រើន សូមអ្នកចូរប្រគល់តម្លៃអាហារសម្រាប់អ្នកទុកហើយ សឹមទៅចុះ, ខ្ញុំនឹង ( ចាត់ចែង ) ដាំស្ល ទុកដើម្បីអ្នក" ។

កាលកុម្ភឃោសកៈពោលថា “កុំអីនាង ខ្ញុំនឹងដាំស្លស៊ីខ្លួនឯងក៏បាន” ក៏និយាយអង្វររឿយៗ រហូតទាល់តែបានសម្រេច ធ្វើទ្រព្យដែលកុម្ភ-ឃោសកៈឲ្យនោះ ឲ្យត្រឹមតែជាទ្រព្យដែលខ្លួនបានទទួលទុកហើយប៉ុណ្ណោះ ប្រើគេឲ្យនាំភោជន និងវត្ថុផ្សេងៗ មានអង្ករដ៏បរិសុទ្ធជាដើម មកអំពីផ្សារដាំបាយឲ្យឆ្ងាញ់ និងធ្វើម្ហូបអាហារពីរបីមុខ ដែលមានរសជាតិឆ្ងាញ់ ដូចការដាំស្លក្នុងរាជត្រកូល បានឲ្យដល់កុម្ភឃោសកៈដែលមកអំពីព្រៃ ។ លុះដឹង ( ថា ) កុម្ភឃោសកៈបរិភោគហើយ ដល់ភាពជាអ្នកឃ្លានមានចិត្តរីករាយ ក៏និយាយថា “នែ អ្នកដ៏ចម្រើន ខ្ញុំទាំងពីរនាក់ជាអ្នកហត់នឿយ សូមសម្រាកនៅផ្ទះនេះពីរបីថ្ងៃទៀតចុះ” កុម្ភឃោសកៈក៏ទទួលថា “បាន” ។

អប្បមាទវគ្គវណ្ណនា រឿងកុម្ភឃោសកៈ - ១៧៦ -

## កុម្ភឃោសកៈដឹងនាងស្នំជាស្រីស្នំរបស់ព្រះរាជា

គ្រានោះ នាងក៏ចំអិនអាហារយ៉ាងឆ្ងាញ់ពិសា ទាំងក្នុងវេលាល្ងាច ទាំងក្នុងវេលាព្រឹក ហើយបានឲ្យដល់កុម្ភឃោសកៈ ។

លុះដឹងនូវការៈនៃសេដ្ឋីបុត្រនោះ ជាអ្នកមានចិត្តរីករាយហើយក៏អង្វរ ( ទៀត ) ថា “នែ អ្នកដ៏ចម្រើន យើងទាំងពីរនាក់សុំនៅក្នុងផ្ទះនេះពីរបីថ្ងៃទៀត ដូច្នេះហើយ ក៏នៅក្នុងផ្ទះនោះទៅ កាលនៅក្នុងផ្ទះនោះក៏យកសស្រ្តាដ៏មុតកាត់គ្រែពួដ៏ខាងក្រោមនៃមេគ្រែក្នុងទីនោះ ៗ ។ កាលកុម្ភឃោសកៈមកវិញ គ្រាន់តែអង្គុយចុះប៉ុណ្ណោះ គ្រែក៏សំយុងចុះទៅខាងក្រោម ។

កុម្ភឃោសកៈសួរថា “ព្រោះហេតុអ្វី ទើបគ្រែនេះបាក់យ៉ាងនេះ” ?

នាងស្នំឆ្លើយថា “បពិត្រអ្នកដ៏ចម្រើន ខ្ញុំមិនអាចហាមពួកក្មេងៗ ដែលមកប្រជុំគ្នាលេងលើគ្រែនេះបាន” ។

កុម្ភឃោសកៈ. ម្នាលនាងដ៏ចម្រើន ទុក្ខនេះកើតឡើងដល់ខ្ញុំ



ព្រោះអាស្រ័យនាងទាំងពីរ ព្រោះក្នុងកាលមុន មុននឹងខ្ញុំទៅទីណាៗ បិទទ្វារហើយទើបទៅ ។

នាងស្នំ. បពិត្រអ្នកដ៏ចម្រើន ឲ្យខ្ញុំធ្វើដូចម្ដេច "បើខ្ញុំហាមឃាត់ពួកក្មេងៗ មិនបានយ៉ាងនេះ ។

នាងស្នំនោះកាត់ ( ជើងគ្រែ ) ដូចលើកមុនទៀត អស់ពីរបីថ្ងៃ សូម្បីត្រូវកុម្ភឃោសកសេដ្ឋីនោះលើកទោស ហើយតិះដៀលក៏ដោយ ក៏នៅតែពោល ( ដោះខ្លួន ) ដដែលទៀត ហើយកាត់ខ្សែដ៏សេសទាំងឡាយទៀត បន្សល់ទុកតែខ្សែពីរសរសៃប៉ុណ្ណោះ ។

ថ្ងៃនោះ កាលកុម្ភឃោសកៈគ្រាន់អង្គុយចុះប៉ុណ្ណោះ ( គ្រែ ) ទាំងអស់ក៏ធ្លាក់ចុះលើផែនដី ។ សិរសា ( របស់កុម្ភឃោសកៈ ) បាន ( ធ្លាក់ចុះ ) ទៅជាមួយនឹងជង្គង់ទាំងឡាយ កុម្ភឃោសកៈនោះក្រោកឡើងហើយក៏បាននិយាយថា "ខ្ញុំនឹងធ្វើដូចម្ដេច ? ឥឡូវនេះ ខ្ញុំនឹងទៅទីណា? ខ្ញុំជាអ្នកត្រូវពួកនាងធ្វើមិនឲ្យជាម្ចាស់នៃគ្រែដេកហើយ"។

នាងស្នំលួងលោមថា "នែ អ្នកដ៏ចម្រើន នឹងធ្វើដូចម្ដេចទៅ



បើខ្ញុំមិនអាចហាមឃាត់ពួកក្មេងៗ ដែលវាមកលេងលើគ្រែយ៉ាងនេះបាន, ណ្ហើយចុះ អ្នកកុំគិតឡើយ អ្នកនឹងទៅណាបានឥឡូវនេះ"

ដូច្នេះហើយ ហៅធីតាប្រាប់ថា “នែ កូន កូនឯងចូរធ្វើឱកាសសម្រាប់ជាទីដេកដល់បងប្រុសរបស់កូនឯងផងចុះ” ។

## <u>កុម្ភឃោសកៈបានកូនស្រីនាងស្នំជាភរិយា</u>

ធីតានោះដេកក្នុងចំណែកម្ខាងហើយ ពោលថា “បពិត្រអ្នកជាម្ចាស់ សូមមកដេកទីនេះចុះ” សូម្បីនាងស្នំក៏ពោលនឹងកុម្ភឃោសកៈនោះថា “នែ អ្នកដ៏ចម្រើន សូមអ្នកទៅដេកជាមួយនឹងប្អូនស្រីចុះ” ។ កុម្ភឃោសកសេដ្ឋីដេកលើគ្រែមួយ ជាមួយនឹងធីតារបស់នាងស្នំនោះ បានធ្វើនូវសន្ថវៈក្នុងថ្ងៃនោះឯង ។ នាងកុមារិកានោះទួញយំ ។ ក្នុងពេលនោះ មាតារបស់នាងក៏សួរនាងថា “នែ កូនស្រី ហេតុដូចម្ដេចបានជាកូនឯងយំ” ?

ធីតា. បពិត្រមាតា កម្មបែបនេះកើតឡើងហើយ ។

មាតានិយាយថា ម្នាលកូនដ៏ចម្រើន រឿងហ្នឹងលើកទុកសិន



ចុះ យើងធ្វើដូចម្ដេចបាន ការដែលកូនឯងបានបុរសនេះជាស្វាមីក្ដី ការដែលកុម្ភឃោសកៈបានកូនឯងជាភរិយាក្ដី រមែងសមគួរ ដូច្នេះ

ហើយ បានធ្វើកុម្ភឃោសកៈនោះឲ្យជាកូនប្រសារបស់ខ្លួន ។ គេទាំងពីរនាក់នៅរួមគ្នាដោយការព្រមព្រៀងគ្នា ។

## កុម្ភឃោសកៈចំណាយទ្រព្យព្រោះឧបាយរបស់នាងស្នំ

ដោយកាលកន្លងទៅ ២-៣ ថ្ងៃ នាងស្នំនោះក៏បញ្ជូនដំណឹងទៅ ( ក្រាបទូល ) ព្រះរាជាថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គបញ្ជាឲ្យធ្វើការឃោសនាថា "ប្រជាជនចូរបាត់បែងធ្វើមហោស្រពក្នុងវិថីនៃជនអ្នកជួល, ក៏បុគ្គលណាមិនបាត់បែងធ្វើមហោស្រពក្នុងផ្ទះ, ពិន័យប្រមាណប៉ុណ្ណេះ រមែងមានដល់បុគ្គលនោះ ។

ព្រះរាជាបញ្ជាឲ្យធ្វើយ៉ាងនោះ ។ គ្រានោះ ម្ដាយក្មេកនិយាយនឹងកុម្ភឃោសកៈថា "នែ អ្នកដ៏ចម្រើន យើងចាំបាច់ត្រូវបាត់បែងធ្វើមហោស្រពក្នុងវិថីដែលពួកកម្មកររស់នៅតាមព្រះរាជបញ្ជា, យើង



នឹងធ្វើដូចម្ដេច" ?

កុម្ភឃោសកៈ. បពិត្រម៉ែ ខ្ញុំនេះសូម្បីតែធ្វើការស៊ីឈ្នួលគេក៏ស៊ើរតែមិនអាចរស់នៅបានផង នឹងចាត់ចែងធ្វើមហោស្រពបានដូចម្ដេចទៅ ។

ម្ដាយក្មេក. ម្នាលកូន ធម្មតាបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះទាំង-ឡាយ ត្រូវតែទទួលយកបំណុលនេះ ព្រះរាជាទ្រង់ចេញព្រះរាជបញ្ញាហើយ មិនធ្វើតាមមិនបាន, យើងអាចរួចផុតចាកបំណុលបានដោយឧបាយណាមួយ ណ្ហើយចុះ កូនឯងចូរទៅនាំយកកហាបណៈ ១-២ កហាបណៈអំពីទីណាៗ ក៏បាន ។

## នាងស្នំបញ្ជូនទ្រព្យរបស់កុម្ភឃោសកៈ ទៅថ្វាយព្រះរាជា

កុម្ភឃោសកៈតិះដៀលបណ្ដើរ ទៅនាំយកកហាបណៈ ១ កហាបណៈមកអំពីទីកប់កំណប់ទ្រព្យ ៤០ កោដិនោះហុចឲ្យនាងស្នំ នាងស្នំក៏បញ្ជូនកហាបណៈមួយកហាបណៈនោះ ទៅថ្វាយព្រះ

រាជា ហើយ ( ចាត់ចែង ) ធ្វើមហោស្រពដោយកហាបណៈរបស់ខ្លួន, ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនដំណឹងទៅថ្វាយព្រះ-រាជាដូចលើកមុនទៀត ។

ព្រះរាជាក៏ទ្រង់បញ្ជារាជបុរសឲ្យដើរឃោសនាទៀតថា "ប្រជាជនចូរចាត់ចែងធ្វើមហោស្រព កាលបុគ្គលណាមិនធ្វើ មានពិន័យប្រមាណប៉ុណ្ណេះ" កុម្ភឃោសកៈនោះ ត្រូវម្ដាយក្មេកពោលបន្ទិតបន្ទំដូចលើកមុននោះឯង ទើបទៅយកកហាបណៈមក ១ កហាបណៈទៀត នាងស្នំនោះក៏បញ្ជូនកហាបណៈទាំងនោះទៅ ( ថ្វាយ )ព្រះរាជា ទៀត, ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ក៏បញ្ជូនដំណឹងទៅ ( ថ្វាយ ) ព្រះរាជាទៀតថា "ឥឡូវនេះ សូមព្រះអង្គទ្រង់បញ្ជូនរាជបុរសមក បញ្ជាឲ្យហៅកុម្ភឃោសកៈ នេះទៅ ( គាល់ )" ។ ព្រះរាជាក៏ទ្រង់ បញ្ជូនរាជបុរសទៅ ។

## កុម្ភឃោសកៈត្រូវនាំខ្លួនទៅគាល់ព្រះរាជា

ពួករាជបុរសទៅកាន់លំនៅឋាន ដែលពួកកម្មករនោះនៅ

ហើយ សួររកថា "អ្នកណាឈ្មោះកុម្ភឃោសកៈ" បានជួបកុម្ភឃោ-សកៈហើយប្រាប់ថា "ម្នាលអ្នកដ៏ចម្រើន ព្រះរាជាមានរាជបញ្ជាឲ្យលោកចូលទៅគាល់" ។

កុម្ភឃោសកៈភ័យខ្លាចហើយ ពោលពាក្យដោះខ្លួនជាដើមថា "ព្រះរាជាមិនទ្រង់ស្គាល់ខ្ញុំទេ" ហើយមិនប្រាថ្នានឹងចូលទៅគាល់ ។ ពេលនោះ ពួករាជបុរសក៏ចាប់កុម្ភឃោសកៈត្រង់អវយវៈទាំងឡាយមានដៃជាដើមទាញមកដោយកម្លាំងរបស់ខ្លួន ។

ស្ត្រីដែលជាម្តាយក្មេករបស់កុម្ភឃោសកៈនោះ ឃើញបុរសទាំងនោះហើយ ក៏ធ្វើដូចជាគំរាមថា "នែ បុគ្គលប្រដៅក្រ ពួកឯងមិនគួរមកចាប់កូនប្រសាររបស់អញត្រង់អវយវៈទាំងឡាយ មានដៃជាដើមទេ" ហើយក៏លួងលោមថា "នែ កូនដ៏ចម្រើន កូនឯងកុំខ្លាចឡើយ មាតាចូលគាល់ព្រះរាជាហើយ នឹងក្រាបទូលឲ្យព្រះរាជាកាត់ដៃរបស់ពួកអ្នកដែលចាប់អវយវៈ មានដៃជាដើមរបស់កូនឯង" ហើយក៏នាំបុត្រីទៅមុន ដល់ព្រះរាជតំណាក់ហើយផ្លាស់ភេទ ប្រដាប់

តុបតែងនូវគ្រឿងអលង្ការទាំងពួង បានឈរគាល់ព្រះរាជានៅក្នុងទី ដ៏សមគួរមួយ ។ ចំណែកកុម្ភឃោសកៈ ត្រូវពួករាជបុរសចាប់ទាញ មក ( ថ្វាយ ) ព្រះរាជាទាល់តែបាន ។

## ព្រះរាជាទ្រង់សាកសួរកុម្ភឃោសកៈ

គ្រានោះ ព្រះរាជាទ្រង់ត្រាស់ទៅកាន់កុម្ភឃោសកៈដែលមក ថ្វាយបង្គំ ហើយឈរគាល់នោះថា "ឯងនេះឬ?ឈ្មោះកុម្ភឃោសកៈ"

កុម្ភឃោសកៈ. ព្រះករុណាថ្លៃវិសេស ។

ព្រះរាជា. ព្រោះហេតុអ្វី ទើបឯងបិទបាំងទ្រព្យជាច្រើនទុក ប្រើប្រាស់ ?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ទូលព្រះ បង្គំនឹងមានមកអំពីទីណា ? ព្រោះទូលព្រះបង្គំធ្វើការស៊ីឈ្នួលគេ ចិញ្ចឹមជីវិត ។

ព្រះរាជា. ឯងកុំធ្វើយ៉ាងនោះឡើយ ឯងកុហកយើងធ្វើអ្វី ?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមិនបាន

កុហកព្រះអង្គទេ ទ្រព្យរបស់ទូលព្រះបង្គំមិនមានពិតមែន ។

គ្រានោះ ព្រះរាជាទ្រង់បង្ហាញកហាបណៈទាំងនោះដល់កុម្ភ-ឃោសកៈហើយ ត្រាស់សួរថា "កហាបណៈទាំងនេះជារបស់នរណា" ?

## កុម្ភឃោសកៈប្រាប់ចំនួនទ្រព្យ

កុម្ភឃោសកៈចាំ ( កហាបណៈ ) បាន ក៏គិតថា "ឱ អញវិនាសហើយ ហេតុដូចម្តេចហ្ន៎ កហាបណៈទាំងនេះ ទើបធ្លាក់មកដល់ព្រះហស្តរបស់ព្រះរាជាទៅវិញ" ? ក្រឡេកមើលខាងនោះខាងនេះ ក៏ឃើញស្ត្រីទាំងពីរនោះ ប្រដាប់តាក់តែងឈរគោល់ព្រះរាជានៅក្បែរទ្វារបន្ទប់ ទើបគិតថា "កម្មនេះធ្ងន់ណាស់, ប្រហែលជាព្រះរាជាចាត់ចែងស្ត្រីទាំងនេះ ( ទៅបោកបញ្ឆោតយើងទេដឹង )" ។

គ្រានោះព្រះរាជាត្រាស់ទៅកាន់កុម្ភឃោសកៈថា "ម្នាលអ្នកដ៏ចម្រើន អ្នកឯងនិយាយទៅចុះ ហេតុដូចម្តេច ទើបអ្នកឯងធ្វើយ៉ាងនោះ" ។

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ព្រោះទីពឹងរបស់ទូលព្រះបង្គំមិនមាន ។

ព្រះរាជា. មនុស្សប្រាកដដូចជាយើងមិនគួរជាទីពឹងរបស់អ្នកឯងទេឬ ?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ប្រសិនបើព្រះអង្គទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គសោត នោះជាការប្រពៃណាស់ ។

ព្រះរាជា. ម្នាលអ្នកដ៏ចម្រើន បាន, ទ្រព្យរបស់ឯងមានចំនួនប៉ុន្មាន ?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ខ្ញុំព្រះអង្គមាន ៤០ កោដិ ។

ព្រះរាជា. បានអ្វីយកទៅជញ្ជូន ទើបសមគួរ ?

កុម្ភឃោសកៈ. បពិត្រព្រះសម្មតិទេព រទេះទាំងឡាយ ។

## កុម្ភឃោសកៈបានទទួលតំណែងជាសេដ្ឋី

ព្រះរាជា ទ្រង់បញ្ជាឲ្យបាត់បែងរទេះទាំងឡាយច្រើនរយរទេះ ហើយបញ្ជូនទៅឲ្យនាំទ្រព្យនោះមក បញ្ជាឲ្យធ្វើជាគំនរទុកនៅនាលាន

ព្រះរាជវាំងហើយ បញ្ជាឲ្យអ្នកក្រុងរាជគ្រឹះមកប្រជុំគ្នាហើយ ទ្រង់ត្រាស់សួរថា "ក្នុងព្រះនគរនេះ មាននរណា មានទ្រព្យប្រមាណប៉ុណ្ណោះដែរឬទេ"? កាលអ្នកក្រុងក្រាបទូលថា "ព្រះករុណាថ្លៃវិសេស មិនមានទេ ទ្រង់ត្រាស់សួរទៀតថា បើដូច្នោះ យើងគួរធ្វើយ៉ាងណាដល់កុម្ភឃោសកៈ កាលពួកប្រជាជននោះក្រាបទូលថា "បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់តែងតាំងកុម្ភឃោសកៈនោះ ទុកក្នុងតំណែងសេដ្ឋីទៅ សមគួរហើយ" ទើបទ្រង់តែងតាំងកុម្ភឃោសកៈនោះ ទុកក្នុងតំណែងសេដ្ឋីដោយសក្ការៈដ៏ធំ ព្រះរាជទានបុត្រីរបស់ស្រីស្នំនោះដល់កុម្ភឃោសកៈហើយ ស្ដេចទៅកាន់សំណាក់ព្រះសាស្ដាមួយអន្លើដោយកុម្ភឃោសកសេដ្ឋីនោះ ថ្វាយបង្គំហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គចូរទតមើល បុរសនេះចុះ ដែលឈ្មោះថា អ្នកមានបញ្ញាជាគ្រឿងទ្រទ្រង់បែបនេះ មិនមានបុរសនេះសូម្បីមានទ្រព្យសម្បត្តិដល់ ៤០ កោដិ ក៏មិនធ្វើអាការឆ្មើងឆ្មៃ ឬការលើកតម្កើងខ្លួន បន្ទុះបន្ទាប់មើលងាយអ្នកដទៃ, ( ធ្វើ ) ដូចជា

មនុស្សកំព្រា ស្លៀកសំពត់ចាស់ៗ ធ្វើការរកស៊ីឈ្នួលគេចិញ្ចឹមជីវិត ខ្ញុំព្រះអង្គដឹងបានដោយឧបាយនេះ, លុះដឹង ហើយ បញ្ជាឲ្យហៅមក សាកសួរដេញដោលឲ្យទទួលសារភាពថា ខ្លួនជាអ្នកមានទ្រព្យហើយ ឲ្យជញ្ជូនទ្រព្យនោះមក តែងតាំងទុកក្នុងតំណែងសេដ្ឋី ( មិនមែនតែប៉ុណ្ណោះ ) ខ្ញុំព្រះអង្គថែមទាំងបានព្រះរាជទានធីតាឲ្យដល់គេទៀតផង បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលមានបញ្ញាជាគ្រឿងទ្រទ្រង់បែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ ។

## គុណធម៌ជាហេតុចម្រើននៃយស

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវរឿងនោះហើយ ទ្រង់ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ជីវិតរបស់បុគ្គលអ្នករស់នៅយ៉ាងនោះ ឈ្មោះថា រស់នៅប្រកបដោយធម៌, ក៏កម្មមានកម្មរបស់ចោរជាដើម រមែងបៀតបៀន ( បុគ្គលអ្នកធ្វើ ) ទាំងក្នុងលោកនេះផង ទាំងក្នុងលោកខាងមុខផង ឈ្មោះថា សេចក្តីសុខមានកម្មនោះជាហេតុ មានកម្មនោះជាដែនកើត មិនមាន, ក៏បុគ្គលអ្នកធ្វើការស៊ីឈ្នួលគេក្តី ធ្វើ

ស្រេក្តី ចិញ្ចឹមជីវិតក្នុងកាលសាបសូន្យនូវទ្រព្យនោះឯង ឈ្មោះថា ជីវិតប្រកបដោយធម៌, ព្រោះថា ភាពជាធំ ( យស ) រមែងចម្រើន ឡើងតែម្យ៉ាង ដល់បុគ្គលអ្នកដល់ព្រមដោយសេចក្តីព្យាយាម បរិ-បូណ៌ដោយសតិ មានការងារដ៏បរិសុទ្ធដោយទ្វារទាំងឡាយ មាន កាយទ្វារ និងវចីទ្វារជាដើម មានប្រក្រតីពិចារណាដោយបញ្ញាហើយ ទើបធ្វើ អ្នកសង្រួមនូវទ្វារទាំងឡាយ មានកាយទ្វារជាដើម ចិញ្ចឹម ជីវិតដោយធម៌ តាំងនៅក្នុងសេចក្តីមិនប្រមាទបែបនោះ” ។ ដូច្នេះ ហើយ ត្រាស់ព្រះគាថានេះថា ៖

**២ ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ**
**សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ**

**យសតែងចម្រើនយ៉ាងក្រៃលែង ដល់បុគ្គលអ្នកមាន សេចក្តីប្រឹងប្រែង មានស្មារតី មានការងារស្អាត ( ឥត ទោស ) ជាអ្នកពិចារណារួចហើយទើបធ្វើ ជាអ្នក សង្រួម រស់នៅដោយធម៌ មិនមានសេចក្តីប្រមាទ ។**

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ឧដ្ឋានវតោ** គឺអ្នកមានសេចក្ដីព្យាយាមជាគ្រឿងក្រោកឡើង ។

បទថា **សតីមតោ** អ្នកបរិបូណ៌ដោយសតិ ។

បទថា **សុចិកម្មស្ស** គឺប្រកបដោយការងារទាំងឡាយ មានការងារតាមផ្លូវកាយជាដើមប្រាសចាកទោស គឺមិនមានការខុសឆ្គាំ-ឆ្គង ។

បទថា **និសម្មការិនោ** បានដល់ កំណត់ប្រៀបធៀប គឺពិចារណានូវហេតុដែលជាដែនកើតនៃផលយ៉ាងនេះថា ប្រសិនបើផលយ៉ាងនេះនឹងមាន យើងនឹងធ្វើយ៉ាងនេះ ឬថា កាលការងារនេះដែលយើងធ្វើហើយយ៉ាងនេះ ផលបែបនេះនឹងមាន ដូច្នេះហើយ ធ្វើនូវការងារទាំងពួង ដូចពេទ្យត្រួតពិនិត្យដើមហេតុ ( មេរោគ ) ហើយទើបព្យាបាលរោគដូច្នោះ ។

បទថា **សញ្ញតស្ស** បានដល់ សង្រួមហើយ គឺមិនមានចន្លោះ

ដោយទ្វារទាំងឡាយ មានកាយទ្វារជាដើម ។

បទថា **ធម្មជីវិនោ គឺ**អ្នកជាគ្រហស្ថ វៀរចាកនូវអំពើកោង ទាំងឡាយ មានអំពើកោងដោយជញ្ជីងជាដើមហើយ ចិញ្ចឹមជីវិត ដោយការងារដ៏ប្រពៃទាំងឡាយ មានធ្វើស្រែ និងចិញ្ចឹមគោជាដើម, អ្នកជាបព្វជិតវៀរចាកអនេសនាកម្មទាំងឡាយ មានវេជ្ជកម្ម និងទូត-កម្មជាដើមស្រេចហើយ ចិញ្ចឹមជីវិតដោយកិច្ចាចារដ៏ប្រពៃតាមធម៌ ។

បទថា **អប្បមត្តស្ស** គឺជាអ្នករស់នៅដោយមិនមានការ ប្រាសចាកសតិ ( មិនឃ្លាតឆ្ងាយអំពីសតិ ) ។

បទថា **យសោភិវឌ្ឍតិ** សេចក្ដីថា យស ដែលបានដល់ ភាពជាធំ ការមានភោគសម្បត្តិ និងការរាប់អាន និងបានដល់ ការមានកេរ្តិ៍ឈ្មោះបោះសំឡេង និងការសរសើររមែងចម្រើន ។

ក្នុងកាលចប់ព្រះគាថា កុម្ភឃោសកៈតាំងនៅក្នុងសោតាបត្តិ-ផល ។ ជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ទេសនាបានសម្រេចជាប្រយោជន៍ហើយដល់

មហាជនដូច្នេះឯង ។

( រឿងកុម្ភឃោសកៈ ចប់ )

**********

## ៣. រឿងព្រះចូឡបន្ថកត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារពព្រះថេរៈឈ្មោះ ចូឡបន្ថកៈ ត្រាស់ព្រះធម្មទេសនានេះថា “**ឧដ្ឋានេនប្បមាទេន**” ដូច្នេះ ជាដើម ។

## <u>សេដ្ឋីធីតាបានទាសៈជាស្វាមី</u>

មានសេចក្តីតំណាលមកថា ធីតានៃត្រកូលរបស់ធនសេដ្ឋីក្នុងព្រះនគររាជគ្រឹះក្នុងវេលាខ្លួនចម្រើនវ័យឡើង មាតាបិតារក្សាទុកយ៉ាងមាំមួនលើប្រាសាទជាន់ទី ៧ ( ប៉ុន្តែនាង ) ជាស្ត្រីឡេះឡោះក្នុងបុរស ព្រោះភាពជាអ្នកស្រវឹងហើយដោយសេចក្តីស្រវឹងក្នុងភាពជាស្រីក្រមុំ ទើបធ្វើសន្ថវៈនឹងទាសៈរបស់ខ្លួនឯង ហើយខ្លាចក្រែងថា ( អ្នកដទៃនឹងគប្បីដឹងអំពើនេះរបស់ខ្លួន ) ទើបនិយាយនឹងបុរសនោះយ៉ាងនេះថា “យើងទាំងពីរមិនអាចនៅក្នុងទីនេះបានទេ, ប្រសិនបើមាតាបិតារបស់ខ្ញុំដឹងនូវរឿងនេះសោត នឹងកាប់ចិញ្ច្រាំយើងឲ្យជា

កំណាត់តូច និងកំណាត់ធំ យើងនឹងទៅកាន់ទីកន្លែងផ្សេងហើយរស់នៅ” ទាំងពីរនាក់នោះកាន់យកទ្រព្យដែលជាសារៈ ដែលគប្បីនាំយកទៅបានដោយដៃ ចេញទៅតាមទ្វារខាងជើងហើយ បបួលគ្នាថា “យើងទាំង ពីរនឹងត្រូវទៅនៅក្នុងទីណាមួយដែលជនដទៃមិនស្គាល់” ដូច្នេះហើយ ទាំងពីរនាក់ក៏បានធ្វើដំណើរចេញទៅ ។

## <u>មានបុត្រជាមួយគ្នា</u> ២ <u>នាក់</u>

កាលគេទាំងពីរនាក់នៅក្នុងទីកន្លែងមួយ នាងតាំងគភ៌ហើយព្រោះអាស្រ័យការនៅរួមគ្នា គភ៌ចាស់ដោយជុំវិញហើយ ក៏ប្រឹក្សានឹងស្វាមីនោះថា “គភ៌របស់ខ្ញុំដល់ការចាស់ដោយជុំវិញហើយ, ធម្មតាការប្រសូតិបុត្រក្នុងទីដែលប្រាសចាកញាតិ និងផៅពង្សទាំងឡាយរមែងជាហេតុនាំមកនូវសេចក្តីទុក្ខឲ្យដល់យើងទាំងពីរ, យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូលដើមចុះ” បុរសជាស្វាមីនោះពោលបណ្តោះ-បណ្តៃថា ថ្ងៃនេះកុំអាលទៅអី ចាំថ្ងៃស្អែកសិនសឹមទៅ ញុំាងថ្ងៃទាំងឡាយឲ្យកន្លងហួសទៅ ដោយការខ្លាចថា “ប្រសិនបើយើងទៅទី

នោះ ជីវិតរបស់យើងនឹងមិនមាន” ស្ត្រីដែលជាប្រពន្ធគិតថា “ស្វាមីអញនេះ ជាមនុស្សល្ងង់ខ្លៅ មិនហ៊ានទៅព្រោះការដែលខ្លួនជាអ្នកមានទោសធំ ធម្មតាមាតាបិតារមែងមានការអនុគ្រោះដោយចំណែកមួយប៉ុណ្ណោះ បុរសដែលជាស្វាមីរបស់អញនេះទៅឬមិនទៅក៏ដោយ យើងនឹងទៅ” ។

លុះស្វាមីរបស់ខ្លួនចេញអំពីផ្ទះហើយ នាងក៏ទុកដាក់នូវគ្រឿងបរិក្ខារក្នុងផ្ទះ ប្រាប់អ្នកជិតខាងថា ខ្ញុំទៅកាន់ផ្ទះនៃត្រកូលរបស់ខ្ញុំហើយ ហើយក៏ធ្វើដំណើរចេញទៅ ។ ចំណែកបុរសដែលជាស្វាមី “ត្រឡប់” មកផ្ទះ មិនឃើញភរិយា ក៏សួរអ្នកជិតខាងបានដឹងថា ទៅកាន់ផ្ទះនៃត្រកូល” ក៏ប្រញាប់តាមទៅទាន់ក្នុងចន្លោះផ្លូវ ។ សូម្បីភរិយារបស់បុរសនោះក៏បានប្រសូតបុត្រក្នុងចន្លោះផ្លូវនោះឯង ។បុរសដែលជាស្វាមីនោះសួរភរិយាថា “ម្នាលនាងដ៏ចម្រើន នេះគឺជាអ្វី” ?

ភរិយា. បពិត្រអ្នកជាម្ចាស់ កូនប្រុសទី ១ ប្រសូតហើយ ។

ស្វាមី. ឥឡូវនេះ យើងធ្វើដូចម្តេច ?

ទាំងពីរនាក់ប្តីប្រពន្ធគិតឃើញដូចគ្នាថា "យើងទាំងពីរទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ដល់កម្មណា កម្មនោះសម្រេចហើយក្នុងចន្លោះផ្លូវ យើងនឹងទៅកាន់ទីនោះធ្វើអ្វីទៀត ? ត្រឡប់ទៅវិញចុះ" ដូច្នេះហើយ ក៏នាំគ្នាត្រឡប់វិញ ។

ទាំងពីរនាក់ប្តីប្រពន្ធបានដាក់ឈ្មោះទារកនោះឯងថា "បន្ថកៈ" ព្រោះកើតក្នុងផ្លូវ ។ ក្នុងសម័យថ្ងៃក្រោយមក មិនយូរប៉ុន្មាន សេដ្ឋីធីតាក៏តាំងគភ៌ទៀត ។ ព្រឹត្តិការណ៍ទាំងពួង គប្បីឲ្យពិស្តារតាមន័យដូចលើកមុនចុះ ។

## ដាក់ឈ្មោះក្មេងទាំងពីរ

ព្រោះក្មេងដែលកើតខាងក្រោយនោះ ក៏កើតក្នុងផ្លូវដែរ ទើបមាតាបិតាដាក់ឈ្មោះបុត្រដែលកើតមុនថា "មហាបន្ថកៈ" ដាក់ឈ្មោះបុត្រដែលកើតខាងក្រោយថា "ចុល្លបន្ថកៈ" ។

សូម្បីស្វាមីភរិយាទាំងពីរនាក់នោះ ក៏នាំក្មេងទាំងពីរទៅកាន់លំនៅរបស់ខ្លួនដូចដើម ។

# មហាបន្ថកៈសួររកញាតិរបស់ខ្លួន

កាលស្វាមីភរិយាទាំងពីរនាក់នៅក្នុងទីនោះ ទារកឈ្មោះមហាបន្ថកៈបានឮក្មេងៗដទៃហៅ ( អ្នកនេះអ្នកនោះ ) ថា ឪពុកមា ឪពុកធំ ដូច្នេះផង ( ជីតា ជីដូន ) ដូច្នេះផង" ទើបសួរមាតាថា បពិត្រម៉ែ ក្មេងដទៃៗ ហៅ ( អ្នកនោះ ) ថា ជីតា, ហៅ ( អ្នកនេះ ) ជីដូន ( យាយ ) ជនទាំងឡាយដែលជាញាតិរបស់យើងមិនមានខ្លះទេឬ" ?

មាតា. ម្នាលកូនសម្លាញ់ ជនទាំងឡាយដែលជាញាតិរបស់យើងក្នុងទីនេះមិនមាន, ប៉ុន្តែជីតារបស់ពួកកូនឯង ឈ្មោះធនសេដ្ឋីមាននៅក្នុងនគររាជគ្រឹះ ជនទាំងឡាយដែលជាញាតិរបស់យើងជាច្រើន មាននៅក្នុងនគរនោះ ។

មហាបន្ថកៈ. បពិត្រម៉ែ ព្រោះហេតុអ្វី ទើបយើងមិនទៅទីនោះ ?

សេដ្ឋីធីតាមិនប្រាប់នូវហេតុដែលខ្លួនមកដល់បុត្រ កាលបុត្រទាំងពីរសួររឿយៗ ទើបប្រាប់ដល់ស្វាមីថា "កូនយើងទាំងពីរនាក់នេះ

ក្រុកកូនខ្ញុំខ្លាំងណាស់ មាតាបិតាឃើញពួកយើងហើយ នឹងទំពាស៊ីសាច់ឬ ណ្ហើយចុះ ឥឡូវនេះ យើងទាំងពីរនឹងសម្ដែងនូវត្រកូលនៃជីតា ជីដូនដល់ពួកកូនយើងទាំងពីរចុះ” ។

ស្វាមី. ខ្ញុំមិនអាចនឹងចូលទៅបង្ហាញមុខបានទេ តែណ្ហើយចុះខ្ញុំនឹងនាំពួកក្មេងទាំងនោះទៅបាន ។

ករិយា. សាធុ ប្រពៃណាស់ ក្មេងទាំងពីរនេះគួរតែឃើញនូវត្រកូលនៃជីតាដោយឧបាយយ៉ាងណាមួយដោយពិត ។

## នាំបុត្រទាំងពីរទៅរកជីតា

ទាំងពីរនាក់ស្វាមីករិយានាំក្មេងៗ ទៅដល់នគររាជគ្រឹះដោយលំដាប់ សម្រាកនៅក្នុងសាលាមួយខាងទៀបទ្វារព្រះនគរ ។ មាតារបស់ក្មេងនាំក្មេងទាំងពីរនាក់ទៅហើយ ញ៉ាំងបុគ្គលឲ្យប្រាប់នូវការៈនៃខ្លួនជាអ្នកនាំយកនូវក្មេងទាំងពីរមកហើយដល់មាតាបិតា ។

សេដ្ឋី និងសេដ្ឋីនីទាំងពីរនាក់នោះ បានឮដំណឹងនោះហើយពោលថា “បណ្ដាជនទាំងឡាយ អ្នកត្រាច់រង្គាត់នៅក្នុងសង្សារ ដែល

ឈ្មោះថា មិនធ្លាប់ជាបុត្រ មិនធ្លាប់ជាធីតានឹងគ្នានោះ រមែងមិនមាន, បុគ្គលទាំងពីរនាក់នោះ មានកំហុសចំពោះយើងទាំងពីរនាក់ជំណាស់ ពួកគេមិនអាចនឹងតាំងនៅក្នុងគន្លងចក្ខុរបស់យើងបានទេ, អ្នកទាំងពីរ ចូរយកទ្រព្យប្រមាណប៉ុណ្ណេះ ទៅកាន់ទីដ៏ជាទីសប្បាយហើយរស់ នៅចុះ ប៉ុន្តែចូរបញ្ជូនក្មេងទាំងពីរនោះមកឲ្យយើង" ។

ទាំងពីរនាក់ស្វាមីភរិយានោះ ទទួលយកទ្រព្យដែលមាតាបិតា បញ្ជូនមកហើយ ប្រគល់ក្មេងទាំងពីរក្នុងដៃនៃអ្នកបម្រើដែលមកនោះ ឯង បញ្ជូនក្មេងទាំងពីរនាក់ទៅហើយដល់មាតាបិតា ។

ក្មេងទាំងពីរនាក់នោះ ចម្រើនវ័យនៅក្នុងត្រកូលនៃជីតា ។

## មហាបន្ថកៈចេញបួស

ក្នុងបណ្តាក្មេងទាំងពីរនាក់នោះ ចូឡបន្ថកៈនៅក្មេងណាស់, ចំណែកមហាបន្ថកៈ រមែងទៅស្តាប់ធម្មកថារបស់ព្រះទសពលជា មួយនឹងជីតា កាលមហាបន្ថកៈទៅកាន់សំណាក់របស់ព្រះសាស្តា អស់កាលជានិច្ច ចិត្តក៏បង្អោនទៅហើយក្នុងបព្វជ្ជា ។ មហាចុល្ល-

បន្ទកៈនិយាយជាមួយនឹងជីតាថា “ប្រសិនបើលោកតាអនុញ្ញាតឲ្យខ្ញុំបួសសោត ខ្ញុំបួសហើយ” ។

សេដ្ឋីពោលថា “នែ ចៅ ចៅឯងនិយាយថាអ្វី ប្រសិនបើចៅឯងបួសសោត ជីតាមានសេចក្តីត្រេកអរក្រៃលែងជាងការបួសរបស់មនុស្សទូទៅក្នុងលោក, បើចៅឯងអាចបួសបានសោត ក៏បួសចុះ” ។ ដូច្នេះហើយ នាំមហាបន្ថកៈទៅកាន់សំណាក់ព្រះសាស្តា កាលព្រះ-អង្គត្រាស់សួរថា “ម្នាលគហបតី អ្នកបានក្មេងមកឬ ? ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ក្មេងនេះជាចៅរបស់ខ្ញុំព្រះអង្គ ប្រាថ្នានឹងបួសក្នុងសំណាក់ព្រះអង្គ” ។

ព្រះសាស្តាត្រាស់បង្គាប់ភិក្ខុអ្នកមានការត្រាច់ទៅដើម្បីបិណ្ឌ-បាតជាវត្តជាប្រក្រតីមួយរូបថា “ម្នាលភិក្ខុ អ្នកចូរឲ្យក្មេងនេះបួសចុះ” ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់មហាបន្ថកៈហើយ ឲ្យបព្វជ្ជា ។

## <u>មហាបន្ថកៈសម្រេចព្រះអរហត្ត</u>

សាមណេរឈ្មោះមហាបន្ថកៈ រៀនទូវព្រះពុទ្ធវចនៈបានច្រើន

មានអាយុគ្រប់បរិបូណ៌ហើយបានឧបសម្បទា មានយោនិសោមន-សិការក្នុងកម្មដ្ឋានហើយបានសម្រេចព្រះអរហត្ត ។

## មហាបន្ថកៈនឹកដល់ប្អូនប្រុស

ព្រះថេរៈ ឈ្មោះមហាបន្ថកៈ នោះញ៉ាំងកាលឲ្យកន្លងទៅដោយសេចក្តីសុខក្នុងឈាន និងសេចក្តីសុខដែលកើតអំពីផល គិតថា "យើងអាចញ៉ាំងសេចក្តីសុខនេះឲ្យកើតឡើងដល់ចុល្លបន្ថកៈបានដែរឬហ្ន៎" ? ក្នុងលំដាប់នោះ បានទៅកាន់សំណាក់នៃសេដ្ឋីដែលជាជីតា ហើយពោលយ៉ាងនេះថា "បពិត្រមហាសេដ្ឋី ប្រសិនបើលោកអនុញ្ញាតសោត អាត្មាភាពនឹងញ៉ាំងចុល្លបន្ថកៈឲ្យចេញបួស" ។

សេដ្ឋីពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន និមន្តលោកម្ចាស់ញ៉ាំងចុល្លបន្ថកៈឲ្យបួសចុះ" ។

បានឮថា សេដ្ឋីជ្រះថ្លាដោយប្រពៃហើយ ក្នុងព្រះសាសនា ប៉ុន្តែចៀសវាងពាក្យគេសួរថា "ក្មេងទាំងនេះជាបុត្រនៃធីតាមួយណារបស់លោក" នឹងប្រាប់ថា "នៃធីតាដែលរត់បាត់ទៅនោះ" រមែងអៀន

ខ្មាស, ព្រោះហេតុនោះ ទើបអនុញ្ញាតការបួសដល់ចៅទាំងពីរនោះដោយងាយ ។

## ចូឡបន្ថកៈបួសហើយបានជាមនុស្សល្ងង់ខ្លៅ

ព្រះថេរៈញ៉ាំងចូឡបន្ថកៈឲ្យបួសហើយ ឲ្យតាំងនៅក្នុងសីលទាំងឡាយ ។ សូម្បីចូឡបន្ថកៈនោះ លុះបួសស្រេចហើយកាលណា ក៏បានជាមនុស្សល្ងង់ខ្លៅ ។

ព្រះថេរៈកាលបង្ហាត់ចូឡបន្ថកៈ លោកពោលគាថានេះ ថា

ផ្កាឈូកក្រហម មានក្លិនក្រអូប ដែលរីកឡើងអំពីព្រលឹម
មានក្លិនមិនទាន់ទៅប្រាស យ៉ាងណា អ្នកចូរឃើញព្រះ
អង្គីរសៈ គឺព្រះពុទ្ធដែលមានព្រះកាយជាដែនផ្សាយចេញ
នៃរស្មី ដូចជាព្រះអាទិត្យបញ្ចាំងរស្មីពួដ៏ផ្ទៃអាកាស ដូច្នោះ ។

តែមួយគាថាប៉ុណ្ណោះ ដោយកាលកន្លងទៅ ៤ ខែ លោកក៏មិនអាចរៀនឲ្យចាំបាន ។

## បុព្វកម្មរបស់ចូឡបន្ថកៈ

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា បានឮថា ចូឡបន្ថកៈបួសក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ជាអ្នកមានបញ្ញាបានធ្វើនូវការសើចចំអកលេង ក្នុងកាលដែលភិក្ខុល្ងង់ខ្លៅមួយរូប កំពុងរៀននូវឧទ្ទេស ( ព្រះបាលី ) ភិក្ខុរូបនោះ ខ្មាសអៀនព្រោះការសើចចំអកលេងនោះ ឈប់រៀនឧទ្ទេស មិនបានធ្វើការស្វាធ្យាយ ។

ព្រោះកម្មនោះ ចូឡបន្ថកៈនេះ គ្រាន់តែបួសហើយប៉ុណ្ណោះ ក៏ទៅជាមនុស្សល្ងង់ខ្លៅ បទធម៌ដែលរៀនរួចហើយៗ កាលលោករៀនបទខាងលើៗ តទៅទៀត ក៏បាត់ទៅអស់ ។ កាលលោកព្យាយាមដើម្បីរៀនគាថានេះឯង ៤ ខែ ក៏បានកន្លងទៅហើយ ។

## ចូឡបន្ថកៈត្រូវបងប្រុសបណ្តេញ

សម័យថ្ងៃក្រោយមក ព្រះមហាបន្ថកៈបានពោលនឹងចូឡបន្ថកៈថា “ម្នាលចូឡបន្ថកៈ អ្នកជាបុគ្គលអភ័ព្វក្នុងសាសនានេះ, ៤

ខែកន្លងទៅហើយ សូម្បីតែមួយគាថាក៏ឯងរៀនមិនចាំ, ឯងនឹងញុំាង
កិច្ចនៃបព្វជិតឲ្យដល់នូវទីបំផុតបានយ៉ាងណា ? ចូរចេញចាកវត្តនេះ
ចុះ" ដូច្នេះហើយ ក៏បណ្តេញចេញអំពីវិហារ ។

ចូឡបន្ថកៈមិនប្រាថ្នាភាពជាគ្រហស្ថ ព្រោះសេចក្តីស្នេហា
ក្នុងព្រះពុទ្ធសាសនា ។

ក៏ក្នុងកាលនោះ ព្រះមហាបន្ថកៈជាភត្តុទ្ទេសក៍ ( អ្នកសម្តែង
ឡើងនូវភត្ត) ។ វេជ្ជបណ្ឌិតឈ្មោះជីវកកោមារភច្ចកាន់យកនូវកម្រង
ផ្កា គ្រឿងក្រអូប និងគ្រឿងលាបជាច្រើនទៅកាន់វត្តអម្ពវ័ន បូជាព្រះ
សាស្តា ស្តាប់ធម្មកថា ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះទសពល
ហើយ ចូលទៅរកព្រះមហាបន្ថកៈ សួរថា "បពិត្រលោក ម្ចាស់ដ៏
ចម្រើន ភិក្ខុក្នុងសំណាក់នៃព្រះសាស្តាមានចំនួនប៉ុន្មាន" ?

ព្រះមហាបន្ថកៈ. ភិក្ខុមានប្រមាណ ៥០០ រូប ។

វេជ្ជបណ្ឌិតជីវក. បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែកនេះ
សូមលោកម្ចាស់នាំភិក្ខុ ៥០០ រូប មានព្រះពុទ្ធជាប្រធាន ( ទៅ )

ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំ ។

ព្រះមហាបន្ថកៈ ម្នាលឧបាសក ភិក្ខុ ( ល្វង់មួយរូប ) ឈ្មោះចូឡបន្ថកៈ ជាអ្នកមានធម៌មិនរីកចម្រើន, អាត្មាភាពនឹងនឹងវៀរចូឡបន្ថកៈនោះចេញ ហើយទទួលនិមន្តដើម្បីភិក្ខុទាំងឡាយដ៏សេស ។

## ព្រះចូឡបន្ថកៈចៀសចេញទៅសឹកតែសឹកមិនបាន

ព្រះចូឡបន្ថកៈឮពាក្យនោះហើយ គិតថា "ព្រះថេរៈ កាលទទួលនិមន្តដើម្បីភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណោះ ក៏ធ្វើអញឲ្យជាអ្នកខាងក្រៅហើយទើបទទួល, ចិត្តរបស់បងអញនឹងជាធម្មជាតិបែក ( អស់នូវសេចក្តីស្នេហា ) ក្នុងអញហើយ ដោយគ្មានសង្ស័យ, ឥឡូវនេះ អញនឹងត្រូវការអ្វីដោយសាសនានេះ អញនឹងជាគ្រហស្ថធ្វើបុណ្យផ្សេងៗ មានទានជាដើម នឹងរស់នៅ" ថ្ងៃស្អែកឡើង ភិក្ខុឈ្មោះចូឡបន្ថកៈដើរទៅដើម្បីសឹកពីព្រលឹម ។ ព្រះសាស្តា ទ្រង់ពិចារណាមើលនូវលោក ( គឺពួកសត្វ ) ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញហេតុនេះហើយ ទើបស្តេចទៅមុនគេបង្អស់ បានទ្រង់ប្រតិស្ឋានទី

ចង្ក្រមទៀបខ្លោងទ្វារក្បែរផ្លូវដែលជាទីទៅនៃព្រះចូឡបន្ថកៈ ។ ព្រះ-ចូឡបន្ថកៈកាលដើរទៅបានឃើញព្រះសាស្តា ក៏ចូលទៅថ្វាយបង្គំ ។

## ព្រះសាស្តាទ្រង់ជានាឲ្យនៅតទៅទៀត

គ្រានោះ ព្រះសាស្តាត្រាស់នឹងលោកថា "ម្នាលចូឡបន្ថកៈ អ្នកឯងទៅណាក្នុងវេលានេះ" ? ចូឡបន្ថកៈទូលថា "បពិត្រព្រះអង្គដ៏ចម្រើន បងប្រុសរបស់ខ្ញុំព្រះអង្គបណ្តេញខ្ញុំព្រះអង្គ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទៅដើម្បីនឹងសឹក" ។

ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលចូឡបន្ថកៈ អ្នកបព្វជ្ជាក្នុងសំណាក់តថាគត សូម្បីត្រូវបងប្រុសបណ្តេញ ហេតុដូចម្តេច ទើបមិនមកកាន់សំណាក់តថាគត ? ណ្ហើយចុះ អ្នកនឹងត្រូវការអ្វីដោយភាពជាគ្រហស្ថ អ្នកត្រូវនៅ ( តទៅ ) ក្នុងសំណាក់តថាគត ដូច្នេះហើយ ទ្រង់យកព្រះហស្តដែលមានផ្ទៃដ៏វិចិត្រទៅដោយចក្រអង្អែលសីរសៈរបស់ចូឡបន្ថកៈហើយ នាំទៅឲ្យគង់ខាងមុខព្រះគន្ធកុដិ ប្រ-ទានកំណាត់សំពត់ដ៏ស្អាត ដែលព្រះអង្គទ្រង់បណ្តាលឡើងដោយឫទ្ធិ

ដោយព្រះពុទ្ធតម្រាស់ថា “ម្នាលចូឡបន្ថកៈ” អ្នកចូរបែរមុខទៅទិសខាងកើត ឈរស្ទាបសំពត់នេះដោយបរិកម្ម ( ធ្វើទុកក្នុងចិត្ត ) ថា **រជោ-ហរណំ រជោហរណំ**” ( សំពត់ជូតធូលីៗ ) នៅទីនេះឯង លុះកាលបុគ្គលក្រាបទូលនូវភត្តកាលហើយ, មានកិក្ខុសង្ឃចោមរោមស្ដេចទៅកាន់ផ្ទះរបស់វេជ្ជបណ្ឌិតជីវក ទ្រង់គង់លើអាសនៈដែលគេតាក់តែងហើយ ។

## ព្រះចូឡបន្ថកៈចម្រើនភាវនាសម្រេចព្រះអរហត្ត

ចំណែកព្រះចូឡបន្ថកៈ អង្គុយសម្លឹងមើលព្រះអាទិត្យផងឈរស្ទាបសំពត់នោះ ហើយបរិកម្មថា “**រជោហរណំ រជោហរណំ**” ។ កាលលោកឈរស្ទាបនូវកំណាត់សំពត់នោះ កំណាត់សំពត់បានប្រាកដឡើងជារបស់សៅហ្មង ។ គ្រានោះ លោកក៏គិតថា “កំណាត់សំពត់នេះស្អាតពិតៗ ប៉ុន្តែអាស្រ័យនូវអត្តភាពនេះក៏លះបង់នូវប្រក្រតីដើមក្លាយជារបស់សៅហ្មងយ៉ាងនេះ, សង្ខារទាំងឡាយមិនទៀងមែនពិត ផ្ដើមនូវការអស់ទៅសូន្យទៅនៃសង្ខារធម៌ហើយ ចម្រើនវិបស្សនា ។

ព្រះសាស្តាទ្រង់ជ្រាបថា "ចិត្តរបស់ព្រះចូឡបន្ថកៈឡើងកាន់វិបស្សនាហើយ" ទើបទ្រង់ត្រាស់ថា "ម្នាលចូឡបន្ថកៈ អ្នកកុំសម្គាល់ចំពោះកំណាត់សំពត់នោះថា "សៅហ្មងហើយ ជិតជាមហើយដោយធូលី" ក៏ធូលីទាំងឡាយ មានធូលី គឺរាគៈជាដើមមាននៅក្នុងខ្លួនអ្នក អ្នកចូរនាំ ( គឺកម្ចាត់បង់ ) វៀរចេញ" ដូច្នេះហើយ ទ្រង់ផ្សាយនូវព្រះរស្មី ជាអ្នកមានរូបប្រាកដ ហាក់ដូចជាទ្រង់គង់នៅចំពោះមុខ បានត្រាស់នូវព្រះគាថានេះថា ៖

រាគៈ ទើបជាធូលីមែនទែន ឯលំអងមិនមែនជាធូលីទេ,
ពាក្យថា "ធូលី" នោះ ជាឈ្មោះនៃរាគៈ ភិក្ខុទាំងនោះ
លះបង់ធូលីនោះបានដាច់ស្រឡះហើយ រមែងនៅក្នុង
សាសនារបស់ព្រះពុទ្ធដែលទ្រង់មានធូលីទៅប្រាសហើយ ។
ទោសៈទើបជាធូលីមែនទែន ឯលំអងមិនមែនជាធូលីទេ
ពាក្យថា "ធូលី" នោះជាឈ្មោះនៃទោសៈ ភិក្ខុទាំងនោះ
លះបង់ដាច់ស្រឡះហើយនូវធូលីនោះ រមែងនៅក្នុងសា-

សនាព្រះពុទ្ធដែលទ្រង់មានធូលីទៅប្រាសហើយ ។

មោហៈ ទើបចាត់ជាធូលីមែនទែន ឯលំអងមិនមែនជាធូលីទេ ពាក្យថា "ធូលី" នោះជាឈ្មោះនៃមោហៈ ភិក្ខុទាំងនោះលះបង់ដាច់ស្រឡះហើយនូវធូលីនោះ រមែងនៅក្នុងសាសនាព្រះពុទ្ធដែលទ្រង់មានធូលី គឺទៅប្រាសហើយ ។

ក្នុងកាលចប់ព្រះគាថា ព្រះចូឡបន្ថកៈបានសម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ បិដកទាំង ៣ មកប្រាកដដល់លោកព្រមនឹងបដិសម្ភិទានោះ ។

## បុព្វកម្មរបស់ព្រះចូឡបន្ថកៈ

បានឮថា ក្នុងកាលមុន ព្រះចូឡបន្ថកត្ថេរនោះ ជាព្រះរាជាទ្រង់ធ្វើប្រទក្សិណព្រះនគរ កាលព្រះសេទោ ( ញើស ) ហូរចេញអំពីព្រះនលាដ ( ថ្ងាស ) ទ្រង់យកសំពត់ជូតនូវទីបំផុតនៃព្រះនលាដ ។ សំពត់ក៏បានក្លាយជារបស់សៅហ្មង ។ ព្រះរាជាត្រឡប់បាននូវអនិច្ច-

សញ្ញាថា “សំពត់ស្អាតបែបនេះអាស្រ័យសរីរៈនេះ លះបង់នូវភាព ប្រក្រតី ក្លាយជារបស់សៅហ្មង សង្ខារទាំងឡាយមិនទៀងទេហ្ន៎” ។

ចំណែកវេជ្ជបណ្ឌិតឈ្មោះជីវក បានបង្អោនទឹកទក្ខិណោទក ចូលទៅថ្វាយព្រះទសពល, ព្រះសាស្ដាទ្រង់បិតបាត្រដោយព្រះហស្ដ ហើយទ្រង់ត្រាស់ថា “ម្នាលជីវក ភិក្ខុក្នុងវិហារ នៅមានមិនមែនឬ” ?

វេជ្ជបណ្ឌិតឈ្មោះជីវក បានក្រាបទូលព្រះសម្មាសម្ពុទ្ធថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាបន្ថកត្ថេរបានប្រាប់ខ្ញុំព្រះអង្គថា ភិក្ខុនៅក្នុងព្រះវិហារមិនមានទេ មិនមែនឬ ព្រះអង្គ ?” ព្រះសាស្ដា ត្រាស់ថា “ម្នាលជីវក ភិក្ខុមាននៅក្នុងវិហារ” វេជ្ជបណ្ឌិតឈ្មោះជីវក បញ្ជូនបុរសទៅដោយពាក្យថា “ម្នាលនាយ បើដូច្នោះ អ្នកចូរទៅ ចូរ ដឹងថា ភិក្ខុក្នុងវិហារមានឬមិនមាន” ។

## ព្រះចូឡបន្ថកៈនិម្មិតខ្លួនជាភិក្ខុ ១០០០ រូប

ក្នុងខណៈនោះ ព្រះចូឡបន្ថកៈគិតថា “បងប្រុសរបស់យើង និយាយថា ភិក្ខុក្នុងវិហារមិនមាន យើងនឹងប្រកាសនូវភាវៈនៃភិក្ខុ

ក្នុងវត្តមានដល់លោក ( បងប្រុស ) ដូច្នេះហើយ ទើបញុំាងវត្តអម្ពវ័នទាំងមូលឲ្យពេញហើយដោយភិក្ខុទាំងឡាយ ភិក្ខុខ្លះកំពុងដេរចីវរ ភិក្ខុខ្លះកំពុងជ្រលក់ចីវរ ភិក្ខុខ្លះកំពុងស្វាធ្យាយ, ព្រះចូឡបន្ថកៈនិម្មិត ភិក្ខុ ១០០០ ឲ្យមានរូបផ្សេងៗ គ្នាដោយប្រការយ៉ាងនេះ ។

បុរសនោះឃើញភិក្ខុច្រើនរូបនៅក្នុងវិហារ ក៏ត្រឡប់មកប្រាប់វេជ្ជបណ្ឌិតឈ្មោះជីវកថា បពិត្រនាយ វត្តអម្ពវ័នទាំងមូលពេញដោយភិក្ខុទាំងឡាយ ។

( ព្រះធម្មសង្គាហកាចារ្យ ពោលថា )

ព្រះថេរៈឈ្មោះចូឡបន្ថកៈនិម្មិតខ្លួនអស់វារៈ ១០០០

ដង ( ជាភិក្ខុ ១០០០ រូប ) ក្នុងវត្តអម្ពវ័ននោះឯង

ហើយគង់ក្នុងវត្តអម្ពវ័ន ដែលបុគ្គលគប្បីត្រេកអរនោះ

ឯង ដរាបដល់ពេលដែលគេមកប្រាប់នូវភត្តកាល ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងបុរសនោះថា “អ្នកចូលទៅកាន់វិហារ ប្រាប់ថា “ព្រះសាស្តាត្រាស់ហៅ ភិក្ខុឈ្មោះចូឡបន្ថកៈ” ។

កាលបុរសនោះ ទៅប្រាប់តាមពាក្យរបស់ព្រះសម្មាសម្ពុទ្ធហើយ ទាំង ១០០០ មាត់ក៏តាំងឡើងថា "អាត្មាឈ្មោះ ចូឡបន្ថកៈ, អាត្មាឈ្មោះ ចូឡបន្ថកៈ" ។

បុរសនោះទៅក្រាបទូលព្រះសាស្ដាទៀតថា "បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ភិក្ខុទាំងអស់នោះសុទ្ធតែឈ្មោះថា ចូឡបន្ថកៈ"។

ព្រះសាស្ដាត្រាស់ថា "បើដូច្នោះ អ្នកចូរទៅ ។ ភិក្ខុរូបណាពោលប្រាប់មុនថា អាត្មាឈ្មោះចូឡបន្ថកៈ, ចូរចាប់ដៃភិក្ខុរូបនោះទុកឲ្យមាំ, ភិក្ខុដ៏សេសនឹងអន្តរធានបាត់ទៅ" ។

បុរសនោះបានធ្វើហើយដោយប្រការដូច្នោះ ភិក្ខុប្រមាណ ១០០០ រូប បាត់ទៅហើយក្នុងខណៈនោះឯង ។ ព្រះថេរៈបាននិមន្តទៅកាន់ផ្ទះវេជ្ជបណ្ឌិតឈ្មោះជីវកជាមួយនឹងបុរសនោះ ។

## ព្រះសាស្ដាបញ្ជាឲ្យចូឡបន្ថកៈអនុមោទនា

ក្នុងវេលាស្រេចភត្តកិច្ច ព្រះសាស្ដាត្រាស់ហៅវេជ្ជបណ្ឌិតឈ្មោះជីវកមកហើយត្រាស់ថា "ម្នាលជីវក អ្នកចូរទទួលបាត្ររបស់

ចូរឡបន្ទកៈចុះ, ចូរឡបន្ទកៈនេះនឹងធ្វើអនុមោទនាដល់អ្នក” ។ វេជ្ជ-បណ្ឌិតឈ្មោះជីវកបានធ្វើហើយដោយប្រការដូច្នោះ ។ ព្រះថេរៈបន្លឺសីហនាទ ហាក់ដូចជាសីហ៍ជំទង់បន្លឺនូវសីហនាទ បានធ្វើអនុមោទនាញ៉ាំងព្រះត្រៃបិដកឲ្យក្ដួកក្ដឹកហើយ ។

ព្រះសាស្ដាស្ដេចក្រោកចាកអាសនៈ មានភិក្ខុចោមរោមស្ដេចទៅកាន់វិហារ, កាលភិក្ខុទាំងឡាយសម្ដែងវត្តហើយ ។ ស្ដេចក្រោកចាកអាសនៈ ទ្រង់ឈរនៅក្នុងទីចំពោះមុខនៃព្រះគន្ធកុដិ ប្រទានសុគតោវាទ ត្រាស់ប្រាប់កម្មដ្ឋានដល់ភិក្ខុសង្ឃ ទ្រង់បញ្ជូនភិក្ខុសង្ឃទៅហើយ ស្ដេចចូរកាន់ព្រះគន្ធកុដិដែលអប់ហើយដោយវត្ថុដែលមានក្លិនក្រអូបដ៏ឈ្ងុយឈ្ងប់ ទ្រង់ធ្វើនូវសីហសេយ្យាដោយបែរព្រះបិដ្ឋិ ( ខ្នង ) មកខាងស្ដាំ ។

## ពួកភិក្ខុប្រារព្ធគុណរបស់ព្រះសាស្ដា

គ្រានោះ នៅក្នុងសាយណ្ហសម័យ ( សម័យជាទីអស់ទៅនៃព្រះអាទិត្យ ) ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាខាងនេះផង ខាងនោះផង

ហាក់ដូចជាបុគ្គលបាំងវាំងននដែលសម្រេចដោយសំពត់កម្ពល ក្រហម ប្រារព្ធដល់គុណរបស់ព្រះសាស្តាថា ម្នាលអាវុសោ ព្រះមហាបន្ថកៈមិនជ្រាបនូវអធ្យាស្រ័យរបស់ព្រះចូឡបន្ថកៈ ទើបមិនអាចដើម្បីញុំាងព្រះចូឡបន្ថកៈឲ្យរៀននូវគាថាតែមួយដោយកាល ៤ ខែ, បណ្តេញចេញចាកវិហារដោយយល់ថា "ភិក្ខុរូបនេះល្ងង់ខ្លៅ" ប៉ុន្តែព្រះសម្មាសម្ពុទ្ធបានប្រទានព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទាក្នុងចន្លោះនៃភត្តតែមួយប៉ុណ្ណោះ ព្រោះព្រះអង្គជាធម្មរាជដ៏កំពូល ( រកបុគ្គលដ៏ទៃប្រៀបផ្ទឹមពុំបាន ), ព្រះត្រៃបិដកក៏មកព្រមជាមួយនឹងបដិសម្ភិទានោះ ឱ ! ដែលឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធទាំងឡាយមានច្រើនក្រៃលែងណាស់" ។

## ព្រះសាស្តាស្តេចទៅកាន់ទីប្រជុំភិក្ខុសង្ឃ

គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបនូវរឿងរ៉ាវនេះក្នុងរោងជាទីប្រជុំពោលនូវធម៌ ( ធម្មសភា ) ហើយ ទ្រង់ព្រះចិន្តាថា "ថ្ងៃនេះតថាគតទៅគួរ" ស្តេចក្រោកចាកពុទ្ធសេយ្យា ទ្រង់ស្លៀកនូវស្បង់ ២

ជាន់ដែលជ្រលក់ល្អហើយ ទ្រង់ចងវត្ថពន្ធចង្កេះដូចជាផ្លេកបន្ទោរ ទ្រង់ដណ្តប់នូវមហាបង្សុកូលចីវរនៃព្រះសុគត ដូចសំពត់កម្ពលមានពណ៌ក្រហម ស្តេចចេញចាកព្រះគន្ធកុដិ ដែលមានក្លិនក្រអូប ទៅកាន់រោងធម្មសភាដោយព្រះដំណើរដ៏ក្លាហានដូចជាដំណើរនៃដំរីដ៏ប្រសើរ ចុះប្រេងនឹងសត្វសីហៈ ( និង ) ដោយពុទ្ធលីលាមិនមានទីបំផុត ស្តេចឡើងកាន់បវរពុទ្ធាសនៈដែលបុគ្គលតាក់តែងល្អហើយ ក្នុងកណ្តាលនៃរោងមូលដែលបុគ្គលប្រដាប់ហើយ ទ្រង់គង់ត្រង់កណ្តាលអាសនៈទ្រង់បញ្ចេញព្រះឆព្វណ្ណរង្សី ៦ ប្រការ ហាក់ដូចជាទេវតាអ្នកពិសេសញ៉ាំងផ្ទៃមហាសមុទ្រឲ្យកម្រើក និងដូចជាព្រះអាទិត្យកំពុងបញ្ចេញរស្មីដ៏ស្រទន់ លើកំពូលភ្នំយុគន្ធរ ដូច្នោះ ។

នាកាលព្រះសម្មាសម្ពុទ្ធ គ្រាន់តែស្តេចមកដល់ភ្លាម ភិក្ខុសង្ឃក៏ផ្អាកនូវការសន្ទនា គង់ស្ងៀម ។

## ទ្រង់រំពឹងដល់អាការៈរបស់ភិក្ខុបរិស័ទ

ព្រះសាស្តាទ្រង់ពិចារណាមើលបរិស័ទ ដោយព្រះទ័យដ៏ទន់

ទ្រង់រំពឹងថា "បរិស័ទនេះល្អក្រៃលែងណាស់, ការឆ្គងដោយដៃក្តី ការឆ្គងដោយជើងក្តី សំឡេងក្អកក្តី សំឡេងកណ្តាស់ក្តី សូម្បីរបស់ភិក្ខុ ១ រូប រមែងមិនមាន, ភិក្ខុទាំងអស់នេះ មានសេចក្តីគោរពក្នុងព្រះពុទ្ធ ដែលតេជះនៃព្រះពុទ្ធគម្រាមហើយ ។ កាលតថាគតគង់ ( ស្ងៀម ) មិនពោលសូម្បីអស់កំណត់នៃអាយុ ក៏គ្មានភិក្ខុរូបណានឹងលើករឿងឡើងមកនិយាយឡើយ, ដែលឈ្មោះថាធម្មទំនៀមនៃការលើករឿងឡើង តថាគតគួរគប្បីដឹង, តថាគតខ្លួនឯងនឹងពោលឡើងមុន" ដូច្នេះហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះសូរសៀងដ៏ពីរោះ ដូចជាសំឡេងនៃព្រហ្ម ត្រាស់សួរថា ( ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយដល់រឿងអ្វី ? រឿងអ្វីដែលពួកអ្នកបញ្ឈប់ទុកក្នុងចន្លោះ ? កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយរឿងឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចូឡបន្ថកៈនេះ មិនមែនជាអ្នកល្ងង់តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកល្ងង់ហើយដូចគ្នាដែរ, ម្យ៉ាងទៀតតថាគត

មិនមែនជាទីពំនាក់អាស្រ័យនៃចូឡបន្ថកៈក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏បានជាទីពឹងពំនាក់អាស្រ័យរបស់ចូឡបន្ថកៈហើយដែរ ។ ហើយក្នុងកាលមុនតថាគតបានធ្វើចូឡបន្ថកៈនេះឲ្យជាម្ចាស់នៃលោកិយទ្រព្យ, ឥឡូវនេះ តថាគតបានធ្វើឲ្យជាម្ចាស់នៃលោកុត្តរទ្រព្យ” ដែលភិក្ខុទាំងឡាយអ្នកប្រាថ្នាដើម្បីនឹងស្តាប់នូវសេចក្តីនោះឲ្យពិស្តារ ទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមក ( សម្តែង ) ។

## រឿងមាណពសិក្សាសិល្បៈក្នុងក្រុងតក្កសិលា

ក្នុងអតីតកាល អ្នកនគរពារាណសីម្នាក់ ទៅកាន់ក្រុងតក្កសិលាហើយ ជាធម្មន្តេវាសិករបស់អាចារ្យទិសាបាមោក្ខ ដើម្បីប្រាថ្នានឹងរៀនសិល្បៈ បានជាអ្នកមានឧបការៈច្រើនដល់អាចារ្យក្នុងចំណោមមាណព ៥០០ នាក់ ធ្វើកិច្ចគ្រប់យ៉ាងមានប្រចុបាច់ជើងជាដើម, ក៏ក៏ប៉ុន្តែមិនអាចរៀនចេះនូវសិល្បៈណាមួយឡើយ ព្រោះភាវៈនៃខ្លួនជាមនុស្សល្ងង់, សូម្បីអាចារ្យខំព្យាយាមបង្ហាត់បង្រៀនដោយគិត

ឃើញថា "សិស្សម្នាក់នេះមានឧបការៈដល់យើងច្រើន, នឹងឲ្យសិក្សាឲ្យចេះទាល់តែបាន" ក៏មិនអាចឲ្យសិក្សាចេះចាំអ្វីបាន ។

មាណពនោះនៅអស់កាលជាយូរ សូម្បីគាថាតែមួយក៏មិនអាចនឹងរៀន ( ឲ្យចាំ ) បាន នឹកអៀនខ្មាស សូមលាអាចារ្យថា "បពិត្រលោកអាចារ្យ ខ្ញុំសូមលាទៅផ្ទះវិញ" អាចារ្យគិតថា "សិស្សម្នាក់នេះមានឧបការៈដល់យើងជាច្រើន, យើងក៏ប្រាថ្នាភាពជាបណ្ឌិតដល់គេដែរ, ប៉ុន្តែមិនអាចនឹងធ្វើភាពជាបណ្ឌិតនោះឲ្យគេបាន ចាំបាច់យើងនឹងត្រូវធ្វើឧបការៈតបស្នងដល់សិស្សម្នាក់នេះដោយពិត, នឹងចងនូវមន្តឲ្យគេ ១ បទ អាចារ្យបាននាំមាណពនោះទៅកាន់ព្រៃ ចងមន្តនេះថា "**ឃដេសិ ឃដេសិ កឹការណា ឃដេសិ ? អហំបិ តំ ជានាមិ ជានាមិ**" ។ ( អ្នកឯងព្យាយាមទៅ ព្យាយាមទៅ, ព្រោះហេតុអ្វី ? ទើបអ្នកឯងព្យាយាម សូម្បីយើងក៏ដឹងនូវហេតុនោះដែរ) ដូច្នេះហើយឲ្យគេរៀនទៅមកៗច្រើនរយដង ហើយសួរថា "ឯងចាំហើយឬ" ? កាលគេឆ្លើយថា "បពិត្រលោកអាចារ្យ ខ្ញុំចាំហើយ"

ប្រាប់ថា “ធម្មតាសិល្បៈទាំងឡាយដែលមនុស្សល្ងង់ព្យាយាមធ្វើឲ្យស្ទាត់ហើយ រមែងមិនភ្លេច” ឲ្យស្បៀងសម្រាប់ធ្វើដំណើរហើយប្រាប់ថា “ឯងទៅចុះ អាស្រ័យមន្តនេះចិញ្ចឹមជីវិតចុះ, តែដើម្បីប្រយោជន៍ដល់ការមិនភ្លេចនៃមន្តនោះ ឯងគប្បីធ្វើនូវការស្វាធ្យាយមន្តនោះអស់កាលជានិច្ចចុះ” ដូច្នេះហើយ ក៏បញ្ជូនគេទៅ ។

ក្នុងកាលគេធ្វើដំណើរទៅដល់ក្រុងពារាណសី មាតាបានធ្វើសក្ការៈ និងសម្មានៈដ៏ធំ ដោយត្រេកអរថា “បុត្ររបស់យើងសិក្សាសិល្បៈត្រឡប់មកវិញហើយ” ។

## ព្រះបាទផែនដីត្រួតមើលការប្រព្រឹត្តិទៅនៃប្រជាជន

ក្នុងកាលនោះ ព្រះបាទពារាណសី ទ្រង់ពិចារណាថា “ទោសអ្វីមួយព្រោះកម្មទាំងឡាយមានកាយកម្មជាដើមរបស់យើង មានឬហ្ន៎” ? មិនទ្រង់ឃើញនូវកម្មអ្វីៗដែលមិនជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គ ក៏ទ្រង់ព្រះចិន្តាថា “ធម្មតាទោសរបស់ខ្លួន រមែងមិនប្រាកដដល់ខ្លួនទេ, រមែងប្រាកដដល់អ្នកដទៃ, យើងនឹងកំណត់ដឹងនូវការ

ប្រព្រឹត្តិទៅនៃពួកអ្នកនគរទាំងឡាយ” ដូច្នេះហើយ ទើបស្តេចចេញទៅដោយភេទនៃព្រះអង្គ ដែលបុគ្គលដទៃមិនស្គាល់ក្នុងវេលាល្ងាច ទ្រង់ព្រះចិន្តាថា “ធម្មតាការសន្ទនាប្រាស្រ័យទាក់ទងគ្នារបស់ពួកមនុស្សអ្នកអង្គុយបរិភោគអាហារក្នុងពេលល្ងាច រមែងមានប្រការផ្សេងៗគ្នា ប្រសិនបើយើងគ្រប់គ្រងរាជដោយអធម៌, ជនទាំងឡាយគង់នឹងនិយាយគ្នាថា ពួកយើងត្រូវព្រះបាទផែនដីដែលមិនតាំងនៅក្នុងធម៌ ជាមនុស្សអាក្រក់ឃោរឃៅបៀតបៀនដោយអាជ្ញា និងពលីជាដើម, ប្រសិនបើយើងគ្រប់គ្រងរាជដោយធម៌, ជនទាំងឡាយក៏នឹងពោលពាក្យជាដើមថា សូមព្រះរាជារបស់យើងទាំងឡាយ ចូរជាអ្នកមានព្រះជន្មយឺនយូរចុះ ហើយក៏គង់សរសើរគុណរបស់យើង” ដូច្នេះហើយ ទើបស្តេចទៅតាមឈ្នូរនៃជញ្ជាំងផ្ទះទាំងឡាយរបស់មនុស្សទាំងនោះៗ ។

ក្នុងខណៈនោះ ពួកចោរអ្នករកស៊ីដោយការជីកឧម្មង្គ ( រូង ) ចូលលួចទ្រព្យសម្បត្តិអ្នកស្រុក កំពុងជីកឧម្មង្គក្នុងចន្លោះផ្ទះពីរខ្នង

ដើម្បីប្រយោជន៍ដល់ការចូលទៅកាន់ផ្ទះទាំង ២ ដោយឧម្មន្តតែមួយ ។

ព្រះរាជាទ្រង់ទតឃើញពួកវាហើយ បានទ្រង់ឈរពួននៅក្នុងម្លប់នៃផ្ទះ ។ ក្នុងវេលាដែលពួកចោរជីកឧម្មង្គចូលទៅផ្ទះបានហើយ កំពុងគយគន់រកមើលនូវភណ្ឌៈទាំងឡាយ មាណពនោះភ្ញាក់ឡើង ក៏ស្វាធ្យាយនូវមន្តនោះថា **“ឃដេសិ ឃដេសិ, កឹការណា ឃដេសិ ? អហំបិ តំ ជានាមិ ជានាមិ”** ។

ចោរទាំងនោះបានឮពាក្យនោះហើយ ក៏តក់ស្លុតខ្លាចបោះបោលសម្បីនូវសំពត់ដែលខ្លួនស្លៀក ហើយរត់ទៅតាមទីចំពោះមុខៗ ដោយប្រាប់គ្នាថា “បានឮថា មាណពនេះស្គាល់ពួកយើងហើយ វានឹងញ៉ាំងពួកយើងឲ្យវិនាសក្នុងកាលឥឡូវនេះ ។

## ទ្រង់ឃើញចោររត់ព្រោះមន្តរបស់មាណព

ព្រះរាជាទ្រង់ទតឃើញចោរទាំងនោះកំពុងរត់ទៅ នឹងទ្រង់ព្រះសណ្តាប់នូវសំឡេងនៃមាណពក្រោនេះស្វាធ្យាយមន្ត ទ្រង់កំណត់ ( ការប្រព្រឹត្តិទៅ ) នៃពួកអ្នកនគរបានហើយ ទើបស្តេចចូលទៅកាន់

ព្រះរាជនិវេសន៍ លុះដល់ពេលរាត្រីភ្លឺច្បាស់ហើយ ក៏ទ្រង់ត្រាស់ហៅរាជបុរសម្នាក់ ( មកគាល់ ) ត្រាស់ថា "ម្នាលនាយ អ្នកឯងចូរទៅពួកចោរជីកឧមង្គក្នុងផ្ទះឯណោះ ក្នុងថ្នល់ឯណោះ, ក្នុងផ្ទះមួយខ្នងនោះមានមាណពដែលរៀនទូវសិល្បៈមកអំពីនគរតក្កសិលា (ម្នាក់) អ្នកចូរនាំមាណពនោះមក" ។

រាជបុរសទៅប្រាប់ថា "ព្រះរាជាត្រាស់ឲ្យហៅអ្នក" ហើយនាំមាណពនោះមក ។

គ្រានោះ ព្រះរាជាត្រាស់ទៅកាន់មាណពនោះថា "ម្នាលអ្នកដ៏ចម្រើន អ្នកឯងជាមាណពដែលរៀនសិល្បៈអំពីនគរតក្កសិលា ទើបមកឬ" ?

មាណព. ព្រះករុណាថ្លៃវិសេស ។

ព្រះរាជា. ចូរឲ្យសិល្បៈដល់យើងផងចុះ ។

មាណព. បពិត្រព្រះសម្មតិទេព ប្រពៃហើយ សូមព្រះអង្គគង់លើអាសនៈដែលស្មើហើយរៀនចុះ ។

គ្រានោះ ព្រះរាជាទ្រង់ធ្វើហើយដោយប្រការយ៉ាងនោះ ទ្រង់រៀនមន្តនោះអំពីមាណពនោះហើយ បានព្រះរាជទានទ្រព្យ ១០០០ ដោយព្រះតម្រាស់ថា "នេះជាចំណែកបូជារបស់អាចារ្យ ( ជាទំនឹបគ្រូរបស់អ្នក )" ។

ក្នុងកាលនោះ សេនាបតីនិយាយនឹងនាយខ្នាន់ព្រះកេសរបស់ព្រះរាជាថា "អ្នកឯងនឹងកោរនូវព្រះមស្សុ ( ពុកចង្កា ) របស់ព្រះរាជាក្នុងកាលណា" ?

នាយខ្នាន់ព្រះកេស. ក្នុងថ្ងៃស្អែក ឬក្នុងថ្ងៃខានស្អែក ។

សេនាបតីនោះឲ្យទ្រព្យ ១០០០ ដល់នាយខ្នាន់ព្រះកេសហើយពោលថា "ខ្ញុំមានកិច្ច ( មួយ )" កាលនាយខ្នាន់ព្រះកេសសួរថា "បពិត្រនាយ កិច្ចអ្វីទៅ" ? ប្រាប់ថា "ឯងត្រូវធ្វើអាការដូចជាដាក់នូវព្រះមស្សុរបស់ព្រះរាជា សំលៀងកាំបិតកោរឲ្យមុត, កាត់នូវបំពង់នៃព្រះសូវង្គរបស់ព្រះរាជា នឹង ( បាន ) ជាសេនាបតី, ខ្ញុំនឹងជាព្រះរាជា ។ នាយខ្នាន់ព្រះកេសទទួលយល់ព្រមថា "បាន" ក្នុងថ្ងៃដាក់នូវ

ព្រះមស្សុថ្វាយព្រះរាជា យកទឹកក្រអូបស្រស់ព្រះមស្សុឲ្យទទឹកជោក សំលៀងកាំបិតកោរ ចាប់ឰដ៏ទីបំផុតនៃព្រះនលាដ ( ថ្ងាស ) គិតថា "កាំបិតកោរមានមុខរលីបន្តិច យើងគួរកាត់បំពង់ ព្រះសូរង្គដោយការកាត់តែម្ដងប៉ុណ្ណោះ" ដូច្នេះហើយ ទើបឈរនៅក្នុងចំណែកម្ខាង សំលៀងកាំបិតកោរទៀត ។

ក្នុងពេលនោះ ព្រះរាជាទ្រង់រឭកដល់មន្តរបស់ព្រះអង្គបាន កាលនឹងទ្រង់ធ្វើការស្វាធ្យាយ ទ្រង់ត្រាស់ថា **"ឃដេសិ ឃដេសិ, កឹការណា ឃដេសិ ? អហំបិ តំ ជានាមិ ជានាមិ"** ។

ញើសក៏បានហូរចេញហើយអំពីថ្ងាសនៃនាយខ្មាន់ព្រះកេស។ នាយខ្មាន់ព្រះកេសយល់ថា "ព្រះរាជាទ្រង់ជ្រាបនូវហេតុនេះ" ភ័យហើយ ក៏បោះកាំបិតកោរចោលទៅលើផែនដី ហើយក្រាបចុះក្នុងទីជិតនៃព្រះបាទ ។

## កុសលោបាយរបស់ព្រះរាជា

ធម្មតាព្រះរាជាទាំងឡាយ រមែងជាអ្នកច្លាត, ព្រោះហេតុនោះ

ទើបព្រះអង្គត្រាស់ទៅកាន់នាយខ្មាន់ព្រះកេសយ៉ាងនេះថា “ម្នាលខ្មាន់ព្រះកេសកំណាច អ្នកឯងសម្គាល់ថា “ព្រះរាជាមិនទ្រង់ជ្រាបឬ” ?

នាយខ្មាន់ព្រះកេស. បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាព្រះរាជទានអភ័យដល់ខ្ញុំព្រះអង្គផងចុះ ។

ព្រះរាជា. ណ្ហើយចុះ, អ្នកឯងកុំភ័យឡើយ, ចូរប្រាប់យើងមកចុះ ។

ខ្មាន់ព្រះកេស. បពិត្រព្រះសម្មតិទេព សេនាបតីបានឲ្យទ្រព្យ ១០០០ ដល់ខ្ញុំព្រះអង្គ ហើយប្រាប់ថា “អ្នកចូរធ្វើដូចជាដាក់នូវព្រះមស្សុថ្វាយព្រះរាជា ហើយកាត់នូវបំពង់ព្រះសូរង្គនៃព្រះរាជា កាលព្រះរាជាសោយទិវង្គតហើយ, ខ្ញុំនឹងជាព្រះរាជា តែងតាំងអ្នកឯងឲ្យជាសេនាបតី ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ទ្រង់ព្រះចិន្តាថា “យើងបានជីវិតព្រោះអាស្រ័យអាចារ្យ” ដូច្នេះហើយ ទើបត្រាស់ឲ្យហៅសេនាបតីមក ( គាល់ ) ត្រាស់ថា “ម្នាលសេនាបតីដ៏ចម្រើន

ឈ្មោះថាអ្វី ដែលអ្នកមិនបានហើយអំពីសំណាក់របស់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំមិនអាចនឹងឃើញអ្នកបានទេ, អ្នកចូរចេញចាកដែនរបស់ខ្ញុំ" ត្រាស់បញ្ជាឲ្យបណ្ដេញសេនាបតីចេញចាកដែនហើយ ក៏ត្រាស់ឲ្យអញ្ជើញមាណពដែលជាអាចារ្យមកគាល់ ត្រាស់ថា "បពិត្រអាចារ្យដ៏ចម្រើន ខ្ញុំមានជីវិតរស់នៅព្រោះអាស្រ័យលោក"ដូច្នេះហើយ ទ្រង់ធ្វើសក្ការៈដ៏ធំ បានព្រះរាជទានតំណែងសេនាបតីដល់អាចារ្យនោះ ។ មាណពក្នុងកាលនោះបានមកជាចូឡបន្ថកៈ, ព្រះសាស្ដាជាអាចារ្យទិសាបាមោក្ខ ។

ព្រះសាស្ដា លុះទ្រង់នាំអតីតនិទាននេះមកហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុនចូឡបន្ថកៈ ក៏ជាអ្នកល្ងង់ខ្លៅយ៉ាងនេះ ដូចគ្នាដែរ ។ សូម្បីក្នុងកាលនោះ តថាគតក៏បានជាទីពឹងពំនាក់អាស្រ័យរបស់ចូឡបន្ថកៈ ញ៉ាំងចូឡបន្ថកៈឲ្យតាំងនៅក្នុងលោកិយទ្រព្យហើយ, ក្នុងថ្ងៃស្អែកឡើង កាលកថា ( សន្ទនាគ្នា ) តាំងឡើងថា "គួរសរសើរក្រៃលែងណាស់ ព្រះសាស្ដាទ្រង់ជា

ទីពឹងពំនាក់របស់ព្រះចូឡបន្ថកៈហើយ” ទ្រង់ត្រាស់ដំណាលនូវរឿងអតីតៈក្នុងចូឡសេដ្ឋិជាតកហើយ ត្រាស់គាថា ថា ៖

បុគ្គលអ្នកមានបញ្ញាទម្ទុះទម្ទាយ អ្នកមានបញ្ញាជា
គ្រឿងពិចារណា រមែងញ៉ាំងខ្លួនឲ្យតាំងឡើងព្រម
ដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិចតួច
ដូចបុគ្គលបង្កាត់ភ្លើងគំនរតូច ឲ្យឆេះជាគំនរធំបាន
ដូច្នោះ ។

ហើយត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនបានជាទីពឹងពំនាក់របស់ចូឡបន្ថកៈតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ។ សូម្បីក្នុងកាលមុន ក៏បានជាទីពឹងពំនាក់ហើយដែរ ។ ប៉ុន្តែថា ក្នុងកាលមុន តថាគតបានធ្វើចូឡបន្ថកៈនេះឲ្យជាម្ចាស់នៃលោកិយទ្រព្យ, ឥឡូវនេះ ធ្វើឲ្យជាម្ចាស់នៃលោកុត្តរទ្រព្យ” ដូច្នេះហើយ ទ្រង់ប្រជុំជាតកថា “ចូឡកន្តេវាសិក ក្នុងកាលនោះ បានមកជាចូឡបន្ថកៈ ( ក្នុងកាលឥឡូវនេះ ), ចំណែកចូឡកសេដ្ឋី ដែលជាបណ្ឌិត ដែល

ជាអ្នកឈ្លាសវៃយល់ដឹងនៅក្នុងនក្ខត្តឫក្ស (ក្នុងគ្រានោះ) គឺតថាគត នេះឯង” ។

## ពួកភិក្ខុសរសើរព្រះចូឡបន្ថកៈ

ក្នុងថ្ងៃមួយទៀត ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា “ម្នាលអាវុសោទាំងឡាយ ព្រះចូឡបន្ថកៈនេះ សូម្បីមិនអាចនឹងរៀនគាថា ៤ បាទ ដោយ ៤ ខែបាន ក៏មិនលះបង់សេចក្តីព្យាយាម តាំងនៅក្នុងព្រះអរហត្តហើយ, ឥឡូវនេះបានជាម្ចាស់នៃទ្រព្យ គឺលោកុត្តរធម៌ហើយ” ។

## ព្រះសាស្តាប្រៀនប្រដៅឲ្យធ្វើនូវទីពឹង ដោយធម៌ ៤ ប្រការ

ព្រះសាស្តាស្តេចមកត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ? កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងឈ្មោះនេះ” ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនារបស់តថាគត

ប្រារព្ធនូវសេចក្តីព្យាយាមហើយ រមែងជាម្ចាស់នៃលោកុត្តរធម៌បាន យ៉ាងពិតប្រាកដ ដូច្នេះហើយ ត្រាស់គាថានេះថា ៖

**៣. ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច**
**ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។**

អ្នកប្រាជ្ញ គប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្តីប្រឹងប្រែងផង ដោយសេចក្តីមិនប្រមាទផង ដោយការសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង ដោយការទូន្មាននូវឥន្រ្ទីយ៍ផង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **ទីបំ កយិរាថ** សេចក្តីថា អ្នកមានបញ្ញាប្រកបព្រមហើយដោយបញ្ញាដ៏រុងរឿងក្នុងធម៌ គប្បីសាង គឺថាគប្បីធ្វើ បានដល់ អាចធ្វើនូវកោះ គឺអរហត្តផល ដែលជាទីពឹងផ្អែករបស់ខ្លួនក្នុងសាគរ គឺសង្សារវដ្តដ៏ជ្រៅក្រៃលែង ដោយការៈជា

ទីពឹងផ្អែក ដែលបុគ្គលគប្បីរកបានដោយកម្រក្រៃលែងនេះ ដោយធម៌ ដែលជាហេតុ ៤ ប្រការនេះគឺ ដោយសេចក្តីខ្នះខ្នែង ពោលគឺសេចក្តីព្យាយាម ១ ដោយសេចក្តីមិនប្រមាទ ពោលគឺការមិននៅប្រាសចាកសតិ ១ ដោយសេចក្តីសង្រួម ពោលគឺបារិសុទ្ធិសីលបួន ១ ដោយការទូន្មាននូវឥន្ទ្រីយ៍ ១ ។

សួរថា "គប្បីសាងនូវកោះដូចម្តេច" ?

ឆ្លើយថា "គប្បីសាងនូវកោះដែលជំនន់ គឺកិលេសជន់ពន្លិចមិនបាន, អធិប្បាយថា គប្បីធ្វើនូវកោះដែលជំនន់ គឺកិលេសទាំង ៤ យ៉ាង មិនអាចនឹងជន់ពន្លិច គឺកម្ចាត់បាន, ពិតណាស់ ព្រះអរហត្តឱយៈមិនអាចនឹងជន់ពន្លិចបានឡើយ ។

ក្នុងកាលចប់ព្រះគាថា ជនជាច្រើនបានជាព្រះអរិយបុគ្គលមានសោតាបន្នជាដើម ។ ទេសនាបានជាប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដោយប្រការដូច្នេះឯង ។

( រឿងព្រះចូឡបន្ថកៈ ចប់ )

## ៤. រឿងនក្ខត្តឫក្សរបស់ជនពាល

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនក្ខត្តឫក្ស របស់ជនពាល ត្រាស់ព្រះធម្មទេសនានេះថា **“បមាទមនុយុញ្ជន្តិ”** ដូច្នេះជាដើម ។

## ជនពាលដែលនៅក្នុងក្រុងសាវត្ថីលេងនក្ខត្តឫក្ស

បានឮថា ក្នុងសម័យមួយ គេប្រកាសឈ្មោះនក្ខត្តឫក្សរបស់ជនពាល ក្នុងនគរសាវត្ថី ។ ក្នុងនក្ខត្តឫក្សនោះ ពួកជនពាលដែលអបឥតបញ្ញា យកផេះ និងអាចម៍គោលាបរាងកាយ ដើរពោលវាចារបស់ជនអសប្បុរសរហូតអស់កាល ៧ ថ្ងៃ ឃើញនរណាៗ ជាញាតិក៏ដោយ ជាសម្លាញ់ក៏ដោយ ជាបព្វជិតក៏ដោយ ឈ្មោះថា មាននូវសេចក្តីអៀនខ្មាស មិនមាន, ឈរពោលវាចារបស់អសប្បុរសទៀបទ្វារផ្ទះអ្នកស្រុក ។ មនុស្សទាំងឡាយមិនអាចស្តាប់អសប្បុរិសវាទរបស់ពួកជនពាលនោះបាន ទើបបញ្ជូនទ្រព្យទៅឲ្យកន្លះបាទខ្លះ១បាទ

ខ្វះ ១ កហាបណៈខ្វះ តាមកម្លាំងរបស់ខ្លួន ពួកជនពាលកាន់យកទ្រព្យដែលបានហើយៗ ទៀបទ្វារនៃផ្ទះរបស់មនុស្សទាំងនោះៗហើយទើបចៀសចេញទៅ ។

ក៏ក្នុងកាលនោះ ក្នុងនគរសាវត្ថី មានព្រះអរិយសាវកប្រមាណ ៥ កោដិ ។ ព្រះអរិយសាវកទាំងនោះបញ្ជូនដំណឹងទៅថ្វាយព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ កុំស្តេចចូលទៅកាន់ព្រះនគរ សូមគង់នៅតែក្នុងព្រះវិហារអស់ ៧ ថ្ងៃ" ក៏ក្នុងកាល ៧ ថ្ងៃនោះ ( ព្រះអរិយសាវកទាំងនោះ ) ញុំាងគ្នានិងគ្នាឲ្យបាត់បែងយាគូ និងភត្តជាដើម ( បញ្ជូនទៅ ) កាន់វិហារដើម្បីភិក្ខុសង្ឃ សូម្បីខ្លួនឯងក៏មិនចេញអំពីផ្ទះអស់ ៧ ថ្ងៃដែរ ។

ក៏ក្នុងកាលនក្ខត្តឫក្សរបស់ជនពាលចប់ទៅហើយ, ក្នុងថ្ងៃទី ៨ អរិយសាវកទាំងនោះ និមន្តព្រះសង្ឃមានព្រះពុទ្ធជាប្រធានឲ្យស្តេចចូលទៅកាន់ព្រះនគរថ្វាយមហាទាន អង្គុយក្នុងទីដ៏សមគួរមួយហើយ

ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ៧ ថ្ងៃរបស់ពួកខ្ញុំព្រះអង្គកន្លង ទៅបានដោយលំបាកក្រៃលែង, កាលពួកខ្ញុំព្រះអង្គបានឮនូវវាចាមិន មែនរបស់សប្បុរសនៃពួកជនពាល, ត្រចៀកទាំង ២ ហាក់ដូចជា ដល់នូវអាការៈបែកធ្លាយ, អ្នកណាក៏មិនមានសេចក្តីអៀនខ្មាសអ្នក ណា, ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គ ទើបមិនឲ្យព្រះអង្គស្តេចចូល កាន់ព្រះនគរ សូម្បីពួកខ្ញុំព្រះអង្គក៏មិនអាចចេញអំពីផ្ទះបានដែរ ។

## បុគ្គលពាល និង បណ្ឌិតមានអាការផ្សេងគ្នា

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់អរិយសាវកទាំង នោះហើយ ត្រាស់ថា "កិរិយារបស់ពួកបុគ្គលដែលអបឥតបញ្ញា រមែងដូច្នេះឯង, ចំណែកបុគ្គលអ្នកមានបញ្ញាទាំងឡាយរក្សានូវ សេចក្តីមិនប្រមាទទុក ដូចជាទ្រព្យដ៏មានខ្លឹមសារ រមែងសម្រេចនូវ សម្បត្តិ គឺអមតមហានិព្វាន" ដូច្នេះហើយ បានទ្រង់ត្រាស់ព្រះគាថា ទាំងនេះថា ៖

**៤. បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**

អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ។

ពួកជនពាលអបឥតប្រាជ្ញា តែងប្រកបរឿយៗ នូវសេចក្ដីប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្ដីមិនប្រមាទដូចទ្រព្យដ៏ប្រសើរ ។ អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗនូវសេចក្ដីប្រមាទ ចូរកុំប្រកបរឿយៗនូវសេចក្ដីរីករាយ ត្រេកអរក្នុងកាមឡើយ ត្បិតបុគ្គលមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបាននូវសេចក្ដីសុខដ៏ទូលាយ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ពាលា** បានដល់ អ្នកប្រកបដោយភាពជាជនពាល គឺអ្នកដែលមិនស្គាល់ប្រយោជន៍ក្នុងលោកនេះ និងលោកខាងមុខ ។

បទថា **ទុម្មេធិនោ** គឺឥតបញ្ញា ។ ពួកជនពាលនោះ កាល

មិនឃើញទោសក្នុងសេចក្តីប្រមាទ រមែងប្រកបរឿយៗ នូវសេចក្តីប្រមាទ គឺថា រមែងញ៉ាំងកាលឲ្យកន្លងទៅដោយសេចក្តីប្រមាទ ។

បទថា **មេធាវី** ជាដើម សេចក្តីថា ចំណែកបណ្ឌិតដែលប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចទ្រព្យ គឺរតនៈ ៧ ប្រការដ៏ប្រសើរ គឺដ៏ខ្ពង់ខ្ពស់ ដែលជាប់តមកអំពីវង្សត្រកូល ។ អធិប្បាយថា ដូចយ៉ាងថា ជនទាំងឡាយកាលឃើញអានិសង្សក្នុងទ្រព្យថា "យើងទាំងឡាយ អាស្រ័យទ្រព្យដ៏ខ្ពង់ខ្ពស់ ទើបដល់នូវសម្បត្តិ គឺកាមគុណ និងធ្វើផ្លូវជាទីទៅកាន់បរលោកឲ្យបរិសុទ្ធបាន" រមែងរក្សាទ្រព្យនោះទុក យ៉ាងណាមិញ, សូម្បីបណ្ឌិតក៏ដូច្នោះ កាលឃើញអានិសង្សក្នុងសេចក្តីមិនប្រមាទថា "បុគ្គលអ្នកមិនប្រមាទហើយ រមែងបានចំពោះនូវឈានទាំងឡាយមានបឋមឈានជាដើម រមែងសម្រេចលោកុត្តរធម៌មានមគ្គ និងផល

ជាដើម រមែងញុំាងវិជ្ជា ៣ ( និង ) អភិញ្ញា ៦[១] ឲ្យដល់ព្រមបាន" រមែង រក្សាសេចក្តីមិនប្រមាទទុក ដូចជាទ្រព្យដ៏ប្រសើរ ។

បទថា **មា បមាទំ** សេចក្តីថា ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរកុំតាមប្រកបរឿយៗនូវសេចក្តីប្រមាទ គឺថា កុំញុំាងកាលវេលាឲ្យកន្លងទៅដោយសេចក្តីប្រមាទ ។

បាទគាថា ថា **មា កាមរតិសន្ថវំ** សេចក្តីថា ចូរកុំប្រកប គឺថា កុំគិត បានដល់ កុំបានចំពោះសូម្បីនូវសេចក្តីស្និទ្ធស្នាលដោយអំណាចនៃតណ្ហា ពោលគឺសេចក្តីត្រេកអរក្នុងវត្ថុកាម និងកិលេស-កាម ។

បទថា **អប្បមត្តោ ហិ** ជាដើម សេចក្តីថា ព្រោះថា បុគ្គលអ្នកមិនប្រមាទហើយ ដោយភាពជាអ្នកមានសតិតាំងមាំ ខំសង្កេតពិនិត្យ រមែងបាននូវសេចក្តីសុខក្នុងព្រះនិព្វាន ដ៏ទូលំទូលាយ គឺដ៏



---

[១] ឥទ្ធិវិធី សម្តែងឫទ្ធិបាន, ទិព្វសោត ត្រចៀកទិព្វ, ចេតោបរិយញ្ញាណ កំណត់ដឹងចិត្តអ្នកដទៃ, បុព្វេនិវាសានុស្សតិ រឭកជាតិបាន ទិព្វចក្ខុ ភ្នែកទិព្វ អាសវក្ខយញ្ញាណ ញាណធ្វើអាសវៈឲ្យអស់ទៅ, រួមជាអភិញ្ញា ៦ ។ ៣ ខាងចុង ហៅថា វិជ្ជា ៣ ក៏បាន ។

ក្រៃលែង ។

ក្នុងកាលចប់ព្រះគាថា ជនជាច្រើន បានជាអរិយបុគ្គល មានសោតាបន្នជាដើម ធម្មទេសនាបានជាប្រយោជន៍ដល់មហាជនហើយដូច្នេះឯង ។

***( រឿងនក្ខត្តប្ញក្សរបស់ជនពាល ចប់ )***

## ៥. រឿងព្រះមហាកស្សបត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហា-កស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **“បមាទំ អប្បមាទេន”** ដូច្នេះជាដើម ។

## <u>ព្រះថេរៈពិចារណាមើលសត្វលោកដោយទិព្វចក្ខុ</u>

សេចក្ដីដំណាលថា ថ្ងៃមួយ ព្រះថេរៈគង់នៅក្នុងបិប្ផលិគុហា ត្រាច់ទៅបិណ្ឌបាត ខាងក្រោយភត្ត គង់ចម្រើនអាលោកកសិណ រមិលមើលសត្វទាំងឡាយដែលប្រមាទហើយ និងមិនប្រមាទហើយ ដែលកំពុងចុតិ និងដែលកំពុងកើតក្នុងទីទាំងឡាយ មានទឹក ផែនដី និងភ្នំជាដើម ដោយទិព្វចក្ខុ ។

ព្រះសាស្ដា ទ្រង់គង់នៅក្នុងវត្តជេតពននោះឯង ទ្រង់រមិលមើលដោយទិព្វចក្ខុថា “ថ្ងៃនេះ កស្សបៈបុត្តរបស់តថាគត នៅដោយវិហារធម៌អ្វីហ្ន៎” ? ទ្រង់ជ្រាបថា “កំពុងរមិលមើលនូវចុតិ និងបដិសន្ធិ

របស់សត្វទាំងឡាយ” ទើបត្រាស់ថា “ដែលឈ្មោះថា ការចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ប្រសិនបើពុទ្ធញាណមិនកំណត់ហើយ, នរណាៗ ក៏មិនអាចនឹងធ្វើការកំណត់ដឹងសត្វទាំងឡាយ ដែលបដិសន្ធិក្នុងផ្ទៃនៃមាតា ដែលមាតាបិតាមិនទាន់ដឹងក៏ចុតិហើយបាន, ការដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងនោះ មិនមែនវិស័យរបស់អ្នកទេ,ម្នាលកស្សបៈ វិស័យរបស់អ្នកមានប្រមាណតិច ចំណែកការដឹង ការឃើញសត្វទាំងឡាយដែលកំពុងចុតិ និងបដិសន្ធិដោយប្រការទាំងពួងនោះជាវិស័យរបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ” ដូច្នេះហើយ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចជាគង់នៅក្នុងទីចំពោះមុខ ហើយត្រាស់ព្រះគាថានេះថា ៖

**៥. បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ**
**បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនី បជំ**
**បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។**

កាលណាបណ្ឌិតបន្ទោបង់នូវសេចក្តីប្រមាទ ដោយ

សេចក្តីមិនប្រមាទ កាលណោះ លោកនឹងឡើងកាន់ប្រាសាទ គឺបញ្ញា ជាបុគ្គលមិនសោក រមែងឃើញនូវសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល ដូចបុគ្គលដែលឈរលើកំពូលភ្នំ ហើយក្រឡេកមើលពួកជនដែលនៅលើផែនដី ដូច្នេះឯង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **នុទតិ** ជាដើម សេចក្តីថា កាលណាបណ្ឌិតចម្រើនកពូននូវអប្បមាទលក្ខណៈ មិនឲ្យឱកាសដល់សេចក្តីប្រមាទ ឈ្មោះថា បន្ទោបង់ គឺរមែងបណ្តេញបង់នូវសេចក្តីប្រមាទនោះ ដោយកម្លាំងនៃសេចក្តីមិនប្រមាទ ដូចទឹកថ្មីហូរចូលកាន់ស្រះបោក្ខរណី ញុំាងទឹកចាស់ឲ្យខ្ចាត់ចេញហើយ មិនឲ្យឱកាសដល់ទឹកចាស់នោះ រមែងប្រានចេញ គឺរមែងញុំាងទឹកចាស់នោះឲ្យហូរចេញទៅ ដោយទីបំផុតនៃខ្លួនដូច្នេះហើយ ។ កាលនោះ បណ្ឌិតនោះមានសេចក្តីប្រមាទដែលបន្ទោបង់ហើយ បំពេញបដិបទាដ៏សមគួរ

ដល់សេចក្តីមិនប្រមាទនោះ, ឡើងកាន់បញ្ញាដូចជាប្រាសាទ ពោលគឺ ទិព្វចក្ខុដ៏បរិសុទ្ធ ដោយអត្ថថា ជាធម្មជាតិដ៏ខ្ពង់ខ្ពស់ក្រៃលែង ដោយ បដិបទានោះ ដូចបុគ្គលឡើងកាន់ប្រាសាទតាមកាំជណ្តើរដូច្នោះ ដែល ឈ្មោះថា អ្នកមិនមានសេចក្តីសោកសៅ ព្រោះភាពជាអ្នកលះបង់នូវ កូនសរ គឺសេចក្តីសោកចេញបានហើយ, រមែងពិចារណាឃើញ គឺ រមែងក្រឡេកឃើញនូវប្រជា គឺពពួកសត្វដែលមាននូវសេចក្តីសោក ព្រោះភាពជាអ្នកលះបង់នូវកូនសរគឺសេចក្តីសោកមិនទាន់បាន ដែល កំពុងចុតិ និងបដិសន្ធិដោយទិព្វចក្ខុ ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចបុគ្គលដែលឈរនៅលើកំពូលភ្នំ រមែងក្រឡេក ឃើញបុគ្គលដែលឈរនៅលើផែនដីបានដូច្នោះ, អធិប្បាយថា បុគ្គល ដែលឈរនៅលើកំពូលភ្នំ រមែងក្រឡេកឃើញបុគ្គលដែលឈរនៅ លើផែនដីបាន ឬបុគ្គលដែលឈរនៅលើប្រាសាទជាន់លើ រមែងក្រ- ឡេកឃើញបុគ្គល ដែលឈរនៅក្នុងបរិវេណនៃប្រាសាទបានដោយ

មិនលំបាក យ៉ាងណាមិញ អ្នកប្រាជ្ញ គឺបណ្ឌិត បានដល់ ព្រះមហាខីណាស្រពរូបនោះ ក៏រមែងពិចារណាឃើញបុគ្គលពាលទាំងឡាយដែលមានពូជ គឺវដ្ដៈមិនទាន់បានកាត់ផ្ដាច់ កំពុងចុតិ និងបដិសន្ធិដោយមិនលំបាកដូច្នោះ ។

ក្នុងកាលចប់គាថា ជនជាច្រើន បានធ្វើឲ្យជាក់ច្បាស់ហើយនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ។

( រឿងមហាកស្សបត្ថេរ ចប់ )

## ៦. រឿងភិក្ខុជាសម្លាញ់នឹងគ្នាពីររូប

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុជាសម្លាញ់នឹងគ្នាពីររូប ត្រាស់ព្រះធម្មទេសនានេះថា "**អប្បមត្តោ បមត្តេសុ**" ដូច្នេះជាដើម ។

## <u>ភិក្ខុពីររូបមានបដិបទាផ្សេងគ្នា</u>

បានឮមកថា ភិក្ខុពីររូបនោះ រៀនកម្មដ្ឋានក្នុងសំណាក់ព្រះសាស្ដាហើយ ចូលទៅកាន់វិហារដែលតាំងនៅក្នុងព្រៃ ។ ក្នុងបណ្ដាភិក្ខុពីររូបនោះ ភិក្ខុមួយរូបនាំយកឧសមកអំពីថ្ងៃ ចាត់ចែងអំបែងរងើកភ្លើងហើយ អង្គុយអាំងភ្លើងចរចាជាមួយនឹងភិក្ខុកំលោះ និងសាមណេរទាំងឡាយរហូតអស់បឋមយាម ។ ភិក្ខុដែលជាអ្នកធ្វើនូវសមណធម៌ដោយសេចក្ដីមិនប្រមាទ រមែងទូន្មាននូវភិក្ខុក្រៅនេះថា "ម្នាលអាវុសោ អ្នកកុំធ្វើយ៉ាងនេះឡើយ ព្រោះអបាយភូមិ ៤ ដូចជាផ្ទះដែលជាទីដេកនៃបុគ្គលដែលប្រមាទហើយ, ធម្មតាព្រះពុទ្ធទាំង-

ឡាយ នរណាៗ មិនអាចដើម្បីឲ្យទ្រទ្រង់ប្រោសប្រណីដោយការៈនៃខ្លួន ជាអ្នកច្រើនទៅដោយការអួតអាងឡើយ" ។

ភិក្ខុដែលមាននូវសេចក្ដីប្រមាទនោះ មិនស្ដាប់ពាក្យទូន្មាន របស់ភិក្ខុនោះ ។ ភិក្ខុក្រៅនេះគិតថា "ភិក្ខុនេះមិនជឿពាក្យទូន្មានរបស់ យើង ទើបមិនប្រាថ្នា ( ទូន្មានទៀត ) ភិក្ខុដែលមិនប្រមាទនោះខំ ព្យាយាមបំពេញនូវសមណធម៌ ។ ចំណែកឯព្រះថេរៈកំជិល អាំង ភ្លើងក្នុងបឋមយាម ក្នុងវេលាដែលភិក្ខុក្រៅនេះដើរចង្រ្កមហើយចូល ទៅកាន់បន្ទប់ ទើបចូលទៅនិយាយថា "ម្នាលលោកមហាកំជិល លោកចូលមកកាន់ព្រៃដើម្បីប្រយោជន៍ដល់ការដេកលក់ឬ ការដែល បុគ្គលរៀនកម្មដ្ឋានក្នុងសំណាក់ព្រះពុទ្ធ ហើយក្រោកឡើងធ្វើសមណ- ធម៌អស់យប់ និងថ្ងៃមិនគួរឬ" ? ដូច្នេះហើយ ក៏ចូលទៅកាន់លំនៅ របស់ខ្លួនហើយដេកលក់ទៅ, ចំណែកភិក្ខុក្រៅនេះ សម្រាកក្នុងមជ្ឈិម ហើយ ក្រោកឡើងធ្វើសមណធម៌ក្នុងបច្ឆិមយាម ។ ព្រះថេរៈនោះ មិនប្រមាទហើយយ៉ាងនោះ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្ត

មួយអន្ទើដោយបដិសម្ភិទាទាំងឡាយ ។

ព្រះថេរៈកំជិលក្រៅនេះ ញ៉ាំងកាលវេលាឲ្យកន្លងទៅសេចក្តីប្រមាទតែម្យ៉ាង ។

ភិក្ខុទាំងពីររូបនោះ ចេញវស្សាហើយ ទៅកាន់សំណាក់ព្រះ-សាស្តា ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីដ៏សមគួរមួយ ។

## ព្រះសាស្តាត្រាស់សួរភិក្ខុទាំងពីររូបនោះ

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈនឹងភិក្ខុទាំងពីររូបនោះហើយ ត្រាស់សួរដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្វើនូវសមណ-ធម៌ដោយសេចក្តីមិនប្រមាទឬ ? កិច្ចនៃបព្វជិតរបស់អ្នកទាំងឡាយដល់ទីបំផុតហើយឬ" ? ភិក្ខុដែលជាអ្នកប្រមាទក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីមិនប្រមាទរបស់ភិក្ខុនោះ នឹងមានអំពីទីណា ? ចាប់តាំងអំពីកាលដែលខ្លួនទៅហើយ លោកដេកលក់ញ៉ាំងពេលវេលាឲ្យកន្លងទៅហើយ" ។

ព្រះសាស្តាត្រាស់សួរថា "ម្នាលភិក្ខុ ចុះអ្នកវិញ" ?

ភិក្ខុដែលជាអ្នកប្រមាទនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនាំយកឧសមកអំពីថ្ងៃ ចាត់ចែងអំបែងរងើកភ្លើងហើយ អង្គុយអាំងរហូតអស់បឋមយាម មិនប្រព្រឹត្តនូវការលក់ មិនញុាំងកាលឲ្យកន្លងហួសទៅហើយដោយការដេកលក់" ។

## អ្នកមានបញ្ញាល្អរមែងបោះបង់នូវបុគ្គលដែលអប្បឥតបញ្ញា

គ្រានោះ ព្រះសាស្តាត្រាស់នឹងភិក្ខុដែលមាននូវសេចក្តីប្រមាទនោះថា "ម្នាលភិក្ខុ អ្នកប្រមាទហើយ បណ្តោតបណ្តោយពេលវេលាឲ្យកន្លងទៅ ( ទទេៗ ) ប៉ុន្តែនិយាយថា ខ្លួនមិនប្រមាទ មិនត្រឹមតែប៉ុណ្ណោះ ធ្វើនូវភិក្ខុដែលមិនប្រមាទហើយ ឲ្យជាអ្នកប្រមាទ ។ អ្នកដូចជាសេះដែលទុព្វលមានកម្លាំងជាគ្រឿងលឿនទៅ ( មានល្បឿន ) ដាច់ហើយក្នុងសំណាក់នៃបុត្ររបស់តថាគត, ចំណែកបុត្ររបស់តថាគតនេះ ដូចជាសេះដែលមានកម្លាំងជាគ្រឿងលឿនទៅដ៏រហ័ស ( មានល្បឿនដ៏រហ័ស ) ក្នុងសំណាក់នៃអ្នក" ដូច្នេះហើយ ទើបត្រាស់ព្រះ-

គាថានេះថា ៖

៦ អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ
អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។

បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុងប្រមាទ
លោកមិនប្រមាទ កាលពួកបុគ្គលកំពុងដេកលក់ លោក
ភ្ញាក់រឭកច្រើន លោករមែងលះបង់ចោលនូវបុគ្គលបែប
នោះ ដូចសេះលឿន ដែលទៅចោលនូវសេះមានកម្លាំង
ទន់ទាប ដូច្នោះឯង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អប្បមត្តោ** សេចក្ដីថា ដែលឈ្មោះថា អ្នកដល់ព្រមហើយដោយសេចក្ដីមិនប្រមាទ ព្រោះភាពជាអ្នកច្រើនទៅដោយសតិ បានដល់ ព្រះខីណាស្រព ។

បទថា **បមត្តេសុ** កាលសត្វទាំងឡាយតាំងនៅហើយក្នុងការប្រមាទ ។ បទថា **សុត្តេសុ** គឺ ( កាលសត្វទាំងឡាយ ) កំពុងលក់

ក្នុងឥរិយាបថទាំងពួង ព្រោះមិនមានធម៌ជាគ្រឿងភ្ញាក់រឭក គឺសតិ ។

បទថា **ពហុជាគរោ** បានដល់ អ្នកតាំងនៅក្នុងធម៌ជាគ្រឿងភ្ញាក់រឭក គឺភាពជាអ្នកបរិបូណ៌ដោយសតិ ។

បទថា **អពលស្សំវ** សេចក្តីថា ដូចសេះសិន្ធពអាជានេយ្យមានល្បឿនដ៏រហ័ស រត់ចោលនូវសេះដែលមានកម្លាំងខ្សោយ មានល្បឿនដាច់ហើយ ដោយភាពជាសេះមានជើងខ្ចកទៅដូច្នោះ ។

បទថា **សុមេធសោ** ជាដើម សេចក្តីថា បុគ្គលអ្នកមានបញ្ញាឆ្លើត រមែងបោះបង់ចោលនូវបុគ្គលបែបនោះទៅ ដោយអាគម គឺបរិយត្តិផង ដោយអធិគម គឺការសម្រេចមគ្គផលផង អធិប្បាយថា កាលបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ ព្យាយាមរៀនព្រះសូត្រមួយព្រះសូត្រនោះឯង បុគ្គលអ្នកមានបញ្ញាឆ្លើតរមែងរៀនបានមួយវគ្គ ។ រមែងលះបង់ដោយអាគម គឺបរិយត្តិយ៉ាងនេះឯង ។ម្យ៉ាងទៀត កាលបុគ្គលអ្នកមានបញ្ញាទន់ខ្សោយ កំពុងព្យាយាមធ្វើនូវទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ នឹងរៀនកម្មដ្ឋានហើយស្វាធ្យាយនោះឯង

សូម្បីក្នុងកាលជាចំណែកខាងដើម បុគ្គលអ្នកមានបញ្ញាធំតែ ចូលទៅកាន់ទីសម្រាកពេលថ្ងៃ ឬទីសម្រាកពេលយប់ដែលអ្នកដទៃធ្វើទុក ពិចារណានូវកម្មដ្ឋាន ញុំាងសព្វកិលេសឲ្យអស់ទៅ ធ្វើលោកុត្តរធម៌ ៩ ប្រការ ឲ្យនៅក្នុងកណ្ដាប់ដៃបាន, បុគ្គលដែលមានបញ្ញាធំតែរមែងបោះបង់ចោលនូវបុគ្គលដែលមានបញ្ញាទន់ខ្សោយដោយអធិគម គឺការសម្រេចមគ្គផលយ៉ាងនេះ ។ម្យ៉ាងទៀត បុគ្គលអ្នកមានបញ្ញាល្អ លះបង់ គឺបោះបង់ចោលនូវបុគ្គល ដែលមានបញ្ញាទន់ខ្សោយនោះទុកក្នុងវដ្តៈ ដក ( ខ្លួន ) ចេញចាកវដ្តៈទៅដោយពិតប្រាកដ ។

ក្នុងកាលចប់គាថា ជនជាច្រើនបានសម្រេចអរិយផលទាំង-ឡាយ មានសោតាបត្តិផលជាដើម ដោយប្រការយ៉ាងនេះឯង ។

( រឿងភិក្ខុដែលជាសម្លាញ់នឹងគ្នាពីររូប ចប់ )

## ៧. រឿងសក្កទេវរាជ

## សេចក្តីខាងដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងវេសាលី គង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធសក្កទេវរាជ ត្រាស់ព្រះធម្មទេសនានេះថា "**អប្បមាទេន មឃវា**" ដូច្នេះជាដើម ។

## <u>ហេតុដែលធ្វើឲ្យសក្កទេវរាជមានព្រះនាមផ្សេងៗ</u>

សេចក្តីពិស្តារថា ស្តេចលិច្ឆវីព្រះនាម មហាលិ ដែលគ្រប់គ្រងរាជសម្បត្តិនៅក្នុងក្រុងវេសាលី ។ ព្រះអង្គទ្រង់ស្តាប់នូវទេសនានៃសក្កបញ្ហាសូត្ររបស់ព្រះតថាគតហើយ ទ្រង់ព្រះតម្រិះថា "ព្រះ-សម្មាសម្ពុទ្ធ រមែងត្រាស់នូវសម្បត្តិរបស់សក្កទេវរាជទុកជាច្រើន ព្រះអង្គទ្រង់ឃើញហើយទើបត្រាស់ ឬមិនទ្រង់ឃើញ ហើយត្រាស់ ? ទ្រង់ស្គាល់សក្កទេវរាជ ឬក៏មិនស្គាល់ទេហ្ន៎ ? យើងនឹងទូលសួរព្រះអង្គ" ។

គ្រានោះឯង ស្តេចលិច្ឆវីព្រះនាម មហាលិ បានចូលទៅគាល់

ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះស្តេចលិច្ឆវីគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់បានឃើញសក្កទេវានមិន្ទដែរឬ" ?

ព្រះសម្មាសម្ពុទ្ធ. បពិត្រមហាលិ តថាគតបានឃើញសក្កទេវានមិន្ទដែរ ។

មហាលិ. បពិត្រព្រះអង្គដ៏ចម្រើន ក្រែងសក្កទេវានមិន្ទ គ្រាន់តែជារូបប្រៀបរបស់សក្កៈទេដឹង, បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាសក្កទេវានមិន្ទ គេមិនងាយនឹងឃើញទេ ។

ព្រះមានព្រះភាគត្រាស់ថា បពិត្រមហាលិ តថាគតស្គាល់ច្បាស់នូវសក្កទេវរាជផង នូវធម៌ធ្វើសត្វឲ្យបានជាសក្កទេវរាជផងមួយវិញទៀត សក្កទេវរាជ បានដល់នូវភាវៈនៃខ្លួនជាសក្កៈ ព្រោះតែសមាទានធម៌ណា តថាគតក៏ដឹងច្បាស់នូវធម៌នោះផង ។

បពិត្រមហាលិ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិ

មុនជាមាណពឈ្មោះមឃៈ ព្រោះហេតុនោះបានជាគេហៅថា មឃវៈ ។

បពិត្រមហាលិ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានឲ្យទានមុនគេ ហេតុនោះ បានជាគេហៅថា បុរិន្ទទៈ ។

បពិត្រមហាលិ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានឲ្យទានដោយគោរព ហេតុនោះបានជាគេហៅថា សក្កៈ ។

បពិត្រមហាលិ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានឲ្យទីសម្រាប់សំណាក់អាស្រ័យ ហេតុនោះ បានជាគេហៅថា វាសវៈ ។

បពិត្រមហាលិ សក្កទេវានមិន្ទ គិតឃើញហេតុសូម្បីទាំងពាន់ដោយមួយរំពេចបាន ហេតុនោះ បានជាគេហៅថា សហស្សក្ខៈ ។

បពិត្រមហាលិ អសុរកញ្ញា ឈ្មោះនាងសុជាតា ជាមហេសីនៃសក្កទេវានមិន្ទ ហេតុនោះ បានជាគេហៅថា សុជម្បតិ ។

បពិត្រមហាលិ សក្កទេវានមិន្ទ សោយរាជជាឥស្សរាធិបតីលើពួកទេវតាជាន់តាវត្តិង្ស ហេតុនោះ បានជាគេហៅថា ទេវានមិន្ទ ។

បពិត្រមហាលិ សក្កទេវានមិន្ទ កាលកើតជាមនុស្សក្នុងជាតិមុន បានសមាទានវត្តបទទាំង ៧ ប្រការដោយបរិបូណ៌ ព្រោះហេតុតែសមាទានវត្តបទទាំង ៧ ប្រការនោះ បានជាសក្កទេវរាជ បានទាមថា សក្កៈ ។ វត្តបទទាំង ៧ នោះ តើដូចម្តេច ? ( សក្កទេវរាជបានសមាទាន ) ថា អាត្មាអញ ត្រូវចិញ្ចឹមមាតាអស់មួយជីវិត ១ ត្រូវកោតក្រែងបុគ្គលជាចម្បងក្នុងត្រកូលអស់មួយជីវិត ១ ត្រូវមានវាចាល្អិតទន់អស់មួយជីវិត ១ មិនត្រូវមានវាចាញុះញង់អស់មួយជីវិត ១ ត្រូវ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ ជាអ្នកមានការបរិច្ចាគរួសរាន់ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះបង់ ជាអ្នកគួរគេសូមទានបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែកទានហើយនៅគ្រប់គ្រងផ្ទះអស់មួយជីវិត ១ ត្រូវមានវាចាទៀងទាត់អស់មួយជីវិត ១ មិនត្រូវមានសេចក្តីក្រោធ បើទុកជាសេចក្តីក្រោធកើតឡើងដល់អាត្មាអញ អាត្មាអញត្រូវបន្ទោបង់នូវសេចក្តីក្រោធនោះអស់មួយរំពេចអស់មួយជីវិត ១ បពិត្រមហាលិ សក្កទេវានមិន្ទ

កាលកើតជាមនុស្សក្នុងជាតិមុន បានសមាទានវត្តបទទាំង ៧ ប្រការនេះបរិបូណ៌ ព្រោះហេតុតែសមាទានបទទាំង ៧ ប្រការនោះ ទើបសក្កទេវរាជបាននូវភាវៈនៃខ្លួនជាសក្កៈ ។

( ព្រះមានព្រះភាគ លុះត្រាស់នូវព្រះសូត្រនេះហើយ បានត្រាស់ព្រះពុទ្ធវចនៈខាងក្រោយថា )

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា គោរពកោតក្រែងបុគ្គលជាចម្បងក្នុងត្រកូល មានវាចាល្អិតទន់ និយាយសំដីផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបតែក្នុងការកម្ចាត់បង់សេចក្ដីកំណាញ់ មានវាចាទៀងទាត់ ជាជនគ្របសង្កត់សេចក្ដីក្រោធនោះឯង ថាជាសប្បុរស ។

## សក្កទេវរាជបំពេញកុសលកាលនៅជាមឃមាណព

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "បពិត្រមហាលិ កម្មនេះសក្កទេវរាជបានធ្វើទុកហើយក្នុងកាលដែលខ្លួនជាមាណពឈ្មោះ មឃៈ"

ដូច្នេះហើយ ដែលស្តេចលិច្ឆវីព្រះនាមមហាលិ ប្រាថ្នានឹងទ្រង់ស្តាប់នូវវត្តបទរបស់សក្កទេវរាជនោះឲ្យពិស្តារ ទើបទូលសួរទៀតថា “បពិត្រព្រះអង្គដ៏ចម្រើន មាណពឈ្មោះមឃៈ រមែងបដិបត្តិដូចម្តេច” ? ទើបត្រាស់ថា “បពិត្រមហាលិ បើដូច្នោះ ទ្រង់ចូរស្តាប់ដោយយកចិត្តទុកដាក់ចុះ” ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ( សម្តែងជាសាធកៈ ) ។

## រឿងមឃមាណព

ក្នុងអតីតកាល មាណពឈ្មោះមឃៈ នៅក្នុងអចលគ្រាម ដែនមគធៈ ទៅកាន់ទីជាទីធ្វើការងារនៃអ្នកស្រុក ឈូសនូវអាចម៍ដីដោយចុងជើងក្នុងទីដែលខ្លួនឈរហើយ បានធ្វើឲ្យជាទីមនោរម្យហើយឈរនៅ ។ បុរសដទៃម្នាក់ទៀតយកដៃប្រានគេនាំចេញចាកទីនោះហើយ បានឈរនៅក្នុងទីនោះឯង ។ មឃមាណពមិនក្រោធចំពោះបុគ្គលនោះ បានធ្វើទីដទៃឲ្យជាទីមនោរម្យហើយឈរវិញ បុរសដទៃក៏យកដៃប្រានមឃមាណពចេញអំពីទីនោះហើយ បានឈរនៅក្នុងទីនោះឯងទៀត ។ មឃមាណពមិនក្រោធសូម្បីដល់បុរសនោះ បានធ្វើទីដទៃឲ្យ

ជាទីមនោរម្យហើយ ក៏ឈរនៅក្នុងទីនោះទៀត បុរសទាំងឡាយដែលចេញទៅហើយៗអំពីផ្ទះ ក៏យកដៃច្រានមឃមាណពចេញអំពីទីដែលមឃមាណពជម្រះហើយៗ ដោយប្រការដូច្នេះ ។ មឃមាណពគិតថា “ជនទាំងអស់គ្នា ជាអ្នកបានទទួលនូវសេចក្ដីសុខហើយ កម្មនេះរមែងជាកម្មឲ្យនូវសេចក្ដីសុខដល់យើង” ។ ដូច្នេះហើយ ថ្ងៃស្អែកឡើងបានកាន់យកចបទៅធ្វើនូវទីមានមណ្ឌលនៃលានឲ្យជា រមណីយដ្ឋានហើយ ។ ជនទាំងពួងបានទៅឈរសម្រាកក្នុងទីនោះឯង ។

សម័យថ្ងៃក្រោយមក លុះដល់រដូវរងា មឃមាណពបានបង្កាត់ភ្លើងឲ្យដល់ជនទាំងនោះ ក្នុងរដូវក្ដៅ បានឲ្យទឹក ។ ក្នុងលំដាប់នោះ មឃមាណពនោះគិតថា “ដែលឈ្មោះថា រមណីយដ្ឋាន រមែងជាទីស្រឡាញ់នៃជនទាំងពួង, ដែលឈ្មោះថា មិនជាទីស្រឡាញ់នៃជនណាមួយមិនមាន, ចាប់ផ្ដើមអំពីនេះទៅយើងគួរដើរធ្វើផ្លូវឲ្យរាបស្មើ” ដូច្នេះហើយ ក៏ចេញទៅអំពីផ្ទះពីព្រលឹមធ្វើផ្លូវឲ្យរាបស្មើ កាត់ឫសឈើ មែកឈើ ដែលគួរកាត់ចេញ ។

## មយមាណពបានសម្លាញ់ ៣៣ នាក់

ខាងក្រោយមក បុរសម្នាក់ទៀតឃើញមយមាណពហើយពោលថា "ម្នាលសម្លាញ់ លោកធ្វើអ្វី" ?

មយៈ. ម្នាលសម្លាញ់ ខ្ញុំធ្វើផ្លូវសំរាប់ទៅកាន់ឋានសួគ៌របស់ខ្ញុំ ។

បុរស. បើដូច្នោះ សូម្បីខ្ញុំក៏នឹងជាសម្លាញ់របស់លោកដែរ ។

មយៈ. ម្នាលសម្លាញ់ អ្នកចូរជាសម្លាញ់របស់ខ្ញុំចុះ ធម្មតាឋានសួគ៌ រមែងជាទីស្រឡាញ់ ជាទីពេញចិត្តនៃជនជាច្រើន ។

ចាប់តាំងអំពីកាលនោះមក ក៏បានបុរសនោះជាសម្លាញ់នឹងគ្នា ២ នាក់ ។ សូម្បីបុរសដទៃទៀត ឃើញជនទាំង ២ នាក់នោះហើយសួរហើយដូចគ្នាដែរ លុះដឹងហើយក៏ជាសម្លាញ់នៃជនទាំង ២ នាក់នោះ សូម្បីជនដទៃៗ ទៀតក៏បានធ្វើហើយដោយប្រការយ៉ាងនោះ រួមទាំងអស់បាន ៣៣ នាក់ ដោយប្រការដូច្នេះ ។

## សម្លាញ់ ៣៣ នាក់ត្រូវចោទថាជាចោរ

ជនទាំងអស់នោះ មានដៃកាន់វត្ថុមានចបជាដើម ធ្វើផ្លូវឲ្យរាប

ស្មើទៅដល់ទីប្រមាណ ១ យោជន៍ និង ២ យោជន៍ ។

ចៅហ្វាយស្រុកឃើញបុរសទាំងនោះហើយគិតថា "មនុស្ស ទាំងនេះប្រកបកិច្ចការងារក្នុងឋានៈដែលមិនគួរប្រកប, ប្រសិនបើ ជនទាំងនេះ គប្បីនាំនូវវត្ថុទាំងឡាយមានត្រី និងសាច់ជាដើមមក អំពីព្រៃ, ឬធ្វើសុរាហើយផឹក, ឬធ្វើកម្មដូច្នោះយ៉ាងដទៃ, យើងគប្បី បានវត្ថុអ្វីៗ ខ្លះ" ។

គ្រានោះ ចៅហ្វាយស្រុកក៏បានបញ្ជាឲ្យគេហៅជនទាំងនោះមក សួរថា "ពួកឯងដើរធ្វើអ្វី" ?

បុរសទាំងនោះ. បពិត្រនាយ ធ្វើផ្លូវសម្រាប់ដើរទៅកាន់ឋាន-សួគ៌ ។

ចៅហ្វាយស្រុក. ធម្មតាបុគ្គលដែលនៅគ្រប់គ្រងផ្ទះទាំងឡាយ នឹងធ្វើយ៉ាងនោះមិនសមគួរ, គួរនាំវត្ថុទាំងឡាយមានត្រី និងសាច់ជា ដើមមកអំពីព្រៃ គួរធ្វើសុរាហើយផឹក និងគួរធ្វើការងារទាំងឡាយ មានប្រការផ្សេងៗ ។

ជនទាំងនោះជំទាស់នឹងពាក្យរបស់ចៅហ្វាយស្រុកនោះ។សូម្បី ត្រូវចៅហ្វាយស្រុកពោលរឿយៗ ក៏នៅតែជំទាស់រឿយៗដែរ ។ ចៅ-ហ្វាយស្រុកក្រោធខឹងហើយ គិតថា "យើងនឹងញុំាងពួកវាឲ្យវិនាស" ទើបទៅកាន់សំណាក់របស់ព្រះរាជា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញចោរត្រាច់ទៅដោយការចងគ្នាជាពួក" កាលព្រះរាជាត្រាស់ថា "អ្នកចូរទៅ, ចូរចាប់ពួកវាហើយនាំមក" បានធ្វើតាមព្រះរាជបញ្ជា ហើយសម្តែងជនទាំងនោះដល់ព្រះរាជា ។

ព្រះរាជាមិនទាន់បានទ្រង់ពិចារណា ទ្រង់ត្រាស់បង្គាប់ថា "ពួកអ្នកចូរញុំាងដំរីឲ្យជាន់ពួកវា" ។

## ដំរីមិនជាន់ព្រោះអានុភាពនៃមេត្តា

មឃមាណពបានឲ្យឱវាទដល់ជនដ៏សេសទាំងឡាយថា "ម្នាលសម្លាញ់ទាំងឡាយ វៀរមេត្តាចេញហើយ ទីពឹងយ៉ាងដទៃរបស់ពួកយើងមិនមាន, អ្នកទាំងឡាយចូរកុំធ្វើនូវសេចក្តីក្រោធក្នុងបុគ្គលណាៗឡើយ ចូរជាអ្នកមានចិត្តស្មើដោយមេត្តាក្នុងព្រះរាជាផង ក្នុងចៅហ្វាយ

ស្រុកផង ក្នុងដំរីដែលទឹងជាន់ផង និងក្នុងខ្ទមឯងផង” ជនទាំងនោះ ក៏បានធ្វើហើយដោយប្រការយ៉ាងនោះ ។

គ្រានោះ ដំរីក៏មិនហ៊ានចូលទៅជិត ព្រោះអានុភាពនៃមេត្តារបស់ជនទាំងនោះ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវសេចក្ដីនោះ ហើយត្រាស់ថា “ដំរីវាឃើញមនុស្សច្រើន ទើបវាមិនហ៊ានចូលទៅដើម្បីជាន់, អ្នកទាំងឡាយចូរទៅ, ចូរយកកន្ទេលផែងគ្របពួកវាហើយ ញុំាងដំរីឲ្យជាន់ចុះ” ។

ដំរីដែលរាជបុរសទាំងឡាយយកកន្ទេលផែងគ្របជនទាំងនោះ ហើយបញ្ជូនទៅដើម្បីឲ្យជាន់ ក៏ថយត្រឡប់ហើយអំពីចម្ងាយ ។

ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវព្រឹត្តិការណ៍នោះហើយ ទ្រង់ព្រះចិន្តាថា “ក្នុងរឿងនេះត្រូវមានហេតុភេទអ្វីជាពិតប្រាកដ” ហើយបញ្ជាឲ្យរាជបុរសហៅជនទាំងនោះមកគាល់ ត្រាស់សួរថា “ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយអាស្រ័យយើង មិនបាននូវអ្វីឬ” ?

ពួកមឃៈ. បពិត្រព្រះសម្មតិទេព ហេតុហ្នឹងវាយ៉ាងម៉េច ?

ព្រះរាជា. បានឮថា ពួកឯងជាចោរត្រាច់ទៅក្នុងព្រៃ ដោយការចងគ្នាជាពួក ។

ពួកមយៈ. បពិត្រព្រះសម្មតិទេព នរណាទូលព្រះអង្គយ៉ាងនោះ ។

ព្រះរាជា. ម្នាលអ្នកទាំងឡាយ ចៅហ្វាយស្រុកបានប្រាប់យើង ។

ពួកមយៈ. បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំទាំងឡាយមិនមែនជាចោរទេ, ប៉ុន្តែថា ទូលព្រះបង្គំទាំងឡាយ ជម្រះផ្លូវសម្រាប់ទៅកាន់ឋានសួគ៌របស់ខ្លួនៗ ទើបធ្វើនូវកម្មនេះ និងកម្មនេះ, ចៅហ្វាយ-ស្រុកណែនាំពួកទូលព្រះបង្គំឲ្យធ្វើនូវអំពើអកុសល ប្រាថ្នានឹងឲ្យទូលព្រះបង្គំទាំងឡាយដែលមិនធ្វើតាមពាក្យរបស់ខ្លួនវិនាស ក្រោធខឹងហើយ ទើបក្រាបទូលយ៉ាងនោះ ។

## ជនទាំង ៣៣ នាក់បានទទួលព្រះរាជទាន

គ្រានោះ ព្រះរាជាទ្រង់ព្រះសណ្តាប់នូវវាចារបស់ជនទាំងនោះ

ជាអ្នកដល់ហើយនូវសោមនស្ស ត្រាស់ថា “ម្នាលអ្នកទាំងឡាយ សត្វតិរច្ឆាននេះអាចដឹងនូវគុណរបស់អ្នកទាំងឡាយ, ប៉ុន្តែយើងជាមនុស្សឲ្យត្រឡាំងក៏មិនអាចដឹងគុណនៃអ្នកទាំងឡាយ, សូមអ្នកទាំង-ឡាយអត់ទោសឲ្យយើងផងចុះ” លុះត្រាស់យ៉ាងនោះហើយ បានព្រះរាជទានចៅហ្វាយស្រុកព្រមទាំងបុត្រ និងកិរិយាឲ្យជាទាសៈ ដំរីនោះឲ្យជាពាហនៈសម្រាប់ជិះ, ហើយព្រះរាជទានស្រុកនោះឲ្យជាគ្រឿងប្រើប្រាស់តាមសប្បាយដល់ជនទាំងនោះ ។

## មឃមាណព និង សម្លាញ់របស់ខ្លួនសាងសាលា

មឃមាណព និងសម្លាញ់របស់ខ្លួននិយាយគ្នាថា “ពួកយើងឃើញអានិសង្សនៃបុណ្យក្នុងបច្ចុប្បន្ននេះឯង” ម្នាក់ ៗ មានចិត្តជ្រះថ្លាយ៉ាងក្រៃលែង ផ្លាស់វេនគ្នាឡើងកាន់ដំរីនោះធ្វើដំណើរទៅបណ្ដើរប្រឹក្សាគ្នាបណ្ដើរថា “ឥឡូវនេះ ពួកយើងគួរធ្វើបុណ្យឲ្យវិសេសក្រៃ-លែងឡើង” ម្នាក់ៗដេញដោលសួរគ្នាថា “ពួកយើងនឹងធ្វើយ៉ាងណា” ? ក៏សម្រេចគ្នាថា “នឹងសាងសាលាជាទីសម្រាកនៃមហាជនឲ្យជារបស់

មាំមួនក្នុងផ្លូវធំបែកជា ៤” ។ មឃមាណព និងសម្លាញ់របស់ខ្លួនក៏បានស្វែងរកជាងឈើមកហើយផ្ដើមសាងសាលា, ក៏ប៉ុន្ដែថា ព្រោះការដែលខ្លួនមិនពេញចិត្តក្នុងមាតុគ្រាម ទើបមិនបានឲ្យចំណែកបុណ្យក្នុងសាលានោះដល់មាតុគ្រាមទាំងឡាយ ។

## មាណពមានភរិយា ៤ នាក់

ក៏ក្នុងផ្ទះរបស់មឃមាណពមានស្ត្រី ៤ នាក់ គឺនាងសុនន្ទា សុចិត្រា សុធម្មា សុជាតា ។

បណ្ដាស្ត្រីទាំង ៤ នាក់នោះ នាងសុធម្មាស៊ុមគ្រលុំជាមួយនឹងជាងឈើ ហើយពោលថា “បពិត្រអ្នកបង សូមបងធ្វើខ្ញុំឲ្យជាធំក្នុងសាលានេះចុះ” ដូច្នេះហើយ បានឲ្យនូវសំណូក ( ជាងឈើ ) ជាងឈើនោះទទួលយល់ព្រមថា “បាន” ហើយហាលឈើសម្រាប់ធ្វើហោជាងឲ្យស្ងួតមុនវត្ថុដទៃ ហើយឈូស ធ្លាក់ធ្វើហោជាងឲ្យសម្រេចហើយ ធ្លាក់អក្សរទាំងឡាយថា “សាលានេះឈ្មោះសុធម្មា” ដូច្នេះហើយ យកសំពត់រុំទុក ។

## នាងសុធម្មាបានរួមកុសលសាងសាលា ជាមួយមឃមាណព

លុះជាងឈើសាងសាលាស្រេចហើយ ក្នុងថ្ងៃលើកហោជាង ក៏ពោលទៅកាន់ជនទាំង ៣៣ នាក់នោះថា "ស្វាប់ហើយនាយ ខ្ញុំបាទនឹកមិនឃើញនូវកិច្ចដែលគួរធ្វើមួយ" ។

ពួកមឃៈ. ម្នាលអ្នកដ៏ចម្រើន អ្នកនឹកមិនឃើញដល់កិច្ចអ្វី ?

ជាង. បពិត្រនាយ ហោជាង ។

ពួកមឃៈ. ម្នាលអ្នកដ៏ចម្រើន ហេតុនោះចូរលើកទុកសិនចុះ ពួកយើងនឹងនាំហោជាងនោះមកដោយខ្លួនឯង ។

ជាង. ខ្ញុំបាទមិនអាចធ្វើដោយឈើដែលបុគ្គលទើបតែកាត់ហើយក្នុងកាលឥឡូវនេះបានទេ, ការបាននូវហោជាងដែលបុគ្គលកាត់ហើយ ឈូសហើយ ធ្លាក់ហើយ តម្កល់ទុកក្នុងកាលមុននោះឯង ទើបសមគួរ ។

ពួកមឃៈ. ឥឡូវនេះ ពួកយើងគួរធ្វើដូចម្ដេច ?

ជាង. ប្រសិនបើក្នុងផ្ទះរបស់អ្នកណាៗ មានហោជាងសម្រាប់លក់ ដែលគេធ្វើស្រេចហើយតម្កល់ទុកសោត គួរស្វែងរកហោជាងនោះមក ។

ពួកមឃមាណពទាំង ៣៣ នាក់ ស្វែងរកនូវហោជាង ក៏ឃើញមាននៅក្នុងផ្ទះរបស់នាងសុធម្មា ហើយឲ្យទ្រព្យ ១០០០ ដើម្បីឲ្យនាងសុធម្មាប្រគល់នូវហោជាងដល់ខ្លួន ក៏មិនបាននូវហោជាងនោះ ដោយទ្រព្យដែលជាតម្លៃ, កាលនាងសុធម្មានិយាយថា "ប្រសិនបើ ពួកលោកធ្វើខ្ញុំឲ្យជាស្ត្រីមានចំណែកបុណ្យក្នុងសាលានោះសោត ខ្ញុំនឹងឲ្យ" ។ ឆ្លើយថា "ពួកខ្ញុំមិនឲ្យនូវចំណែកបុណ្យដល់ពួកមាតុគ្រាម" ។

គ្រានោះ ជាងឈើក៏បានពោលទៅកាន់ជនទាំងនោះថា "បពិត្រនាយ លោកនិយាយអ្វី ? វៀរព្រហ្មលោកចេញ ស្ថានទីដទៃ ដែលឈ្មោះថា ជាទីវៀរមាតុគ្រាមចេញ រមែងមិនមាន, ពួកលោកចូរទទួលយកហោជាងចុះ កាលបើដូច្នោះ ការងាររបស់ពួកយើងក៏នឹងដល់នូវការសម្រេច" ។ ពួកជនទាំង ៣៣ នាក់នោះ ក៏ទទួលយល់ព្រមថា

“ប្រពៃហើយ” ហើយទទួលយកហោជាងនោះទៅ ញុំាងសាលាឲ្យសម្រេចហើយ បែងជា ៣ ចំណែកគឺ មួយចំណែកសម្រាប់ជាទីនៅនៃពួកឥស្សរជន, មួយចំណែកសម្រាប់ជនទុរគតទាំងឡាយ, មួយចំណែកទៀត សម្រាប់មនុស្សឈឺទាំងឡាយ ។

## រឿងដីវឯករវណ

ជនទាំង ៣៣ នាក់ ឲ្យគេក្រាលបន្ទះក្តារ ៣៣ បន្ទះ ហើយឲ្យសញ្ញាដល់ដីរថា “កាលភ្ញៀវមកអង្គុយលើបន្ទះក្តារដែលបុគ្គលណាក្រាលទុក, ឯងចូរនាំភ្ញៀវនោះទៅកាន់ផ្ទះនៃបុគ្គលអ្នកជាម្ចាស់បន្ទះក្តារនោះចុះ ការប្រេបាច់ជើង ការប្រេបាច់ខ្នង របស់ដែលគួរទំពាស៊ី និងរបស់ដែលគប្បីបរិភោគ ទីដេកទាំងឡាយគ្រប់យ៉ាង នឹងជាភារៈនៃបុគ្គលដែលជាម្ចាស់នៃបន្ទះក្តារនោះ” ។

ដីរទទួលអ្នកដែលមកហើយៗ នាំទៅកាន់ផ្ទះបុគ្គលអ្នកជាម្ចាស់នៃបន្ទះក្តារនោះឯង ។ ក្នុងថ្ងៃនោះ ម្ចាស់បន្ទះក្តារនោះ រមែងធ្វើកិច្ចដែលគួរធ្វើដល់អ្នកដែលដីរនាំទៅនោះ ។

មយមាណពដាំនូវដើមរលួសផ្កុងមួយដើម ក្នុងទីមិនឆ្ងាយអំពីសាលា ហើយក្រាលនូវផ្ទាំងថ្មក្បែរគល់ដើមរលួសផ្កុងនោះ ។

ពួកជនដែលចូលទៅកាន់សាលាហើយ ក្រឡេកមើលនូវហោជាង អានអក្សរទាំងឡាយហើយ រមែងនិយាយគ្នាថា "សាលាឈ្មោះ សុធម្មា" ឈ្មោះរបស់ជនទាំង ៣៣ នាក់មិនប្រាកដ ។

នាងសុនន្ទាគិតថា ជនទាំងនេះ កាលធ្វើសាលា ធ្វើពួកយើងមិនឲ្យជាអ្នកមានចំណែកនៃបុណ្យផង, ចំណែកឯនាងសុធម្មា ក៏ធ្វើហោជាងចូលរួមចំណែកទាល់តែបាន ព្រោះភាវៈនៃខ្លួនជាស្ត្រីឈ្លាសវៃ, យើងក៏គួរនឹងធ្វើនូវកុសលកម្មអ្វីមួយ, យើងនឹងធ្វើនូវអ្វីហ្ន៎ ?

គ្រានោះឯង នាងក៏មានការគិតដូច្នេះថា "ពួកជនដែលមកកាន់សាលាគួរនឹងបានទឹកផឹក និងទឹកងូត, យើងនឹងឲ្យគេជីកស្រះបោក្ខរណី" នាងសុនន្ទាក៏បានញ៉ាំងបុគ្គលឲ្យជីកស្រះបោក្ខរណីមួយ ។

នាងសុចិត្រាគិតថា "នាងសុធម្មាបានឲ្យហោជាង, នាងសុនន្ទាបានសាងស្រះបោក្ខរណី, យើងក៏គួរសាងកុសលអ្វីមួយដែរ យើងនឹង

ធ្វើអ្វីហ្ន៎” ?

គ្រានោះ នាងមានការគិតដូច្នេះថា “ក្នុងកាលដែលពួកជនមកកាន់សាលា ផឹកទឹក ងូតទឹកហើយទៅ គួរប្រដាប់នូវកម្រងផ្កាហើយសឹមទៅ រមែងសមគួរ, យើងនឹងសាងសួនច្បារ” នាងបានឲ្យគេសាងសួនច្បារមួយដ៏ជាទីមនោរម្យ ។ អ្នកដែលនឹងពោលថា “ដោយច្រើនក្នុងសួននោះមិនមានដើមឈើដែលចេញផ្កា ចេញផ្លែឯណោះ” ដូច្នេះរមែងមិនមាន ។

ចំណែកនាងសុជាតា គិតថា “យើងជាជីតានៃឪពុកធំរបស់មឃមាណពផង ទាំងជាបាទបរិចារិកា ( ភរិយា ) ផង ។ កម្មដែលមឃមាណពនោះធ្វើហើយ ក៏ជារបស់យើងដែរ, កម្មដែលយើងធ្វើហើយ ក៏ជារបស់មឃមាណពនោះដែរ” ដូច្នេះហើយ មិនធ្វើនូវកុសលអ្វីៗ ទាំងអស់ ខំប្រឹងតែស្អិតស្អាងរាងកាយរបស់ខ្លួនប៉ុណ្ណោះ ញុំាងកាលឲ្យកន្លងហួសទៅ ។

# មយមាណពបំពេញវត្តបទ ៧ ប្រការ

ចំណែកមឃមាណព បំពេញវត្តបទ ៧ ប្រការនេះ គឺ បម្រើមាតាបិតា ១ ប្រព្រឹត្តឱនលំទោនគោរពរៀមច្បងក្នុងត្រកូល ១ ពោលពាក្យល្អិតទន់ ១ មិនពោលនូវវាចាទ្រគោះ ១ មិនពោលពាក្យញុះញង់ ១ កម្ចាត់បង់នូវសេចក្ដីកំណាញ់ ១ មិនក្រោធ ១ ដល់នូវភាពជាអ្នកគួរសរសើរយ៉ាងនេះថា ៖

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតា
បិតា គោរពកោតក្រែងបុគ្គលជារៀមច្បងក្នុងត្រកូល
មានវាចាល្អិតទន់ និយាយសំដីផ្អែមល្ហែម លះបង់ពាក្យ
ញុះញង់ ប្រកបតែក្នុងការកម្ចាត់បង់នូវសេចក្ដីកំណាញ់
មានវាចាទៀងទាត់ ជាជនគ្របសង្កត់សេចក្ដីក្រោធនោះ
ឯងថា ជាសប្បុរស ។

ក្នុងវេលាអស់ជីវិត បានកើតជាសក្កទេវរាជក្នុងភពតាវត្តិង្ស ។ សម្លាញ់របស់មឃមាណពទាំងនោះ ក៏កើតក្នុងទីនោះដែរ ។ ជាងឈើ

កើតជាវិស្សកម្មទេវបុត្រ ។

## ទេវតា និង អសុរច្បាំងគ្នា ច្រើងាន ជាមួយគ្នា

ក្នុងកាលនោះ ពួកអសុរនៅក្នុងភពតាវត្តិង្សទេវលោក អសុរទាំងនោះ គិតថា "ទេវបុត្រថ្មីៗ កើតហើយ ទើបចាត់ចែងនូវទឹកបាន ( ទឹកដែលបុគ្គលគប្បីផឹក ) ដ៏ជាទិព្វ ។

សក្កទេវរាជបានឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គ ដើម្បីប្រយោជន៍មិនឲ្យនរណាៗ ផឹក ។ ពួកអសុរផឹកនូវទឹកបានដ៏ជាទិព្វ ស្រវឹងទាំងអស់គ្នា ។ សក្កទេវរាជទ្រង់គិតថា "យើងនឹងត្រូវធ្វើដូចម្តេចទៅ ដោយភាពជារាជាទូទៅដល់អសុរទាំងនេះ" ? ទ្រង់ឲ្យសញ្ញាដល់បរិស័ទរបស់ព្រះអង្គហើយ បញ្ជាឲ្យជួយគ្នាចាប់អសុរទាំងនោះពួដ៏ជើងទាំង ២ បោះទៅក្នុងមហាសមុទ្រ ។ អសុរទាំងនោះមានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងមហាសមុទ្រ, ខណៈនោះ អសុរវិមានបានកើតនាផ្ទៃខាងក្រោមនៃភ្នំសិនេរុ ដោយអានុភាពបុណ្យរបស់ពួកអសុរ ។ ដើមឈើឈ្មោះចិត្តបាដលិ ( ដើមច្រនៀង ) ក៏កើតហើយដែរ ។

កាលសង្គ្រាមរវាងទេវតា និងអសុរ ( ប្រយុទ្ធគ្នាហើយ ), លុះកាលពួកអសុរបរាជ័យហើយ, ទេពនគរក្នុងជាន់តាវត្តិង្សប្រមាណ ១០០០០ យោជន៍ កើតឡើងហើយ ។ ហើយក្នុងចន្លោះទ្វារដែលតាំងនៅទិសខាងកើត និងទិសខាងលិចនៃព្រះនគរនោះ ក៏មានផ្ទៃដីប្រមាណ ១០០០០ យោជន៍ដូចគ្នាដែរ, ចន្លោះទ្វារទិសខាងត្បូង និងទិសខាងជើងក៏មានផ្ទៃដីប្រមាណប៉ុណ្ណោះដែរ ។ ម្យ៉ាងទៀត ព្រះនគរនោះប្រកបដោយទ្វារ ១០០០ ប្រដាប់ដោយឧទ្យាន និងស្រះបោក្ខរណី ។ ប្រាសាទឈ្មោះ វេជយន្ត កំពស់ ៧០០ យោជន៍ សំរេចហើយដោយកែវ ៧ ប្រការ ប្រដាប់ដោយទង់ទាំងឡាយ កំពស់ ៣០០ យោជន៍ ផុសឡើងហើយដោយផលនៃសាលាត្រង់កណ្តាលព្រះនគរនោះ, ដងទង់ធ្វើអំពីមាស ចំណែកទង់ធ្វើអំពីកែវមណី, ដងធ្វើអំពីកែវមណី ទង់ធ្វើអំពីមាស ដងធ្វើអំពីកែវប្រវាឡ ទង់ក៏ធ្វើអំពីកែវមុក្តា ដងធ្វើអំពីកែវមុក្តា, ទង់ធ្វើអំពីកែវប្រវាឡ ទង់ដែលតាំងនៅត្រង់កណ្តាលមានកំពស់ ៣០០ យោជន៍ ប្រាសាទ កំពស់ ១០០០ យោជន៍ សុទ្ធ-

តែសម្រេចអំពីកែវ ៧ ប្រការ កើតហើយដោយផលនៃសាលា ដោយប្រការដូច្នេះ ។

ដើមបារិច្ឆត្តកព្រឹក្ស មានមណ្ឌល ( ផ្សាយទៅ ) ៣០០ យោជន៍ដោយជុំវិញ កើតឡើងហើយដោយផលនៃការដាំដើមរលួសផ្អុង ។ បណ្ឌុកម្ពលសិលាមានពណ៌លឿងស្រស់ ដូចជាពណ៌នៃផ្ការាជព្រឹក្ស និងពណ៌ក្រហមព្រឿង និងដូចពណ៌នៃទឹកល័ក្ត ដោយមានបណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កំរាស់ ១៥ យោជន៍ បណ្ឌុកម្ពលសិលាអាសនៈនេះ ក្នុងកាលដែលសក្កទេវរាជគង់ហើយ កាយពាក់កណ្តាលក៏លិចចូលទៅ ក្នុងកាលដែលសក្កទេវរាជក្រោកឡើង រមែងប៉ោងឡើងពេញបរិបូណ៌ដូចដើមវិញ កើតឡើងហើយទៀបគល់នៃដើមបារិច្ឆត្តកព្រឹក្ស ដោយផលនៃការក្រាលផ្ទាំងសិលា ។

## ទេវបុត្រ ៣៣ អង្គអង្គុយលើពោធិ៍ដំរីឯរាវ័ណ

ចំណែកដំរីកើតជាទេវបុត្រឈ្មោះឯរាវ័ណ ។ ពិតណាស់ សត្វ

តិរច្ឆានទាំងឡាយ រមែងមិនមានក្នុងទេវលោក ព្រោះហេតុនោះ ក្នុងកាលដែលសក្កទេវរាជស្តេចចេញទៅ ដើម្បីក្រសាលនៅក្នុងរាជឧទ្យានទេវបុត្រនោះក៏និម្មិតខ្លួនជាដំរីឈ្មោះឯរាវ័ណ កំពស់ ១៥០ យោជន៍ ។ ដំរីទេវបុត្រនោះ និម្មិតពោង ៣៣ ដើម្បីប្រយោជន៍ដល់ជនទាំង ៣៣ នាក់, ក្នុងបណ្តាពោងទាំងនោះ ពោងនីមួយៗ ដោយចំណែកមូល ៣ គាវុត ដោយចំណែកខាងបណ្តោយកន្លះយោជន៍ ។ ទេវបុត្រនោះនិម្មិតពោងឈ្មោះសុទស្សនៈ ប្រមាណ ៣០ យោជន៍ ត្រង់កណ្តាលពោងទាំងអស់ ដើម្បីប្រយោជន៍ដល់សក្កទេវរាជ ខាងលើនៃពោងនោះមានមណ្ឌបកែវប្រមាណ ១២ យោជន៍ ទង់កែវ ៧ ប្រការកំពស់ ១ យោជន៍តាំងឡើងក្នុងចន្លោះៗ ក្នុងមណ្ឌបកែវនោះ ។ សំឡេងនៃចង្កោមកណ្តឹង ដែលខ្យល់យ៉ាងស្រទន់បក់ត្រូវហើយ លាយនឹងសំឡេងនៃតន្ត្រីដែលប្រកបដោយអង្គ ៥ រមែងលាន់ចេញយ៉ាងពិរោះដូចជាសំឡេងសង្គីតៈដ៏ជាទិព្វ ។ ចង្កោមនៃកណ្តឹងនោះព្យួរនៅក្នុងទីបំផុតជុំវិញ ។ បល្ល័ង្កកែវមណីប្រមាណ ១ យោជន៍ជាព្រះទីនាំង ជា

របស់ដែលបុញ្ញកម្មតាក់តែងល្អហើយ ដើម្បីសក្កទេវរាជត្រង់កណ្តាលមណ្ឌប, សក្កទេវរាជរមែងគង់លើបល្ល័ង្កនោះជានិច្ច ។ ទេវបុត្រ ៣៣ អង្គអង្គុយលើរតនបល្ល័ង្កក្នុងពោងរបស់ខ្លួនៗ ។ បណ្តាពោងទាំង ៣៣ នោះ ក្នុងពោងនីមួយៗ ដ៏រទេវបុត្រនោះនិម្មិតកូកប្រាំពីរៗ, ក្នុងបណ្តាកូកទាំងនោះ កូកនីមួយៗ ប្រវែងប្រមាណ ៥០ យោជន៍, ក្នុងកូកនីមួយៗ មានស្រះបោក្ខរណីប្រាំពីរៗ,ក្នុងបណ្តាស្រះបោក្ខរណីទាំងនោះ ស្រះបោក្ខរណីនីមួយៗ មានគុម្ពឈូកប្រាំពីរៗ,ក្នុងបណ្តាគុម្ពឈូកទាំង ៧ នោះ ក្នុងមួយគុម្ពៗ មានផ្កាប្រាំពីរៗ, ក្នុងផ្កានីមួយៗមានត្របកប្រាំពីរៗ, ក្នុងត្របកនីមួយៗ មានទេពធីតាឈររាំ ៧ អង្គ, របាំនិងមហោស្រពទាំងឡាយ រមែងមានលើកូកដ៏រទាំងឡាយក្នុងទីប្រមាណ ៥០ យោជន៍ ដោយជុំវិញយ៉ាងនេះឯង ។

សក្កទេវរាជសោយយសដ៏ធំស្តេចត្រាច់ទៅដោយប្រការដូច្នេះ។

## កិរិយារបស់មយមាណព ៣ នាក់ក៏កើតក្នុងភពតាវត្តិង្ស

សូម្បីនាងសុធម្មា ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុង

កពតាវត្តិង្សនោះដែរ ។ ទេវសភាឈ្មោះសុធម្មា មានប្រមាណ ៥០០ យោជន៍ បានកើតឡើងហើយដើម្បីនាងសុធម្មានោះ ។ បានឮថា ដែលឈ្មោះថាទីដទៃ ដែលគួរជាទីរីករាយជាងទេវសភានោះ រមែងមិនមាន ។ ក្នុងថ្ងៃអដ្ឋមី ( តិថីទី ៨ ) នៃខែ រមែងមានការស្តាប់នូវព្រះធម៌ក្នុងទេវសភានោះឯង ។

រហូតដល់សព្វថ្ងៃនេះ ជនទាំងឡាយ ឃើញនូវទីណាមួយដែលគួរជាទីត្រេកអរ រមែងពោលថា "ហាក់ដូចជាទេវសភាឈ្មោះសុធម្មា" ។

សូម្បីនាងសុនន្ទា ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងកពតាវត្តិង្សនោះដែរ ។ ស្រះបោក្ខរណីឈ្មោះសុនន្ទា មានទំហំប្រមាណ ៥០០ យោជន៍ កើតឡើងហើយដល់នាងសុនន្ទានោះ ។

សូម្បីនាងសុចិត្រា ធ្វើកាលកិរិយាហើយ ក៏ទៅកើតក្នុងកពតាវត្តិង្សនោះដែរ ។ ឧទ្យានឈ្មោះចិត្តលតាវ័នមានប្រមាណ ៥០០ យោជន៍ ដែលពួកទេវតានាំទេវបុត្រអ្នកមានបុព្វនិមិត្តកើតឡើងហើយ

ឲ្យវង្វេង វង្វាន់ត្រាច់ទៅ កើតឡើងហើយដល់នាងសុចិត្រានោះ ។

## សក្កទេវរាជឲ្យឱវាទដល់នាងសុជាតាដែលជាកុកញី

ចំណែកឯនាងសុជាតា ធ្វើកាលកិរិយាហើយ កើតជាកុកញី នៅនាជ្រោះភ្នំមួយ ។ សក្កទេវរាជ ទ្រង់រមិលមើលនូវនាងបរិចារិកា របស់ព្រះអង្គ ទ្រង់ជ្រាបថា "នាងសុធម្មាកើតហើយក្នុងទីនេះដែរ ។ នាងសុនន្ទា និងនាងសុចិត្រាក៏យ៉ាងនោះដែរ" ។ ទ្រង់គិតតទៅទៀត ថា "នាងសុជាតាកើតទីណាហ្ន៎" ? ឃើញនាងកើតនៅនាជ្រោះភ្នំនោះ ហើយ ទ្រង់គិតថា"នាងសុជាតានេះជាស្រីពាលល្ងង់ខ្លៅ មិនធ្វើបុណ្យ អ្វីៗ ឥឡូវនេះ កើតហើយក្នុងកំណើតសត្វតិរច្ឆាន, សូម្បីឥឡូវនេះ គួរ យើងនឹងញុំាងនាងសុជាតានោះឲ្យធ្វើនូវបុណ្យ ហើយនាំមកអំពីជ្រោះ ភ្នំនោះ"ដូច្នេះហើយ ក៏ទ្រង់និម្មិតអត្តភាព ស្តេចទៅកាន់សំណាក់របស់ នាងដោយភេទដែលអ្នកដទៃមិនស្គាល់ ត្រាស់សួរថា "នាងដើរធ្វើអ្វី នៅនាជ្រោះភ្នំនេះ" ?

កុកញី. បពិត្រនាយ លោកជានរណា ?

សក្កទេវរាជ. យើងគឺជាមឃមាណព ស្វាមីរបស់នាង ។

កុកញ្ញី. បពិត្រនាយ លោកកើតនៅទីណា ?

សក្កទេវរាជ. យើងកើតនៅក្នុងតាវត្តិង្សទេវលោក ។ នាងដឹងថា ស្ត្រីដែលជាសម្លាញ់របស់នាងកើតទីណាហើយឬ ?

កុកញ្ញី. បពិត្រនាយ ខ្ញុំមិនដឹងទេ ។

សក្កទេវរាជ. ស្ត្រីទាំងនោះ ក៏កើតក្នុងសំណាក់របស់យើងដែរ នាងប្រាថ្នាទៅសួរសុខទុក្ខស្ត្រីដែលជាសម្លាញ់របស់នាងដែរទេ ?

កុកញ្ញី. បពិត្រនាយ ខ្ញុំនឹងទៅកាន់ទីនោះបានដោយប្រការដូចម្តេច ?

សក្កទេវរាជត្រាស់ថា "យើងនឹងនាំនាងទៅកាន់ទីនោះ" ដូច្នេះហើយ នាំនាងកុកទៅកាន់ទេវលោក, លែងទុកទៀបឆ្នេរស្រះបោក្ខរណីឈ្មោះនន្ទា ត្រាស់ប្រាប់ព្រះមហេសីទាំង ៣ ក្រៅនេះថា "ពួកនាងប្រាថ្នានឹងឃើញនាងសុជាតាដែលជាសម្លាញ់របស់ពួកនាងដែរទេ" ?

មហេសី. បពិត្រព្រះឱបបត្តិទេព នាងសុជាតានៅទីណា ?

សក្កទេវរាជ. នាងឈរនៅទៀបច្រាំងស្រះបោក្ខរណីឈ្មោះនន្ទា ។

ព្រះមហេសីទាំង ៣ នោះ ស្តេចទៅកាន់ទីនោះ ធ្វើការចំអកថា "ឱ ! រូបរបស់ព្រះនាងម្ចាស់, ឱ ! ផលនៃការស្អិតស្អាងខ្លួន, ឥឡូវនេះអ្នកទាំងឡាយចូរមើលនូវចំពុះ, ចូរមើលនូវស្នងទាំងឡាយ, ចូរមើលនូវជើងទាំងឡាយ, អត្តភាពរបស់ព្រះនាងម្ចាស់ល្អណាស់ហ្ន៎ ដូច្នេះហើយ ក៏ចៀសចេញទៅ ។

សក្កទេវរាជ ស្តេចទៅកាន់សំណាក់របស់នាងទៀត ត្រាស់សួរថា "នាងបានជួបស្ត្រីដែលជាសម្ចាញ់របស់នាងហើយឬ" ? កាលនាងទូលថា "ព្រះមហេសីទាំង ៣ នោះ ខ្ញុំបានជួបហើយ ( គេនាំគ្នា ) ពោលចំអកដាក់ខ្ញុំហើយ ក៏ចៀសចេញទៅ, សូមព្រះអង្គមេត្តានាំខ្ញុំទៅកាន់ជ្រោះភ្នំនោះវិញចុះ" ដូច្នេះហើយ ក៏ទ្រង់នាំមេកុកនោះទៅកាន់ជ្រោះភ្នំដូចដើមវិញ លែងទុកក្នុងទីនោះហើយ ត្រាស់សួរថា "នាងឃើញសម្បត្តិរបស់ស្ត្រីទាំង ៣ នោះហើយឬ" ?

កុកញី. បពិត្រព្រះឱបបត្តិទេព ខ្ញុំបានឃើញហើយ ។

សក្កទេវរាជ. សូម្បីនាងក៏គួរធ្វើនូវឧបាយដែលជាហេតុនាំឲ្យកើតក្នុងទីនោះដែរ ។

កុកញី. បពិត្រព្រះឧបបត្តិទេព នឹងធ្វើនូវអ្វី ?

សក្កទេវរាជ. នាងនឹងរក្សានូវឱវាទរបស់យើងបានទេ ?

កុកញី. បពិត្រព្រះឧបបត្តិទេព ខ្ញុំរក្សាបាន ។

គ្រានោះ សក្កទេវរាជក៏ប្រទានសីល ៥ ឲ្យដល់មេកុក ហើយត្រាស់ថា "នាងចូរជាអ្នកមិនប្រមាទ រក្សាចុះ" ដូច្នេះហើយ ក៏ស្ដេចចៀសចេញទៅ ។

ចាប់ដើមអំពីកាលនោះមក មេកុក ក៏ដើរស្វែងរកនូវត្រីដែលស្លាប់ឯងប៉ុណ្ណោះ ។

ដោយកាលកន្លងទៅ ២-៣ ថ្ងៃ សក្កទេវរាជស្ដេចទៅដើម្បីប្រាថ្នានឹងល្បងមើលនូវមេកុកនោះ ទើបទ្រង់និម្មិតខ្លួនដូចជាត្រីស្លាប់ដេកផ្ងារពោះនៅលើឆ្នេរខ្សាច់ ។ កុកញីនោះឃើញត្រីនោះហើយ បានចឹកយកដោយសេចក្ដីសម្គាល់ថា "ត្រីស្លាប់ហើយ" ក្នុងកាលនឹង

លេប ត្រីនោះក៏ញ៉ាំងកន្ទុយឲ្យកម្រើក ។ កុកញីនោះដឹងថា “ត្រីនៅរស់” ទើបលែងទៅក្នុងទឹក ។ សក្កទេវរាជទ្រង់ញ៉ាំងកាលបន្តិចឲ្យកន្លងទៅហើយ ក៏ទ្រង់ធ្វើដូចជាដេកផ្ងាពោះនៅអំពីខាងមុខមេកុកទៀត មេកុកក៏ចឹកយកទៀត ដោយសម្គាល់ថា “ត្រីស្លាប់” ក្នុងកាលនឹងលេប ឃើញចុងកន្ទុយនៅកម្រើក ក៏លែងទៅដោយសម្គាល់ថា “ត្រីនៅរស់” សក្កទេវរាជទ្រង់ល្បងមើលអស់វារៈ ៣ ដងយ៉ាងនេះហើយ ត្រាស់ថា “នាងរក្សាសីលបានល្អ” ញ៉ាំងមេកុកឲ្យដឹងច្បាស់នូវព្រះអង្គហើយ ត្រាស់ថា “យើងមកដើម្បីប្រាថ្នានឹងល្បងមើលនាង, នាងរក្សាសីលបានល្អ, កាលនាងរក្សាបានយ៉ាងនេះ មិនយូរប៉ុន្មានក៏នឹងបានទៅកើតក្នុងសំណាក់របស់យើងជាពិតប្រាកដ នាងចូរជាអ្នកមិនប្រមាទចុះ” ដូច្នេះហើយ ស្ដេចក៏ចៀសចេញទៅ ។

## នាងសុជាតាត្រាច់រង្គាត់ទៅកាន់ភពផ្សេងៗ

ចាប់ផ្ដើមអំពីកាលនោះមក ជួនកាលនាងបានត្រីដែលស្លាប់ឯង ជួនកាលមិនបាន, កាលមិនបាន ដោយកាលកន្លងទៅ ២-៣ ថ្ងៃ

ប៉ុណ្ណោះ ក៏ស្លាំងស្គម ធ្វើកាលកិរិយាហើយ ទៅកើតជាធីតានៃនាយ ស្មូនឆ្នាំងក្នុងក្រុងពារាណសី ដោយផលនៃសីលនោះ ។

គ្រានោះ ក្នុងកាលដែលនាងមានអាយុប្រហែល ១៥-១៦ ឆ្នាំ សក្កទេវរាជទ្រង់ពិចារណាមើលថា "នាងកើតនៅទីណាហ្ន៎" ? បាន ឃើញហើយ ទ្រង់គិតថា "ឥឡូវនេះ គួរយើងទៅកាន់ទីនោះ" ដូច្នេះ ហើយ ក៏ទ្រង់យកកែវ ៧ ប្រការដែលមានពណ៌ប្រាកដដូចជាពណ៌នៃ ផ្លែល្ពៅ ញ៉ាំងយានតូចឲ្យពេញដោយរតនៈ ៧ ប្រការនោះ បរទៅកាន់ ក្រុងពារាណសី ស្ដេចទៅកាន់ថ្នល់ពពាយនាយ ( អំពាវនាវ ) ថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយមកយកផ្លែល្ពៅទាំងឡាយនេះចុះ" ប៉ុន្តែត្រាស់ទៅកាន់អ្នកដែលយកសណ្ដែកខៀវ និងសណ្ដែករាជមាស ជាដើមមកថា "ខ្ញុំមិនឲ្យដោយតម្លៃទេ" កាលជនទាំងនោះទូលសួរថា "លោកនឹងឲ្យដោយប្រការដូចម្ដេច" ? ត្រាស់ថា "ខ្ញុំនឹងឲ្យដល់ស្ត្រីអ្នក រក្សាសីល" ។

អ្នកក្រុង. បពិត្រនាយ ដែលឈ្មោះថា សីល តើដូចម្ដេច ?

មានពណ៌ខ្មៅ ឬពណ៌ខៀវជាដើម ។

សក្កទេវរាជ. ពួកអ្នកទាំងឡាយមិនស្គាល់សីលថា "ជាអ្វីផង" នឹងរក្សាសីលនោះដូចម្តេចកើត ? ប៉ុន្តែយើងនឹងឲ្យដល់ស្ត្រីអ្នករក្សាសីល ។

អ្នកក្រុង. បពិត្រនាយ ធីតារបស់នាយស្នូលផ្ទាំងនោះត្រាច់ទៅនិយាយថា ខ្ញុំរក្សាសីល សូមលោកចូរឲ្យដល់នាងនោះចុះ ។

សូម្បីធីតារបស់នាយស្នូលផ្ទាំងនោះ ក៏ពោលនឹងសក្កទេវរាជថា "បពិត្រនាយ បើដូច្នោះ ចូរឲ្យមកខ្ញុំចុះ" ។

សក្កទេវរាជ. នាងគឺជាអ្វី ?

ធីតារបស់នាយស្នូលផ្ទាំងឆ្លើយថា ខ្ញុំគឺជាស្ត្រីដែលមិនលះបង់នូវសីល ៥ ។

សក្កទេវរាជ. ផ្លែល្ពៅទាំងនោះ ខ្ញុំក៏នាំមកដើម្បីនាងប៉ុណ្ណោះ ។

សក្កទេវរាជទ្រង់បរយានតូចទៅកាន់ផ្ទះរបស់នាង ហើយប្រទានទ្រព្យ ដែលទេវតាគប្បីឲ្យដោយមានពណ៌ដូចជាផ្លែល្ពៅ ធ្វើមិន

ឲ្យជនជទែលួចយកទៅបាន ញុំាំងធីតានៃនាយសូ្ទធ្នាំឲ្យជើងនូវព្រះអង្គហើយ ត្រាស់ថា "នេះជាទ្រព្យសម្រាប់ចិញ្ចឹមជីវិតរបស់នាង ។ នាងចូររក្សាសីល ៥ កុំឲ្យដាច់ ហើយស្តេចក៏ចៀសចេញទៅ ។

## នាងសុជាតាជាធីតារបស់អសុរ

ចំណែកធីតារបស់នាយសូ្ទធ្នាំងនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងភពអសុរដែលជាអ្នកមានពៀរចំពោះសក្កទេវរាជ ជាធីតារបស់ស្តេចអសុរក្នុងភពអសុរ ព្រោះការដែលនាងរក្សាសីលយ៉ាងល្អក្នុងពីរអត្តភាព ទើបនាងបានជាស្ត្រីមានរូបស្រស់ស្អាត មានពណ៌សម្បុរដូចមាស ប្រកបដោយរូបសិរីមិនសាធារណៈ ( ទូទៅ ) ។ ស្តេចអសុរដែលមាននាមថា វេបចិត្តិនិយាយនឹងអ្នកដែលមកហើយៗថា "ពួកអ្នកមិនសមគួរដល់ធីតារបស់យើងទេ" ហើយក៏មិនឲ្យធីតានោះដល់អ្នកណាមួយឡើយ គិតថា "ធីតារបស់យើង នឹងជ្រើសរើសបុរសដែលសមគួរដល់ខ្លួនដោយខ្លួនឯង" ដូច្នេះហើយ ទើបឲ្យពួកអសុរប្រជុំគ្នា ហើយបានឲ្យកួងផ្កាក្នុងដៃនៃធីតានោះ ដោយពោលថា

“នាងចូរជ្រើសរើសយកបុរសដែលសមគួរដល់នាងធ្វើជាស្វាមីចុះ” ។

## សក្កទេវរាជបន្ទំធ្វើជាអសុរដណ្តើមនាងសុជាតា

ក្នុងខណៈនោះ សក្កទេវរាជ ទ្រង់ពិចារណារកមើលទីដែលនាងកើត ទ្រង់ជ្រាបនូវព្រឹត្តិការណ៍នោះហើយ ទ្រង់ត្រិះរិះថា ឥឡូវនេះសមគួរដែលយើងនឹងទៅនាំយកនាងមក ដូច្នេះហើយ បានទ្រង់និម្មិតភេទជាអសុរកញ្ចាស់ ទៅឈរនៅខាងចុងទីបំផុតបរិស័ទ ។ សូម្បីនាងអសុរកញ្ញានោះ កាលរមិលមើលខាងនោះ និងខាងនេះ លុះឃើញសក្កទេវរាជនោះ ក៏ជាស្ត្រីមានហឫទ័យ គឺសេចក្តីស្រឡាញ់ដូចជាជំនន់ទឹកដ៏ធំកើតឡើងហើយ ដោយអំណាចបុព្វេសន្និវាសគ្របសង្កត់ហើយ ក៏ដាក់ចិត្តថា “នោះស្វាមីរបស់យើង” ទើបបោះកួងផ្កាទៅលើអសុរកញ្ចាស់ ( សក្កទេវរាជ ) នោះ ។

ពួកអសុរក៏ចំអកថា “ព្រះរាជារបស់ពួកយើងមិនបានអ្នកដែលសមគួរដល់ធីតារហូតអស់កាលប្រមាណប៉ុណ្ណេះ ឥឡូវនេះបានហើយ, អ្នកដែលចាស់ជាងអសុររូបនេះ ទើបសមគួរដល់ធីតារបស់

ព្រះអង្គ” ដូច្នេះហើយ ក៏ចៀសចេញទៅ ។

ចំណែកឯសក្កទេវរាជ ទ្រង់ចាប់ដៃអសុរកញ្ញានោះហើយ ទ្រង់ប្រកាសថា “យើងគឺជាសក្កទេវរាជ” ហើយទ្រង់ហោះទៅក្នុងអាកាស ។

ពួកអសុរដឹងថា “ពួកយើងត្រូវសក្កៈកញ្ឆក់បញ្ឆោតហើយ” ទើបនាំគ្នាដេញតាមសក្កទេវរាជនោះទៅ ។ ទេពសារថីឈ្មោះមាតលីនាំវេជយន្តរថមកបញ្ឈប់ចាំនៅពាក់កណ្តាលផ្លូវ ។ សក្កទេវរាជទ្រង់លើកអសុរកញ្ញាឡើងកាន់វេជយន្តរថនោះហើយ មានមុខឆ្ពោះទៅកាន់ទេវនគរ បរវេជយន្តរថទៅ ។

គ្រានោះ កូនគ្រុឌទាំងឡាយបានឮសូរសំឡេងរថហើយក៏ភ័យខ្លាចស្រែកយំ ។ សក្កទេវរាជទ្រង់ព្រះសណ្តាប់នូវសំឡេងយំរបស់កូនគ្រុឌហើយ ត្រាស់សួរមាតលីថា នុ៎ះជាសំឡេងស្រែកយំរបស់ពួកណា ?

មាតលី. បពិត្រមហារាជ សំឡេងយំរបស់កូនគ្រុឌ ។

សក្កទេវរាជ. ព្រោះហេតុអ្វី ទើបវាយំ ?

មាតលី. ព្រោះបានឮសំឡេងរថហើយ ខ្លាចស្លាប់ ។

សក្កទេវរាជត្រាស់ថា "ព្រោះអាស្រ័យយើងតែម្នាក់ បក្សីមានប្រមាណប៉ុណ្ណេះ ត្រូវកម្លាំងនៃរថឲ្យវិនាសទៅហើយ ពួកវាកុំវិនាសឡើយ, អ្នកចូរត្រឡប់រថវិញចុះ" ។

មាតលីទេវបុត្រនោះ ឲ្យសញ្ញាដល់សេះសិន្ធពដោយរំពាត់ឲ្យត្រឡប់ ។

ពួកអសុរឃើញកិរិយានោះហើយគិតថា "សក្កៈកញ្ចាស់ចៀសចេញទៅតាំងអំពីអសុរបុរី ឥឡូវនេះត្រឡប់រថមកវិញ នឹងបានអ្នកជំនួយជាពិតប្រាកដ" ទើបត្រឡប់ចូលទៅកាន់អសុរបុរីតាមផ្លូវដែលមកហើយនោះឯង មិនងើបក្បាលឡើងទៀត ។

ចំណែកសក្កទេវរាជ ទ្រង់នាំអសុរកញ្ញាឈ្មោះសុជាតាទៅកាន់ទេពនគរហើយ ទ្រង់ស្ថាបនាទុកក្នុងតំណែងប្រធាននាងទេពអប្សរ ២ កោដិកន្លះ ។ អសុរកញ្ញាទូលសូមពរសក្កទេវរាជថា "សូមតេជៈ

មហារាជ មាតាបិតា ឬបងប្រុសបងស្រីរបស់ខ្ញុំព្រះអង្គ ក្នុងទេវលោកនេះមិនមាន,ព្រះអង្គនឹងស្ដេចទៅកាន់ទីណាៗ គប្បី ( ទ្រង់ព្រះករុណា ) នាំខ្ញុំព្រះអង្គទៅកាន់ទីនោះ ៗ ផង សក្កទេវរាជបានព្រះរាជទានបណ្ដាដល់អសុរកញ្ញាថា "បាន" ។

## ពួកអសុរខ្លាចសក្កទេវរាជ

ក៏ចាប់ដើមអំពីកាលនោះមក កាលផ្កាចិត្តបាដលិរីក ពួកអសុរ ប្រាថ្នាដើម្បីនឹងច្បាំងនឹងសក្កទេវរាជ ឡើងមកដើម្បីប្រយោជន៍ដល់ការច្បាំង ដោយសម្គាល់ថា "ជាកាលដែលផ្កាបារិច្ឆត្តកព្រឹក្សដ៏ជាទិព្វរបស់យើងទាំងឡាយរីក" ។

សក្កទេវរាជបានទទួលនូវការរក្សាអំពីពួកនាគ ដែលនៅខាងក្រោមនៃសមុទ្រ ។ បន្ទាប់អំពីនោះ ពួកគ្រុឌ, បន្ទាប់អំពីនោះ ពួកកុម្ភណ្ឌ, បន្ទាប់អំពីនោះ ពួកយក្ស, បន្ទាប់អំពីនោះ ពួកទេវតាចាតុម្មហារាជិកា, ចំណែកជាន់លើជាងគេបង្អស់ ប្រតិស្ឋានរូបចម្លាក់ព្រះឥន្ទដែលមានអាវុធពេជ្រក្នុងព្រះហស្ត ត្រង់ទ្វារនៃទេពនគរទាំងឡាយ ។

ពួកអសុរ សូម្បីឈ្មោះពួកនាគជាដើមមកហើយ ឃើញរូបប្រៀបរបស់ព្រះឥន្ទអំពីចម្ងាយ ក៏រមែងរត់ទៅ ដោយគិតថា "សក្កទេវរាជស្ដេចចេញមកហើយ" ។

## អានិសង្សនៃសេចក្ដីមិនប្រមាទ

ព្រះសាស្ដាត្រាស់ថា "បពិត្រមហាលិ មឃមាណពបដិបត្តិអប្បមាទបដិបទាយ៉ាងនេះ, លុះមឃមាណពនោះជាអ្នកមិនប្រមាទហើយយ៉ាងនេះ ទើបដល់ភាពជាធំបែបនេះ ទ្រង់សោយរាជ្យក្នុងទេវលោកទាំង ២, ដែលឈ្មោះថា សេចក្ដីមិនប្រមាទនោះ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម សរសើរហើយ, ព្រោះថា ការសម្រេចគុណវិសេសដែលជាលោកិយ និងលោកុត្តរៈសូម្បីទាំងអស់ រមែងមានបាន ព្រោះអាស្រ័យសេចក្ដីមិនប្រមាទ" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

**៧. អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

មឃមាណព ដល់នូវភាពជាបុគ្គលប្រសើរបំផុត ជាង ទេវតាទាំងឡាយ ព្រោះតែសេចក្តីមិនប្រមាទ អ្នកប្រាជ្ញ ទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ ត្មិះតិះដៀល នូវសេចក្តីប្រមាទ សព្វៗ កាល ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បមាទេន** គឺ ព្រោះតែសេចក្តី មិនប្រមាទ ដែលខ្លួនធ្វើទុក តាំងអំពីការសំអាតភូមិប្រទេសក្នុង អចលគ្រាម ជាដើម ។

បទថា **មឃវា** ជាដើម សេចក្តីថា មឃមាណពដែល ប្រាកដឈ្មោះថា “មឃវៈ” ឥឡូវនេះ ឈ្មោះថា ដល់ភាពជាអ្នកប្រ- សើរជាទីបំផុតជាងទេវតាទាំងឡាយ ព្រោះភាពជាព្រះរាជានៃទេវតា ទាំង ២ ជាន់ ។

បទថា **បសំសន្តិ** សេចក្តីថា បណ្ឌិតទាំងឡាយមានព្រះពុទ្ធជា ដើម រមែងសរសើរសេចក្តីមិនប្រមាទតែម្យ៉ាង ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្តីមិនប្រមាទ ជាហេតុនាំឲ្យបានសម្រេចនូវគុណវិសេសដែលជាលោកិយ និងលោកុត្តរៈទាំងអស់ ។

បាទព្រះគាថាថា **បមាទោ គរហិតោ សទា** សេចក្តីថា ចំណែកសេចក្តីប្រមាទ ព្រះអរិយៈទាំងឡាយរមែងតិះដៀល គឺនិន្ទាហើយជានិច្ច ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្តីប្រមាទ ជាឫសគល់នៃគុណវិបត្តិគ្រប់យ៉ាង ។ ពិតណាស់ ភាពជាអ្នកជួបគ្រោះអាក្រក់ក្នុងមនុស្សក្តី ការចូលដល់អបាយភូមិក្តី សុទ្ធតែមានសេចក្តីប្រមាទជាមូលទាំងអស់ ។

ក្នុងកាលចប់ព្រះគាថា ស្តេចលិច្ឆវីនាមថា មហាលិ ទ្រង់តាំងនៅក្នុងសោតាបត្តិផល ។ សូម្បីបរិស័ទដែលប្រជុំគ្នាជាច្រើននោះ ក៏បានជាព្រះអរិយបុគ្គល មានសោតាបន្នជាដើមដែរ ៕

( រឿងសក្កទេវរាជ ចប់ )

## ៨ រឿងភិក្ខុមួយរូប

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ត្រាស់ព្រះធម្មទេសនានេះថា “**អប្បមាទរតោ ភិក្ខុ**” ដូច្នេះជាដើម ។

## ភិក្ខុអង្គុយពិចារណាភ្លើងឆេះព្រៃជាអារម្មណ៍

បានឮមកថា ភិក្ខុរូបនោះរៀនកម្មដ្ឋាន ដរាបដល់ព្រះអរហត្តក្នុងសំណាក់ព្រះសាស្ដាហើយ ចូលទៅកាន់ព្រៃខ្ទប់ព្រៃង ព្យាយាមក៏មិនអាចសម្រេចព្រះអរហត្តផលបាន ។

ភិក្ខុនោះគិតថា “យើងនឹងទៅទូលសូមព្រះសាស្ដា ឲ្យទ្រង់ត្រាស់ប្រាប់កម្មដ្ឋានឲ្យវិសេស ( ឡើងទៅ )” ដូច្នេះហើយ ចេញអំពីព្រៃនោះ កំពុងដើរមកកាន់សំណាក់ព្រះសាស្ដា ឃើញភ្លើងព្រៃដ៏ធំតាំងឡើងហើយក្នុងចន្លោះផ្លូវ ប្រញាប់ឡើងកាន់កំពូលភ្នំត្រងោលមួយ អង្គុយសម្លឹងមើលនូវភ្លើងដែលកំពុងឆេះព្រៃ កាន់យកជាអារម្មណ៍ថា “ភ្លើងនេះឆេះនូវកំកាច់ឈើទាំងតូចទាំងធំ យ៉ាងណាមិញ សូម្បីភ្លើង គឺ

អរិយមគ្គញាណ ក៏រមែងដុតនូវសំយោជនៈទាំងតូចទាំងធំដូច្នោះដែរ ។

## បដិបទាកាត់សំយោជនៈ

ព្រះសាស្តា គង់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុនោះហើយ ត្រាស់ថា "ម្នាលភិក្ខុ យ៉ាងហ្នឹងឯង សំយោជនៈទាំងល្អិតទាំងគ្រោតគ្រាត ទាំងតូចទាំងធំ ដែលកើតនៅខាងក្នុងសន្តានរបស់សត្វទាំងនេះ ដូចរំកាច់ឈើធំខ្លះ តូចខ្លះ ដូច្នោះ ភិក្ខុគួរដុតសំយោជនៈដោយភ្លើង គឺញាណហើយ ធ្វើឲ្យជាធម្មជាតិមិនគួរដល់ការកើតឡើងបានទៀត" ដូច្នេះហើយ ទ្រង់បញ្ចេញនូវព្រះរស្មីហាក់ដូចជាគង់នៅក្នុងទីចំពោះមុខនៃភិក្ខុនោះ ត្រាស់ព្រះគាថានេះថា ៖

**៨ អប្បមាទរតោ ភិក្ខុ មាទេ ភយទស្សិ វា**
**សំយោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ តែងដុតបោលសំយោជនៈទាំងតូចទាំងធំដូចភ្លើងឆេះ ( រាលនូវកំទេចទាំងតូចទាំងធំ ) ដូច្នោះឯង ។

# អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អប្បមាទរតោ** សេចក្តីថា ត្រេកអរហើយ គឺត្រេកអរក្រៃលែងហើយក្នុងសេចក្តីមិនប្រមាទ បានដល់ញុំាងកាលឲ្យកន្លងទៅដោយសេចក្តីមិនប្រមាទ ។

បាទព្រះគាថាថា **បមាទេ ភយទស្សិ វា** សេចក្តីថា អ្នកឃើញភ័យក្នុងសេចក្តីប្រមាទ មានការចូលទៅកើតក្នុងនរកជាដើម, មួយប្រការទៀត ឈ្មោះថា អ្នកឃើញសេចក្តីប្រមាទដោយភាវៈជាគ្រឿងភ័យ ព្រោះសេចក្តីប្រមាទនោះជាឫសគល់នៃវិបត្តិទាំងនោះ ។

បទថា **សញ្ញោជនំ** សេចក្តីថា សំយោជនៈ ១០ យ៉ាង ជាគ្រឿងប្រកប ជាគ្រឿងចង ( សត្វ ) ទុកក្នុងវដ្តទុក្ខ អាចញុំាងសត្វឲ្យលិចចុះក្នុងវដ្តៈបាន ។

បទថា **អណុំ ថូលំ** គឺ ធំ និងតូច ។

បាទព្រះគាថាថា **ឌហំ អគ្គីវ គច្ឆតិ** សេចក្តីថា ភិក្ខុនោះត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ រមែងដុតសំយោជនៈនោះដោយ

ភ្លើង គឺញាណ ដែលខ្ជួនសម្រេចហើយដោយសេចក្ដីមិនប្រមាទ គឺធ្វើឲ្យជាធម្មជាតិមិនគួរដល់ការកើតឡើងតទៅទៀតបាន ដូចភ្លើងដុតកំទេចតូច និងកំទេចធំដូច្នោះឯង ។

ក្នុងកាលចប់ព្រះគាថា ភិក្ខុនោះអង្គុយនៅក្នុងទីនោះឯង ក៏បានដុតបោលនូវសំយោជនៈទាំងអស់ ហើយបានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ហើយនិមន្តមកតាមអាកាស ( ហោះមក ) ស្ញើចសរសើរនូវព្រះសរីរៈរបស់ព្រះតថាគត ដែលមានវណ្ណៈដូចជាវណ្ណៈនៃមាស ថ្វាយបង្គំហើយ ក៏ចៀសចេញទៅ ដោយប្រការដូច្នេះៗ

( រឿងភិក្ខុមួយរូប ចប់ )

**********

# ៩. រឿងព្រះនិគមវាសីតិស្សត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនិគមវាសីតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **“អប្បមាទរតោ”** ដូច្នេះជាដើម ។

## <u>ព្រះថេរៈត្រាច់បិណ្ឌបាតតែក្នុងស្រុកនៃពួកញាតិ</u>

សេចក្តីពិស្តារថា កុលបុត្តម្នាក់កើតមកហើយចម្រើនវ័យក្នុងស្រុកមួយ ដែលនៅមិនឆ្ងាយពីក្រុងសាវត្ថី បព្វជ្ជាហើយបានឧបសម្បទាក្នុងសាសនារបស់ព្រះសាស្តាហើយ ប្រាកដនាមថា “ព្រះនិគមតិស្សត្ថេរ ជាអ្នកមានសេចក្តីប្រាថ្នាតិច សន្តោស ត្រេកអរតែក្នុងវត្ថុដែលខ្លួនមាន ស្ងប់ស្ងាត់ ប្រារព្ធនូវសេចក្តីព្យាយាម” ។

ព្រះថេរៈរមែងត្រាច់ទៅដើម្បីបិណ្ឌបាតតែក្នុងស្រុករបស់ញាតិជាប់ជានិច្ច ។ កាលជនទាំងឡាយមានអនាថបិណ្ឌិកសេដ្ឋីជាដើម ធ្វើនូវមហាទានក្តី កាលព្រះបាទបសេនទិកោសល ទ្រង់បំពេញនូវ

អសទិសទានក្តី, ក៏មិនព្រមមកកាន់ក្រុងសាវត្ថី ។

ពួកភិក្ខុក៏សន្ទនាគ្នាថា "ព្រះនិគមតិស្សត្ថេរនេះ ក្រោកឡើងហើយ ក្រោកឡើងព្រមហើយ ក៏ច្រឡូកច្រឡំ ជាប់ជំពាក់ដោយពួកញាតិ កាលជនទាំងឡាយមានអនាថបិណ្ឌិកសេដ្ឋីជាដើម ធ្វើមហាទានក្តី កាលព្រះបាទបសេនទិកោសលបំពេញអសទិសទានក្តី លោកក៏មិនមក ដូច្នេះហើយ ក៏ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។

## ព្រះថេរៈបានទទួលសាធុការអំពីព្រះសាស្តា

ព្រះសាស្តា ត្រាស់ឲ្យហៅព្រះថេរៈមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតមែនឬ" ? កាលព្រះថេរៈក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមាននូវការច្រឡូកច្រឡំ ឬក៏ជាប់ជំពាក់ទៅដោយពួកញាតិទេ, ខ្ញុំព្រះអង្គអាស្រ័យពួកមនុស្សដែលជាញាតិទាំងនោះ រមែងបាននូវអាហារល្មមនឹងលេបចូលបាន,ខ្ញុំព្រះអង្គគិតថា "កាលយើងបានអាហារដែលសៅហ្មងក្តី ប្រណីតក្តី ដែលល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានហើយ, ប្រយោជន៍អ្វី

ដោយការស្វែងរកនូវអាហារដទៃទៀត ? ដូច្នេះហើយ ទើបមិនមកកាន់ក្រុងសាវត្ថី បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា ការប្រឡូកប្រឡំដោយពួកញាតិ ឬការជាប់ជំពាក់នឹងពួកញាតិរមែងមិនមានដល់ខ្ញុំព្រះអង្គ" ។ សូម្បីតាមប្រក្រតី ( ព្រះអង្គ ) ក៏ទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះថេរៈ ទើបទ្រង់ប្រទានសាធុការថា "ម្នាលភិក្ខុ ប្រពៃហើយៗ" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុ ក៏ការដែលអ្នកបានអាចារ្យប្រាកដដូចជាតថាគតហើយ បានជាអ្នកប្រាថ្នាតិចដោយហេតុឯណា ហេតុនោះ មិនទាន់ជាអស្ចារ្យនៅឡើយទេ, ព្រោះថា ដែលឈ្មោះថា ភាពជាអ្នកប្រាថ្នាតិចនេះជាបែបផែនរបស់តថាគត ជាទំនៀមរបស់តថា-គត" ដូច្នេះហើយ ដែលភិក្ខុទាំងឡាយទូលអារាធនាហើយ ទ្រង់នាំអតីតនិទានមកសម្ដែងថា ៖

## រឿងសត្វសេក

ក្នុងអតីតកាល សត្វសេកច្រើនពាន់ក្បាល នៅក្នុងព្រៃនៃដើមល្វាមួយដើម ទៀបច្រាំងស្ទឹងគង្គាក្នុងហេមវន្តប្រទេស ។

បណ្ដាសត្វសេកទាំងនោះ សត្វសេកមួយជាស្ដេចនៃសេកទាំងនោះ នាកាលផ្លែទាំងឡាយនៃដើមឈើ ដែលខ្លួននៅអាស្រ័យនោះអស់ហើយ, ចឹកស៊ីពន្លក ស្លឹក ឬសំបកដែលនៅសល់ ផឹកទឹកក្នុងស្ទឹងគង្គា ជាសត្វមានសេចក្ដីប្រាថ្នាតិចក្រៃលែង ជាសត្វត្រេកអរចំពោះតែវត្ថុដែលខ្លួនមាន រមែងមិនត្រាច់ទៅកាន់ទីដទៃ, ដោយអំណាចគុណ គឺសេចក្ដីប្រាថ្នាតិច និងសេចក្ដីសន្ដោសរបស់ស្ដេចសេកនោះ ពិភពរបស់សក្កទេវរាជក៏បានកម្រើកញាប់ញ័រ ។

## សក្កទេវរាជទ្រង់ល្បងមើលស្ដេចសេក

សក្កទេវរាជទ្រង់រំពឹងមើល ទ្រង់ឃើញហេតុនោះហើយ ទ្រង់(បណ្ដាល)ឲ្យដើមឈើនោះស្ងួតដោយអានុភាពរបស់ខ្លួន ដើម្បីល្បងមើលនូវស្ដេចសេកនោះ ។

ដើមឈើនោះបាក់ធ្លាក់ចុះហើយ សល់នៅតែដង្គត់ប៉ុណ្ណោះ មានប្រហោងតូច និងប្រហោងធំ (...) ។ កាលខ្យល់បក់មកប៉ះត្រូវបានបញ្ចេញសំឡេងដូចត្រូវគេគោះតាំងនៅហើយ ។

លំអិតទាំងឡាយ ហុយចេញតាមប្រហោងឈើទាំងនោះ ។ ស្តេចសេកចឹកស៊ីលំអិតទាំងនោះ ហើយផឹកទឹកក្នុងស្ទឹងគង្គា មិនទៅកាន់ទីដទៃ មិនអើពើចំពោះខ្យល់ និងកំដៅថ្ងៃ ទំនៅលើទីបំផុតនៃដង្គត់ឈើល្វានោះ សក្កទេវរាជទ្រង់ជ្រាបដល់ការដែលស្តេចសេកនោះ ជាសត្វមានសេចក្តីប្រាថ្នាតិចក្រៃលែង ទ្រង់ព្រះតម្រិះថា "យើងនឹងឲ្យស្តេចសេកនោះ ពោលនូវគុណនៃមិត្តធម៌ ហើយឲ្យពរដល់ស្តេចសេកនោះ ធ្វើ ( បណ្តាល ) ដើមល្វាឲ្យមានផ្លែមិនស្រាក" ដូច្នេះហើយ ( និម្មិត ) ខ្លួនព្រះអង្គជាស្តេចហង្សមួយ នាំនាងអសុរកញ្ញា ដែលមាននាមថា សុជាតាអំពីខាងមុខ ស្តេចទៅកាន់ព្រៃនៃឈើល្វានោះ ទំនៅហ្នឹងមែកនៃដើមឈើមួយដើមមិនឆ្ងាយអំពីទីនោះ កាលនឹងត្រាស់សន្ទនាជាមួយនឹងស្តេចសេកនោះ ត្រាស់គាថានេះថា ៖

**សន្តិ រុក្ខា ហរិតបត្តា ទុមានេកផលា ពហូ**

**កស្មា នុ សុក្ខេ កោលាបេ សុវស្ស និរតោ មនោ ។**

ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ

មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះ

មានចិត្តរីករាយជានិច្ច តែនឹងជន្លត់ឈើពុកស្ងួត ។

សុវជាតកទាំងអស់ បណ្ឌិតគប្បីឲ្យពិស្ដារ តាមន័យដែលពោលមកហើយក្នុងនវកនិបាតនោះចុះ, ប៉ុន្តែការកើតឡើងនៃរឿងប៉ុណ្ណោះ ក្នុងនវកនិបាត និងក្នុងទីនេះផ្សេងគ្នា ពាក្យដ៏សេសដូចគ្នាទាំងអស់ ។

## ភិក្ខុគួរប្រាថ្នាតិច និង សន្ដោស

ព្រះសាស្ដា លុះទ្រង់នាំព្រះធម្មទេសនានេះហើយ ទ្រង់ត្រាស់ថា "សក្កទេវរាជក្នុងកាលណោះ បានមកជាអានន្ទ ស្ដេចសេកក្នុងកាលណោះ គឺតថាគតនេះឯង" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងហើយ ដែលឈ្មោះថា ភាពជាអ្នកមានសេចក្ដីប្រាថ្នាតិច នេះជាបែបផែន ជាទំនៀមរបស់តថាគត ការដែលនិគមវាសី-តិស្សបុត្ររបស់តថាគតបានអាចារ្យដូចជាតថាគត ហើយជាអ្នកមាននូវសេចក្ដីប្រាថ្នាតិច មិនគួរអស្ចារ្យណាស់ណាទេ, ធម្មតាភិក្ខុគប្បីជា

អ្នកមានសេចក្តីប្រាថ្នាតិច ឲ្យដូចជាភិក្ខុនិគមវាសីតិស្សៈ, ព្រោះថា ភិក្ខុបែបនោះ ជាអ្នកមិនគួរសោបសូន្យចាកមគ្គ និងផល, រមែងឋិតនៅក្នុងទីជិតនៃព្រះនិព្វានដោយពិតប្រាកដ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

**៩. អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
**អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ
ក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាក
គុណធម៌ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អភព្វោ បរិហានាយ** សេចក្តីថា ភិក្ខុបែបនោះៗ ជាអ្នកមិនគួរដើម្បីនឹងសាបសូន្យចាកធម៌ គឺសមថៈ និងវិបស្សនា ឬចាកមគ្គ និងផល គឺរមែងមិនសាបសូន្យចាកគុណធម៌ដែលខ្លួនបានដល់ហើយ មិនមែនមិនបានដល់គុណធម៌

ដែលខ្លួនមិនទាន់ដល់ទេ ។

បាទព្រះគាថាថា **និព្វានស្សេវ សន្តិកេ** សេចក្តីថា ឋិតនៅក្នុងទីជិតនៃកិលេសបរិនិព្វាន ( ការរលត់កិលេស ) ផង អនុបាទិសេសនិព្វាន ( ការរំលត់បញ្ចក្ខន្ធ ) ផង ។

ក្នុងកាលចប់ព្រះគាថា ព្រះនិគមវាសីតិស្សត្ថេរ សម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ជនដទៃជាច្រើនក៏បានសម្រេចជាអរិយបុគ្គល មានសោតាបន្នជាដើម ។ ទេសនាបានមានប្រយោជន៍ច្រើនដល់មហាជន ដោយប្រការដូច្នេះឯង ។

( រឿងព្រះនិគមវាសីតិស្សត្ថេរ ចប់ )

**************

# អប្បមាទវគ្គវណ្ណនា ចប់

## វគ្គទី ២ ចប់

# អ្នកជួយពិនិត្យនូវអក្ខរាវិរុទ្ធ

១- ភិក្ខុ **ម៉េន សឿន**

២- ភិក្ខុ **ម៉ៅ អៀប**

៣- សាមណេរ **អ៊ឹម សុជាន**

៤- លោកគ្រូ **ហ៊ឹង វង្ស** សាស្ត្រាចារ្យភាសាបាលីសាលាអ៊ីង ជួង

៥- ឧបាសក **សន ម៉ារឌី**　　　៦- ឧបាសក **ទុំ ទួន** គ្រូបាលី

# ផ្នែកខាងកុំព្យូទ័រ

១- ភិក្ខុ **ម៉ី សាលួន**

២- សាមណេរ **អឿង សំអួន** ហៅ **អាយ**

៣- ឧបាសក **ហាយ ចំរើន**

# អ្នកឧបត្ថម្ភចង្ហាន់បិណ្ឌបាត និង ភ្លើង

១- ឧបាសក **ប៉េង តាំងហៃ** ឧបាសិកា **ហ៊ូ គឹមហៀក**

២- ឧបាសក **ប៉េង រិទ្ធ** ឧបាសិកា **អាត់ ភក្តី** ព្រមទាំងបុត្រ

# នាមពុទ្ធបរិស័ទដែលចូលប្រាក់បោះពុម្ពសៀវភៅនេះ

***********

| | |
|---|---|
| ១- ឧកញ៉ា សេង ឆាយអូ និងតាំង ហ្គិចណៃ លោកជំទាវ ព្រមទាំងបុត្រ | ១០០ $ |
| ២- ឧបាសិកា ឈ គីមស៊ីន ព្រមទាំងបុត្រ | ៧០ $ |
| ៣- ឧបាសិកា ឱម លក្ខណា ព្រមទាំងបុត្រ | ៥០ $ |
| ៣- ឧបាសក ហេង ប៊ុលៀង ឧ.សិ អ៊ឹម មល្លី ព្រមទាំងបុត្រ | ៥០ $ |
| ៤- ឧបាសក ចាន់ ណា ឧ.សិ ស្រី វង ព្រមទាំងបុត្រ | ៥០ $ |
| ៥- ភិក្ខុ ចិត្តរក្ខិតោ សំ សម្បត្តិ | ៣០ $ |
| ៦- ឧបាសិកា ថាប់ លឿម | ២០ $ |
| ៧- ឧបាសិកា បុប្ផណា ព្រមទាំងបុត្រ | ២០ $ |
| ៨- ឧបាសិកា សាយ ស៊ុយគី ព្រមទាំងបុត្រ | ២០ $ |
| ៩- ឧបាសក ស៊ិន បៀន ឧបាសិកា សុក យាន | ២០ $ |
| ១០- លោក ឈុន សេថាលី អ្នកស្រី ឡាំ ច័ន្ទគន្ធា | ២០ $ |
| ១១- ឧបាសក ជួន បូផា ឧ.សិ ហេង ស ព្រមទាំងបុត្រ | ២០ $ |
| ១២- លោកគ្រូធម្មាចារ្យ កែវ វិមុត្តិ | ២០១០០០ ៛ + ១០ $ |
| ១៣- ឧបាសិកា នួវ ណាន | ២៥០០០ ៛ + ១០ $ |
| ១៤- ភិក្ខុ ឱវាទរក្ខិតោ ហោ គឹមសាន | ១០ $ |

១៥- ឧបាសិកា តាំង ប៉ោជីង ( ហៅ ទន់ ) ១០ $

១៦- អ្នកគ្រូ សាន ផល្លីន ១០ $

១៧- នាង ហាយ ស្រី ប៉ូច ៥ $

១៨- ឧបាសិកា ឡុង អ៊ីម ៥ $

១៩- ឧបាសក ទូច ស៊ុន្ទរ និងភរិយា ព្រមទាំងបុត្រ ៥ $

២០- ឧបាសក ឈួរ ទ្រី ( ហៅ សាន ) ឧ.សិ សុខ ច័ន្ទ ៥ $

២១- ឧបាសិកា តូច សាខន ៥ $

២២- ឧបាសិកា តាំង ប៉ោណៃ ៥ $

២៣- ឱ ធឿម ២ $

២៤- ឧបាសិកា ឱម លក្ខិណា ១០០ ϐ

២៥- ក្រុមវេនបិណ្ឌទី ១០ មានឧបាសិកា គឹម ហាក់ ២០០០០០ ៛

២៦- ប្រាក់ទេសនារបស់លោកគ្រូរស់ សុផាត ១៥០០០០ ៛

២៧- ឧបាសិកា ប្រាក់ សាភិត ៣០០០០ ៛

២៨- ភិក្ខុ ម៉េន សឿន ២០០០០ ៛

២៩- ឧបាសិកា ប៉ុល នាង និងនាង លេង ស្រីពៅ ២០០០០ ៛

៣០- ឧបាសក ហម ស៊ុនទៀង+ភរិយា ព្រមទាំងបុត្រ ២០០០០ ៛

៣១- ឧបាសិកា ប៊ូ សៀកលីវ ២០០០០ ៛

៣២- ឧបាសក គឹម សាយ ឧបាសិកា ព្រាប ញឹម ២០០០០ ៛

៣៣- លោកយាយ ឈួម ព្រមទាំងបុត្រ ១៥០០០ ៛

៣៤- លោកយាយបារាំងសាលាសតិប្បដ្ឋាន ១៣០០០ ៛

| | | |
|---|---|---|
| ៣៥- | ឧបាសិកា ធន កៀត | ១០០០០ ៛ |
| ៣៦- | ឧបាសិកា នួន ប៊ុនលី | ១០០០០ ៛ |
| ៣៧- | ឧបាសិកា ថាប់ | ១០០០០ ៛ |
| ៣៨- | ឧបាសិកា ប៊ុត សុម៉ាលី | ១០០០០ ៛ |
| ៣៩- | ភិក្ខុ យ៉ាត មាឃ | ១០០០០ ៛ |
| ៤០- | ឧបាសិកា អ៊ឹម ញ៉ាត់ហៀង | ១០០០០ ៛ |
| ៤១- | លោកគ្រូ ប្រាក់ យុន ឧ.សិ ហុយ | ១០០០០ ៛ |
| ៤២- | ឧបាសក ប៉េង រស់ និងភរិយា | ១០០០០ ៛ |
| ៤៣- | ឧបាសក ស៊ុន សេន | ៨០០០ ៛ |
| ៤៤- | ឧបាសិកា ម៉ី ហ៊ុន | ៥០០០ ៛ |
| ៤៥- | ឧបាសិកា ប៊ុត សេដាដួង | ៥០០០ ៛ |
| ៤៦- | ឧបាសិកា ឃិន ឃិម | ៥០០០ ៛ |
| ៤៧- | ឧបាសិកា កា អ៊ី | ៥០០០ ៛ |
| ៤៨- | ឧបាសិកា យ៉ុន | ៥០០០ ៛ |
| ៤៩- | ឧបាសិកា ខាត កាន | ៥០០០ ៛ |
| ៥០- | ឧបាសិកា តួច សាវុន | ៥០០០ ៛ |
| ៥១- | ឧបាសិកា គង់ ហៀត | ៥០០០ ៛ |
| ៥២- | ឧបាសិកា ថា | ៥០០០ ៛ |
| ៥៣- | ឧបាសិកា ស៊ីម ស៊ីម | ៥០០០ ៛ |
| ៥៤- | ឧបាសិកា ឃិន ឃឹន | ៥០០០ ៛ |

| | |
|---|---|
| ៥៥- ស៊ាន សារី | ៥០០០ ៛ |
| ៥៦- ញ៉ិប ស៊ីនួន | ៥០០០ ៛ |
| ៥៧- យាយ វើយ | ៥០០០ ៛ |
| ៥៨- ឧបាសិកា គង់ សាវិន | ៥០០០ ៛ |
| ៥៩- កញ្ញា គង់ លក្ខិណា | ៥០០០ ៛ |
| ៦០- យាយ ថាប់ | ៥០០០ ៛ |
| ៦១- ឧបាសិកា នេត នរិទ្ធ | ៥០០០ ៛ |
| ៦២- ឧបាសិកា ភួង លីណា ( ហៅ បូ ) | ៥០០០ ៛ |
| ៦៣- យាយ ឈូក | ៥០០០ ៛ |
| ៦៤- យឹម សុទ្ធ | ៥០០០ ៛ |
| ៦៥- ឧបាសិកា រស់ ខាត ( នៅប៉ោយប៉ែត ) | ៥០០០ ៛ |
| ៦៦- ឧបាសិកា ជិប ឱរតនះ | ៥០០០ ៛ |
| ៦៧- ឧបាសិកា ស្រី យឹន | ៥០០០ ៛ |
| ៦៨- ឧបាសិកា បួ គិមតោ | ៥០០០ ៛ |
| ៦៩- ឧបាសិកា ជិប ឱរ៉ែ | ៥០០០ ៛ |
| ៧០- ឧបាសិកា លឹម គិមណា | ៥០០០ ៛ |
| ៧១- ឧបាសិកា ប៉ាន គិមហ័រ | ៥០០០ ៛ |
| ៧២- យុវជន ធុំ សុផល | ៥០០០ ៛ |
| ៧៣- ឈិន វិជែ | ៥០០០ ៛ |
| ៧៤- ឧបាសក កៅ | ៥០០០ ៛ |

| | |
|---|---|
| ៧៥- ឧបាសក ទៀម + កំសត់ | ៥០០០ ៛ |
| ៧៦- សាម ផេង | ៥០០០ ៛ |
| ៧៧- ឧបាសក កង ស៊ាន + ឡុប យិប | ៥០០០ ៛ |
| ៧៨- នាង ហាយ ស្រីពៅ | ៥០០០ ៛ |
| ៧៩- នាង ស្រី ប្រពន្ធរបស់ហាយប្រុស | ៥០០០ ៛ |
| ៨០- ឧបាសិកា យី ពៅ | ៥០០០ ៛ |
| ៨១- ឧបាសិកា បុរាំង | ៣០០០ ៛ |
| ៨២- ឧបាសក យ៉ាំង សាវឿន និងភរិយា | ៣០០០ ៛ |
| ៨៣- ឧបាសិកា ថោង ថងបែ | ២០០០ ៛ |
| ៨៤- ម៉ៅ កុសល និងភរិយា | ២០០០ ៛ |
| ៨៥- ឧបាសិកា ចាន់ ប៉ា | ២០០០ ៛ |
| ៨៦- មួយ ជា | ២០០០ ៛ |
| ៨៧- ស្រី អូន | ១០០០ ៛ |
| ៨៨- នូ ញ៉ី | ១០០០ ៛ |
| ៨៩- តាន់ សុខគីម | ១០០០ ៛ |
| ៩០- លាង សុគន្ធា | ១០០០ ៛ |
| ៩១- យុវជន រ័ត្ន | ១០០០ ៛ |
| ៩២- លាង - សុគន្ធ - វាសនា | ៥០០ ៛ |

************